សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលសម្រេចបាន របស់ខណ្ឌបឹងកេងកង

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ខ៉ូយ ជូរី**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉េត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម នាងខ្ញុំឈ្មោះ **ង៉ុយ ជូរី** ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤ ឆមាសទី២ ជំនាន់ទី១៥ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២១-២០២២។ ជាបឋម នាងខ្ញុំសូមសម្ដែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកឪពុក **ឯក ម៉ុឡ** និងអ្នកម្ដាយ **ឡុច លីមហ៊ាង** ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ណែនាំ ផ្ដល់នូវដំបូន្មានល្អៗ រួមទាំងឧបត្ថម្ភគ្រប់បែបយ៉ាងទាំង ធនធាន (ថវិកា និងសម្ភារៈ) រួមទាំងស្មារតីដល់រូបនាងខ្ញុំរហូតដល់ខ្ញុំមានឱកាសបានសិក្សារៀនសូត្រដល់ថ្ងៃបញ្ចប់ថ្នាក់មហាវិទ្យាល័យដោយលោកទាំងពីរ ខិតខំជំនះនូវរាល់ឧបសគ្គ មិនខ្លាចនឿយហត់ ពុះពារឱ្យកូនបានរៀនសូត្រ មានចំណេះដឹងខ្ពង់ខ្ពស់ ដើម្បីរួមរស់នៅក្នុងសង្គមប្រកបដោយសុភវិនិច្ឆ័យ។ ហើយនាងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ សាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំផ្ទេរនូវចំណេះដឹង និងការស្វាគមន៍ រាក់ទាក់កក់ក្ដៅបំផុត ក្នុងការជួយសម្រួលផ្នែកឯកសារ ទិន្នន័យ ស្មារតី រួមទាំងសម្ភារៈផ្សេងៗ ដើម្បីផ្ដល់លទ្ធភាពដល់នាងខ្ញុំបន្តការសិក្សា និងឈានដល់ការសរសេរសារណាមួយនេះប្រកបដោយជោគជ័យអំពីសំណាក់៖

- ឯកឧត្ដម **បណ្ឌិត លុយ ចន្ណា** ជាសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈគ្រប់គ្រងទាំងអស់ ដែលបានខិតខំដឹកនាំសាកលវិទ្យាល័យ និងសម្របសម្រួលរាល់តម្រូវការនៃការសិក្សារបស់និស្សិតគ្រប់ជំនាន់។
- លោកសាស្ត្រាចារ្យ **បណ្ឌិត ឈុន ណារ៉េត** ជាសាស្ត្រាចារ្យដឹកនាំសារណាដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន អប់រំ ណែនាំ ផ្ដល់មតិយោបល់ ផ្ដល់ឯកសារ និងត្រួតពិនិត្យសារណាស្រាវជ្រាវមួយនេះយ៉ាងយកចិត្តទុកដាក់ រួមទាំងជម្រុញលើកទឹកចិត្តក្នុងការស្រាវជ្រាវឯកសារមួយនេះឡើង។
- លោកអភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង **ធីម សំអាន** ដែលបានអនុញ្ញាតឱ្យនាងខ្ញុំចុះស្រាវជ្រាវឯកសារនៅសាលាខណ្ឌបឹងកេងកង។
- លោកស្រី **សាត ឆវិន** ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក ដែលបានអនុញ្ញាតឱ្យរូបនាងខ្ញុំបានចូលជួបសម្ភាស៍ផ្ទាល់ ជាពិសេសបានឆ្លៀតឱកាសដ៏មានតម្លៃ ណែនាំ ផ្ដល់ជាឯកសារគ្រប់បែបយ៉ាង និងត្រួតពិនិត្យសារណាមួយនេះឱ្យកាន់តែមានភាពល្អប្រសើរ។

ជាចុងបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធពរជ័យសេរីបវរ ជូនចំពោះលោកអ្នកមានគុណទាំងពីរ និងសាស្ត្រាចារ្យ រួមទាំងអ្នកស្រាវជ្រាវទាំងអស់ សូមបានប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិធានៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នាពេលបច្ចុប្បន្ននេះប្រទេសកម្ពុជា គឺជាប្រទេសមួយដែលស្ថិតនៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍន៍ជាពិសេសស្ទើរគ្រប់វិស័យទាំងអស់ពុំទាន់មានការអភិវឌ្ឍ និងរីកចម្រើនខ្លាំងក្លានៅឡើយទេ។ ជាក់ស្តែងប្រទេសកម្ពុជាបានធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅ លើការគ្រប់គ្រងរដ្ឋបាលសាធារណៈ របស់ខ្លួនតាមរយៈនយោបាយវិសហមជ្ឈការ និងវិមជ្ឈការ។ ដោយហេតុថារដ្ឋបាលសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់កំណែទម្រង់ច្រើនលើកច្រើនសារមកហើយ រហូតដល់ពេលបច្ចុប្បន្ននេះរមែងនៅតែមានចំណុចខ្វះខាតមិនទាន់មានភាពល្អប្រសើរនៅឡើយទេ។ ដូច្នេះហើយ ប្រទេសកម្ពុជាគ្មានជម្រើសណាល្អប្រសើរក្រៅពីការខិតខំប្រឹងប្រែងធ្វើការកំណែទម្រង់ប្រព័ន្ធរដ្ឋបាលឱ្យក្លាយជារដ្ឋបាលមួយដែលមានលក្ខណៈបែបទំនើប និងនវានុវត្តន៍ ជាពិសេសផ្តោតលើប្រជាពលរដ្ឋជាស្នូលនោះទេ។

តួយ៉ាងប្រព័ន្ធរដ្ឋបាល នៃព្រះរាជាណាចក្រកម្ពុជា គឺជាឆ្អឹងខ្នងមួយសំខាន់ដែលផ្សារភ្ជាប់ទំនាក់ទំនងល្អរវាងអ្នកគ្រប់គ្រង និងអ្នកទទួលសេវា ហើយរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជាពីរគឺរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិគឺចាប់ពី រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ក្រោយពីបានសិក្សានូវជំនាញរដ្ឋបាលសាធារណៈអស់រយៈពេលបួនឆ្នាំកន្លងមកនេះ នាងខ្ញុំបានយល់កាន់តែច្បាស់លាស់ថា វិស័យរដ្ឋបាលសាធារណៈនេះ គឺជាវិស័យមួយសំខាន់នៅក្នុងចំណោមវិស័យដ៏ទៃផ្សេងៗទៀត។ ជាពិសេសវិស័យមួយនេះ គឺជាគន្លងមួយនៅក្នុងការគ្រប់គ្រង ក្រសួង ស្ថាប័ន នានាដើម្បីឱ្យការដឹកនាំប្រកបដោយរលូនលើសពីនេះទៀត ក្នុងគោលបំណងលើកកម្ពស់នូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់នូវសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ការិយាល័យ អង្គភាពជំនាញនានា ដែលពីមុនជាខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន នៅថ្នាក់ខណ្ឌ ត្រូវបានធ្វើសមាហរណកម្មចូលក្នុងរដ្ឋបាល។ តួយ៉ាងនាងខ្ញុំបានទទួលនូវចំណេះដឹង និងបទពិសោធន៍ល្អៗជាច្រើនអំពីសំណាក់សាស្ត្រាចារ្យ ដោយរួមផ្សំជាមួយការខិតខំប្រឹងប្រែង ព្យាយាម ទើបទទួលបាននូវឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទស្តីអំពី «**ការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកងក្នុងឆ្នាំ ២០២១**» ដើម្បីទុកជាស្នាដៃក្នុងការសិក្សានៅថ្នាក់បរិញ្ញាបត្រនេះ។

ចំពោះស្នាដៃមួយនេះនាងខ្ញុំបានខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវប្រមូលទិន្នន័យ ប្រមូលព័ត៌មានដើម្បីយកមកសរសេរចងក្រងនិងពិនិត្យយ៉ាងផ្ចិតផ្ចង់ប៉ុន្តែពុំទាន់មានភាពល្អប្រសើរនៅឡើយទេ។ អាស្រ័យហេតុនេះ សូមមេត្តាអធ្យាស្រ័យនូវរាល់ភាពខ្វះចន្លោះ ការឆ្គាំឆ្គងពាក្យពេចន៍ត្រង់ប្រការណាមួយព្រមទាំងអត្ថន័យ ខ្លឹមសារ និងកំហុសខុសឆ្គងផ្នែកអក្ខរាវិរុទ្ធដោយអចេតនាអំពីសំណាក់សាស្ត្រាចារ្យ និងនិស្សិតទាំងអស់ជាពិសេសនោះគឺ សូមស្វាគមន៍ជានិច្ចនូវរាល់មតិរិះគន់របស់សាស្ត្រាចារ្យ និងនិស្សិតទាំងអស់។

# មាតិកា

**ទំព័រ**


អក្សរកាត់..........v


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ..........១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ..........២

៣. គោលបំណងនៃការស្រាវជ្រាវ..........៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ..........៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ..........៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ..........៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..........៤


## ជំពូកទី១
## រំលឹកទ្រឹស្តីនៃការគ្រប់គ្រងរដ្ឋបាល


**១.១. សញ្ញាណទូទៅរដ្ឋបាលសាធារណៈ**..........៦

១.១.១. និយមន័យនៃពាក្យរដ្ឋបាលសាធារណៈ និងលក្ខណៈរបស់រដ្ឋបាលសាធារណៈ..........៦

១.១.២. តួនាទីរដ្ឋបាលសាធារណៈនៅក្នុងសម័យទំនើប..........៨

**១.២. ប្រវត្តិរដ្ឋបាលសាធារណៈ**..........៩

១.២.១. សម័យមុនអាណានិគមបារាំង..........៩

១.២.២. សម័យអាណានិគមបារាំង..........១០

១.២.៣. សម័យក្រោយអាណានិគមបារាំង..........១១

**១.៣. គោលការណ៍នៃការរៀបចំគ្រប់គ្រងរដ្ឋបាល**..........១២

១.៣.១. គោលការណ៍នៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ..........១២

១.៣.១.១. និយមន័យមជ្ឈការ..........១២

១.៣.១.២. ចរិតលក្ខណៈ..........១៣

១.៣.១.៣. គុណសម្បត្តិ និងគុណវិបត្តិ..........១៣

១.៣.២. បច្ចេកទេសក្នុងការចែករំលែកអំណាច..........១៤

១.៣.២.១. សញ្ញាណ និងនិយមន័យវិសហមជ្ឈការ..........១៤

១.៣.២.២. ចរិតលក្ខណៈ ....... ១៥
១.៣.២.៣. គុណសម្បត្តិ និងគុណវិបត្តិ ....... ១៥
១.៣.២.៤. វិធីសាស្ត្រ ....... ១៥
១.៣.៣. គោលការណ៍នៃការរៀបចំគ្រប់គ្រងរដ្ឋបាលតាមវិមជ្ឈការ ....... ១៧
១.៣.៣.១. សញ្ញាណ និងនិយមន័យ ....... ១៧
១.៣.៣.២. ចរិតលក្ខណៈ ....... ១៨
១.៣.៣.៣. គុណសម្បត្តិ និងគុណវិបត្តិ ....... ២០

## ជំពូកទី២

## ស្ថានភាពទូទៅ និងការគ្រប់គ្រងរដ្ឋបាលរបស់ខណ្ឌបឹងកេងកង

**២.១. ទិដ្ឋភាពទូទៅរបស់សាលាខណ្ឌបឹងកេងកង** ....... ២២
២.១.១. ក្របខ័ណ្ឌគតិយុត្ត ....... ២២
២.១.២. ទីតាំងភូមិសាស្ត្រ ....... ២២
២.១.៣. ស្ថានភាពប្រជាសាស្ត្រ ....... ២២
**២.២. រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ** ....... ២២
២.២.១. ក្រុមប្រឹក្សា ....... ២២
២.២.១.១. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា ....... ២៤
២.២.១.២. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា ....... ២៤
២.២.១.៣. ការប្រជុំរបស់ក្រុមប្រឹក្សា ....... ២៥
២.២.១.៤. សមាសភាពរបស់ក្រុមប្រឹក្សា ....... ២៨
២.២.២. គណៈអភិបាល ....... ៣៦
២.២.២.១. សិទ្ធិអំណាចរបស់គណៈអភិបាល ....... ៣៧
២.២.២.២. សមាសភាពរបស់គណៈអភិបាល ....... ៣៨
២.២.២.៣. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា ....... ៣៨
២.២.៣. នាយករដ្ឋបាល ....... ៤១
២.២.៤. ការិយាល័យ និងអង្គភាពចំណុះ ....... ៤៣
**២.៣. ការគ្រប់គ្រងរដ្ឋបាលខណ្ឌបឹងកេងកង** ....... ៤៨
២.៣.១. ការងាររដ្ឋបាល ....... ៤៨

២.៣.២. ការងារគ្រប់គ្រងធនធានមនុស្ស ........................................................................................................៥០
២.៣.៣. ការងារអន្តរវិស័យ ........................................................................................................................៥១
២.៣.៤. កម្មវិធីវិនិយោគបីឆ្នាំរំកិល ..................................................................................................................៥២

# ជំពូកទី៣

# សមិទ្ធផល បញ្ហាប្រឈម និងទិសដៅអនាគតរបស់ខណ្ឌបឹងកេងកង

**៣.១. សមិទ្ធផលរបស់ខណ្ឌ** ..............................................................................................................៥៤
៣.១.១. សេវាសាធារណៈដែលផ្តល់ដោយខណ្ឌបឹងកេងកង ...................................................................៥៤
ក. ការងារអត្រានុកូលដ្ឋាន.....................................................................................................................៥៤
ខ. ការងារនីត្យានុកូលកម្ម......................................................................................................................៥៤
៣.១.២. វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច.........................................................................................................៥៥
៣.១.២.១. វិស័យហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍ ...........................................................................៥៥
៣.១.២.២. វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ ពាណិជ្ជកម្ម និងទេសចរណ៍ .......................៥៥
៣.១.២.៣. វិស័យអប់រំ យុវជន និងកីឡា វប្បធម៌ និងវិចិត្រសិល្បៈ និងវិស័យសុខាភិបាល ...........៥៦
៣.១.២.៤. វិស័យសង្គមកិច្ច សុខុមាលភាព និងកិច្ចការនារី...................................................................៥៧
៣.១.៣. វិស័យផ្សេងៗទៀត........................................................................................................................៥៩
៣.១.៣.១. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ..................................................................................៥៩
៣.១.៣.២. ការបង្ក្រាបបទល្មើស ក្មេងទំនើង និងល្បែងស៊ីសង ការប្រើប្រាស់អាវុធខុសច្បាប់.........៦០
៣.១.៣.៣. ការចុះត្រួតពិនិត្យ និងរឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក..............................៦១
៣.១.៣.៤. ការងារសាធារណៈការ ដឹកជញ្ជូន បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ..................៦២
**៣.២. បញ្ហាប្រឈម** ............................................................................................................................៦២
៣.២.១. ផ្នែកធនធានហិរញ្ញវត្ថុ.....................................................................................................................៦៣
៣.២.២. ផ្នែកសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ..........................................................................................៦៣
៣.២.៣. ផ្នែកអប់រំ ......................................................................................................................................៦៤
៣.២.៤. ផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់.............................................................................................................៦៤
៣.២.៥. ផ្នែកសុខាភិបាល និងបរិស្ថាន..........................................................................................................៦៤
៣.២.៦. ផ្នែកការងារវប្បធម៌ និងព័ត៌មាន .....................................................................................................៦៥
៣.២.៧. ផ្នែកការងារផែនការ និងអភិវឌ្ឍន៍ ..................................................................................................៦៥

៣.២.៨. ផ្នែកសង្គមកិច្ច ........................................................................................................................ ៦៥
**៣.៤. ទិសដៅអនាគត** ............................................................................................................................. ៦៦
៣.៤.១. ការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ...................................................................................... ៦៦
៣.៤.២. ពង្រឹងផ្នែកសណ្តាប់ធ្នាប់សាធារណៈ ........................................................................................ ៦៦
៣.៤.៣. យន្តការសេវាសាធារណៈ ................................................................................................... ៦៦
**សេចក្តីសន្និដ្ឋាន** ..................................................................................................................................... ៦៨
**អនុសាសន៍** ............................................................................................................................................. ៧០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | | |
|---|---|---|
| ១. | **អ.ក.ន.ក** | អង្គភាពទទួលបន្ទុកកិច្ចការនារី និងកុមារ |
| ២. | **គ.ក.ស.ក** | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| ៣. | **ស.យ.អ** | ក្រសួង/មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

តាមការសិក្សាស្រាវជ្រាវ ប្រទេសកម្ពុជាមានប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានជាយូរណាស់មកហើយ។[1] ហើយប្រព័ន្ធអភិបាលកិច្ចនេះ មានការប្រែប្រួលពីរបបនយោបាយមួយទៅរបបនយោបាយមួយទៀត ដោយផ្អែកតាមស្ថានភាព នយោបាយ ប្រជាសាស្ត្រ ភូមិសាស្ត្រ សេដ្ឋកិច្ច និងសង្គមក្នុងសម័យកាលនីមួយៗ ។ បើគិតមកដល់បច្ចុប្បន្ននេះប្រទេសកម្ពុជាបានឆ្លងកាត់សម័យកាលជាច្រើនសម័យកាល តួយ៉ាងនៅក្នុងសម័យកាលនីមួយៗ តែងតែមានការគ្រប់គ្រង ដឹកនាំ ខុសៗគ្នាហើយការដឹកនាំតែងតែផ្តល់អំណាចឱ្យអ្នកដែលមានអំណាច ឬហៅថាអំណាចកណ្តាល ឆ្លងកាត់ពីសម័យកាលមួយទៅសម័យកាលមួយ ប្រទេសកម្ពុជាមានការវិវត្ត និងរីកចម្រើនជាដំណាក់កាលៗ រហូតមកដល់ឆ្នាំ១៩៩៨ ប្រទេសកម្ពុជាទទួលបាននូវ សុខសន្តិភាព ស្ថេរភាពនយោបាយ ឯកភាពជាតិ និងឯកភាពទឹកដីដោយការអនុវត្តនូវនយោបាយ ឈ្នះ ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ការបង្រួបបង្រួមជាតិ សមាហរណកម្មក្នុងតំបន់។[2] នាចុងឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី២នៃរដ្ឋសភា បានសម្រេចចិត្តអនុវត្តនូវកំណែទម្រង់វិសហមជ្ឈការ និងវិមជ្ឈការ នៅថ្នាក់ឃុំ សង្កាត់ តាមរយៈការដាក់ចេញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅឆ្នាំ២០០២ និងបានរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី១ នៅឆ្នាំ២០០២។

ដោយធ្លាប់មានបទពិសោធន៍ជោគជ័យនៃការអនុវត្ត គោលនយោបាយវិសហមជ្ឈការ និងវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានសម្រេចចិត្តពង្រីកវិសាលភាព នៃការអនុវត្តកំណែទម្រង់វិសហមជ្ឈការ និងវិមជ្ឈការ នៅថ្នាក់ក្រោមជាតិទាំងមូល ដោយបានដាក់ចេញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបានរៀបចំច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅឆ្នាំ២០០៨ ហើយរាជរដ្ឋាភិបាលបានសម្រេចចិត្តបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅឆ្នាំ២០០៩។ មួយវិញទៀតនាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថារាជរដ្ឋាភិបាលកម្ពុជា គឺបានខិតខំយកចិត្តទុកដាក់ក្នុងការរិះរក ឬមួយស្វែងរកនូវវិធីសាស្ត្រណាដែលមានប្រសិទ្ធិភាព អាចផ្តល់នូវសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋឱ្យបានឆាប់រហ័សមានភាពងាយស្រួល និងទាន់ពេលវេលា ដូច្នេះ រាជរដ្ឋាភិបាលបាន

[1] Organisation de la Cammune Cambodgienne, 1919

[2] https://www.khsearch.com/qna/16901

ដាក់ឱ្យអនុវត្តនូវគោលនយោបាយវិសហមជ្ឈការ និងវិមជ្ឈការ។ ម្យ៉ាងវិញទៀតគោលនយោបាយវិសហមជ្ឈការ និង វិមជ្ឈការ មានគោលដៅអភិវឌ្ឍន៍ ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ជម្រុញការអភិវឌ្ឍនៅមូលដ្ឋានកាត់បន្ថយភាពក្រីក្រ រួមទាំងលើកកម្ពស់សិទ្ធសេរីភាពរបស់ប្រជាពលរដ្ឋ។ ការរៀបចំរដ្ឋបាលនៅមូលដ្ឋាន ឬរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជាបានបែងចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ចំពោះការបែងចែកនេះត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ១៩៩៣។[3]

តាមកម្មវិធីកំណែទម្រង់គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺមានគោលបំណងដើម្បីផ្តល់នូវសិទ្ធិជូនដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ជាពិសេសដើម្បីអភិវឌ្ឍន៍ខណ្ឌបឹងកេងកងដោយខ្លួនឯងផ្ទាល់។ តួយ៉ាងបានឆ្លុះបញ្ចាំងពីភាពទាក់ទងគ្នាយ៉ាងល្អរវាងប្រជាពលរដ្ឋ និងអាជ្ញាធរ ដែនដីនៅមូលដ្ឋានខណ្ឌបឹងកេងកង ដើម្បីឆ្ពោះទៅរកភាពសហការគ្នា ដោយមានការរាក់ទាក់យ៉ាងស្និទ្ធស្នាល ទាំងការងាររដ្ឋបាល ការងារទំនាក់ទំនងគ្នា និងសន្តិសុខ សណ្តាប់ធ្នាប់ ជាពិសេសគឺការអភិវឌ្ឍដែលនាំឱ្យខណ្ឌទទួលបាននូវការរីកចម្រើនពោរពេញដោយមោទនភាព និងប្រកបដោយនិរន្តភាពផងដែរ។ យោងតាមមាត្រា៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ បានកំណត់ថាភ្នំពេញគឺជារាជធានី នៃព្រះរាជាណាចក្រកម្ពុជា រាជធានីបែងចែកចេញជាខណ្ឌ ហើយខណ្ឌបែងចែកចេញជាសង្កាត់។[4] ម្យ៉ាងវិញទៀត រាជធានីភ្នំពេញ បានបែងចែកចេញជា ១២ខណ្ឌ ប៉ុន្តែនៅឆ្នាំ២០១៩ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតឡើងនូវខណ្ឌបន្ថែមចំនួន២ទៀត គឺខណ្ឌបឹងកេងកង និងខណ្ឌកំបូល។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅប្រទេសកម្ពុជា មានការបែងចែកអំណាចតាមលំដាប់ថ្នាក់ នៃការគ្រប់គ្រងរបស់រដ្ឋបាល ដោយអនុវត្តនូវគោលនយោបាយមជ្ឈការ វិសហមជ្ឈការ និងវិមជ្ឈការ គឺជាគោលនយោបាយដែលបានផ្តល់ឱកាសឱ្យប្រជាពលរដ្ឋបានចូលរួមកាន់តែទូលំទូលាយ ក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ហើយបានជម្រុញឱ្យរដ្ឋបាលខណ្ឌបឹងកេងកងមានការទទួលខុសត្រូវលើការគ្រប់គ្រងលើកិច្ចការរដ្ឋបាល ការផ្តល់សេវាសាធារណៈការពារផលប្រយោជន៍ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងបានដោះស្រាយរាល់បញ្ហាប្រឈមនៅក្នុងដែនសមត្ថកិច្ចតាងនាមជាអ្នកដឹកនាំ និងជាអ្នកតំណាងឱ្យប្រជាពលរដ្ឋ។ ដូច្នេះចំណុចសំខាន់នៃការសិក្សា

[3] ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ទំព័រទី៥៧ មាត្រា១៤៥ថ្មី

[4] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ ទំព័រទី១ មាត្រា៤

ស្រាវជ្រាវលើប្រធានបទស្តីពី **ការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកង ក្នុងឆ្នាំ ២០២១** ដែលស្ថិតនៅរាជធានីភ្នំពេញ ផ្តោតសំខាន់លើបញ្ហាជាច្រើនមានដូចជា តើការគ្រប់គ្រងរដ្ឋបាលខណ្ឌបឹងកេងកងតាមបែបប្រព័ន្ធវិសហមជ្ឈការ និងវិមជ្ឈការមានអត្ថន័យ និងខ្លឹមសារយ៉ាងដូចម្តេច? តើការគ្រប់គ្រងខណ្ឌតាមបែបប្រព័ន្ធវិសហមជ្ឈការ និងវិមជ្ឈការមានផលប្រយោជន៍អ្វីខ្លះដល់ប្រជាជន? តើការគ្រប់គ្រងខណ្ឌបឹងកេងកងតាមបែបវិសហមជ្ឈការ និងវិមជ្ឈការ មានបញ្ហាប្រឈមអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះ គឺមានគោលបំណងដើម្បីការចូលរួមចំណែកបង្កើននូវចំណេះដឹងដល់នាងខ្ញុំដែលបានសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីនិយមន័យ អត្ថន័យនៃការគ្រប់គ្រងរដ្ឋបាល ព្រមទាំងយល់កាន់តែច្បាស់លាស់ អំពីការអនុវត្តការងារជាក់ស្តែង និងការគ្រប់គ្រងរដ្ឋបាលនៅក្នុងខណ្ឌបឹងកេងកង។ ម្យ៉ាងវិញទៀតអាចជាឯកសារមួយផ្នែកតូចសម្រាប់តម្កល់ទុកក្នុងបណ្ណាល័យ ដើម្បីឱ្យនិស្សិតជំនាន់ក្រោយសិក្សាស្រាវជ្រាវបន្ទាប់បន្សំ។

គោលបំណងនៃការសិក្សាស្រាវជ្រាវ គឺនាងខ្ញុំផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម៖

- សិក្សាទៅលើការគ្រប់គ្រងរដ្ឋបាលនៅខណ្ឌបឹងកេងកង
- សិក្សាទៅលើដំណើរការផ្តល់នូវសេវាសាធារណៈនៅខណ្ឌ
- សិក្សាទៅលើគោលការណ៍នៃការអភិវឌ្ឍរបស់ខណ្ឌ និងសិក្សាទៅលើបញ្ហាប្រឈមរបស់ខណ្ឌ
- ចូលរួមចំណែកក្នុងការកែលំអរចំណុចខ្វះខាតដែលពាក់ព័ន្ធ ក្នុងការគ្រប់គ្រងរដ្ឋបាលខណ្ឌ និងជម្រុញកិច្ចអភិវឌ្ឍន៍សង្គមប្រកបដោយប្រសិទ្ធភាព តាមរយៈការចូលរួមផ្តល់អនុសាសន៍បន្ទាប់បន្សំ
- សិក្សាទៅលើ សមិទ្ធផល និងទិសដៅអនាគតដែលសម្រេចបានរបស់ខណ្ឌបឹងកេងកង

កិច្ចការស្រាវជ្រាវនេះផងដែរ គឺយើងអាចធ្វើការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយនៃការគ្រប់គ្រងរដ្ឋបាលខណ្ឌដើម្បីស្វែររកចំណុចខ្វះខាតនិងកែលំអរដើម្បីឈានដល់ការធ្វើសេចក្តីសន្និដ្ឋានលើគ្រប់ចំណុចព្រមទាំងផ្តល់អនុសាសន៍ផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ គឺមានដែនកំណត់ និងវិសាលភាពគ្របដណ្តប់តែទៅលើសកម្មភាពនៃការអនុវត្ត «**ការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកង ក្នុងឆ្នាំ ២០២១**» ស្ថិតនៅរាជធានីភ្នំពេញ ហើយទិន្នន័យដែលខ្ញុំបានស្រាវជ្រាវចាប់ពីខែមីនា រហូតដល់ ខែមេសា ឆ្នាំ ២០២២។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ជាទូទៅ ការសិក្សាស្រាវជ្រាវតែងតែមាន គុណតម្លៃដល់អ្នកសិក្សាគ្រប់រូបលើប្រធានបទ ឬជំនាញដែលខ្លួនបានជ្រើសរើសថាមានប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវជាដំបូង គឺបានផ្តល់ឱ្យអ្នកសិក្សាស្រាវជ្រាវបានយល់ដឹង និងចងចាំបានយ៉ាងច្បាស់ ហើយជាពិសេសកាន់តែលម្អិតលើសារណាមួយនេះ បន្ទាប់មកទៀតគឺបានផ្តល់នូវសារៈប្រយោជន៍ ជាច្រើនទៀតដល់អ្នកអាន និងសាធារណជនទាំងឡាយ ដែលបានអាននូវការសិក្សាស្រាវជ្រាវសារណាមួយនេះ។ សារៈប្រយោជន៍ទាំងនេះរួមមានដូចជា សម្រាប់និស្សិតបានប្រតិបត្តិតាមទិសដៅរបស់សាស្ត្រាចារ្យ និងបង្កើនសមត្ថភាពលើការសិក្សាស្រាវជ្រាវសរសេរសារណាមួយនេះ រួមទាំងបានស្វែងយល់កាន់តែច្បាស់ អំពីប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកង បញ្ហាប្រឈមជាពិសេសគឺបានសិក្សាស្រាវជ្រាវអំពីទិសដៅអនាគតរបស់ខណ្ឌបឹង។ ដោយឡែកសម្រាប់សាធារណជនវិញគឺអាចស្វែងយល់បន្ថែមអំពីទិដ្ឋភាពមួយចំនួនពាក់ព័ន្ធសារណាមួយនេះ និងយល់កាន់តែច្បាស់លាស់ពីប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សមិទ្ធផលសម្រេចបាន បញ្ហាប្រឈម រួមទាំងទិសដៅអនាគតរបស់ខណ្ឌ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ នាងខ្ញុំបានជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យមានន័យថាការស្រាវជ្រាវដែលផ្តោតទៅលើការយកចិត្តទុកដាក់ទាំងខ្លឹមសារ និងអត្ថន័យ។ ចំណែកឯវិធីសាស្ត្រប្រមូលទិន្នន័យបានប្រភពពីរសំខាន់ៗគឺ ទី១ ទិន្នន័យចម្បងដែលប្រមូលបានតាមរយៈការចុះស្រាវជ្រាវនៅខណ្ឌបឹងកេងកងដោយផ្ទាល់ សម្ភាសផ្ទាល់ជាមួយមន្ត្រី ឬបុគ្គលិក ដែលបានបំពេញការងារនៅក្នុងខណ្ឌបឹងកេងកង និងទី២ គឺទិន្នន័យបន្ទាប់បន្សំ ដែលប្រមូលបានតាមរយៈការប្រមូលឯកសារពីសាលាខណ្ឌ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធរួមមាន អនុក្រឹត្យ ប្រកាស និងសេចក្តីសម្រេច រួមទាំងសៀវភៅដែលទាក់ទងការគ្រប់គ្រងរដ្ឋបាលនៅប្រទេសកម្ពុជា ឯកសារដែលមាននៅក្នុងបណ្ណាល័យមួយចំនួនដែលទាក់ទងប្រធានបទរួមទាំងបានស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណេត (Internet) ឬមួយវេបសាយ (Website) មួយចំនួនដើម្បីបានជាឯកសារសម្រាប់ធ្វើឱ្យប្រធានបទមួយនេះកាន់តែមានអត្ថន័យទូលំទូលាយថែមមួយកម្រិតទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធក្រោមប្រធានបទ «**ការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកងក្នុងឆ្នាំ២០២១**» នេះត្រូវបានចងក្រងបែងចែកចេញជាប្លង់ដូចតទៅ សេចក្តីថ្លែងអំណរគុណ គឺបានរៀបរាប់អំពីការដឹងគុណជូនចំពោះលោកឪពុក អ្នកម្តាយ និងសូមថ្លែងអំណរគុណសាស្ត្រាចារ្យ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរងជាពិសេស គឺលោកគ្រូសាស្ត្រាចារ្យណែនាំសារណា គណៈអភិបាល ប្រធានការិយាល័យ

រួមទាំងមន្ត្រី បុគ្គលិក ដែលបំពេញការងារនៅក្នុងខណ្ឌបឹងកេងកង រៀមច្បង និងមិត្តរួមជំនាន់ទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងធំធេងបំផុត បានជួយជម្រុញរូបនាងខ្ញុំរហូតទទួលបាននូវជោគជ័យ ក្នុងការសរសេរបញ្ចប់សារណាមួយនេះ។ ចំណែកឯអារម្ភកថា គឺរៀបរាប់អំពីអារម្មណ៍ រួមទាំងការយល់ឃើញចំពោះប្រធានបទរបស់នាងខ្ញុំដែលបានខិតខំស្រាវជ្រាវ រួមទាំងគំនិតផ្សេងៗទៀត។ មួយវិញទៀត សេចក្តីផ្តើម បានរៀបរាប់អំពីការវិវត្ត និងបង្ហាញអំពីចំណុចដំបូងនៃប្រធានបទមួយនេះ ហើយរៀបរាប់អំពីការរៀបចំគោលនយោបាយជាតិការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធវិសហមជ្ឈការ និងវិមជ្ឈការនៅថ្នាក់ក្រោមជាតិឆ្នាំ១៩៩៩។ មួយវិញទៀតចំណោទបញ្ហា ដែលប្រមូលផ្តុំដោយចម្ងល់ជាច្រើន ទាក់ទងនិងលិខិតបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងរដ្ឋបាលការអនុវត្តការងារ ជាពិសេសលើសេវាសាធារណៈ និងការដោះស្រាយចំពោះបញ្ហាផ្សេងៗ គោលបំណងនៃការសិក្សាស្រាវជ្រាវរបស់អត្ថបទទាំងមូល ទំហំ និងដែនកំណត់នៃការស្រាវជ្រាវដែលរូបនាងខ្ញុំបានកំណត់ស្រាវជ្រាវ គឺនៅក្នុងឆ្នាំ២០២១ តែប៉ុណ្ណោះ សារៈសំខាន់នៃការស្រាវជ្រាវ គឺពិតជាល្អណាស់សម្រាប់ប្រជាពលរដ្ឋនៅក្នុងខណ្ឌបឹងកេងកង និងសាកលវិទ្យាល័យ សាធារណជននានា រួមទាំងប្រទេសជាតិដោយរួមមានវិធីសាស្ត្រស្រាវជ្រាវដែលបង្ហាញអំពីវិធីសាស្ត្រក្នុងការប្រមូលព័ត៌មានជាមួយសាលាខណ្ឌបឹងកេងកង។ ម្យ៉ាងវិញទៀត ជំពូកទី១ គឺជាជំពូកមួយដែលបង្ហាញអំពីទ្រឹស្តីមួយចំនួន ដែលពាក់ព័ន្ធប្រធានបទដែលរួមមានដូចជា ប្រព័ន្ធមជ្ឈការ ប្រព័ន្ធវិសហមជ្ឈការ និងប្រព័ន្ធវិមជ្ឈការ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌរចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលខណ្ឌតួនាទី មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលខណ្ឌ រួមទាំងកិច្ចការរដ្ឋបាលខណ្ឌ។ ចំណែកមួយផ្នែកទៀតជំពូកទី២ គឺជាជំពូកមួយដែលបានបង្ហាញអំពីស្ថានភាពទូទៅ ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលខណ្ឌផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រួមទាំងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខណ្ឌបឹងកេង រីឯជំពូកទី៣ គឺជាជំពូកមួយដែលបានបង្ហាញអំពី សមិទ្ធផលសម្រេចបានបញ្ហាប្រឈម រួមទាំងទិសដៅអនាគតរបស់រដ្ឋបាលខណ្ឌបឹងកេងកង។ ជាចុងបញ្ចប់ គឺបាននិយាយទាក់ទងសេចក្តីសន្និដ្ឋានរួមទាំង អនុសាសន៍ ផ្នែកនេះជាចំណុចបញ្ចប់នៃការសរសេរសារណា ដោយសង្ខេបនូវរាល់លទ្ធផលទាំងអស់ដែលទទួលបានពីការស្រាវជ្រាវ និងបានបង្ហាញអនុសាសន៍មួយចំនួនផងដែរ។

# ជំពូកទី១
# រំលឹកទ្រឹស្តីនៃការគ្រប់គ្រងរដ្ឋបាល

# ជំពូកទី១

# រំលឹកទ្រឹស្តីនៃការគ្រប់គ្រងរដ្ឋបាល

## ១.១. សញ្ញាណទូទៅរដ្ឋបាលសាធារណៈ

### ១.១.១. និយមន័យនៃពាក្យរដ្ឋបាលសាធារណៈ និងលក្ខណៈរបស់រដ្ឋបាលសាធារណៈ

ជាបឋមមុននិងឈានទៅដល់ការបកស្រាយអ្វីទៅជា អំណាចរដ្ឋបាលសាធារណៈ យើងគួរគប្បីយល់នៅពាក្យថា «រដ្ឋបាល» និងពាក្យថា «រដ្ឋបាលសាធារណៈ» ជាមុនសិន។ ពាក្យថា «រដ្ឋបាល» មានប្រភពមកពីពាក្យ «រដ្ឋ បូកជាមួយពាក្យ បាល» រដ្ឋ មានន័យថា នគរ ឬបុរី ចំណែកឯពាក្យ «បាល» មានន័យថាគ្រប់គ្រង ដូច្នេះពាក្យថារដ្ឋបាលមានន័យថាមើលថែរក្សា ឬការគ្រប់គ្រងរដ្ឋ ប្រទេស ឬមួយបុរី។ [5]

ប៉ុន្តែបើតាមអត្ថន័យទូទៅដែលជាការអនុវត្តជាក់ស្តែងនោះ រដ្ឋបាល មានអត្ថន័យសំខាន់ពីរយ៉ាងគឺ៖

- តាមន័យអង្គការ សំដៅទៅលើការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការមួយ។
- តាមន័យសកម្មភាព គឺសំដៅដល់កិច្ចការរដ្ឋបាលរបស់ក្រសួង ស្ថាប័ន។

រដ្ឋបាល គឺជាសកម្មភាពមួយដែលបម្រើឱ្យការរស់នៅជាប្រចាំពោល គឺសកម្មភាពបម្រើប្រយោជន៍ទាំងឡាយណាដែលទាក់ទងការរស់នៅប្រចាំថ្ងៃ ឬតម្រូវការជាប្រចាំរាល់ថ្ងៃរបស់មនុស្សក្នុងសង្គមជាតិ។

រដ្ឋបាល មានបេសកម្មបម្រើឱ្យផលប្រយោជន៍សាធារណៈ ហើយមានលក្ខណៈជាប្រចាំនោះ គឺមានន័យថាបម្រើផលប្រយោជន៍ក្នុងការរស់នៅប្រចាំថ្ងៃ។ គេអាចនិយាយដោយខ្លីថា៖[6]

ក. រដ្ឋបាល គឺជាម៉ាស៊ីនដែលប្រមូលផ្តុំចូលគ្នា ( គោលនយោបាយ លិខិតរដ្ឋបាល នីតិវិធី ប្រព័ន្ធរចនាសម្ព័ន្ធ អង្គការចាត់តាំងបុគ្គលិក) ដែលផ្តល់ប្រាក់ដោយថវិការបស់រដ្ឋ ហើយមានការទទួលខុសត្រូវក្នុងការគ្រប់គ្រងមានគោលដៅឆ្ពោះទៅរកការងារទាំងឡាយរបស់រាជរដ្ឋាភិបាល ហើយមានការធ្វើអន្តរសកម្មភាពជាមួយភ្នាក់ងារពាក់ព័ន្ធនានាដែលមាននៅក្នុងរដ្ឋ សង្គម ក៏ដូចជាបរិស្ថានដែលមាននៅក្រៅផ្សេងៗទៀត។

ខ. រដ្ឋបាល គឺជាការគ្រប់គ្រង និងការអនុវត្តគ្រប់ប្រភេទនៃសកម្មភាពរបស់រាជរដ្ឋាភិបាល គឺមានការពាក់ព័ន្ធនិងការអនុវត្តច្បាប់ បទបញ្ញត្តិនានា និងសេចក្តីសម្រេចចិត្តដែលធ្វើឡើងដោយរាជរដ្ឋាភិបាល និងការគ្រប់គ្រងទៅលើបទបញ្ញត្តិស្តីពីសេវាសាធារណៈនានា។ ចំណែកឯពាក្យ រដ្ឋបាលសាធារណៈ វិញមានន័យដូចខាងក្រោម៖

[5] សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ

[6] UNDP Practice: Public Administration Reform

+ ការឱ្យនិយមន័យនៃពាក្យ រដ្ឋបាលសាធារណៈ មានច្រើនយ៉ាង និងមានលក្ខណៈស្មុគស្មាញដោយផ្អែកទៅលើប្រព័ន្ធលើពិភពលោកយើង ជាពិសេសគឺនៅក្នុងការគ្រប់គ្រងរដ្ឋបាលនៃប្រព័ន្ធច្បាប់ Common Law និង Civil Law។ ទស្សនៈវិទូខាងច្បាប់មួយចំនួនបានឱ្យនិយមន័យខុសប្លែកៗពីគ្នាដូចខាងក្រោម៖

- លោក រ៉ូល ហ្គូសមេន ( Raul Guzment ) យល់ថា « នៅទីណាមានរាជរដ្ឋាភិបាលទីនោះ គឺមានរដ្ឋបាលសាធារណៈ»មានន័យថារដ្ឋបាលសាធារណៈគឺជាកិច្ចសហប្រតិបត្តិការណ៍រវាងប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលដើម្បីសម្រេចបានគោលដៅអ្វីមួយក្នុងការបម្រើផលប្រយោជន៍ជាសាធារណៈ។
- លោក រ៉ូប៊ឺត ព្រីសធូស ( Robert Presthus ) បានយល់ថា រដ្ឋបាលសាធារណៈ គឺជាទិដ្ឋភាពនៃការគ្រប់គ្រងដែលធ្វើឡើងដោយភ្នាក់ងារផ្លូវការរបស់រាជរដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់។ លើសពីនេះទៅទៀតកាលណាគេនិយាយពីពាក្យ រដ្ឋបាលសាធារណៈ គឺសំដៅលើរដ្ឋបាល ឬរាជការ។

+ បើផ្អែកតាមការឱ្យនិយមន័យនៃពាក្យ រដ្ឋបាលសាធារណៈ នៅក្នុងនីតិរដ្ឋបាលវិញមានពីរយ៉ាងគឺ៖ ទីមួយតាមមុខងារ ឬសកម្មភាព និងនិយមន័យទីពីរ គឺតាមន័យអង្គការ។ ហើយន័យទាំងពីរនេះ គឺអាចប្រើប្រាស់បានទាំងវិស័យឯកជន និងវិស័យសាធារណៈ។ ឧទាហរណ៍ កិច្ចការរដ្ឋបាលនៅក្នុងក្រុមហ៊ុនលក់ម៉ូតូមួយកន្លែងសំដៅលើ វិស័យឯកជន មួយវិញទៀតកិច្ចការរដ្ឋបាលរបស់ខណ្ឌបឹងកេងកងសំដៅលើ វិស័យសាធារណៈ។ មុខងាររដ្ឋបាលសំដៅទៅលើការបម្រើដែលមានប្រភពដើមចេញពីភាសាឡាតាំង Minister មានន័យថា បាវបម្រើ។ មុខងារ រដ្ឋបាលកាលពីសម័យចក្រភពរ៉ូម៉ាំងជាមុខងារអនុវត្តច្បាប់ (នីតិប្រតិបត្តិ)។ នាពេលបច្ចុប្បន្ននេះ រដ្ឋបាលសាធារណៈលែងមានមុខងារនៅក្នុងការធ្វើសេចក្តីសម្រេចផ្សេងៗទៀតហើយ។

- តាមន័យមុខងារសាធារណៈរដ្ឋបាល គឺជាសកម្មភាពក្នុងការបំពេញសេចក្តីត្រូវការរបស់សមូហភាព ឬផលប្រយោជន៍រួម លើកលែងតែសកម្មភាពរបស់អង្គការនីតិបញ្ញត្តិ និងអង្គការតុលាការដែលមានរបបគតិយុត្តផ្ទាល់ខ្លួន។
- រីឯតាមន័យអង្គការវិញ រដ្ឋបាលសាធារណៈ គឺជាសកម្មភាពរបស់អង្គការ ដែលមានតួនាទីក្នុងការបម្រើផលប្រយោជន៍ទូទៅបើទោះបីជាអង្គការមួយនោះមានលក្ខន្តិកៈបែបណាក៏ដោយ (អង្គការ មានលក្ខន្តិកៈដោយឡែក) ឧទាហរណ៍ នីតិបុគ្គលសាធារណៈ (រដ្ឋ គ្រឹះស្ថានសាធារណៈ) នីតិបុគ្គលឯកជន (ក្រុមហ៊ុន សហគ្រាស សហគមន៍ អង្គការ) និងគណៈវិជ្ជាជីវៈ (គណៈមេធាវី)

+ ម្យ៉ាងវិញទៀតគេបានឱ្យនិយមន័យទៅលើ រដ្ឋបាលសាធារណៈ ដោយផ្អែកលើនិយមន័យតាមបែបនយោបាយតាមបែបច្បាប់តាមការគ្រប់គ្រង និងតាមអាជីព។

- តាមបែបច្បាប់ រដ្ឋបាលសាធារណៈ គឺជាច្បាប់ដែលកំពុងចូលជាធរមាន (កំពុងអនុវត្តន៍)

- តាមបែបនយោបាយ រដ្ឋបាលសាធារណៈ គឺជាជំហាននៃការធ្វើគោលនយោបាយសាធារណៈដែលគ្មានដែនកំណត់។
- តាមការគ្រប់គ្រង រដ្ឋបាលសាធារណៈ គឺជាសិល្បៈនៃការគ្រប់គ្រងនៅក្នុងជួររាជរដ្ឋាភិបាល។
- ចំណែកឯតាមន័យអាជីពវិញ រដ្ឋបាលសាធារណៈ ជាប្រភេទនៃអាជីពមួយ។

+ លក្ខណៈរបស់រដ្ឋបាលសាធារណៈ

រដ្ឋបាលត្រូវបានបែងចែកជាពីរប្រភេទ គឺរដ្ឋបាលសាធារណៈ និងរដ្ឋបាលឯកជន។ លោក NIGRO អ្នកនិពន្ធជនជាតិ អាមេរិចបានលើកឡើងថា រដ្ឋាភិបាល គឺមិនដូចគ្នានឹង ក្រុមហ៊ុនឯកជននោះទេ ទាំងទំហំ និងវិសាលភាពនៃការងារ។ សកម្មភាពរបស់រដ្ឋាភិបាល ប៉ះពាល់ដល់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសទាំងមូល។ ក្នុងន័យនេះ រដ្ឋបាលសាធារណៈ ត្រូវបានកំណត់សម្គាល់ដោយលក្ខណៈមួយចំនួនដូចខាងក្រោម៖

- ត្រូវបានប្រើប្រាស់នៅក្នុងក្របខណ្ឌ អង្គភាព ក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យរបស់រដ្ឋ។
- ការគ្រប់គ្រងមានលក្ខណៈទូលំទូលាយ
- សកម្មភាពរបស់មន្ត្រីរាជការ គឺផ្អែកលើមូលដ្ឋាននៃទំនុកចិត្តពីសាធារណជនពោល គឺការទទួលខុសត្រូវខាងផ្លូវច្បាប់
- នីតិក្នុងការចេញសេចក្តីសម្រេចមានលក្ខណៈជាប្រចាំ និងជាក់លាក់
- ទទួលរងនូវការរិះគន់ពីសាធារណជន។

### ១.១.២. តួនាទីរដ្ឋបាលសាធារណៈនៅក្នុងសម័យទំនើប

រដ្ឋបាលសាធារណៈ មានតួនាទីសំខាន់ណាស់នៅក្នុងរដ្ឋមួយ។ ការផលិត និងការផ្គត់ផ្គង់សេវាសាធារណៈ ការការពារ និងថែរក្សាសណ្តាប់ធ្នាប់សង្គម ការការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ គឺជាតួនាទីភារកិច្ចរបស់រាជរដ្ឋាភិបាលដែលត្រូវធ្វើតាមរយៈរាជរដ្ឋាបាលភិបាលសាធារណៈ។ មិនត្រឹមតែប៉ុណ្ណោះទេរាជរដ្ឋាភិបាលកាន់តែគិតគូរយ៉ាងខ្លាំងក្លាអំពីការអភិវឌ្ឍជាតិរបស់គេទាក់ទងសេដ្ឋកិច្ច សង្គមកិច្ច លើសពីអ្វីដែលរាជរដ្ឋាភិបាលធ្លាប់ធ្វើពីមុន គឺថែរក្សាសន្តិសុខជាតិ និងបានផ្តល់ផលិតផលនូវសេវាសាធារណៈ។ រដ្ឋបាលសាធារណៈមានតួនាទីមួយទៀត គឺភាពជាអ្នកដឹកនាំនៃប្រតិបត្តិ (Executive Leadership)។ ជារួមតួនាទីរបស់រាជរដ្ឋាភិបាលសាធារណៈត្រូវបានកំណត់ដូចខាងក្រោម៖

- បង្កើត និងផ្គត់ផ្គង់សេវាសាធារណៈ
- ថែរក្សាប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ បេតិកភ័ណ្ឌ
- ដាក់ចេញនូវគោលនយោបាយរដ្ឋបាល និងគោលនយោបាយការបរទេស។

- ថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ផ្តល់នូវយុត្តិធម៌សង្គម ការការពារនូវសិទ្ធិលើកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ថែរក្សាធនធានធម្មជាតិ ផលិត និងផ្គត់ផ្គង់នូវទំនិញសាធារណៈដល់ប្រជាពលរដ្ឋ ថែរក្សាទ្រព្យសម្បត្តិសាធារណៈដូចជា សួនច្បារ ទន្លេ សមុទ្រ សាលារៀន មន្ទីរពេទ្យ សារៈមន្ទី ជាដើម។

## ១.២. ប្រវត្តិរដ្ឋបាលកម្ពុជា

### ១.២.១. សម័យមុនអាណានិគមបារាំង

សម័យមុនអាណានិគមបារាំង គឺជារបបរាជានិយមដែលព្រះមហាក្សត្រ ក្តោបអំណាចទាំងអស់ដោយផ្ទាល់តែអង្គឯងជាពិសេស អំណាចនយោបាយ និងអំណាចរដ្ឋបាល។ ព្រះមហាក្សត្រមិនធ្វើច្បាប់ដោយផ្ទាល់ព្រះអង្គទេ គឺទ្រង់យកច្បាប់ដែលចេញពី គម្ពីរវេទ និងទំនៀមទម្លាប់មកប្រតិបត្តិតែម្តង។ ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យបញ្ញាតែក្នុងវិស័យរដ្ឋបាល និងក្នុងនីតិវិធីតុលាការខ្លះតែប៉ុណ្ណោះ។ ព្រះអង្គទ្រង់ធ្វើសវនាការកិច្ចការរដ្ឋបាលកាលសម័យយុគកណ្តាល (Moyen Age) ពីរដងក្នុងមួយថ្ងៃ ហើយព្រះអង្គជាចៅក្រមផងដែរ។[7] កាលសម័យនោះព្រះមហាក្សត្រត្រូវតែដឹកនាំចំបាំង ដោយផ្ទាល់ព្រះអង្គ ទើបសមជាព្រះមហាក្សត្រ ពីព្រោះព្រះអង្គត្រូវធ្វើជាគំរូដល់មេទ័ពឯទៀតៗដែលជាលោកមេបញ្ជាការកំពូលនោះ។ ព្រះអង្គទ្រង់ជាអធិបតីនៃសេនាបតីសភាដែលមានសមាសភាពដូចតទៅៈ

- សេនាបតី «ឧកញ៉ា ឬសម្តេច» ឥឡូវយើងហៅថា នាយករដ្ឋមន្ត្រី
- សេនាបតី «ឧកញ៉ា យោមរាជ» ឥឡូវហៅថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- សេនាបតី «ឧកញ៉ា វាំង» ជារដ្ឋមន្ត្រី នៃព្រះបរមរាជវាំង និងហិរញ្ញវត្ថុ
- សេនាបតី «ឧកញ៉ា ឬសម្តេចចក្រី» រដ្ឋមន្ត្រីខាងដឹកជញ្ជូនតាមជើងគោក និងខាងកងទ័ព
- សេនាសេនាបតី «ឧកញ៉ា ក្រឡាហោម» ជារដ្ឋមន្ត្រីខាងដឹកជញ្ជូនតាមផ្លូវទឹកសមុទ្រ
- សេនាបតីមានន័យ ដូចឥឡូវដែលហៅថា « រដ្ឋមន្ត្រី» ចំណែកឯសក្តិជា «ឧញ៉ា ឬសម្តេច» គឺជាយសដែលព្រះមហាក្សត្រប្រទានបន្ថែម។ គោរមងារ «សម្តេច» ធំជាង «ឧញ៉ា»។

អ្នកទាំងអស់នេះ គឺសុទ្ធតែព្រះមហាក្សត្រទ្រង់តែងតាំងដោយផ្ទាល់ទាំងអស់។ សេនាបតី ជាការប្រជុំសេនាបតីដូចយើងសព្វថ្ងៃគេហៅថា ប្រជុំគណៈរដ្ឋមន្ត្រី។ ចំពោះការរៀបចំរដ្ឋបាលដែនដី គឺយើងមានដូចជាៈ[8]

ក. **ដី** ដែលជាអតីតាជាណាចក្រ នៃប្រទេសដែលស្តេចខ្មែរវាយយកមកចំណុះរួមបញ្ចូលទឹកដីខ្មែរតែមួយ។ តាំងពីបរាជ័យនៅសម័យលង្វែកកាលពីឆ្នាំ១៥៩៣ មកឯកសារសំខាន់ៗបានបាត់អស់ ហេតុនេះហើយយើងពុំ

[7] លោក ជីវ តាហ្វាន់ កំណត់ហេតុរបស់សាស្ត្រាចារ្យចិន ឆ្នាំ១២៦៩

[8] សាស្ត្រាចារ្យ កេត ឧត្តម សៀវភៅរដ្ឋបាលសាធារណៈ ឆ្នាំ២០១៣

អាចដឹងច្បាស់ថាមានខេត្តចំនួន៩០ ឬ១០១ខេត្តទេ ពីព្រោះវាទៅជារឿងព្រេងអស់ហើយ ដោយសារការរលំរលាយនៃបន្ទាយលង្វែកនោះ។ ស្តេចដែលត្រូវកាន់កាប់ដីនោះគេហៅថា ស្តេចក្រាញ់ ដែលមានអំណាចតែងតាំង ឬដេញចោលមន្ត្រីទាំងអស់ដែលមាននៅក្នុងដីនោះ។ ស្តេចក្រាញ់បានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ។ ចាប់តាំងពីពាក់កណ្តាលសតវត្សទី១៩ មកព្រះអង្គឌួង (សោយរាជ្យ១៨៤៥ ដល់១៨៦០) បានលុបចោលស្តេចក្រាញ់ជាបន្តបន្ទាប់លើការកាន់កាប់ដីទាំងនោះ និងបានដកអំណាចទាំងអស់របស់ស្តេចក្រាញ់ឱ្យសល់ត្រឹម ៧៧ ងារតែប៉ុណ្ណោះ។

ខ. **មឿង** គឺជាការបែងចែករដ្ឋបាលដែនដី។ មន្ត្រីដែលគ្រប់គ្រងមឿង ក្នុងព្រះនាមនៃព្រះមហាក្សត្រគេហៅថា ចៅមឿង។ ព្រះបាទអង្គឌួងក្រោយមក ព្រះអង្គមិនចង់ឱ្យមានឈ្មោះមឿងដែលជាឈ្មោះសៀម ព្រះអង្គបានផ្លាស់ប្តូរឈ្មោះហើយបានហៅខេត្តវិញ។ ដូច្នេះ ខេត្តត្រូវបានកើតពីសម័យព្រះអង្គឌួង ហើយបានជាប់ឈ្មោះរហូតមកដល់សព្វថ្ងៃនេះទៅ។ នៅឆ្នាំ១៨៨៤ មាន៥៧ ខេត្ត។

គ. **ស្រុក** គឺជាឈ្មោះមួយដែលខ្មែរទូទៅហៅសម្រាប់សម្គាល់ភូមិកំណើតរបស់ខ្លួន កាលមុនសម័យបារាំងចូលមកមិនមែនជាមណ្ឌលរដ្ឋបាលឡើយ។ ស្រុកនេះជា ភូមិ ឥឡូវយើងហៅថា ឃុំ កើតឡើងពីគ្រួសារមួយ ឬហេតុនេះបានជាជួនកាលគេឱ្យឈ្មោះ ភូមិ ស្រុក។

កាលសម័យនោះកាលណារាស្ត្រនិយាយថា ចៅហ្វាយស្រុក គឺគាត់ចង់និយាយពី ចៅហ្វាយខេត្តវិញទេ។ ចាស់ៗជំនុំគ្នាជាក្រុមជំនុំហើយចាត់ក្នុងចំណោមជនដែលមានវ័យនៅក្មេងជាងគាត់ រួមទាំងមានបញ្ញាឆ្លាតវៀងវៃធ្វើការឱ្យស្រុកខ្លួនគេហៅថា មេស្រុក។ ដូច្នេះតាមប្រវត្តិសាស្ត្រ មេស្រុក គឺជាជំនួយការតែប៉ុណ្ណោះ។

ចាស់ៗនោះដល់ក្រោយមកបញ្ចូលក្នុងជំនុំរបស់ស្រុកនូវអតីតមន្ត្រី អាចារ្យវត្ត ឬអ្នកប្រាជ្ញអក្សរសាស្ត្រដើម្បីជួយគិតការងារដែលឱ្យឈ្មោះក្រុមនោះថា ក្រុមពញ្ញា ពួកនេះឥតមានបៀវត្សអ្វីទេ។ ក្រុមពញ្ញានេះបានបង្កើតភ្នាក់ងារជំនួយការ មេស្រុក ដែលហៅថា ជំទប់។ ហើយជំទប់អាចរកស្មៀនឱ្យមកជួយសរសេរ ឬធ្វើការងារផ្សេងៗបានដែរ។ គេទាំងអស់គ្នាធ្វើការងារគ្មានប្រាក់ខែទេ ពីព្រោះពុំទាន់មានការបង្កើតលុយចាយនៅឡើយ។ គេទទួលអំណោយជារង្វាន់ដូចជា៖ អង្ករ ទឹកត្រី ត្រី ជំនួសឱ្យប្រាក់ខែ។ ព្រះបាទអង្គឌួងទ្រង់បានបង្កើតប្រាក់ឱ្យចាយនៅពាក់កណ្តាលសតវត្សទី១៩។

### ១.២.២. សម័យអាណានិគមបារាំង

យើងបានដឹងហើយថា បារាំងបានធ្វើសន្ធិសញ្ញាមួយនៅក្នុងឆ្នាំ១៨៦៣ ដោយដាក់ប្រទេសកម្ពុជាឱ្យនៅក្រោមអាណាព្យាបាល (Protectorate) របស់ប្រទេសបារាំង។ ម្ភៃ (២០) ឆ្នាំក្រោយមកសន្ធិសញ្ញាឆ្នាំ១៨៦៣ គឺនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ សន្ធិសញ្ញាមួយទៀតដែលបារាំងបានបង្ខំឱ្យព្រះបាទ នរោត្តម

ទ្រង់ចុះហត្ថលេខាទាំងក្តៅក្រហាយនោះ បានធ្វើឱ្យប្រទេសខ្មែរ ក្លាយជាប្រទេសមួយដែលស្ថិតនៅក្រោមអាណានិគមបារាំង ថ្វីបើគេសរសេរជាផ្លូវការថា អាណាព្យាបាលក៏ដោយ ពីព្រោះថាបារាំងបានដកអំណាចពីមហាក្សត្រខ្មែរឱ្យលោក Resident Superior បារាំងគ្រប់គ្រងវិញ។ សេនាបតីសភាត្រូវប្រជុំក្រោមអធិបតីរបស់ Resident Superior កិច្ចប្រជុំលែងនៅក្រោមព្រះរាជាធិបតីរបស់ព្រះមហាក្សត្រខ្មែរដូចកាលពីដើមទេ។ នៅក្នុងវិស័យរដ្ឋបាល បារាំងបានយកគំរូរចនា សម្ព័ន្ធរបស់បារាំង ដែលបានអនុវត្តនៅប្រទេសវៀតណាមយកមកចម្លងដាក់ទាំងស្រុងនៅប្រទេសខ្មែរ។ នៅត្រួតពីលើចៅហ្វាយខេត្តខ្មែរ គឺមានលោក Resident បារាំងម្នាក់នៅគ្រប់ខេត្ត។ Resident នេះមានអំណាចខ្លាំងណាស់លើមន្ត្រីទាំងអស់លើចៅហ្វាយខេត្តខ្មែរទៀត។ ក្នុងខេត្តនីមួយៗមានចែកចេញជា Arrondissement (ដែលយើងហៅរហូតមកដល់សព្វថ្ងៃនេះថា ស្រុក) និងជា Communes (ដែលយើងហៅថា ឃុំ)។

### ១.២.៣. សម័យក្រោយអាណានិគមបារាំង

ក្រោយពីទទួលបានឯករាជ្យ បារាំងបានកាន់កាប់ប្រទេសខ្មែរជាង ៩០ឆ្នាំ ទើបសុខចិត្តប្រគល់មកឱ្យខ្មែរនូវឯករាជ្យភាពជាតិវិញនៅ ឆ្នាំ១៩៥៣ ដោយសារស្នាព្រះហស្តរបស់ព្រះបាទនរោត្តម សីហនុ ព្រះមហាក្សត្រខ្មែរ និងដោយសារការរួមសាមគ្គីរបស់ប្រជាពលរដ្ឋខ្មែរប្រកបដោយសេចក្តីប្តេជ្ញាចិត្តយ៉ាងមុតមាំ។ បារាំងដកចេញទៅមែនតែអ្វីៗដែលបារាំងបានបង្កើត ហើយនៅក្នុងវិស័យរដ្ឋបាល រចនាសម្ព័ន្ធ រួមទាំងរបៀបរបបនៃការធ្វើការនៅបន្តជាប់ជានិច្ចរបបសង្គមរាស្ត្រនិយម (រាជាណាចក្រទី១) ដូចជារបបសាធារណៈខ្មែរ លន់ នល់ ផងដែរ។ លិខិតស្នាមផ្លូវការច្រើនតែសរសេរជាភាសាបារាំង របៀបនៃធ្វើការ និងច្បាប់ទាំងឡាយនៅតែទៅតាមបារាំងទាំងអស់ពីព្រោះពួកជំនាញការ (Experts) ច្រើនតែពួកបារាំង។ នៅលើក្រដាសមានច្បាប់ដែលឱ្យសិទ្ធិទៅរាស្ត្រតាម ឃុំ ខេត្ត គ្រប់គ្រងផ្ទាល់កិច្ចការទាំងឡាយជាប្រយោជន៍ដល់ឃុំ ខេត្ត។

ប៉ុន្តែតាមប្រវត្តិសាស្ត្រជាក់ស្តែងអំណាចចៅហ្វាយខេត្ត (អភិបាលខេត្ត) ចៅហ្វាយក្រុង (អភិបាលក្រុង) និងចៅហ្វាយស្រុក (អភិបាលស្រុក) ដែលជាតំណាងកណ្តាលនោះនៅតែខ្លាំងដូចជំនាន់មុនដដែល។ ពីឆ្នាំ១៩៧៥ មកដល់ឆ្នាំ១៩៩៣ ប្រជាពលរដ្ឋចង់កាន់កាប់វាសនាជាតិដោយខ្លួនឯង គឺចង់រំដោះខ្លួនពីរបបអាណានិគមដែលខ្មែរគ្នាឯងធ្វើជំនួសបារាំងនោះ។ ខ្មែរក្រហមបានឆក់យកឱកាសនេះបានដាក់ពាក្យស្លោក «ឯករាជ្យម្ចាស់ការ» ដើម្បីទាក់ទាញចិត្តរាស្ត្រដែលចង់បាននោះ។ ប៉ុន្តែជាអកុសលចំពោះប្រជារាស្ត្រខ្មែរ ខ្មែរក្រហមមិនបានធ្វើអាណានិគមថ្មីទេតែធ្វើរបបផ្តាច់ការឃោរឃៅ កាប់សម្លាប់គតត្រាប្រណីហួសវិស័យដែលធ្វើឱ្យអ្នកទាំងអស់គ្នាមិនស្មានដល់ទេ។ លទ្ធិកុំម្មុយនីស្តផ្តាច់ការបានគ្រប់គ្រងប្រទេសចាប់ពីឆ្នាំ១៩៧៥ (ឆ្នាំ១៩៧៥ ដល់ ១៩៧៩) ដល់ឆ្នាំ១៩៨៩ (ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា) ហើយទើបតែធ្វើ

កំណែទម្រង់នយោបាយទៅរកសេដ្ឋកិច្ចទីផ្សារសេរីជាជំហានៗ តាំងពីឆ្នាំ១៩៨៩ រហូតមកដល់ការបង្កើតរាជាណាចក្រទី២ នៅឆ្នាំ១៩៩៣ ដោយសារតែមានការជួយជ្រោមជ្រែងពីសហគមន៍អន្តរជាតិដែលប្រជាពលរដ្ឋខ្មែរស្គាល់ហើយបានហៅថា អ៊ុនតាក់ (UNTAC = United Nations Transactional Authority of Cambodia)។ រាជាណាចក្រទី២ (Second-Kingdom) យោងតាមរដ្ឋធម្មនុញ្ញ១៩៩៣ យើងឃើញថាប្រទេសកម្ពុជានឹងធ្វើដំណើរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ កម្មវិធីរបស់រាជរដ្ឋាភិបាលមានចែងក្នុងទិសដៅថ្មីនេះដែរ។ យើងបានខិតខំកសាងស្តារ ប្រទេសឱ្យទៅជាប្រទេសមួយមានការអភិវឌ្ឍ និងជាប្រទេសនីតិរដ្ឋ។ ដោយសារតែផលវិបាកដែលបង្កឡើងដោយសង្គ្រាមរ៉ាំរ៉ៃជាងម្ភៃ (២០) ឆ្នាំមកនេះឧបសគ្គមានលើមាគ៌ាសេរីនិយម។

ស្ថានភាពប្រទេសកម្ពុជា បើតាមការសង្កេតក្នុងប្រវត្តិសាស្ត្រឃើញថាការអភិវឌ្ឍទៅមិនឆ្ងាយពីការប្រមូលផ្តុំអំណាចនៅថ្នាក់លើ (អំណាចកណ្តាល) ដូចពីសម័យដើមដែរ។

## ១.៣ គោលការណ៍នៃការរៀបចំគ្រប់គ្រងរដ្ឋបាល

នៅក្នុងការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋ នៅលើពិភពលោកយើងនេះ គឺគេធ្វើតាមស្ថានភាពជាក់ស្តែង ប្រសិនបើដែនដីនៃរដ្ឋនោះធំគេធ្វើការគ្រប់គ្រងដែនដីនោះ ដោយបែងចែកចេញជា តំបន់ ខេត្ត ស្រុក ឃុំ។ ការបែងចែកនេះ គឺធ្វើឡើងដើម្បីងាយស្រួលក្នុងការគ្រប់គ្រងលើវិសាលភាពដែនដីនេះ។ ប៉ុន្តែបើរដ្ឋដែលមានទំហំដែនដីតូចគេពុំអាចបែងចែកដែនដីនេះជា តំបន់ ខេត្ត ស្រុក ឃុំ បានទេគឺគេធ្វើការបែងចែកបានត្រឹមតែមណ្ឌលតូចៗតែប៉ុណ្ណោះ។

ពាក់ព័ន្ធនិងការគ្រប់គ្រងរដ្ឋបាលដែនដីនេះ គេតែងតែអនុវត្តនូវគោលការណ៍ជាសកលចំនួន២គឺៈ

- គោលការណ៍គ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធមជ្ឈការ
- គោលការណ៍គ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធវិមជ្ឈការ។

### ១.៣.១. គោលការណ៍គ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធមជ្ឈការ (Centralization)

#### ១.៣.១.១. និយមន័យមជ្ឈការ

ប្រព័ន្ធមជ្ឈការ គឺជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលមួយប្រភេទ ដែលអាជ្ញាធររដ្ឋបាលកណ្តាល មានសិទ្ធិអំណាចដោយផ្ទាល់ក្នុងការសម្រេចលើគ្រប់កិច្ចការ។ នៅក្នុងបរិបទប្រទេសកម្ពុជា គឺសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការនានាមានលក្ខណៈប្រមូលផ្តុំនៅអាជ្ញាធររដ្ឋបាលថ្នាក់ជាតិ ហើយអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិគ្មានសិទ្ធិអំណាចអ្វីឡើយ ដោយគ្រាន់តែជាភ្នាក់ងារជួយសម្របសម្រួលកិច្ចការតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតបើគេនិយាយអំពីប្រព័ន្ធមជ្ឈការ គឺនិយាយអំពីអំណាចកណ្តាល។ អំណាចកណ្តាល គឺជា

អំណាចរបស់រាជរដ្ឋាភិបាលដែលកាន់កាប់ដោយនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័នរដ្ឋទាំងឡាយ។ ប្រព័ន្ធមជ្ឈការ មានគោលដៅចំបងបីគឺៈ[9]

- នីតិបុគ្គលសាធារណៈមានតែមួយ (រដ្ឋ)
- អំណាចសម្រេចសេចក្តី និងបញ្ជាប្រមូលផ្តុំនៅរដ្ឋបាលកណ្តាល
- រដ្ឋបាលទាំងអស់ត្រូវរៀបចំតាមគោលការណ៍ឋានានុក្រម ដែលស្ថិតនៅក្រោមចំណុះ និងការត្រួតពិនិត្យផ្ទាល់របស់អំណាចកណ្តាល ឬអំណាចរដ្ឋបាលកណ្តាល។ ភ្នាក់ងាររដ្ឋបាលគ្រប់ជាន់ថ្នាក់ទាំងអស់ដែលមានទីតាំងនៅមូលដ្ឋាននានាដែលបំពេញតួនាទី ជាអ្នកប្រើប្រាស់អំណាចរដ្ឋបាល ហើយត្រូវស្ថិតនៅក្រោមអំណាចឋានានុក្រមរបស់អំណាចកណ្តាល។ ភ្នាក់ងារទាំងនេះទទួលបទបញ្ជា ពីរដ្ឋបាលកណ្តាល និងទទួលបន្ទុកអនុវត្តន៍បទបញ្ជាទាំងនោះ ចំណែកឯសិទ្ធ និងគំនិតផ្តួចផ្តើមរបស់ខ្លួននៅមានកម្រិតនៅឡើយ។

**១.៣.១.២. ចរិតលក្ខណៈ**

ក្នុងការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធមជ្ឈការ គឺធ្វើការគ្រប់គ្រងតាមរាងសាជីដោយអំណាចក្នុងការធ្វើការសម្រេចទាំងអស់ជាសិទ្ធិផ្តាច់មុខរបស់រាជរដ្ឋាភិបាល។ ដូចនេះរាល់ការបង្កើត រាល់ការសម្រេច ការកែប្រែអ្វីៗគឺដោយរាជរដ្ឋាភិបាលទាំងអស់។ អាស្រ័យដោយការរីកចម្រើនជាលំដាប់នៃបេសកកម្ម តួនាទីភារកិច្ចរបស់រដ្ឋ ក្នុងការបម្រើផលប្រយោជន៍ទូទៅ តម្រូវឱ្យរដ្ឋបាលកណ្តាលរំលែកអំណាចមួយចំនួន ដែលអាចធ្វើបានដើម្បីឱ្យអាជ្ញាធរមូលដ្ឋានជួយសម្រេច។ ការរំលែកអំណាចនេះ ពីព្រោះរដ្ឋបាលកណ្តាលមានភារកិច្ចច្រើនមានបញ្ហារាប់មិនអស់នាំឱ្យលេចលង់ដោយសំណុំរឿង ធ្វើឱ្យរងការកកស្ទះសំណុំរឿងជាច្រើននៅរដ្ឋបាលកណ្តាល។ ម្យ៉ាងវិញទៀតធ្វើឱ្យមានគម្លាតធំពេករវាងរដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋានពោល គឺរដ្ឋបាលកណ្តាលមិនបានដឹងអំពីស្ថានភាព សុខទុក្ខ តម្រូវការរបស់រាស្ត្រប្រជាបានឡើយ។

**១.៣.១.៣. គុណសម្បត្តិ និងគុណវិបត្តិ**

+ ចំពោះគុណសម្បត្តិមានដូចជាៈ

- អំណាចកណ្តាលអាចជួយខេត្តបាន និងអំណាចកណ្តាលតែងតាំងទៅសុទ្ធតែជាមនុស្សមានសមត្ថភាព
- មានឯករាជ្យភាពជាតិ បានន័យថាធ្វើឱ្យរដ្ឋសម្រេចអ្វីមួយដូចៗគ្នាទូទាំងប្រទេស គឺនាំឱ្យមានឯកភាពទាំងទស្សនៈ ទាំងអំពើរបស់រដ្ឋ ហើយម្យ៉ាងទៀតឯកភាពនៃប្រទេសមានភាពរឹងមាំល្អ ព្រោះរដ្ឋក្តាប់ស្ថានការណ៍បានទាំងអស់។

[9] សាស្ត្រាចារ្យ កេត ឧត្តម ឯកសារមេរៀនសាធារណៈ

+ ចំពោះគុណវិបត្តិមានដូចជា៖

- ខ្វះលទ្ធិប្រជាធិបតេយ្យ (អាជ្ញាធរតែងតាំង) និងអាចបង្កនូវភាពយឺតយ៉ាវក្នុងការសម្រេច
- សម្រេចកិច្ចការមិនយល់អំពីសភាពការណ៍ (សម្រេចលើកិច្ចការដែលខ្លួនក្តាប់មិនបាន) រដ្ឋមិនអាចដឹងពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅតាមទីកន្លែង ឱ្យបានសព្វគ្រប់ឡើយប្រការនេះនាំឱ្យសេចក្តីសម្រេច ឬកម្មវិធីនយោបាយដែលចេញដោយអំណាចកណ្តាលពុំសូវមានប្រសិទ្ធិភាព និងមិនអាចឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានបាន។
- ប្រជាពលរដ្ឋជួបការលំបាកក្នុងជីវភាពប្រចាំថ្ងៃពីព្រោះពួកគេត្រូវឡើងមកធ្វើការ នៅរាជធានីភ្នំពេញដើម្បីធ្វើកិច្ចការឱ្យចប់តាំងពីការងារតូចតាចឡើងទៅ។
- ការធ្វើមជ្ឈការដែលប្រមូលផ្តុំរឿងទាំងអស់នេះ មកថ្នាក់លើតែមួយបណ្តាលឱ្យអង្គការនៃអំណាចកណ្តាលលេចលង់ទៅដោយសំណុំរឿងទាំងនេះ។ កិច្ចការកកកុញ កកស្ទះមិនចេញនាំឱ្យមានការយឺតយ៉ាវខាតសោហ៊ុយ (រដ្ឋបាលកណ្តាលសម្រេចតែម្នាក់ឯងដោយអត្តនោម័ត)។

**១.៣.២. បច្ចេកទេសក្នុងការរំលែកអំណាច**

ដោយមានភាពតានតឹងរ៉ឹង នៅក្នុងការគ្រប់គ្រងរដ្ឋបាលកណ្តាល នៃប្រព័ន្ធមជ្ឈការ បានបញ្ចេញនូវបច្ចេកទេសមួយ គឺបច្ចេកទេសក្នុងការចែករំលែកអំណាច ក្នុងគោលការណ៍ដើម្បីកាត់បន្ថយនូវផលអាក្រក់របស់ខ្លួនដែលគេហៅថា ការរំលែកអំណាចកណ្តាលបែង (វិសហមជ្ឈការ)។

**១.៣.២.១. សញ្ញាណ និងនិយមន័យវិសហមជ្ឈការ** ( Deconcentration )

វិសហមជ្ឈការ គឺជាបច្ចេកទេសរដ្ឋបាលមួយដែលអាជ្ញាធររដ្ឋបាលកណ្តាល រំលែកកិច្ចការមួយចំនួនឱ្យរដ្ឋបាលមូលដ្ឋានធ្វើការសម្រេចចិត្តដោយខ្លួនឯងផ្ទាល់មានន័យថា ជាបច្ចេកទេសនៃការរៀបចំរដ្ឋបាលមួយដែលត្រូវបានបង្កើតឡើងដើម្បីកែសម្រួលប្រព័ន្ធមជ្ឈការ ហើយបានផ្តល់ឱ្យអាជ្ញាធរមូលដ្ឋាននូវអំណាចសម្រេចសេចក្តីលើកិច្ចការខ្លះៗ ដែលជាធម្មតាអំណាចទាំងនេះជាអំណាចរដ្ឋបាលកណ្តាល។ ភ្នាក់ងារដែលទទួលដឹកនាំអាជ្ញាធរដែនដីទាំងនេះ គឺត្រូវស្ថិតនៅក្រោមអំណាចឋានានុក្រមនៃរដ្ឋបាលកណ្តាលដដែលគេមិនត្រូវច្រលំពាក្យវិសហមជ្ឈការជាមួយនិង ពាក្យវិមជ្ឈការនោះទេ ពីព្រោះវិសហមជ្ឈការមិនបានធ្វើឱ្យមានការផ្លាស់ប្តូរប្រព័ន្ធរដ្ឋបាលឡើយ គឺគ្រាន់តែសម្រួលដល់ប្រព័ន្ធមជ្ឈការតែប៉ុណ្ណោះ។ បើតាមន័យម្យ៉ាងទៀត វិសហមជ្ឈការ គឺរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្ម មុខងារ សិទ្ធិអំណាច និងធនធានឱ្យអង្គភាពនៅក្រោមបង្គាប់ឬឱ្យទៅក្រុមប្រឹក្សាប្រភេទមួយណាដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាពចំពោះ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ស្របតាមតម្រូវការនៃការធ្វើប្រតិភូកម្មនេះ។ វិសហមជ្ឈការ បានផ្តល់នូវភាពទន់ភ្លន់ដល់ដំណើរការរដ្ឋបាល និងភាពធូរស្រាលដល់

អំណាចកណ្តាល ពីព្រោះបានផ្តល់នូវការទទួលខុសត្រូវចំពោះកិច្ចការខ្លះៗ ដល់អាជ្ញាធរដែនដីដើម្បីសម្រេចបានកិច្ចការក្នុងនាមជាអំណាចកណ្តាល។

**១.៣.២.២. ចរិតលក្ខណៈ**

ការគ្រប់គ្រងរដ្ឋបាលខណ្ឌតាមបែបបច្ចេកទេស គឺជាការគ្រប់គ្រងតាមឋានានុក្រមរដ្ឋបាល ដែលអំណាចកណ្តាលបានផ្តល់ឱ្យសម្រេចតាមលំដាប់ថ្នាក់រៀងៗខ្លួន។ រាល់ប្រព័ន្ធការងារ គឺតែងតាំងតំណាងរដ្ឋបាលដោយគ្មានការបោះឆ្នោតជ្រើសតាំងទេពោល គឺអាជ្ញាធរមូលដ្ឋានកើតមានឡើងនូវសិទ្ធិក្នុងការសម្រេច អាស្រ័យដោយសប្បុរសធម៌របស់អាជ្ញាធរកណ្តាលតែប៉ុណ្ណោះ។ ចំណែកឯការប្រើប្រាស់ថវិកាវិញ គឺថវិកាជាតិ អាជ្ញាធរមូលដ្ឋានគ្មានថវិកាផ្ទាល់ខ្លួនទេ។ ក្នុងករណីត្រូវការបុគ្គលិកអាជ្ញាធរមូលដ្ឋានគ្មានសិទ្ធិជ្រើសរើសដែរ។ យើងដឹងស្រាប់ហើយថាអាជ្ញាធររដ្ឋបាលកណ្តាលជាអ្នកកំណត់រាល់កិច្ចការរបស់រដ្ឋ ឯអាជ្ញាធរមូលដ្ឋានដែលទទួលបាននូវសិទ្ធិក្នុងការសម្រេច គឺត្រូវធ្វើតាមការកំណត់តែប៉ុណ្ណោះ។

**១.៣.២.៣. គុណសម្បត្តិ និងគុណវិបត្តិ**

+ គុណសម្បត្តិ

- កាត់បន្ថយការប្រើប្រាស់អំណាចជ្រុលហួសហេតុរបស់អាជ្ញាធរកណ្តាល
- អាជ្ញាធរមូលដ្ឋានសម្រេចបញ្ហានៅទីកន្លែងផ្ទាល់ៗ ជួយសម្របសម្រួលជីវភាព និងកិច្ចការរបស់ប្រជារាស្ត្រ
- ការងាររឆាប់រហ័ស ទាន់ពេលវេលា ចំណេញពេលវេលា និងកាត់បន្ថយការចំណាយ។

+ គុណវិបត្តិ

- ខ្វះលទ្ធិប្រជាធិបតេយ្យ

**១.៣.២.៤. វិធីសាស្ត្រ**

ការបែងចែកអំណាចក្នុងការសម្រេចនេះគឺ គេប្រើវិធីមួយដែលហៅថាប្រតិភូកម្ម។ ប្រតិភូកម្មនេះបានចែកចេញជាពីរគឺ ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា។ ជួនកាលគេបញ្ជាក់ដោយពាក្យទូទៅមួយហៅថាប្រតិភូកម្មសមត្ថកិច្ច។

**ប្រតិភូកម្មអំណាចៈ** គឺជាការផ្ទេរសមត្ថកិច្ចមួយបែប ទៅឱ្យអាជ្ញាធររដ្ឋបាល ទាំងឡាយដែលនៅក្នុងឋានានុក្រមរដ្ឋបាលរបស់ខ្លួន។ ប្រតិភូកម្មអំណាចនេះអាចធ្វើទៅបានលុះត្រាតែ មានលិខិតបទដ្ឋានគតិយុត្តចែងហើយពុំអាចធ្វើប្រតិភូកម្មអំណាច តាមការនឹកឃើញនោះទេ ជាពិសេសមិនអាចធ្វើប្រតិភូកម្មទាំងស្រុងបានទេ។[10]

[10] សាស្ត្រាចារ្យ កេត ឧត្តម សៀវភៅរដ្ឋបាលសាធារណៈ ឆ្នាំ២០១៣

នីតិវិធីនៃការធ្វើប្រតិភូកម្មអំណាច គឺត្រូវផ្សព្វផ្សាយជាសាធារណៈ និងដើម្បីឱ្យថ្នាក់ក្រោមទទួលយកទៅអនុវត្ត ហើយយុត្តិសាស្ត្រទាមទារឱ្យសរសេរជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់ពីការធ្វើប្រតិភូកម្មអំណាច។

ប្រតិភូកម្មអំណាចនេះ ត្រូវធ្វើឡើងដោយអាជ្ញាធរកណ្ដាលឱ្យទៅ អាជ្ញាធរថ្នាក់ក្រោមជាតិដែលពេលនោះមានសិទ្ធិសម្រេចផ្ទាល់បាន ប៉ុន្តែក្នុងនាមជាអាជ្ញាធររដ្ឋបាលកណ្ដាលដដែល។ ប្រតិភូកម្មអំណាចមានផលវិបាកជាក់លាក់ណាស់ដូចជា៖

- នាំឱ្យមានការផ្ទេរអំណាចមួយយ៉ាងពិតប្រាកដ គឺថាអ្នកផ្ទេរក្លាយជាអសមត្ថភាពដោយខ្លួនគ្មានសិទ្ធិចេញសេចក្ដីសម្រេចអ្វីផ្សេងទាក់ទង និងផ្នែកដែលបានផ្ទេរនោះទេ។ នៅពេលនោះសេចក្ដីសម្រេចគឺជាសិទ្ធិរបស់អ្នកទទួលការផ្ទេរ។
- សេចក្ដីសម្រេចរបស់អ្នកទទួលការផ្ទេរ គឺមានអានុភាពគតិយុត្តស្មើ និងថ្នាក់របស់អាជ្ញាធរដែលខ្លួនចេញ។ ពោលគឺសេចក្ដីសម្រេចរបស់អាជ្ញាធរទទួលការផ្ទេរ។

**ប្រតិភូកម្មហត្ថលេខា:** គឺជាវិធីសាស្ត្រមួយដែលតាមរយៈនេះ អាជ្ញាធររដ្ឋបាលកណ្ដាលនីមួយៗបានប្រគល់ឱ្យសហការីណាម្នាក់របស់ខ្លួននូវការចុះហត្ថលេខាជួសលើសេចក្ដីសម្រេចខ្លះៗ ចំពោះកិច្ចការនានា។

ប្រតិភូកម្មហត្ថលេខានេះ បានផ្ដល់ភាពងាយស្រួលមួយផ្នែកក្នុងការងារគ្រប់គ្រងរដ្ឋបាលដោយពុំចាំបាច់ធ្វើប្រតិភូកម្មបន្តទៀតទេ។ ការធ្វើប្រតិភូកម្មហត្ថលេខានេះ គឺអាជ្ញាធរដែលបានប្រគល់ (ប្រតិភូនាយក) ត្រូវប្រគល់ឱ្យចំឈ្មោះបុគ្គល (ប្រតិភូ) ដោយបញ្ជាក់អំពី ឋានៈ តួនាទីឱ្យបានច្បាស់លាស់ និងត្រូវធ្វើសារជាថ្មីបើមានការផ្លាស់ប្ដូរបុគ្គល។ ការធ្វើប្រតិភូកម្មហត្ថលេខា គឺមានតែលើការចុះហត្ថលេខាតែប៉ុណ្ណោះ ដោយគ្មានការប៉ះពាល់ដល់ការបែងចែកអំណាចទេ ហើយអាជ្ញាធរដែលបានផ្ទេរហត្ថលេខាអាចរក្សាសិទ្ធិចុះហត្ថលេខាវិញគ្រប់ពេលវេលា។[11] ប្រតិភូកម្មនេះ បើតាមផ្លូវច្បាប់សេចក្ដីសម្រេចទាំងនេះ គឺជាសេចក្ដីសម្រេចរបស់អាជ្ញាធរផ្ទេរហត្ថលេខា ដូចនេះ អាជ្ញាធរជាម្ចាស់អំណាចជាអ្នកទទួលខុសត្រូវ។ ផ្ទុយទៅវិញរាល់ការចុះហត្ថលេខាជួសនេះត្រូវទុកឯកសារឱ្យអាជ្ញាធរផ្ទេរហត្ថលេខាធ្វើការត្រួតពិនិត្យគ្រប់ពេលវេលា និងគ្រប់ករណី។

<u>**សម្គាល់៖**</u> អាជ្ញាធរផ្ទេរហត្ថលេខាទៅឱ្យបុគ្គលណាម្នាក់ដើម្បីចុះហត្ថលេខាជំនួស បុគ្គលនោះមិនអាចផ្ទេរការចុះហត្ថលេខាបន្តទៅបុគ្គលផ្សេងទៀតបានទេ។ ហើយអាចផ្ទេរទៅបុគ្គលផ្សេងទៀតបានលុះត្រាតែមានការយល់ព្រមពីម្ចាស់ហត្ថលេខា។

[11] ឧត្តមសិក្សាជាន់ខ្ពស់ ង៉ុយ ធឿន នីតិរដ្ឋបាល ឆ្នាំ២០១៧

តារាងទី១៖ ប្រៀបធៀបប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា

| | **ប្រតិភូកម្មអំណាច** | **ប្រតិភូកម្មហត្ថលេខា** |
|---|---|---|
| ធ្វើឡើង | អង្គការមួយទៅអង្គការមួយ | ពីអាជ្ញាធរមួយទៅសហការី (អាជ្ញាធរជាអ្នកទ្រទ្រង់អំណាច) |
| លក្ខណៈ | – អរូបីមិនចំពោះបុគ្គល<br>– មិនប្រែប្រួលទៅតាមការផ្លាស់ប្តូរប្រតិកម្ម ប្រតិភូនាយក<br>– ផ្ទេរភាគរយនៃអំណាច (មិនអាចអនុវត្តបានទៀតទេ) ប្រតិភូនាយក និងប្រតិភូអនុវត្តមានកាព្វកិច្ចដាច់ដោយឡែក | – ចង្អុលចំបុគ្គលឈ្មោះ (តួនាទី ឋានៈ)<br>– ប្រែប្រួលតាមប្រតិភូ ឬប្រតិភូនាយក<br>– ប្រតិភូនាយកគ្រាន់តែបានដកបន្ទុកការងារជាក់ស្តែងមួយចំណែកប៉ុណ្ណោះ (អនុវត្តវិញបានគ្រប់ពេលវេលា) ប្រតិភូនាយក និងប្រតិភូអនុវត្តកិច្ចការរួមគ្នា |
| តម្លៃសេចក្តីសម្រេច | អនុវត្តសេចក្តីសម្រេចនៅក្នុងឋានានុក្រម | ដូចសេចក្តីសម្រេចរបស់ប្រតិភូនាយក |
| ភាពទទួលខុសត្រូវ | ប្រតិភូទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្តអំណាចដែលផ្ទេរនោះ | ប្រតិភូនាយកជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តភារកិច្ចដែលផ្ទេរទៅឱ្យប្រតិភូ |
| ប្រតិភូកម្មបន្ត | អាចធ្វើប្រតិភូកម្មហត្ថលេខាបន្ត | គ្មានលទ្ធភាពធ្វើប្រតិភូកម្មបន្ត (អាចធ្វើបានបើមានការយល់ព្រមពីប្រតិភូនាយក) |

### ១.៣.៣. គោលការណ៍នៃការរៀបចំគ្រប់គ្រងបែបវិមជ្ឈការ ( Decentralization )

#### ១.៣.៣.១. សញ្ញាណ និងនិយមន័យ

វិមជ្ឈការ មានន័យថា រាជរដ្ឋាភិបាលបានប្រគល់នូវភាពជាម្ចាស់លើ មុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គល) ឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹង

តម្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងអស់។[12] ប្រព័ន្ធវិមជ្ឈការ គឺជាប្រព័ន្ធនៃកិច្ចអភិបាលសំដៅលើអនុញ្ញាតឱ្យចំពោះសមូហភាពមនុស្សជាតិមួយ (ការរំលែកអំណាចខាងដែនដី) ឬចំពោះកិច្ចការមួយ (ការរំលែកអំណាចខាងបច្ចេកទេស) ដើម្បីអភិបាលដោយខ្លួនឯងក្រោមការត្រួតពិនិត្យរបស់រដ្ឋបាលដោយឱ្យបុគ្គលភាពគតិយុត្ត អំណាចផ្ទាល់ខ្លួន និងធនធាន។

ប្រព័ន្ធវិមជ្ឈការ គឺជាប្រព័ន្ធមួយដែលអាជ្ញាធររដ្ឋបាលកណ្តាលទទួលស្គាល់នូវសិទ្ធិអំណាចចំពោះការធ្វើសេចក្តីសម្រេចរបស់អាជ្ញាធរមូលដ្ឋានដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នានា។ ក្នុងការទទួលស្គាល់សិទ្ធិអំណាចរបស់ អាជ្ញាធរមូលដ្ឋាននេះ គឺជាការផ្ទេរអំណាច និងផ្ទេរការទទួលខុសត្រូវលើកិច្ចការមួយចំនួនឱ្យអាជ្ញាធរមូលដ្ឋានចាត់ចែងការងារដើម្បីបម្រើផលប្រយោជន៍មូលដ្ឋានខ្លួន។[13] ម្យ៉ាងវិញទៀតវិមជ្ឈការ គឺរាជរដ្ឋាភិបាលបានប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានដើម្បីឆ្លើយតបសេចក្តីត្រូវការមូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋានលើបញ្ហាទាំងអស់។[14]

**១.៣.៣.២. ចរិតលក្ខណៈ**

ទោះបីជាទម្រង់នៃការរៀបចំនេះ គឺបានប្រគល់អំណាចឱ្យទៅសមូហភាពដែនដី នូវសិទ្ធិអំណាចក្នុងការសម្រេចប្រកបដោយស្វ័យភាព មានកិច្ចការមួយចំនួនធំសំខាន់ចាំបាច់ផ្សេងៗទៀតដែលជាអាជ្ញាធរកណ្តាលអោបក្រសោបតែម្នាក់ឯងនោះគឺ កិច្ចការការពារជាតិ កិច្ចការសន្តិសុខ កិច្ចការពាណិជ្ជកម្មក្រៅប្រទេស កិច្ចការបោះពុម្ពប្រាក់ កិច្ចការធ្វើច្បាប់ កិច្ចការការទូត កិច្ចការអត្រានុកូលដ្ឋាន ធនធានធម្មជាតិ ជាកិច្ចការផ្តាច់មុខរបស់រដ្ឋ។ ក្នុងប្រព័ន្ធនេះអំណាចកណ្តាលបានប្រគល់ឱ្យសមូហភាពដែនដីធ្វើការភាគច្រើនជាកិច្ចការផ្នែកសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ ជាពិសេស គឺការងារអភិវឌ្ឍន៍។

**ក. ការទទួលស្គាល់នៅប្រយោជន៍តាមមូលដ្ឋាន**

គេធ្វើការវែកញែករវាងផលប្រយោជន៍ប្រជារាស្ត្រទូទាំងប្រទេស រួមទាំងផលប្រយោជន៍ប្រជារាស្ត្រនៅទីកន្លែង។ ផលប្រយោជន៍ប្រជារាស្ត្រ តាមទីកន្លែងដូចជា ភូមិ ឃុំ សង្កាត់ ជាដើមផលប្រយោជន៍ផ្ទាល់សម្រាប់រាស្ត្រប្រជានៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ប្រជារាស្ត្រតែងតែប្រកបមុខងារខ្លះ មានផ្ទះសម្បែងផ្ទាល់ខ្លួន ខ្លះជួលផ្ទះគេ និងធ្វើដំណើរចុះឡើងរៀនសូត្រ កំសាន្ត និងធ្វើបុណ្យទាន់នៅនិងកន្លែង ឬបុណ្យកំណើតរបស់ខ្លួន។

[12] សាស្ត្រាចារ្យ ឥន យឿន សៀវភៅស្តីពីស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣

[13] បណ្ឌិត សុខ ទូច នីតិរដ្ឋបាលសាធារណៈ ឆ្នាំ២០០៩

[14] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សន្ទានុក្រម ឆ្នាំ២០០៨

**ខ. ការបោះឆ្នោតជ្រើសរើសអ្នកតំណាងដឹកនាំ**

អង្គភាពដឹកនាំនៃសមូហភាពដែនដី ត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតរបស់រាស្ត្រប្រជានៅទីកន្លែង។ នៅប្រទេសបារាំងមាត្រា២៧ នៃរដ្ឋធម្មនុញ្ញកំណត់ថា អង្គការ ឬអ្នកដឹកនាំមូលដ្ឋានត្រូវកើតចេញពីការបោះឆ្នោតរបស់ប្រជារាស្ត្រនៅតាមមូលដ្ឋាន។ លក្ខណៈនេះហើយបានធ្វើឱ្យប្រព័ន្ធវិមជ្ឈការ ខុសប្លែកពីប្រព័ន្ធវិសហមជ្ឈការ ព្រោះថានៅក្នុងប្រព័ន្ធវិសហមជ្ឈការអ្នកដឹកនាំ តាមមូលដ្ឋានមិនមែនកើតឡើងពីការបោះឆ្នោតរបស់រាស្ត្រប្រជានោះទេ ប៉ុន្តែជាមន្ត្រីដែលត្រូវបានតែងតាំងដោយអំណាចកណ្តាល។ អង្គការដែលដឹកនាំសមូហភាពដែនដីជាតំណាងស្របច្បាប់របស់ប្រជារាស្ត្រនៅមូលដ្ឋាន។

**គ. ការផ្តល់បុគ្គលភាពគតិយុត្តដល់សមូហភាពដែនដី**

ច្បាប់ផ្តល់បុគ្គលភាពគតិយុត្តដល់សមូហភាពដែនដី គឺមានន័យថាសមូហភាព និងទៅជានីតិបុគ្គលសាធារណៈដែលអង្គការដឹកនាំមានស្វ័យភាពពីរគឺៈ ១/ ស្វ័យភាពគ្រប់គ្រង ឬរដ្ឋបាលស្វ័យភាពក្នុងការគ្រប់គ្រងនេះគឺអង្គការគ្រប់គ្រងសមូហភាពដែនដីកើតឡើងដោយការបោះឆ្នោតជ្រើសតាំង មានសិទ្ធិអំណាចក្នុងការសម្រេចដោយផ្ទាល់។ សិទ្ធិ និងអំណាចនេះមានចែងនៅច្បាប់។ ២/ ស្វ័យភាពហិរញ្ញវត្ថុ គឺអង្គការគ្រប់គ្រងសមូហភាពដែនដីនេះមានថវិកាផ្ទាល់ខ្លួន។ ថវិការបស់អង្គការបានមកពីការយកពន្ធដារ ជួលអគារជាដើម។

<u>**សម្គាល់៖**</u> ការទទួលស្គាល់របស់អាជ្ញាធរកណ្តាល មិនមែនមានន័យថាគ្រប់គ្រងនោះទេតែថែមទាំងមិនលូកដៃទៀតផង។ ផ្ទុយទៅវិញអាជ្ញាធររដ្ឋបាលកណ្តាលអាចត្រួតពិនិត្យតិច ឬច្រើនតាមសមូហភាពដែនដីបានលុះត្រាតែមានកំណត់ និងចែងដោយច្បាប់តែប៉ុណ្ណោះ។

**ឃ. អំណាចត្រួតពិនិត្យរដ្ឋបាល**

រដ្ឋបាលអាចធ្វើការត្រួតពិនិត្យលើផ្នែករដ្ឋបាលនៃសមូហភាពដែនដី តែក្នុងការកំណត់នៃក្របខណ្ឌច្បាប់។ ប្រសិនបើគ្មានអត្ថបទច្បាប់កំណត់ទេ គឺរដ្ឋមិនអាចធ្វើការត្រួតពិនិត្យជា ស្វ័យប្រវត្តិបានឡើយ។ ហើយរដ្ឋពុំអាចត្រួតពិនិត្យឱ្យហួសពីការកំណត់របស់ច្បាប់បានទេ។ ការត្រួតពិនិត្យអាជ្ញាធរវិមជ្ឈការ គឺគេហៅថាការត្រួតពិនិត្យអាណាព្យាបាលហើយអាចធ្វើលើបុគ្គល និងអាចធ្វើលើសេចក្តីសម្រេច។

១/ ការត្រួតពិនិត្យលើបុគ្គលក្រោយពីអត្ថបទច្បាប់កំណត់ពីការរៀបចំ និងប្រព្រឹត្តិទៅនៃការរៀបចំរដ្ឋបាលវិមជ្ឈការតែងតែឃើញមាននូវសិទ្ធិអំណាចមួយចំនួនដែលរដ្ឋធ្វើការត្រួតពិនិត្យនោះ ទាក់ទិនបេក្ខភាពនានារបស់រដ្ឋបាលវិមជ្ឈការដូចជា តំណាងឱ្យប្រជារាស្ត្រ តំណាងឱ្យរដ្ឋ គណនេយ្យភាពជាដើម។

២/ ការត្រួតពិនិត្យលើសេចក្តីសម្រេចៈ រដ្ឋបាលវិមជ្ឈការ ដែលទទួលបាននូវស្វ័យភាព គឺមិនមែនមានន័យថាឯករាជ្យ ក្នុងការធ្វើសេចក្តីសម្រេចទេ តែផ្ទុយទៅវិញរាល់សេចក្តីសម្រេចទាំងនោះ ទោះទាក់ទិននិងវិស័យរដ្ឋបាលដូចវិស័យហិរញ្ញវត្ថុក៏ដោយ គឺត្រូវស្ថិតនៅក្នុងការត្រួតពិនិត្យ ពីសំណាក់អាជ្ញាធរថ្នាក់ជាតិដដែលដែល

គេហៅថាការត្រួតពិនិត្យជាបច្ឆាកាល។ សរុបសេចក្តីមករដ្ឋបាលមានតួនាទីយ៉ាងសំខាន់ណាស់ នៅក្នុងការតាមដានដូចជា ការត្រួតពិនិត្យរាល់សកម្មភាពរបស់ប្រព័ន្ធវិមជ្ឈការនេះព្រមទាំងមានសិទ្ធិកែប្រែ ឬលុបចោលសេចក្តីសម្រេចដូចជារំលាយក្រុមប្រឹក្សានានារបស់រដ្ឋបាលវិមជ្ឈការ។

**១.៣.៣.៣. គុណសម្បត្តិ និងគុណវិបត្តិ**

\+ ចំពោះគុណសម្បត្តិរបស់ប្រព័ន្ធវិមជ្ឈការមានដូចខាងក្រោម៖[15]

- **អំពីនយោបាយ**៖ ជាការកាត់បន្ថយអំណាចរដ្ឋបាលកណ្តាល ហើយធ្វើឱ្យមានលក្ខណៈប្រជាធិបតេយ្យដែលបានអនុវត្តន៍នៅមូលដ្ឋាន។ ម្យ៉ាងវិញទៀត ជាមួយគោលការណ៍ធ្វើឱ្យមានប្រជាធិបតេយ្យកាន់តែទូលំទូលាយ ដោយបើកឱកាសឱ្យមូលដ្ឋានបានចូលរួមក្នុងដេញដោល និងបញ្ចេញនូវទស្សនៈ។
- **អំពីវិស័យរដ្ឋបាល**៖ បណ្តុះបណ្តាលនូវសមត្ថភាពស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យទទួលខុសត្រូវចេះបំផុសគំនិតធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន ដោយគិតគូរផលប្រយោជន៍ទូទៅជាងផលប្រយោជន៍ផ្ទាល់ខ្លួន។

\+ ចំពោះគុណវិបត្តិរបស់វិមជ្ឈការមានដូចជា៖

ការកាត់បន្ថយអំណាចរដ្ឋបាលថ្នាក់ជាតិខ្លាំងពេក អាចធ្វើឱ្យមានគុណវិបត្តិដូចជា៖

- អាចធ្វើឱ្យមានគ្រោះថ្នាក់ដល់ប្រទេសជាតិ ដោយសារតែអំណាចថ្នាក់ជាតិមានការចុះអន់ថយ ហើយអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែខ្លាំងឡើង។
- ពេលខ្លះដោយសារតែសមត្ថភាពនៃការយល់ដឹងនៅមានកម្រិត ឬខ្វះខាតមនុស្សនៅតាមមូលដ្ឋានធ្វើឱ្យអាជ្ញាធរនៅថ្នាក់ក្រោមជាតិមិនអាចធ្វើការងារបានល្អ មិនសូវចេះធ្វើការងារ ឬមិនចេះធ្វើផែនការការងារ។

ប្រព័ន្ធវិមជ្ឈការ គឺគ្មានអំណាចឋានានុក្រមទេ ពីព្រោះតែអាជ្ញាធរនីមួយៗមានសិទ្ធិអំណាចក្នុងសម្រេចរឿងៗខ្លួនតាមដែលច្បាប់កំណត់។

**ការប្រៀបធៀបរវាងប្រព័ន្ធវិសហាមជ្ឈការ និងប្រព័ន្ធវិមជ្ឈការនៅកម្ពុជា**

- ប្រព័ន្ធវិសហាមជ្ឈការ គ្មាននីតិបុគ្គល, មានអំណាចឋានានុក្រម, សមត្ថកិច្ចពាក់ព័ន្ធគ្នា, មន្ត្រីត្រូវបានតែងតាំង, ពុំមានធនធានផ្ទាល់ខ្លួន, គ្មានស្វ័យភាព និងត្រួតពិនិត្យជាអាទិភាព (ជាមុន)។
- ប្រព័ន្ធវិមជ្ឈការ មាននីតិបុគ្គល, គ្មានអំណាចឋានានុក្រម, សមត្ថកិច្ចដាច់ចំណាង, អាជ្ញាធរជ្រើសតាំងមានធនធានផ្ទាល់ខ្លួន, មានស្វ័យភាព និងត្រួតពិនិត្យបច្ឆាកាល (ជាក្រោយ)។

ក្នុងការគ្រប់គ្រងដែនដី គេធ្វើតាមលក្ខណៈនៃភូមិសាស្ត្រ និងលក្ខណៈប្រជាសាស្ត្រដូចជាការបែងចែកក្រឡាផ្ទៃសម្រាប់រដ្ឋបាលប្រតិបត្តិការងាររបស់ខ្លួនយ៉ាងជាក់ស្តែង ជាការកំណត់នូវវង្វង់នៃសមត្ថកិច្ចរបស់

[15]សាស្ត្រាចារ្យ ឥន យឿន ស្ថាប័នរដ្ឋបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣

រដ្ឋតាមតំបន់។ ការរៀបចំបែបនេះគេហៅថា មណ្ឌលរដ្ឋបាល (មជ្ឈការ)។ តែបើមណ្ឌលរដ្ឋបាលនេះទទួលបាននូវការរំលែកអំណាចពីថ្នាក់ជាតិ (រដ្ឋបាលកណ្តាល) នោះមណ្ឌលរដ្ឋបាល គឺជាមណ្ឌលរដ្ឋបាលនៃអំណាចរដ្ឋបាលបែង (វិសហមជ្ឈការ)។ ចំណែកឯសមូហភាពដែនដីវិញ (វិមជ្ឈការ) គឺជាការប្រមូលផ្តុំមនុស្ស ដែលផ្តល់អំណាចឱ្យដើម្បីគ្រប់គ្រងការងារដោយខ្លួន ឬអាចនិយាយម្យ៉ាងទៀតថា ជាការទទួលស្គាល់នូវផលប្រយោជន៍ប្រជាសាស្ត្រតាមរយៈសមូហភាពដែលត្រូវគ្រប់គ្រងតាមរង្វង់ដែនដីតែមួយ។

# ជំពូកទី២
# ស្ថានភាពទូទៅ និងការគ្រប់គ្រងរដ្ឋបាល
# ខណ្ឌបឹងកេងកង

# ជំពូកទី២

# ស្ថានភាពទូទៅ និងការគ្រប់គ្រងរដ្ឋបាលរបស់ខណ្ឌបឹងកេងកង

## ២.១. ទិដ្ឋភាពទូទៅរបស់សាលាខណ្ឌបឹងកេងកង

### ២.១.១. ក្របខណ្ឌគតិយុត្ត

ខណ្ឌបឹងកេងកង ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ ដោយបានកាត់យកសង្កាត់ចំនួន៧ ពីខណ្ឌចំការមន នៃរាជធានីភ្នំពេញ គឺមានដូចជា ១/ សង្កាត់បឹងកេងកងទី១ ២/ សង្កាត់បឹងកេងកងទី២ ៣/ សង្កាត់បឹងកេងកងទី៣ ៤/ សង្កាត់អូឡាំពិក ៥/ សង្កាត់ទំនប់ទឹក ៦/ សង្កាត់ទួលស្វាយព្រៃទី១ និង ៧/ សង្កាត់ទួលស្វាយព្រៃទី២។ ហើយសាលាខណ្ឌបឹងកេងកងត្រូវបានប្រកាសឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ហើយមកដល់បច្ចុប្បន្ន (២០២១)នេះ គឺដឹកនាំដោយលោក **ធឹម សំអាន** ជាអភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង។[16]

### ២.១.២. ទីតាំងភូមិសាស្ត្រ

ខណ្ឌបឹងកេងកងជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ត្រូវបានបង្កើតឡើងនៅលើផ្ទៃដីចំនួន ៣,៩៧៦ គីឡូម៉ែត្រការ៉េ ដោយបានកាត់យកសង្កាត់ចំនួន៧ ពីខណ្ឌចំការមន នៃរាជធានីភ្នំពេញ។ ខណ្ឌបឹងកេងកងមានព្រំប្រទល់ខាងជើងជាប់ជាមួយខណ្ឌ៧មករា ខាងកើតជាប់ជាមួយខណ្ឌចំការមន ខាងត្បូងជាប់ជាមួយខណ្ឌមានជ័យ និងមួយផ្នែកទៀតជាប់ខណ្ឌចំការមន ហើយខាងលិចជាប់ជាមួយខណ្ឌទួលគោក។ ខណ្ឌបឹងកេងកង គឺជាខណ្ឌមួយដែលសម្បូរដោយផ្លូវគមនាគមន៍ និងទីតាំងសម្រាប់ប្រជាពលរដ្ឋប្រកបអាជីវកម្ម ផ្សារទំនើប និងកត្តាផ្សេងៗទៀត។

### ២.២.៣. ស្ថានភាពប្រជាសាស្ត្រ

ប្រជាពលរដ្ឋដែលបានរស់នៅក្នុងខណ្ឌបឹងកេងកងសរុបចំនួន ៥៦,០៥៨នាក់ គឺស្មើ៩,៦៥៦គ្រួសារ និងមានដងស៊ីតេប្រជាជនចំនួន ១៣,៤៥០ ក្នុងមួយគីឡូម៉ែត្រ។[17] ស្រីចំនួន ២២,៦២៨នាក់ ប្រជាពលរដ្ឋខ្មែរដែលមានអាយុចាប់ពី១៨ឆ្នាំឡើងគឺមានចំនួន ៤២,៤៦៥នាក់ ស្រីចំនួន ២០,៨៣៣នាក់។

[16] អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពីការបង្កើតខណ្ឌបឹងកេងកង ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩

[17] របាយការណ៍ប្រចាំឆ្នាំ២០២១ និងទិសដៅអនាគតការងាររបស់ខណ្ឌបឹងកេងកង

## ២.២. រចនាសម្ព័ន្ធនៃការគ្រប់គ្រងខណ្ឌ

### ២.២.១. ក្រុមប្រឹក្សា

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួនដែលត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតជាអសកលស្របតាមនីតិវិធីដែលបាន កំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។[18] ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានក្រុមប្រឹក្សាដែលត្រូវបានបោះឆ្នោតជាអសកលដោយសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់។ ចំនួនក្រុមប្រឹក្សានីមួយៗត្រូវកំណត់ដោយអនុក្រឹត្យផ្អែកទៅលើកត្តាប្រជាសាស្ត្រ និងភូមិសាស្ត្រ តែទោះជាយ៉ាងណាក៏ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានបញ្ជាក់ចន្លោះនៃចំនួនសមាជិកសម្រាប់ក្រុមប្រឹក្សានីមួយៗ។[19]

ក្រុមប្រឹក្សាខណ្ឌបឹងកេងកងមានសមាជិកសរុបចំនួន ១៧រូប ដោយមានប្រធាន ១រូប (**លោក គឹម ឈុនអ៊ី**) និង ១៦រូបជាសមាជិក ក្នុងនោះមានស្រីចំនួន ២រូប មានអាណត្តិ ៥ឆ្នាំ។[20] ហើយត្រូវប្រជុំសាមញ្ញចំនួន១២ ដងក្នុងមួយឆ្នាំ។[21] ដើម្បីត្រួតពិនិត្យវាយតម្លៃតាមដានរៀបចំផែនការអភិវឌ្ឍន៍ និងអនុម័តកិច្ចការស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ដែលការប្រជុំត្រូវបានបែងចែកចេញជាពីរ គឺប្រជុំសាមញ្ញ និងប្រជុំវិសាមញ្ញ។ យោងមាត្រា ៥០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំដែលពាក់ព័ន្ធដូចជា ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញ សកម្មភាពនានាដែលបានអនុវត្តរបាយការណ៍ហិរញ្ញវត្ថុ ការវាយតម្លៃ ការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា លទ្ធផលនៃការតាមដាន និងវាយតម្លៃ ដូចមានចែងក្នុងមាត្រា៤០ នៃច្បាប់នេះ។[22] វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំខាងលើនេះមិនឱ្យលើសពីសែសិបប្រាំ (៤៥) ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំ។

ក្រុមប្រឹក្សាខណ្ឌមានគណៈកម្មាធិការចំនួន ៣ដូចជា៖[23]

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

---

[18] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ ទំព័រទី៣ មាត្រា៤

[19] ដ.ឯ.ម ឆ្នាំ២០០៨ ទំព័រទី៤ មាត្រា១៨

[20] ដ.ឯ.ម ឆ្នាំ២០០៨ ទំព័រទី៣ មាត្រា១៥

[21] ដ.ឯ.ម ឆ្នាំ២០០៨ ទំព័រទី២១ មាត្រា៧៤

[22] ដ.ឯ.ម ឆ្នាំ២០០៨ ទំព័រទី១៥ មាត្រា៥០

[23] ដ.ឯ.ម ឆ្នាំ២០០៨ ទំព័រទី៣១ មាត្រា១១៤

- គណៈកម្មាធិការលទ្ធកម្ម
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមារ។

### ២.២.១.១ សិទ្ធអំណាចរបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាមានសិទ្ធអំណាច ធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។[24] ក្រុមប្រឹក្សាប្រើប្រាស់នូវអំណាចខាងបញ្ញត្តិរបស់ខ្លួនតាមរយៈការធ្វើដីកា។[25] រួមទាំងអំណាចខាងប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា។[26] ស្របតាមក្របខណ្ឌដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ទន្ទឹមនិងនេះក្រុមប្រឹក្សាអាចស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតគណៈអភិបាល ចេញពីតំណែងក្នុងករណី គណៈអភិបាលនោះមានករណីណាមួយដូចខាងក្រោម៖[27]

- បាត់បង់លក្ខណៈសម្បត្តិជាអភិបាល ឬអភិបាលរង
- អសមត្ថភាព
- មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
- បោះបង់ចោលការងារ
- ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។

### ២.២.១.២ តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាមានតួនាទីចាត់ចែង កិច្ចការចាំបាច់នានា ដើម្បីសម្រេចបាននូវគោលបំណងក្នុងការបង្កើតជម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្ម ដោយមានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ការងាររៀបចំបទបញ្ជាផ្ទៃក្នុង
- ការងារដាក់ចេញដីកា និងសេចក្តីសម្រេច
- ការងាររៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- ការងារផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

[24] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទំព័រទី៧ មាត្រា៣០

[25] ដ.ឯ.ម ទំព័រទី៨ មាត្រា៣២

[26] ដ.ឯ.ម ទំព័រទី៨ មាត្រា៣៣

[27] ដ.ឯ.ម ទំព័រទី៤០ មាត្រា១៥១

- ការអនុវត្តការងារ
- ការងារគ្រប់គ្រងបុគ្គលិក
- ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

**២.២.១.៣. កិច្ចប្រជុំរបស់ក្រុមប្រឹក្សា**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាមានពីរប្រភេទ គឺការប្រជុំសាមញ្ញ និងការប្រជុំវិសាមញ្ញ។[28]

**ក. ការប្រជុំសាមញ្ញ**

ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញនៅក្នុងដែនដីរបស់ខ្លួន យ៉ាងហោចណាស់ដប់ពីដង (១២) ជារៀងរាល់ឆ្នាំ។[29] អង្គប្រជុំសាមញ្ញលើកទីមួយរបស់ក្រុមប្រឹក្សា ត្រូវប្រារព្ធឡើងមិនឱ្យលើសពីដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា។ កិច្ចប្រជុំសាមញ្ញនីមួយៗ របស់ក្រុមប្រឹក្សាត្រូវប្រារព្ធឡើងមិនក្រោមឱ្យម្ភៃប្រាំ (២៥)ថ្ងៃ ឬមិនលើសពីសាមសិបប្រាំ (៣៥)ថ្ងៃ ឬបន្ទាប់ពីអង្គប្រជុំសាមញ្ញលើកមុនឡើយ។ ក្រុមប្រឹក្សាត្រូវអនុម័តប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនសម្រាប់រយៈពេលដប់ពីរ (១២)ខែ មិនឱ្យហួសកិច្ចប្រជុំសាមញ្ញលើទី២ និងសម្រាប់រយៈពេលជាបន្តបន្ទាប់ទៀតក្នុងរយៈពេលដប់ពីរ (១២) ខែម្តងៗ ដោយបញ្ជាក់អំពីការបរិច្ឆេត និងកន្លែងឱ្យបានជាក់លាក់។[30] ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈ និងបន្ទាន់នូវប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួន។

**ខ. ការប្រជុំវិសាមញ្ញ**

ក្រុមប្រឹក្សាអាចកោះប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមការចាំបាច់ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬករណីពិសេសណាមួយ។[31]

**គ. ប្រធានអង្គប្រជុំ**

ប្រធានអង្គប្រជុំ គឺជាប្រធានអង្គប្រជុំទាំងនៅក្នុងអង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សា។ ក្នុងករណីដែលប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សា ដែលនៅលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាជាអធិបតីនៃអង្គប្រជុំ។ បើក្នុងករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខ

[28] អនុក្រឹត្យលេខ ២១៦ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

[29] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទំព័រទី២១ មាត្រា៧៤

[30] អនុក្រឹត្យលេខ ២១៦ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

[31] ដ.ឯ.ម ទំព័រទី២២ មាត្រា៧៧

រៀងលើគេនៃបញ្ជីបេក្ខជនដែលជាប់ឆ្នោតលំដាប់ទីពីរក្នុងក្រុមប្រឹក្សាអវត្តមានគឺត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតក្នុងលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយនោះឱ្យធ្វើជាអធិបតីនៃអង្គការប្រជុំ។[32]

ប្រធានអង្គប្រជុំក្រុមប្រឹក្សាមានភារកិច្ចៈ[33]

- ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សា ដោយមិនលំអៀង
- គោរពអនុវត្តច្បាប់ និងបទបញ្ញាផ្ទៃក្នុងសម្រាប់អង្គប្រជុំរបស់ក្រុមប្រឹក្សា

❖ កូរ៉ុមនៃការប្រជុំរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងមានសុពលភាពទៅបាន លុះត្រាតែមានសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល។[34]

តារាងទី២៖ កូរ៉ុមនៃអង្គប្រជុំនៃក្រុមប្រឹក្សា

| **ចំនួនសមាជិកក្រុមប្រឹក្សាសរុប** | **កូរ៉ុមសម្រាប់កិច្ចប្រជុំ** |
|---|---|
| ១៧ | ១៣ |

សមាជិកក្រុមប្រឹក្សាគ្រប់រូប ដែលមានវត្តមានក្នុងកិច្ចប្រជុំក្រុមប្រឹក្សា មានសិទ្ធិបោះឆ្នោតមួយសម្លេងដើម្បីអនុម័តរាល់ការសម្រេចរបស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាត្រូវអនុម័តដីកា ឬសេចក្តីសម្រេចរបស់ខ្លួនដោយសម្លេងលើសពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។[35]

ការប្រជុំរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងជាសាធារណៈ ប៉ុន្តែក្រុមប្រឹក្សាអាចប្រជុំជាសម្ងាត់បានផងដែរ។ កិច្ចដំណើរការប្រជុំជាសម្ងាត់ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[36]

**<u>បញ្ជាក់</u>៖** ក្នុងកិច្ចប្រជុំលើកទី២ របស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវអនុម័តដីកាស្តីពីបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន។ រាល់សកម្មភាព ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ដែលធ្វើឡើងមិនស្របច្បាប់ នឹងបទបញ្ញាផ្ទៃក្នុងដែលក្រុមប្រឹក្សាអនុម័តសេចក្តីសម្រេចនោះនឹងពុំមានសុពលភាពឡើយ។[37]

❖ **កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា**

កំណត់ហេតុនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌត្រូវកត់ត្រានូវបញ្ហាដូចខាងក្រោម៖

- ទីកន្លែង និងកាលបរិច្ឆេត (ថ្ងៃ ខែ ឆ្នាំ និងម៉ោង) នៃកិច្ចប្រជុំ

[32] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទំព័រទី១៩ មាត្រា៦៤
[33] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទំព័រទី១៩ មាត្រា៦៦
[34] ដ.ឯ.ម ទំព័រទី១៩ មាត្រា ៦៦
[35] ដ.ឯ.ម ទំព័រទី១៩ មាត្រា ៦៦
[36] ដ.ឯ.ម ទំព័រទី២០ មាត្រា ៦៨
[37] ដ.ឯ.ម ទំព័រទី២២ មាត្រា៧៩

- ការបញ្ជាក់អះអាងថាការប្រជុំមានលក្ខណៈស្របច្បាប់តាម (កូរ៉ុម របៀបវារៈ ការបន្ថែមរបៀបវារៈ)។ បញ្ជីឈ្មោះ និងអង្គភាពរបស់អ្នកដែលចូលរួមប្រជុំ (ប្រសិនបើមាន)
- របៀបវារៈពេលវេលា និងទីកន្លែងសម្រាប់កិច្ចប្រជុំលើកក្រោយ
- សេចក្តីសម្រេច និងលទ្ធផលនៃការបោះឆ្នោតអនុម័តលើបញ្ហាផ្សេងៗក្នុងរបៀបវារៈនៃកិច្ចប្រជុំ រួមទាំងបញ្ហាបានបន្ថែមនៅក្នុងរបៀបវារៈ
- ពេលវេលាបិទអង្គប្រជុំ និងបញ្ហាផ្សេងៗទៀតដែលត្រូវកត់ត្រា។

កំណត់ហេតុនៃកិច្ចប្រជុំត្រូវកត់ត្រានូវពាក្យពេជន៍ និងឃ្លាប្រយោគសំខាន់ៗ នៃកិច្ចពិភាក្សាដោយមិនត្រូវកត់ត្រាខ្លាំងពេកនាំឱ្យបាត់បង់នូវខ្លឹមសារនៃកិច្ចប្រជុំឡើយ។

❖ **អំពីការខកខានមិនបានចូលរួមកិច្ចប្រជុំ**

សមាជិកក្រុមប្រឹក្សាខណ្ឌគ្រប់រូប ត្រូវតែចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌ។ ក្នុងករណីមានធុរកិច្ចមិនអាចចូលរួមប្រជុំបានសមាជិកក្រុមប្រឹក្សាខណ្ឌ ត្រូវសុំអនុញ្ញាតជាលាយលក្ខណ៍អក្សរជូនប្រធានក្រុមប្រឹក្សាខណ្ឌ យ៉ាងតិចមួយថ្ងៃមុនកិច្ចប្រជុំ។ បើសិនជាក្នុងករណីមានឧបទ្ទវហេតុ ឬមានធុរកិច្ចបន្ទាន់ សមាជិកក្រុមប្រឹក្សារូបនោះ ត្រូវតែដាក់លិខិតសុំច្បាប់ជាលាយលក្ខណ៍អក្សរមកប្រធានក្រុមប្រឹក្សាខណ្ឌ។[38] ក្នុងករណីសមាជិកក្រុមប្រឹក្សាខណ្ឌណាម្នាក់ដើរចេញពីអង្គប្រជុំ ត្រូវចាត់ទុកថាអវត្តមានដោយគ្មានច្បាប់មួយដង។ សមាជិកក្រុមប្រឹក្សាខណ្ឌដែលអវត្តមានក្នុងកិច្ចប្រជុំសាមញ្ញចំនួនពីរលើកជាប់ៗគ្នា ដោយជំងឺ ត្រូវមានឯកសារបញ្ជាក់ពីគ្រូពេទ្យ។ ប្រធានក្រុមប្រឹក្សាខណ្ឌអាចអនុញ្ញាតច្បាប់ឱ្យសមាជិកក្រុមប្រឹក្សាខណ្ឌបានពីរលើកជាប់ៗគ្នាត្រូវសុំឱ្យក្រុមប្រឹក្សាខណ្ឌអនុម័ត។

❖ **អំពីវិន័យ និងទណ្ឌកម្មខាងវិន័យ**

សមាជិកក្រុមប្រឹក្សាខណ្ឌគ្រប់រូបត្រូវគោរពវិន័យដូចជា ត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខណ្ឌឱ្យបានត្រឹមត្រូវ, គោរពតាមការណែនាំ និងការចាត់តាំងរបស់ប្រធានអង្គប្រជុំ, ទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួនដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់ក្រុមប្រឹក្សា។

❖ **ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាខណ្ឌមានដូចខាងក្រោម៖**

ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាខណ្ឌ ដែលបានខកខានមកប្រជុំដោយគ្មានច្បាប់អនុញ្ញាត និងទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាក្នុងកិច្ចប្រជុំ។

---

[38] អនុក្រឹត្យលេខ២១៦ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

❖ **ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាខណ្ឌដែលខកខានមកប្រជុំដោយគ្មានច្បាប់អនុញ្ញាត៖**

ប្រសិនបើខកខានមិនបានចូលប្រជុំដោយគ្មានច្បាប់អនុញ្ញាត ចំនួនមួយលើក ត្រូវទទួលការក្រើនរំលឹកពីប្រធានក្រុមប្រឹក្សាខណ្ឌ និងត្រូវចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំនោះ, ប្រសិនបើខកខានមិនបានចូលរួមប្រជុំដោយគ្មានច្បាប់អនុញ្ញាតចំនួនពីរលើកមិនជាប់ៗគ្នាក្នុងអំឡុងពេល១២ខែ ត្រូវទទួលការស្តីបន្ទោសជាលាយលក្ខណ៍អក្សរ និងត្រូវកាត់ប្រាក់បំណាច់ម្ភៃប្រាំ (២៥%) ភាគរយនៃខែអវត្តមានលើកទី២, ប្រសិនបើខកខានមិនបានមកចូលរួមប្រជុំដោយគ្មានច្បាប់អនុញ្ញាតចំនួនបី (៣)លើក មិនជាប់គ្នាក្នុងអំឡុងពេល ១២ខែ ត្រូវទទួលការស្តីបន្ទោសជាលាយលក្ខណ៍អក្សរ និងត្រូវកាត់ប្រាក់បំណាច់ចំនួនហាសិប (៥០%) ភាគរយនៃខែអវត្តមានលើកទី៣។ ក្នុងករណីអនុវត្ត ទណ្ឌកម្មខាងវិន័យខាងលើនេះរួចទៅហើយ សាម៉ីខ្លួនមិនព្រមរាងចាលក្រុមប្រឹក្សា ត្រូវដាក់ករណីនេះទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនដើម្បីអនុម័តបណ្តេញសមាជិកនោះចេញពីក្រុមប្រឹក្សារបស់ខ្លួន, ប្រសិនបើខកខានមិនបានចូលរួមប្រជុំសាមញ្ញ ដោយគ្មានច្បាប់អនុញ្ញាតចំនួនពីរលើកជាប់ៗគ្នាត្រូវបាត់បង់សមាជិកភាពពីក្រុមប្រឹក្សាខណ្ឌ និងប្រធានក្រុមប្រឹក្សាខណ្ឌ ត្រូវចាត់ចែងផ្ញើជាលាយលក្ខណ៍អក្សរ នូវរាល់ការក្រើនរំលឹកការស្តីបន្ទោស ការដាក់ពិន័យ និងការបញ្ឈប់ពីសមាជិកក្រុមប្រឹក្សា ឱ្យដល់លំនៅឋាននៃសមាជិកក្រុមប្រឹក្សាខណ្ឌដែលទទួលទណ្ឌកម្មខាងវិន័យនោះ។

– **ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំ៖**

ក្រើនរំលឹក, ក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំ និងបណ្តេញចេញពីអង្គប្រជុំ។

**២.២.១.៤. សមាសភាពរបស់ក្រុមប្រឹក្សា**

សមាជិកក្រុមប្រឹក្សាខណ្ឌបឹងកេងកង អាណត្តិទី៥ នៃរាជធានីភ្នំពេញមានរាយនាមដូចខាងក្រោមនេះ៖[39]

តារាងទី៣៖ សមាសភាពក្រុមប្រឹក្សាខណ្ឌបឹងកេងកង អាណត្តិទី៥

| ល.រ | គោត្តនាម និងនាម | ភេទ | មុខតំណែង |
|---|---|---|---|
| ១ | គឹម ឈុនអ៊ូ | ប្រុស | ជាប្រធានក្រុមប្រឹក្សាខណ្ឌ |
| ២ | នៅ កាអុន | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៣ | វិន សុខសន្តិវ័ត្ន | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៤ | ស៊ុន ផាត | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |

[39] អនុក្រឹត្យលេខ ៦៧៧ អនក្រ.តក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌបឹងកេង នៃរាជធានីភ្នំពេញ

| | | | |
|---|---|---|---|
| ៥ | ម៉ែន សុភាវី | ស្រី | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៦ | ប៉ាង សេង | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៧ | ហ៊ុន សារឿន | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៨ | ប៉ា សុខា | ស្រី | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៩ | ទន់ សំអាន | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១០ | រស់ សុផារិទ្ធ | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១១ | ចិន វិបុល | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១២ | ចាន់ ផល | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៣ | ស៊ឹម ច័ន្ទដារ៉ា | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៤ | ឌី ចន្ធូ | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៥ | ខៀវ សុផាន់ណា | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៦ | ណុប ប៊ុនហ៊ | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៧ | ហែម រតនា | ប្រុស | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |

យោងតាមមាត្រា ១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ បានចែងថាគ្រប់ក្រុមប្រឹក្សា គឺមានកាតព្វកិច្ចបង្កើតគណៈកម្មាធិការយ៉ាងតិចចំនួន៣ដូចជា៖ ១/ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ២/ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ៣/ គណៈកម្មាធិការលទ្ធកម្ម។[40] ក្រៅពីគណៈកម្មាធិការទាំងបីខាងលើ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការផ្សេងៗទៀតបន្ថែមពីលើ ដើម្បីជួយរំលែកការងាររបស់ក្រុមប្រឹក្សា ប៉ុន្តែមិនត្រូវមានតួនាទី ភារកិច្ច ត្រួតពិនិត្យជាមួយនិងគណៈកម្មាធិការទាំងបីខាងលើឡើយ។[41] ក្រុមប្រឹក្សាអាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀតតាមការស្នើសុំរបស់គណៈកម្មាធិការនានា ឬគណៈអភិបាលខណ្ឌ។ អនុគណៈកម្មាធិការ ឬក្រុមការងារខាងលើត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការ ឬគណៈអភិបាលខណ្ឌ។

[40] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទំព័រទី៣១ មាត្រា១១៤

[41] ដ.ឯ.ម ទំព័រទី៣១ មាត្រា១១៥

**ក. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវបានក្រុមប្រឹក្សាខណ្ឌបឹងកេងកងធ្វើសេចក្តីសម្រេចសមាសភាពនៅក្នុងកិច្ចប្រជុំសាមញ្ញ៖[42]

តារាងទី៤៖ សមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

| ល.រ | គោត្តនាម និងនាម | ភេទ | មុខតំណែង |
|---|---|---|---|
| ១ | ធឹម សំអាន | ប្រុស | ប្រធាន |
| ២ | ស៊ិន រតនា | ស្រី | អនុប្រធាន |
| ៣ | នៅ កាអុន | ប្រុស | សមាជិក |
| ៤ | វិន សុខសន្តិរ័ត្ន | ប្រុស | សមាជិក |
| ៥ | យុត ឡុងឌី | ប្រុស | សមាជិក |
| ៦ | សែន វ៉ាន់ណាក់ | ប្រុស | សមាជិក |
| ៧ | គិត សូរិយា | ស្រី | សមាជិក |
| ៨ | ថន គន្ធា | ស្រី | សមាជិក |
| ៩ | ជួប សុខសេរី | ប្រុស | សមាជិក |

– **តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺផ្តល់យោបល់ដល់ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

១/ ផែនការអភិវឌ្ឍ និងថវិកា៖

- ធ្វើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខណ្ឌ
- ធ្វើសេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់សាលារាជធានី
- ធ្វើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខណ្ឌ
- រៀបចំរបាយការណ៍ស្តីពីភាពរីកចម្រើននានាទាក់ទងដល់ការងារអភិវឌ្ឍន៍របស់ខណ្ឌ។

[42] សេចក្តីសម្រេចស្តីពីការបង្កើតសមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខណ្ឌបឹងកេងកង

២/ សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាខណ្ឌជាមួយការិយាល័យអង្គភាពរបស់ក្រសួងស្ថាប័ននានា៖

- ❖ កិច្ចសហប្រតិបត្តិការ ពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សាខណ្ឌជាមួយការិយាល័យ អង្គភាពរបស់ស្ថាប័ន
- ❖ សម្របសម្រួលការផ្តល់សេវា និងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័នដើម្បីឆ្លើយតបនិងតម្រូវការរបស់មូលដ្ឋាន
- ❖ ការសម្របសម្រួលភាពមិនចុះសម្រុងរវាងកិច្ចការរបស់ក្រុមប្រឹក្សាខណ្ឌជាមួយក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យអង្គភាពជំនាញនានា
- ❖ ផ្តល់អនុសាសន៍ ដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍនានាឱ្យស្របតាមតម្រូវការរបស់មូលដ្ឋាន។

៣/ កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខណ្ឌ៖

- ❖ រៀបចំយន្តការពិគ្រោះយោបល់ និងការចូលរួមក្នុងដំណើរការអនុវត្តការងារឯកភាពខណ្ឌ
- ❖ រៀបចំប្រព័ន្ធ និងនីតិវិធីបំពេញការងារ ព្រមទាំងទំនាក់ទំនងការិយាល័យនានារបស់សាលាខណ្ឌ
- ❖ សម្របសម្រួលភាពមិនចុះសម្រុងគ្នាក្នុងការអនុវត្តការងាររបស់ការិយាល័យនានានៃសាលាខណ្ឌ

៤/ កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាខណ្ឌជាមួយក្រុមប្រឹក្សាសង្កាត់នៅក្នុងខណ្ឌ៖

- ❖ រៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាខណ្ឌ និងរវាងក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌ
- ❖ ឆ្លើយតបចំពោះអនុសាសន៍ សំណើ សំណូមពរ នានារបស់ក្រុមប្រឹក្សាសង្កាត់ ក្នុងករណីដែលក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបាន
- ❖ សម្របសម្រួលនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ហើយរវាងក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សាសង្កាត់។ ការងារទាក់ទងវិធានការលើកម្ពស់ប្រសិទ្ធភាពការងារអនុវត្តមុខងារ និងធនធានដែលបានប្រតិភូកម្ម។

៥/ មុខងារ និងធនធាន៖

- ❖ រៀបចំនូវលក្ខណៈសម្បត្តិ និងមធ្យោបាយដើម្បីទទួល អនុវត្តមុខងារ និងធនធានដែលបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលខណ្ឌ
- ❖ ផ្តួចផ្តើមស្នើឡើងនូវមុខងារ និងធនធានដែលត្រូវធ្វើប្រតិភូកម្មឱ្យទៅរដ្ឋបាលខណ្ឌរួមទាំងរដ្ឋបាលសង្កាត់
- ❖ ការវាយតម្លៃលើការអនុវត្តមុខងារ និងធនធានដែលបានធ្វើប្រតិភូកម្មដោយរដ្ឋបាលរាជធានី

ក្រៅពីនេះ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនៃក្រុមប្រឹក្សាខណ្ឌ អាចទទួលអនុវត្តកិច្ចការផ្សេងទៀតតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។

**ខ. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ខណ្ឌបឹងកេងកងត្រូវបានក្រុមប្រឹក្សាខណ្ឌបឹងកេងកងធ្វើសេចក្តីសម្រេចសមាសភាពក្នុងកិច្ចប្រជុំសាមញ្ញ៖[43]

តារាងទី៥៖ សមាសភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

| ល.រ | គោត្តនាម និងនាម | ភេទ | មុខតំណែង |
|---|---|---|---|
| ១ | ធឹម សំអាន | ប្រុស | ប្រធាន |
| ២ | ស៊ិន រតនា | ស្រី | អនុប្រធាន |
| ៣ | នៅ កាអុន | ប្រុស | សមាជិក |
| ៤ | វិន សុខសន្តិវ័ត្ន | ប្រុស | សមាជិក |
| ៥ | យុត ឡុងឌី | ប្រុស | សមាជិក |
| ៦ | សែន វ៉ាន់ណាក់ | ប្រុស | សមាជិក |
| ៧ | គិត សូរិយា | ស្រី | សមាជិក |
| ៨ | ថន គន្ធា | ស្រី | សមាជិក |
| ៩ | ជួប សុខសេរី | ប្រុស | សមាជិក |

- **តួនាទី និងភារកិច្ច**

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ គឺផ្តល់នូវយោបល់ដល់ក្រុមប្រឹក្សាខណ្ឌនិងគណៈអភិបាលខណ្ឌលើកិច្ចការសំខាន់ៗដូចជាចូលរួមក្នុងការកសាងចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងដើម្បីសម្រេចបាននូវសមភាពយេនឌ័រ រួមទាំងការផ្តល់សេវាផ្សេងៗដែលពាក់ព័ន្ធនិងសមភាពយេនឌ័រស្ត្រី យុវវ័យ និងកុមារ ប្រមូល និងវិភាគព័ត៌មានទិន្នន័យដែលទាក់ទងយេនឌ័រ តម្រូវការស្ត្រី យុវវ័យ និងកុមារដើម្បីដាក់បញ្ចូលព័ត៌មានទាំងនោះក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ហើយចូលរួមការរៀបចំតាក់តែង ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាទាក់ទងការលើកកម្ពស់ និងឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ

[43] សេចក្តីសម្រេចស្តីពីការបង្កើតសមាសភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខណ្ឌបឹងកេងកង

ស្ត្រី យុវវ័យ និងកុមារ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួនដើម្បីដាក់បញ្ចូលក្នុងផែនការសកម្មភាព និងថវិការបស់ក្រុមប្រឹក្សា ម្យ៉ាងវិញទៀតគឺស្វែងរកការគាំទ្រពីក្រុមប្រឹក្សា គណៈអភិបាល និង គណៈកម្មាធិការផ្សេងៗទៀតនៃក្រុមប្រឹក្សាដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធ និងសកម្មភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា សហការ និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងការដោះស្រាយបញ្ហាសំណូមពរ ឬសំណើនានាដែលគណៈកម្មាធិការនៃក្រុមប្រឹក្សាប្រភេទផ្សេងនោះ មិនអាចដោះស្រាយបញ្ហាបានក្នុងការអនុវត្តមុខងាររបស់ខ្លួន លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សា ឬគណៈអភិបាល អំពីវិធានការសម្របនានាដើម្បីជម្រុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតឡើងពាក់ព័ន្ធនិងកិច្ចការស្ត្រី យុវវ័យ និងកុមារ ស្វែងរក និងទទួលបាននូវរាល់ព័ត៌មានដែលពាក់ព័ន្ធនិងកិច្ចការស្ត្រី យុវវ័យ និងកុមារ ជម្រុញការលើកកម្ពស់ ការយល់ដឹងអំពីផ្នែកច្បាប់ និងគោលនយោបាយនានាទាក់ទងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារដែលសហគមន៍នានា ក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជម្រុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍ អំពីអ្វីដែលបានកើតមានឡើងជាប្រចាំពាក់ព័ន្ធសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ និងមានវិធានការដើម្បីឆ្លើយតប ស្វែងរកការគាំទ្រដើម្បីជម្រុញឱ្យធ្វើសេចក្តីសម្រេចពាក់ព័ន្ធ និងការងារអភិវឌ្ឍន៍ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា លើកយោបល់ និងផ្តល់អនុសាសន៍អំពីការពង្រឹងទំនាក់ទំនង កិច្ចសហការ និងសម្របសម្រួលរវាងក្រុមប្រឹក្សាផ្សេងទៀត មន្ទីរ អង្គការពាក់ព័ន្ធនានា អ្នកផ្តល់សេវាអង្គការមិនមែនរដ្ឋាភិបាល (NGO) ក្រុមអ្នកស្ម័គ្រចិត្តនិងសហគមន៍ដើម្បីធានាថាសកម្មភាពទាំងឡាយត្រូវបានគាំទ្រដល់ស្ត្រី យុវវ័យ និងកុមារ ពិនិត្យមើលការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពស្ត្រី យុវវ័យ និងកុមារជាពិសេសដើម្បីកំណត់រកគម្លាតផ្សេងៗនៅក្នុងការទទួលសេវានានាដែលមាន និងដើម្បីលើកអនុសាសន៍ក្នុងការដោះស្រាយបញ្ហាទាំងនោះ រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាសមភាពយេនឌ័រ ការបង្កើនសមត្ថភាព ស្ត្រី យុវវ័យ និងកុមារ គាំទ្រគ្រប់កិច្ចខិតខំប្រឹងប្រែង ដើម្បីកៀរគរមូលនិធិសម្រាប់ការងារសមភាពយេនឌ័រ ការបង្កើនសមត្ថភាព ស្ត្រី យុវវ័យ និងកុមារ។

**គ. គណៈកម្មាធិការលទ្ធកម្ម**

គណៈកម្មាធិការលទ្ធកម្មរបស់ខណ្ឌត្រូវបានក្រុមប្រឹក្សាខណ្ឌធ្វើសេចក្តីសម្រេចសមាសភាពក្នុងកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌ ៖[44]

[44] សេចក្តីសម្រេចសមាសភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

តារាងទី៦៖ គណៈកម្មាធិការលទ្ធកម្ម

| ល.រ | គោត្តនាម និងនាម | ភេទ | មុខតំណែង |
|---|---|---|---|
| ១ | ធឹម សំអាន | ប្រុស | ប្រធាន |
| ២ | ស៊ិន រតនា | ស្រី | អនុប្រធាន |
| ៣ | នៅ កាអុន | ប្រុស | សមាជិក |
| ៤ | វិន សុខសន្តិរ័ត្ន | ប្រុស | សមាជិក |
| ៥ | យុត ឡុងឌី | ប្រុស | សមាជិក |
| ៦ | សែន វ៉ាន់ណាក់ | ប្រុស | សមាជិក |
| ៧ | គិត សូរិយា | ស្រី | សមាជិក |
| ៨ | ថន គន្ធា | ស្រី | សមាជិក |
| ៩ | ជួប សុខសេរី | ប្រុស | សមាជិក |

- **តួនាទី និងភារកិច្ច**

គណៈកម្មាធិការលទ្ធកម្ម របស់រដ្ឋបាលខណ្ឌបឹងកេងកង មានភារកិច្ចដូចជា គោរពតាមក្រមសីលធម៌លទ្ធកម្ម ពិនិត្យ និងផ្តល់យោបល់លើសេចក្តីសម្រេច ផែនការលទ្ធកម្មប្រចាំឆ្នាំ ផែនការរៀបចំដោយ អង្គភាពលទ្ធកម្ម ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាព មុននឹងផ្ញើរជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត ធ្វើការណែនាំឱ្យអង្គភាពលទ្ធកម្ម អនុវត្តឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម ប្រជុំវាយតម្លៃកំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចការលទ្ធកម្ម ដែលមានលក្ខណៈស្មុគស្មាញ ត្រួតពិនិត្យឡើងវិញទៅលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ មុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម ត្រួតពិនិត្យ និងផ្តល់ទិដ្ឋការលើឯកសារដេញថ្លៃ ដែលស្ថិតនៅក្នុងសិទ្ធិសម្រេចរបស់ខ្លួន បើកការប្រជុំវាយតម្លៃ ប្រគល់កិច្ចសន្យា ត្រួតពិនិត្យ និងវាយតម្លៃឡើងវិញនូវលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃ នាំមុខការសម្រេចប្រគល់កិច្ចសន្យាជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាឱ្យអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់ ហើយផ្សព្វផ្សាយលទ្ធផលដេញថ្លៃជាសាធារណៈ និងរាយការណ៍ជូនក្រុមប្រឹក្សាខ្លួនអំពីដំណើរការកិច្ចការលទ្ធកម្មក្នុងប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់ និងកំណត់របស់ក្រុមប្រឹក្សា ត្រូវផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចការលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាម សមត្ថកិច្ចរបស់ខ្លួន។

**ឃ. គណៈបញ្ជាការស្រាល ដើម្បីត្រៀមទ្រទ្រង់សភាពការណ៍ពាក់ព័ន្ធនិងបញ្ហាកូវីដ១៩**

គណៈបញ្ជាការស្រាល ដើម្បីត្រៀមទ្រទ្រង់សភាពការណ៍ពាក់ព័ន្ធនិងបញ្ហាកូវីដ១៩ ត្រូវបានបង្កើតឡើងដើម្បីត្រៀមទ្រទ្រង់សភាពការណ៍ពាក់ព័ន្ធបញ្ហាកូវីដ១៩ នៅក្នុងខណ្ឌមានៈ[45]

តារាងទី៧៖ សមាសភាពគណៈបញ្ជាការស្រាល ដើម្បីត្រៀមទ្រទ្រង់សភាពការណ៍ពាក់ព័ន្ធបញ្ហាកូវីដ១៩

| ល.រ | គោត្តនាម និងនាម | ភេទ | មុខតំណែង |
|---|---|---|---|
| ១ | ធឹម សំអាន | ប្រុស | ប្រធាន |
| ២ | ស៊ិន រតនា | ស្រី | អនុប្រធាន |
| ៣ | នៅ កាអុន | ប្រុស | សមាជិក |
| ៤ | វិន សុខសន្តិវ័ត្ន | ប្រុស | សមាជិក |
| ៥ | យុត ឡុងឌី | ប្រុស | សមាជិក |
| ៦ | សែន វ៉ាន់ណាក់ | ប្រុស | សមាជិក |
| ៧ | គិត សូរិយា | ស្រី | សមាជិក |
| ៨ | ថន គន្ធា | ស្រី | សមាជិក |
| ៩ | ជួប សុខសេរី | ប្រុស | សមាជិក |

- **តួនាទី និងភារកិច្ច**

តាមដានសភាពការណ៍ទាក់ទងវីរុសកូវីដ១៩ ក្នុងខណ្ឌបឹងកេងកង ដូចជាបញ្ហាសុខភាពសាធារណៈ ព័ត៌មានក្លែងក្លាយ និងពាក្យចចាមអារ៉ាម ដែលធ្វើអោយចលាចលក្នុងសង្គម ការដំឡើងថ្លៃទំនិញនៅទីផ្សារ ហើយចាំទទួលដោះស្រាយរាល់បញ្ហា និងសហការជួយសង្គ្រោះបឋមគ្រប់សភាពការណ៍ផ្សេងៗ ដែលបានកើតមានក្នុងខណ្ឌបឹងកេងកង ដោយសារតែវីរុសកូវីដ១៩ មួយវិញទៀតតាមដានគ្រប់សកម្មភាពរបស់ពួកបំពុលសង្គម ជនអគតិ និងត្រូវស្រាវជ្រាវរកមុខរកជនល្មើសដែលបង្កនោះឱ្យមកទទួលទោសតាមច្បាប់ តាមដាន និងស្រង់សំណូមពររបស់ប្រជាពលរដ្ឋជាប្រចាំ ក្នុងប្រព័ន្ធទំនាក់ទំនងបណ្តាយសង្គមហ្វេសប៊ុក រដ្ឋបាលខណ្ឌបឹងកេងកង និងអង្គភាពចំណុះរដ្ឋបាលខណ្ឌបឹងកេងកងទាំងអស់ដែលពាក់ព័ន្ធ និងបញ្ហាវីរុសកូវីដ១៩ រួមទាំងចាត់ចែងឆ្លើយតបឱ្យបានទាន់ពេលវេលា ជាពិសេសត្រូវធ្វើការផ្សព្វផ្សាយ អប់រំ ណែនាំ ឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋ អំពីការថែរក្សាអនាម័យដើម្បីបង្ការ និងទប់ស្កាត់នូវការរីករាលដាលនៃជម្ងឺកូវីដ១៩ តាមរយៈសារ

[45] សេចក្តីសម្រេចលេខ ០២៥ សសរ ស្តីពីការបង្កើតគណៈបញ្ជាការស្រាល ដើម្បីត្រៀមទ្រទ្រង់សមាសភាពការណ៍ពាក់ព័ន្ធបញ្ហាកូវីត ១៩ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០

អប់រំជារូបភាព និងជាសម្លេង បន្ថែមពីនេះត្រូវត្រៀមរថយន្តគិលានសង្គ្រោះ សម្រាប់អន្តរាគមន៍សង្គ្រោះបន្ទាន់ មានការរាយការណ៍សភាពការណ៍នានាដែលពាក់ព័ន្ធនិងវីរុសកូវីដ១៩ ជូនដល់លោកអភិបាល ដែលជាប្រធានក្រុមប្រឹក្សាការងារដើម្បីជ្រាប និងគោរពសុំមតិយោបល់ដឹកនាំបន្តបំពេញភារកិច្ចចាំបាច់ផ្សេងទៀតៗតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីឱ្យការការពារប្រយុទ្ធប្រឆាំងនិងវីរុសកូវីដ១៩ នេះទទួលបានជោគជ័យត្រូវចាត់វិធានការចាំបាច់មួយចំនួន ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុសកូវីដ១៩ ចូលរួមប្រជុំ តាមការអញ្ជើញរបស់លោកប្រធានក្រុមប្រឹក្សា។

### ២.២.២. គណៈអភិបាល

គណៈអភិបាល ត្រូវបានបង្កើតឡើងសម្រាប់ដឹកនាំកិច្ចការការងារទូទៅរបស់ ក្រុង ស្រុក ខណ្ឌ។ គណៈអភិបាល គឺប្រមូលផ្តុំនៃអភិបាល និងអភិបាលរង ក្រុង ស្រុក ខណ្ឌ។ គណៈអភិបាល ក្រុង ស្រុក ខណ្ឌ មានចំនួន ៣រូប ទៅ៧រូប ចំពោះការតែងតាំងត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[46] ការកំណត់ជាក់ស្តែងនៃចំនួនគណៈអភិបាល ក្រុង ស្រុក ខណ្ឌត្រូវធ្វើឡើងដោយ អនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ម្យ៉ាងវិញទៀតគណៈអភិបាល ក្រុង ស្រុក ខណ្ឌ មិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ។

- លក្ខណៈនៃការតែងតាំង ឬជ្រើសតាំង

អភិបាល ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតនៅក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖[47]

- ➤ មានឋានន្តរសក្តិ ចាប់ពីអនុមន្ត្រីឡើងទៅ និងមិនធ្លាប់មានទោសឧក្រិដ្ឋ ឬទោសមជ្ឈិមណាមួយ
- ➤ មានអាយុ ចាប់ពីសាមសិប (៣០) ឆ្នាំឡើងទៅគិតដល់ថ្ងៃតែងតាំង
- ➤ មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈ យ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬត្រូវមាននូវសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

- អភិបាលរង ក្រុង ស្រុក ខណ្ឌ ត្រូវបានការជ្រើសពីក្នុងចំណោមមន្ត្រីទាំងពីភេទដែលស្ថិតនៅក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលក្រសួងមហាផ្ទៃដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖[48]

- ➤ មានឋានន្តរសក្តិ ចាប់ពីនាយក្រមការឡើងទៅ និងមិនធ្លាប់មានទោសឧក្រិដ្ឋ ឬទោសមជ្ឈិមណាមួយ
- ➤ មានអាយុចាប់ពីម្ភៃប្រាំ (២៥) ឆ្នាំឡើងទៅគិតដល់ថ្ងៃតែងតាំង

[46] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទំព័រទី៣៧ មាត្រា១៤០

[47] ដ.ឯ.ម ទំព័រទី៣៨ មាត្រា១៤៤

[48] ដ.ឯ.ម ទំព័រទី៣៨ មាត្រា១៤៥

- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនបី(០៣)ឆ្នាំ ឬត្រូវមានសញ្ញាបត្របរិញ្ញាបត្រទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

**២.២.២.១. សិទ្ធិអំណាចរបស់គណៈអភិបាល**

គណៈអភិបាលមានតួនាទីជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ក្រៅពីនេះអភិបាលមានតួនាទីជាតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងដែនសមត្ថកិច្ចរបស់ខណ្ឌផងដែរ។

ក្នុងនាមជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គណៈអភិបាលមានភារកិច្ចសំខាន់ៗដូចជា៖

- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- លើកយោបល់ជូនក្រុមប្រឹក្សា ពាក់ព័ន្ធកិច្ចការនានាដែលក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័ត
- ផ្តួចផ្តើម រៀបចំ និងដាក់ជូនក្រុមប្រឹក្សានូវសេចក្តីព្រាងដីកា សេចក្តីសម្រេច និងបទបញ្ជានានាដើម្បីក្រុមប្រឹក្សា និងអនុម័ត
- ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្ត សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ថវិកា និងសកម្មភាពផ្តល់សេវាកម្មនានារបស់រដ្ឋបាលខណ្ឌព្រមទាំងការអនុវត្តគម្រោង ឬកម្មវិធីនានា។

ក្នុងតួនាទីជាតំណាងរបស់រាជរដ្ឋាភិបាល តំណាងរបស់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អភិបាលត្រូវមាន៖

- មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ន នានា និងត្រូវធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា

  ដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សា សន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ការអនុវត្តច្បាប់ និងការការពារសិទ្ធិមនុស្សក្នុងនាមជាប្រធានគណៈបញ្ជាការឯកភាព
- ណែនាំ សម្របសម្រួល តម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រតិបត្តិការនៅក្នុងខណ្ឌ ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីឆ្លើយតបនិងតម្រូវការជាអាទិភាពនៅមូលដ្ឋាន
- ការតែងតាំងផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៅក្នុងរដ្ឋបាលខណ្ឌបឹងកេងកង។

**២.២.២.២. សមាសភាពរបស់គណៈអភិបាល**

តារាងទី៨៖ សមាសភាពគណៈអភិបាលៈ[49]

| ល.រ | គោត្តមាន និងនាម | ភេទ | មុខតំណែង |
|---|---|---|---|
| ១ | ធឹម សំអាន | ប្រុស | អភិបាលនៃគណៈអភិបាល |
| ២ | ហេង ពិសិដ្ឋ | ប្រុស | អភិបាលរងខណ្ឌ |
| ៣ | គឹមណៃ វីរៈខេមរា | ប្រុស | អភិបាលរងខណ្ឌ |
| ៤ | ស៊ិន រតនា | ស្រី | អភិបាលរងខណ្ឌ |
| ៥ | ម៉ៅ កុលម៉ារឌី | ប្រុស | អភិបាលរងខណ្ឌ |

**២.២.២.៣. តួនាទី និងភារកិច្ចរបស់គណៈអភិបាល**

គណៈអភិបាលខណ្ឌមានតួនាទី និងភារកិច្ចដូចជា៖[50]

– គណៈអភិបាលខណ្ឌ ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់ជាយោបល់ជូនក្រុមប្រឹក្សាអំពីកិច្ចការនានាដែលពាក់ព័ន្ធ និងអំណាចបញ្ញត្តិ រួមទាំងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សា ដើម្បីខណ្ឌធ្វើការពិភាក្សា និងអនុម័តកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានធ្វើប្រតិភូកម្មមកឱ្យក្រុមប្រឹក្សាខណ្ឌ និងរៀបចំរបៀបរបប បែបបទ នីតិវិធីនៃការងារអនុវត្តមុខងារ ភារកិច្ច និងចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានដើម្បីទទួលយកមុខងារ ភារកិច្ច ធនធានដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ រួមទាំងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានី
- ក្របខណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់ខណ្ឌ
- ការបង្កើតការសម្របសម្រួល ឬការរំលាយការិយាល័យនានា
- ការងារបុគ្គលិក និងក្របខណ្ឌ

[49] តារាងបែងចែកការងារគណៈអភិបាលខណ្ឌបឹងកេងកង

[50] សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលខណ្ឌ ឆ្នាំ២០១០ ទំព័រទី២០ ដល់ទំព័រទី២៦

- កំណត់អំពីនីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
- រៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តមិនលើសពី៤៥ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗដែលទាក់ទងទៅនឹង ១/ ដីកា និងសេចក្តីសម្រេចនានា ដែលបានដាក់ចេញដោយក្រុមប្រឹក្សា និងសកម្មភាពលទ្ធផលនៃការអនុវត្ត ២/ បញ្ហាហិរញ្ញវត្ថុ និងថវិកា ៣/ ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលខណ្ឌ និងបុគ្គលិកលើកកម្ពស់សមភាពយេនឌ័រ ៤/ កិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាខណ្ឌយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន
- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ដើម្បីជួយដល់ការអនុវត្តការងារដោយរបស់ក្រុមប្រឹក្សាខណ្ឌ
- រៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជនដូចជា រៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវដោយក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន
- នៅពេលមានរបាយការណ៍ ឬមួយព័ត៌មានអំពីការរំលោភអំណាច គណៈអភិបាលខណ្ឌត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចយ៉ាងពិតប្រាដកមែន គណៈអភិបាលខណ្ឌត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារាជធានី។

– គណៈអភិបាលខណ្ឌមានតួនាទីជាតំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលក្នុងខណ្ឌ។ ក្នុងនាមជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដូចជា៖

- ធ្វើជាតំណាងរាជរដ្ឋាភិបាលតំណាងក្រសួង ស្ថាប័ន នានានៃរាជរដ្ឋាភិបាលក្នុងការរក្សា សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងខណ្ឌអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងខណ្ឌ
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពខណ្ឌក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា និងសង្កាត់នៅក្នុងខណ្ឌដើម្បីធានារក្សា សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងាររបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងខណ្ឌដើម្បីឆ្លើយតបតម្រូវការជាអាទិភាពរបស់មូលដ្ឋាន។ ក្នុងករណីដែលកិច្ចការ ទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យអភិបាលខណ្ឌត្រូវសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តកិច្ចការទាំងនោះ ដោយផ្អែកទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការជាអាទិភាពរបស់មូលដ្ឋាន
- ពិនិត្យវាយតម្លៃ ផ្តល់ជាមូលវាចារណ៍ និងដាក់ពិន្ទុប្រធានការិយាល័យ និងអង្គភាព នៃក្រសួង ស្ថាប័ននានាដែលប្រចាំនៅក្នុងខណ្ឌ
- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំខណ្ឌឱ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ស្របតាមគោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ និងការិយាល័យ អង្គភាព និងទីភ្នាក់ងាររបស់ក្រសួងនីមួយៗ។
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌជាមុនក្នុងការផ្តល់យោបល់បេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួង ស្ថាប័ន នានាប្រចាំនៅក្នុងខណ្ឌរបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះ ជូនលោកអភិបាលរាជធានីដើម្បីអភិបាលរាជធានីធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរអង្គភាពសាមីជាមុន មុននិងធ្វើសេចក្តីរាយការណ៍ជូនលោករដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។
- រាយការណ៍ជាលាយលក្ខណ៍អក្សរ និងជាបន្ទាន់ទៅកាន់អភិបាលរាជធានីក្នុងករណីបានឃើញពីភាពមិនប្រក្រតីកើតមានក្នុងការិយាល័យ អង្គភាព និងភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅក្នុងខណ្ឌរបស់ខ្លួន ឬក្នុងករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យអង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទីភារកិច្ចរបស់ខ្លួន។ អភិបាលរាជធានីត្រូវណែនាំមន្ទីរអង្គភាពខ្សែបណ្តាញសាមីនៅថ្នាក់រាជធានីដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ឬអាចចាត់តាំងគណៈកម្មការ ឬក្រុមការងារដែលមានការចូលរួមពីរដ្ឋបាលពាក់ព័ន្ធ ឱ្យធ្វើការស៊ើបអង្កេតលើករណីជាបន្ទាន់ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីដោះស្រាយទៅតាមនីតិវិធី។
- មានសិទ្ធស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់ អភិបាលរាជធានីដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតមុខតំណែងប្រធានការិយាល័យ ប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ ក្រសួង ស្ថាប័ន ដែលបានប្រព្រឹត្តខុសច្បាប់ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។

- **តួនាទីរបស់អភិបាល និងអភិបាលរងនៅក្នុងខណ្ឌបឹងកេងកង**

លោក **ធីម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង ទទួលបន្ទុកដឹកនាំការងារខណ្ឌបឹងកេងកង និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងកិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន។[51]

លោក **ហេង ពិសិដ្ឋ** អភិបាលរង គឺជាជំនួយការជូនលោកអភិបាល ទទួលបន្ទុកដឹកនាំការងារនៅក្នុងខណ្ឌបឹងកេងកងរួមមាន ១/ ការិយាល័យនគរូបនីយកម្មសំណង់ និងភូមិបាល ២/ គណបក្សនយោបាយ NGO សមាគមន៍ និងសិទ្ធិមនុស្ស ៣/ អភិវឌ្ឍន៍ជនបទ ៤/ គ្រោះមហន្តរាយ ៥/ ធម្មការ និងសាសនា ៦/ សុខាភិបាល ៧/ ឧស្សាហកម្ម រ៉ែ ថាមពល អគ្គិសនី ៨/ សម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ។

លោក **គឹមណៃ ធីរៈខេមរា** អភិបាលរង គឺជាជំនួយការជូនលោកអភិបាល ទទួលបន្ទុកដឹកនាំការងារនៅក្នុងខណ្ឌបឹងកេងកងរួមមាន ១/ ពាណិជ្ជកម្ម ផ្សារ អាជីវកម្ម ភាស៊ី ២/ សង្គម អតីតយុទ្ធជន ៣/ អប់រំយុវជន និងកីឡា ៤/ ធនធានទឹក ឧតុនិយមធារាសាស្ត្រ ៥/ គយ ពន្ធដារ និងកាំកុងត្រូល ៦/ ប្រៃសណីយ៍ និងទូរគមនាគមន៍ ៧/ កសិកម្ម រុក្ខាប្រមាញ់ ៨/ បាតុកម្ម និងសណ្តាប់ធ្នាប់ ៩/ គ្រឿងញៀន។

លោកស្រី **ស៊ិន រតនា** អភិបាលរង គឺជាជំនួយការជូនលោកអភិបាល ទទួលបន្ទុកដឹកនាំការងារនៅក្នុងខណ្ឌបឹងកេងកងរួមមានដូចជា ១/ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ២/ កិច្ចការនារី និងកុមារ ៣/ ស្ថិតិ ៤/ អត្រានុកូលដ្ឋាន ៥/ ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ៦/ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៧/ ធនាគារ និងរតនាគារ ៨/ ការិយាល័យច្រកចេញចូលតែមួយ។

លោក **ម៉ៅ កុលម៉ារឌី** អភិបាលរង គឺជាជំនួយការជូនលោកអភិបាលទទួលបន្ទុកដឹកនាំការងារនៅក្នុងខណ្ឌបឹងកេងកង ១/ ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ២/ ការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ ៣/ សហគមន៍ និងសិទ្ធិមនុស្ស។[52]

### ២.២.៣. នាយករដ្ឋបាល

- **លក្ខណៈសម្បត្តិនៃការតែងតាំងនាយករដ្ឋបាល**

ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌត្រូវមាននាយករដ្ឋបាលមួយ (១) រូប ហៅថានាយករដ្ឋបាលសាលាខណ្ឌដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលខណ្ឌ ដោយយោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌ។ រដ្ឋបាលសាលាខណ្ឌ ត្រូវមាននាយករងរដ្ឋបាលសាលាខណ្ឌយ៉ាងច្រើន

[51] តារាងបែងចែកការងារ អភិបាល អភិបាលរងខណ្ឌបឹងកេងកង

[52] តារាងបែងចែកការងារ អភិបាល អភិបាលរងខណ្ឌបឹងកេងកង

ពីរ (២) រូប គឺជាជំនួយការ តែងតាំងដោយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់លោកអភិបាលខណ្ឌដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌ។ នាយករដ្ឋបាលនៃសាលាខណ្ឌ ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតនៅក្នុងឋានន្តរសក្តិចាប់ពីក្រមការដើមខ្សែនៃក្របខណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

នាយករងរដ្ឋបាលសាលាខណ្ឌ ត្រូវបានតែងតាំងឡើងពី ក្នុងចំណោមមន្ត្រីដែលស្ថិតនៅក្នុងឋានន្តរសក្តិចាប់ពីក្រមការនៃក្របខណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។[53]

- **តួនាទី និងភារកិច្ចរបស់នាយករដ្ឋបាល**

នាយករដ្ឋបាល មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សា គណៈអភិបាល ក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តន៍ភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខណ្ឌ។ ក្នុងតួនាទីនេះនាយករដ្ឋបាលសាលាខណ្ឌត្រូវរាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលខណ្ឌ និងក្រុមប្រឹក្សារបស់ខ្លួន។

ការអនុវត្តតួនាទី នាយករដ្ឋបាលសាលាខណ្ឌមានភារកិច្ចដូចជា មានការរៀបចំ និងការដាក់ជូនគណៈអភិបាលខណ្ឌពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខណ្ឌក្នុងក្របខណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលខណ្ឌ ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគិតយុត្ត និងទម្រង់បែបបទលិខិតស្នាមរដ្ឋបាល និងរៀបចំ និងដាក់ជូនគណៈអភិបាលខណ្ឌនូវវិធាន និងគោលការណ៍ក្នុងការអនុវត្តដីកា សេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាខណ្ឌ ហើយធ្វើជាសេនាធិការជូនអភិបាល និងប្រធានក្រុមប្រឹក្សា ក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់នៃក្រុមប្រឹក្សាខណ្ឌ រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសាររបៀបវារៈនីមួយៗ នៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាង របៀបវារៈ ឯកសារ និងខ្លឹមសារ ទាំងអស់ដែលនាយករដ្ឋបាលសាលាខណ្ឌបានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាត្រូវតែដាក់ជូនគណៈអភិបាល ដើម្បីពិនិត្យ និងផ្តល់យោបល់ជាមុនលើកលែងតែមានការកំណត់ផ្សេងនេះ ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដោយត្រូវធ្វើជាសេនាធិការជូនដល់ក្រុមប្រឹក្សាខណ្ឌក្នុងការរៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំនិងកំណត់ហេតុគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌ មានការត្រៀមរៀបចំកិច្ចការនានាសម្រាប់បម្រើឱ្យកិច្ចការប្រជុំទាំងអស់របស់គណៈអភិបាលខណ្ឌតាមការណែនាំរបស់អភិបាលខណ្ឌ ត្រូវធានាក្នុងការទទួលនិងបែងចែកលិខិតស្នាមឯកសារនានាឱ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធនានា ជាពិសេសគ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលខណ្ឌឱ្យបានត្រឹមត្រូវតាមការកំណត់ ត្រូវតែធានារក្សាទុកឱ្យបានត្រឹមត្រូវនឹងគង់វង្សនូវឯកសារ លិខិតបទដ្ឋាន ទាំងអស់

[53] សៀវភៅការណែនាំស្តីពី តួនាទីភារកិច្ច និងរបៀបរបបការងាររបស់ខណ្ឌ

របស់ក្រុមប្រឹក្សាខណ្ឌគណៈអភិបាលខណ្ឌ និងរដ្ឋបាលខណ្ឌរបស់ខ្លួន មានការបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ ឬដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

- **សមាសភាពនាយករដ្ឋបាល**

ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌត្រូវមាន នាយករដ្ឋបាលចំនួនមួយ (០១)រូប និងនាយករងរដ្ឋបាលពីរ (០២) រូបជាជំនួយការដើម្បីចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តន៍ភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខណ្ឌបឹងកេងកង។ លោក **យុត ឡុងឌី** នាយករដ្ឋបាល និង លោក **សែន វ៉ាន់ណាក់** លោក **ម៉ូវ ម៉ានីន** ជានាយករងរដ្ឋបាលសាលាខណ្ឌត្រូវបំពេញមុខងារ និងទទួលខុសត្រូវស្របតាមលំដាប់ឋានានុក្រម និងអនុវត្តតួនាទី ភារកិច្ច ដែលបានចែងខាងលើ។ នាយករងរដ្ឋបាលដែលទទួលបានការបែងចែកភារកិច្ចនេះត្រូវមានគណនេយ្យភាព និងទទួលខុសត្រូវចំពោះមុខនាយករដ្ឋបាលលើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវចូលរួមជាមួយនាយករដ្ឋបាលទទួលខុសត្រូវលើការសម្រេច និងសកម្មភាពអភិបាល អភិបាលរង និងក្រុមប្រឹក្សាខ្លួន។

### ២.២.៤. ការិយាល័យ និងអង្គភាពចំណុះ

សាលាខណ្ឌបឹងកេងកងមានការិយាល័យចំនួនដប់មួយ (១១) ការិយាល័យៈ[54]

**១. ការិយាល័យរដ្ឋបាល និងបុគ្គលិក**

- **សមាសភាព**

នៅក្នុងការិយាល័យរដ្ឋបាល និងបុគ្គលិកគឺមាន លោកស្រី **សាត ឆវិន** ជាប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក ហើយនៅពុំទាន់មានសមាសភាពជាអនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកនៅឡើយទេ ដោយយោងទៅតាមប្រសាសន៍របស់លោកស្រីប្រធានការិយាល័យ គឺកំពុងតែស្នើទៅកាន់លោកអភិបាលនៃគណៈអភិបាលដើម្បីឱ្យលោកអភិបាលដាក់ជូនក្រុមប្រឹក្សាខណ្ឌប្រជុំពិភាក្សា ក្នុងការធ្វើសេចក្តីសម្រេចបង្កើននូវសមាសភាពការិយាល័យរដ្ឋបាល និងបុគ្គលិកតាមតម្រូវការជាចាំបាច់។

- **តួនាទី និងភារកិច្ចការិយាល័យរដ្ឋបាល និងបុគ្គលិក**

ជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងាររដ្ឋបាល និងបុគ្គលិក រួមទាំងមានមានភារកិច្ចចាត់ចែងការងារដូចជាការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងការងារសហប្រតិបត្តិការអន្តរជាតិ ការគ្រប់គ្រង និងការថែរក្សា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលខណ្ឌ ការពិនិត្យ និងការលើកយោបល់លើការកែលំអររចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិក

[54] អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩

របស់រដ្ឋបាលខណ្ឌតាមការផ្ទេរសិទ្ធពីរដ្ឋបាលរាជធានី ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករដ្ឋបាលខណ្ឌ ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំរបស់រដ្ឋបាលខណ្ឌ និងការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់គណៈអភិបាលខណ្ឌបឹងកេងកង។

**២. ការិយាល័យផែនការ និងហិរញ្ញវត្ថុ**

- **សមាសភាព**

នៅក្នុងការិយាល័យផែនការ និងហិរញ្ញវត្ថុគឺមាន លោក **យី សុភី** ជាអនុប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ ហើយនៅពុំទាន់មានសមាសភាពជាប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុនៅឡើយទេដោយយោងទៅតាមប្រសាសន៍របស់លោកអនុប្រធានការិយាល័យ គឺកំពុងតែមានការស្នើទៅកាន់លោកអភិបាលនៃគណៈអភិបាលខណ្ឌដើម្បីឱ្យ លោកអភិបាលដាក់ជូនក្រុមប្រឹក្សាខណ្ឌប្រជុំពិភាក្សាក្នុងការធ្វើសេចក្តីសម្រេចបង្កើនសមាសភាពប្រធានការិយាល័យ ។

- **តួនាទី និងភារកិច្ចរបស់ការិយាល័យផែនការ និងហិរញ្ញវត្ថុ**

ជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារផែនការ និងហិរញ្ញវត្ថុ និងមានភារកិច្ចចាត់ចែងលើការងារដូចជាការសិក្សា ការរៀបចំ និងការអនុវត្តគម្រោងនានារបស់រដ្ឋបាលខណ្ឌការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល រួមទាំងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលខណ្ឌការតាមដានការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីរំកិល រួមទាំងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ រួមទាំងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលខណ្ឌ ការណែនាំ និងការ ជម្រុញការប្រមូលទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ខណ្ឌតាមការកំណត់ ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ខណ្ឌ ការងារហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខណ្ឌការងាររបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលខណ្ឌ និងការងារស្ថិតិប្រជាជន ការគាំទ្រដល់រដ្ឋបាលសង្កាត់ក្នុងខណ្ឌតាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់គណៈអភិបាលខណ្ឌ។

**៣. អង្គភាពលទ្ធកម្ម**

- **សមាសភាព**

នៅក្នុងអង្គភាពលទ្ធកម្ម គឺមាន លោក **ជួប សុខសេរី** ជាប្រធានអង្គភាពលទ្ធកម្ម និងលោក **ប៉េង សុខឃៀង** ជាអនុប្រធានអង្គភាពលទ្ធកម្ម ។

– **តួនាទី និងភារកិច្ចរបស់អង្គភាពលទ្ធកម្ម**

ជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារ លទ្ធកម្មសាធារណៈ និងមានភារកិច្ចចាត់ចែងលើការងារដូចជាការងាររៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ការរៀបចំឯកសារដេញថ្លៃ ហើយការរៀបចំ និងផ្សព្វផ្សាយអំពីលទ្ធកម្ម ការផ្តល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ ការរៀបចំសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ ការៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចសន្យាលទ្ធកម្ម និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់គណៈអភិបាលខណ្ឌ។

### ៤. ការិយាល័យលេខាធិការក្រុមប្រឹក្សា

– **សមាសភាព**

នៅក្នុងការិយាល័យលេខាធិការក្រុមប្រឹក្សា គឺនៅពុំទាន់មានសមាសភាពជាប្រធាន និងអនុប្រធាន ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សានៅឡើយទេ ដោយយោងទៅតាមការសម្ភាសន៍ផ្ទាល់ជាមួយមន្ត្រីនៅក្នុងការិយាល័យ គឺកំពុងតែមានការស្នើទៅកាន់លោកអភិបាលនៃគណៈអភិបាល ដើម្បីឱ្យលោកអភិបាលដាក់ជូនក្រុមប្រឹក្សាខណ្ឌប្រជុំពិភាក្សាក្នុងការធ្វើសេចក្តីសម្រេច បង្កើតសមាសភាពជាប្រធាន និងអនុប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាតាមតម្រូវការជាចាំបាច់។

– **តួនាទី និងភារកិច្ចរបស់ការិយាល័យ**

ជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារលេខាធិការដ្ឋានជូនក្រុមប្រឹក្សាខណ្ឌ និងមានភារកិច្ចចាត់ចែកទៅលើការងារដូចជាការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ របស់ក្រុមប្រឹក្សាការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា ការរៀបចំវេទិការផ្សព្វផ្សាយ និងការពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេចនិងឯកសារនានារបស់ក្រុមប្រឹក្សាការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ។

### ៥. ការិយាល័យអប់រំ យុវជន និងកីឡា

– **សមាសភាព**

នៅក្នុងការិយាល័យអប់រំ យុវជន និងកីឡា គឺមាន លោក **ទូន ភារ៉ា** ជាប្រធានការិយាល័យអប់រំ យុវជន និងកីឡា និងលោក **សេក វុឌ្ឍា** ជាអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា ។

– **តួនាទី និងភារកិច្ចរបស់ការិយាល័យអប់រំ យុវជន និងកីឡា**

ជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារ អប់រំ យុវជន និងកីឡារួមទាំងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចជា ការងារអប់រំកុមការងារអប់រំកុមារតូចៗ ការងារអប់រំបឋមសិក្សា ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះដឹងទូទៅ ការងារអប់រំក្រៅប្រព័ន្ធ ការងារអភិវឌ្ឍយុវជន ការងារអប់រំកាយ និងកីឡា ការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់គណៈអភិបាល។

**៦. ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល**

– **សមាសភាព**

នៅក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលគឺមាន លោក **ខុន សន្ធនា** ជាប្រធានការិយាល័យ និងលោក **ថា សុវណ្ណារី** ជាអនុប្រធានការិយាល័យ។

– **តួនាទី និងភារកិច្ចរបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល**

ជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងាររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងភូមិបាល រួមទាំងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចជា ការងាររៀបចំដែនដី នគររូបនីយកម្ម ការងារភូមិបាល ការងារសំណង់ ការងារលំនៅដ្ឋាន រួមទាំងការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់ អភិបាលនៃគណៈអភិបាលខណ្ឌ។

**៧. ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន**

– **សមាសភាព**

នៅក្នុងការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានគឺមាន លោក **ថេង ច័ន្ទពិសិដ្ឋ** ជាប្រធានការិយាល័យ ហើយនៅពុំទាន់មានសមាសភាពជាអនុប្រធានការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាននៅឡើយនោះទេ ដោយយោងតាមប្រសាសន៍របស់លោកប្រធានការិយាល័យ គឺកំពុងតែមានការស្នើទៅកាន់លោកអភិបាល នៃគណៈអភិបាលដើម្បីឱ្យលោកអភិបាលដាក់ជូនក្រុមប្រឹក្សាខណ្ឌប្រជុំពិភាក្សាក្នុងការធ្វើសេចក្ដីសម្រេចបង្កើតនូវសមាសភាពការិយាល័យតាមតម្រូវការ។

– **តួនាទី និងភារកិច្ចរបស់ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន**

សេនាធិការឱ្យរដ្ឋបាលខណ្ឌ លើការងារនីតិកម្ម និងការសម្រុះសម្រួលវិវាទមូលដ្ឋាន ក្រៅប្រព័ន្ធតុលាការ និងមានភារកិច្ចចាត់ចែងការងារដូចខាងក្រោម ការសិក្សាស្រាវជ្រាវ និងការរៀបចំ រួមទាំងការផ្ដល់ជាយោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលខណ្ឌ ហើយផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដល់ មន្ត្រី បុគ្គលិក និងប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌការផ្ដល់ប្រឹក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ ការរៀបចំបណ្ដុះបណ្ដាលជំនាញសម្រុះសម្រួលវិវាទ នៅមូល

ដ្ឋានដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌស្របតាមច្បាប់កំណត់ និងការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់គណៈអភិបាលខណ្ឌ។

**៨. ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ**

- **សមាសភាព**

នៅក្នុងការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈគឺ លោក **អ៊ឹង ដារ៉ា** ជាប្រធានការិយាល័យ និងលោក **រិន កែវ** ជាអនុប្រធានការិយាល័យ។

- **តួនាទី និងភារកិច្ចរបស់ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ**

ជាសេធិការឱ្យរដ្ឋបាលខណ្ឌលើការងារសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចជា ការងារសាធារណការ ដឹកជញ្ជូន ការងារគ្រប់គ្រងសម្រាម សំណល់រឹងនៅទីប្រជុំជនរួមទាំងគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកង្វក់ និងគ្រប់គ្រងផ្សែង សម្លេង ក្លិន និងការបំពុលបរិយាកាស ការដាំ ហើយក៏គ្រប់គ្រងការថែទាំដើមឈើ និងសួនសាធារណៈ និងគ្រប់គ្រងចំណតយានយន្តសាធារណៈមានការងារផ្សេងៗ ទៀតតាមការប្រគល់ភារកិច្ចរបស់គណៈអភិបាលខណ្ឌ។

**៩. ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍**

- **សមាសភាព**

នៅក្នុងការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ គឺលោក **សួស ប៊ុច** ជាប្រធានការិយាល័យ និងលោក **ជ្រូក គឹមហៀក** លោក **ឡាយ ច័ន្ទថា** ជាអនុប្រធានការិយាល័យ ។

- **តួនាទី និងភារកិច្ចរបស់ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍**

ជាសេនាធិការរបស់រដ្ឋបាលខណ្ឌលើការអភិវឌ្ឍសេដ្ឋកិច្ច ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសហគមន៍ រួមទាំងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងជា ការងារឧស្សាហកម្ម និងសិប្បកម្មការងាររ៉ែ និងថាមពល ការងារទេសចរណ៍ ការងារពាណិជ្ជកម្ម ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការងារធនធានទឹក ការងារប្រៃសណីយ៍ និងទូរគមនាគមន៍ រួមទាំងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់គណៈអភិបាលខណ្ឌ។

**១០. ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**

- **សមាសភាព**

នៅក្នុងការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម គឺលោក **ញ៉ រ សុភក្តិ** ជាប្រធានការិយាល័យ និងលោក **យន្ត សារ៉ុន** លោក **មាស ច័ន្ទណារិទ្ធ** ជាអនុប្រធានការិយាល័យ ។

– **តួនាទី និងភារកិច្ចរបស់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**

ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ជាសេនាធិការរបស់រដ្ឋបាលខណ្ឌលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គម និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងជា ការងារសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា ការងារសុខាភិបាល ការងារធម្មការ និងសាសនា ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈការងារ វប្បធម៌ និងវិចិត្រសិល្បៈ ការងាររងគ្រោះមហន្តរាយ ការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់គណៈអភិបាលខណ្ឌបឹងកេងកង។

**១១. ការិយាល័យច្រកចេញចូលតែមួយ**

– **សមាសភាព**

នៅក្នុងការិយាល័យច្រកចេញចូលតែមួយ គឺលោក **ស៊ុន វិបុល** ជាប្រធានការិយាលច្រកចេញចូលតែមួយ ហើយពុំទាន់មានសមាសភាព ជាអនុប្រធានការិយាល័យច្រកចេញចូលតែមួយនៅឡើយទេដោយយោងតាមប្រសាសន៍របស់លោកប្រធានការិយាល័យគឺកំពុងតែមានការស្នើទៅលោកអភិបាលដើម្បីឱ្យអភិបាលដាក់ជូនក្រុមប្រឹក្សាខណ្ឌប្រជុំពិភាក្សាក្នុងការធ្វើសេចក្តីសម្រេចបង្កើននូវសមាសភាពរបស់ការិយាល័យតាមតម្រូវការ។

– **តួនាទី និងភារកិច្ចរបស់ការិយាល័យច្រកចេញចូលតែមួយ**

ការិយាល័យច្រកចេញចូលតែមួយ ជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារផ្តល់សេវារដ្ឋបាលនានា និងមានភារកិច្ចចាត់ចែងទៅលើការងារដូចជា ការទទួល និងការផ្តល់សេវារដ្ឋបាលនានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌ ការប្រមូល និងបង់កម្រៃសេវារដ្ឋបាលតាមគោលការណ៍ និងនីតិវិធីកំណត់ការផ្តល់ព័ត៌មាននានា និងការផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនិងការផ្តល់សេវារដ្ឋបាល ការទុកដាក់ ការថែរក្សា និងការគ្រប់គ្រងឯកសារនានាពាក់ព័ន្ធនិងការផ្តល់ សេវារដ្ឋបាលរួមទាំងការងារផ្សេងៗទៀតតាមការប្រគល់នូវភារកិច្ចរបស់គណៈអភិបាលខណ្ឌ។

## ២.៣. ការគ្រប់គ្រងរដ្ឋបាលខណ្ឌបឹងកេងកង

### ២.៣.១. ការងាររដ្ឋបាល

#### ក. ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

ដីការអមដែលបានដាក់ចេញ ៥០លិខិត, សេចក្តីសម្រេចដែលបានដាក់ចេញ ១លិខិត, លិខិតរដ្ឋបាលដែលបានដាក់ចេញ ៨២លិខិត, លិខិតដែលបានទទួល ២៤១លិខិត, ផ្តល់សៀវភៅស្នាក់នៅជូនប្រជាពលរដ្ឋ ២៤សៀវភៅ។

តារាងទី៩៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ដីកាដែលបានដាក់ចេញ | ០២ |

| | | |
|---|---|---|
| ២ | សេចក្ដីសម្រេចដែលបានដាក់ចេញ | ៥៥ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ៤៦៨៨ |
| ៤ | លិខិតដែលទទួលបាន | ២០០០ |

**ខ. ការគ្រប់គ្រងប្រជាពលរដ្ឋ**

ស្ថិតិប្រជាពលរដ្ឋមានចំនួន ៩១៨៦គ្រួសារ ប្រជាពលរដ្ឋសរុប ៥២១២៩នាក់, ស្ត្រី ២០៤៨៣នាក់ និង ប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើង ៤១១២៦នាក់ ស្ត្រី ២០៤៨៧នាក់។

តារាងទី១០៖ ការគ្រប់គ្រងប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ចំនួនគ្រួសារសរុប | ៩១៨៦ |
| ២ | ចំនួនគ្រួសារអចិន្ត្រៃយ៍ | ៨៣៤៩ |
| ៣ | ចំនួនគ្រួសារបណ្ដោះអាសន្ន | ៨៣៧ |
| ៤ | ចំនួនប្រជាពលរដ្ឋសរុប | ៥២១២៩ |
| ៥ | ចំនួនប្រជាពលរដ្ឋជាស្ត្រី | ២៥៧៧៨ |
| ៦ | ចំនួនប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងសរុប | ៤១១២៦ |
| ៧ | ចំនួនប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងជាស្ត្រី | ២០៤៨៣ |

**គ. ការងារអត្រានុកូលដ្ឋាន**

ការចម្លងសំបុត្រអត្រានុកូលដ្ឋានអនុវត្តបានដូចជា សេចក្ដីចម្លងសំបុត្រកំណើតចំនួន ២១៩នាក់, សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតចំនួន៦៨៨នាក់, សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចំនួន១២៣នាក់ និងសេចក្ដីចម្លងសំបុត្រមរណភាពចំនួន ១៣នាក់។

តារាងទី១១៖ ការចេញសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេចក្ដីចម្លងសំបុត្រកំណើត | ១៥៣២ |
| ២ | សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត | ៥៥០៨ |
| ៣ | សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ១០៤៤ |
| ៤ | សេចក្ដីចម្លងសំបុត្រមរណភាព | ១០៨ |

**ឃ. ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| | ឃ.១. ការផ្សព្វផ្សាយព័ត៌មាន | |
| ១ | តាមរយៈវិទ្យុ | ០០ |
| ២ | តាមរយៈទូរទស្សន៍ | ០៤ |
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | ៧២ |
| ៤ | ព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តី សារព័ត៌មាន | ០០ |
| | ឃ.២. ទំនាក់ទំនងសាធារណៈ | |
| ១ | សាធារណៈជនមកទំនាក់ទំនងសាលាខណ្ឌ | ១១៩ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ និងអន្តរជាតិ | ៣៧ |

**ង. ការងារគណៈអភិបាលខណ្ឌ**

តារាងទី១២៖ កិច្ចប្រជុំគណៈអភិបាល

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ១៨ |
| ២ | កិច្ចប្រជុំប្រចាំខែ (អឌ្ឍមាសទី២) របស់គណៈអភិបាល | ០៩ |

**ច. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

តារាងទី១៣៖ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១០ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ១០ |

**២.២.៣. ការគ្រប់គ្រងធនធានមនុស្ស**

– **ចំពោះការគ្រប់គ្រងបុគ្គលិកនៅក្នុងខណ្ឌ**

រចនាសម្ព័ន្ធរួមមាន សមាជិកក្រុមប្រឹក្សាខណ្ឌចំនួន ១៧នាក់ ស្រីចំនួន ២នាក់, ប្រធានក្រុមប្រឹក្សាខណ្ឌចំនួន ១នាក់ (ប្រុស), សមាជិកក្រុមប្រឹក្សាខណ្ឌដែលបានផ្លាស់ប្តូរ គ្មាន, អភិបាល នៃគណៈអភិបាលខណ្ឌមានចំនួន ១នាក់, អភិបាលរងខណ្ឌចំនួន ៤នាក់ ស្រីចំនួន ១នាក់, នាយក នាយករងរដ្ឋបាល ចំនួន ៣នាក់, ប្រធាន

ការិយាល័យ និងអង្គភាពចំនួន ៩នាក់ ស្រី ចំនួន ១នាក់, អនុប្រធានការិយាល័យ និងអង្គភាព ១៤នាក់ ស្រី ៣នាក់, ស្មៀន សង្កាត់ ៧នាក់, មន្ត្រីកម្មសិក្សា ១៩នាក់ ស្រី ១៤នាក់, បុគ្គលិកជាប់កិច្ចសន្យា ២០៨នាក់ ស្រី ៥៣នាក់។

**២.៣.៣. ការងារអន្តរវិស័យ**

**ក. ការសម្របសម្រួលតាមវិស័យ និងការដោះស្រាយ សម្រុះសម្រួលទំនាស់**

– **ការសម្របសម្រួលតាមវិស័យ**

សាលារាជធានីភ្នំពេញបានធ្វើប្រតិភូកម្ម មុខងារនៅក្នុងវិស័យនានាមកឱ្យរដ្ឋបាលខណ្ឌបឹងកេងកងដែលមានដូចវិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល, វិស័យអភិវឌ្ឍន៍ជនបទ, វិស័យធនធានទឹក, វិស័យបរិស្ថាន និងធនធានធម្មជាតិ, វិស័យរ៉ែ និងថាមពល, វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, វិស័យសាធារណការ និងដឹកជញ្ជូន, វិស័យឧស្សាហកម្ម និងសិប្បកម្ម, វិស័យពាណិជ្ជកម្ម, វិស័យទេសចរណ៍, វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, វិស័យកិច្ចការនារី, វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, វិស័យធម្មការ និងសាសនា, វិស័យវប្បធម៌ និងវិចិត្រសិល្បៈ, វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, វិស័យសុខាភិបាល, ការងារនីត្យានុកូលកម្ម រដ្ឋបាល និងអត្រានុកូលដ្ឋាន, វិស័យអប់រំ និងមុខគ្រប់គ្រងសេវាទីប្រជុំជន។

– **ការសម្រុះសម្រួលទំនាស់**

តារាងទី១៤៖ ការសម្រុះសម្រួលទំនាស់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលខណ្ឌ | ៦៥ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ០២ |

**ខ. កិច្ចការច្រកចេញចូលតែមួយ**

ចាប់ពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ការិយាល័យច្រកចេញចូលតែមួយបានផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋចំនួន ៣៧,៩៥២ នាក់ ស្រីចំនួន ១៥,២០២នាក់ ក្នុងនោះមានដូចជាវិស័យនីត្យានុកូលកម្មចំនួន ៣០១២៥នាក់ ស្រីចំនួន ១២១៣១នាក់, វិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន ១១នាក់ ស្រីចំនួន ៥នាក់, វិស័យអប់រំ យុវជន និងកីឡា ចំនួន ៣នាក់, វិស័យទេសចរណ៍ចំនួន ៤៦នាក់ ស្រីចំនួន ៨នាក់, វិស័យអត្រានុកូលដ្ឋាន ចំនួន ៦៤៦៣នាក់ ស្រីចំនួន ២៥៧៧នាក់, វិស័យសុរិយោដី ចំនួន ៩៥នាក់ ស្រីចំនួន ១០នាក់, វិស័យសំណង់ ចំនួន ៦២នាក់ ស្រីចំនួន ៣នាក់, វិស័យពាណិជ្ជកម្ម ចំនួន ៦៥៣ នាក់ ស្រីចំនួន ៣៦៣នាក់, វិស័យសុខាភិបាល ចំនួន ២៨នាក់ ស្រីចំនួន ៤នាក់, វិស័យសាធារណការ ចំនួន ៤៦៦នាក់ ស្រីចំនួន ១០១នាក់។

តារាងទី១៥៖ កិច្ចការច្រកចេញតែមួយ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់ | ៣៧៩៥២ |
| ២ | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | ៣៧៩៥២ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | ១៥,២០២ |
| ៤ | ចំណូលដែលទទួលបានពីការផ្តល់សេវា (រ) | ១៧៥,១២៩,៣៣០ |

**គ. កិច្ចការសេវាសង្គម និងការបង្កើនសិទ្ធិអំណាចស្ត្រី និងកុមារ**

តារាងទី១៦៖ ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់ គ.ក.ស.ក

| ល.រ | សូចនាករ | ផែនការប្រចាំឆ្នាំ | លទ្ធផលសម្រេច | |
|---|---|---|---|---|
| | | | ជាក់ស្តែង | % |
| ១ | ចំនួនកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ខណ្ឌ | ១២ | ០៩ | ៧៥ |
| ២ | ចំនួនថវិកាប្រចាំឆ្នាំសម្រាប់ចំណាយផ្នែកសេវាសង្គម (រ) | ៥,៦១៦,០០០ | ១,២២០,០០០ | ២៣ |
| ៤ | ចំនួនបេសកម្មដែល គ.ក.ស.ក ខណ្ឌបានចុះគ្រាំទ្រ និងផ្តល់សេវាសង្គម | ៩៤ | ០៧ | ៧.៥ |
| ៥ | ចំនួនសង្កាត់ដែល គ.ក.ស.ក ខណ្ឌបានចុះគាំទ្រ | ០៧ | ០៧ | ១០០ |

**២.៣.៤. កម្មវិធីវិនិយោគបីឆ្នាំរំកិល**

ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខណ្ឌបឹងកេងកង

- ចំពោះគម្រោងជាអាទិភាពសម្រាប់ឆ្នាំ ២០២១-២០២៣ របស់រដ្ឋបាលខណ្ឌបឹងកេងកងមានដូចជា៖
  - ផ្នែកសេដ្ឋកិច្ច៖ មានចំនួន ៨ គម្រោង ក្នុងតម្លៃប៉ាន់ស្មាន ៦៦៨,៥៧០,០០០រៀល
  - ផ្នែកសង្គមកិច្ច៖ មាន ១៦គម្រោង ក្នុងតម្លៃប៉ាន់ស្មាន ៣៣៨,៦០០,០០០រៀល
  - ផ្នែកធនធានធម្មជាតិ បរិស្ថាន ការបន្សាំ និងការប្រែប្រួលអាកាសធាតុ៖ មាន៧គម្រោង ក្នុងតម្លៃប៉ាន់ស្មាន ១៩៤,៦០០,០០០រៀល
  - ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ៖ គឺមាន ២៣គម្រោងនៅក្នុងតម្លៃប៉ាន់ស្មាន ៧០,០០០,០០០រៀល។

តារាងទី១៧៖ គម្រោងវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌ

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង (រៀល) |
|---|---|---|---|
| ១ | សេដ្ឋកិច្ច | ០៨ | ៦៦៨,៥៧០,០០០ |
| ២ | សង្គមកិច្ច | ១៦ | ៣៣៨,៦០០,០០០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួល អាកាសធាតុ និងគ្រោះមហន្តរាយ | ០៧ | ៣៣៨,៦០០,០០០ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ២៣ | ១៩៤,៦០០,០០០ |
| សរុប | | ៥៤ | ១,២៧១,៧៧០,០០០ |

តារាងទី១៨៖ ការអនុវត្តគម្រោងវិនិយោគខណ្ឌ

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ០៨ | ០០ | ០០ | ០៨ |
| ២ | សង្គមកិច្ច | ១៦ | ០០ | ០០ | ១៦ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថានការប្រែប្រួល អាកាសធាតុ និងគ្រោះមហន្តរាយ | ០៧ | ០០ | ០០ | ០៧ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ២៣ | ០០ | ០០ | ២៣ |
| សរុប | | ៥៤ | ០០ | ០០ | ៥៤ |

# ជំពូកទី៣

# សមិទ្ធផល បញ្ហាប្រឈម និងទិសដៅ
# អនាគត

# ជំពូកទី៣

# សមិទ្ធផល បញ្ហាប្រឈម និងទិសដៅអនាគត

## ៣.១. សមិទ្ធផល

### ៣.១.១. សេវាសាធារណៈដែលបានផ្តល់ដោយសាលាខណ្ឌបឹងកេងកង

ការិយាល័យច្រកចេញចូលតែមួយបង្កើតឡើង ក្នុងគោលបំណងបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋដែលរស់នៅក្នុងខណ្ឌបឹងកេងកង ដើម្បីចូលរួមចំណែកកាត់បន្ថយអំពើពុករលួយរបស់មន្ត្រីរាជការ និងដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងមូលដ្ឋានប្រកបដោយ គណនេយ្យភាព តម្លាភាព និងមានប្រសិទ្ធភាពខ្ពស់ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

តារាងទី១៩៖ ការិយាល័យច្រកចេញតែមួយ

| ល.រ | ការបរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| **ក. ភាគរអត្រានុកូលដ្ឋាន** | | | | | | |
| ១ | សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | 0 | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | 0 | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៣ | សេចក្តីចម្លងសំបុត្រមរណៈភាព | 0 | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| **ខ. ការងារនីត្យានុកូលកម្ម** (**បញ្ជាក់ឯកសារថតចម្លង**) | | | | | | |
| ១ | ប័ណ្ណប៉ាតង់ | 0 | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់បានចុះបញ្ជី | 0 | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៣ | ប័ណ្ណបើកបរ | 0 | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៤ | អត្តសញ្ញាណប័ណ្ណ | 0 | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៥ | សៀវភៅស្នាក់នៅ | 0 | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

### ៣.១.២. វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច

#### ៣.១.២.១. វិស័យហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍

សាលាខណ្ឌបឹងកេងកងបានធ្វើការជួសជុលផ្លូវ ដោយអ៊ុតកៅស៊ូបេទីមីណឺ ចាប់ពីផ្លូវលេខ៦៣ ដល់ផ្លូវលេខ៥១ កម្រាស់ ៥សង់ទីម៉ែត្រ បណ្តោយ ២៤០ម៉ែត្រ ទទឹង ៦ម៉ែត្រ សរុបផ្ទៃក្រឡា ១,៤៤០ម៉ែត្រការ៉េ ក្នុងសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកងជូនរដ្ឋបាលខណ្ឌបឹងកេងកង ក្នុងឆ្នាំ២០២១ អនុវត្តបាន ១០០%។ ម្យ៉ាងវិញទៀត ដោយសារតែបញ្ហាកូវីដ១៩ ទើបធ្វើឱ្យខណ្ឌបឹងកេងកងពុំបានជួសជុលផ្លូវនៅតាមបណ្តាលសង្កាត់ទាំង៧។

#### ៣.១.២.២. វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ ពាណិជ្ជកម្ម និងទេសចរណ៍

- **វិស័យការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ**

បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌបឹងកេងកង ចំនួន៧លើក បានចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកងចំនួន ១២លើក បានចូលរួមកិច្ចប្រជុំ គ.ក.ស.ក ចំនួន ៩លើក, បានចូលរួមកិច្ចប្រជុំសំណេះសំណាលជាមួយមន្ត្រីរាជការ ដែលកំពុងបម្រើការងារនៅក្នុងរដ្ឋបាលខណ្ឌបឹងកេងកងបានចំនួន១លើក ក្រោមអធិបតីភាព លោក **ធីម សំអាន** អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង, បានចូលរួមប្រចាំការនៅតាមមណ្ឌលចាក់វ៉ាក់សាំងគ្រប់ការចាត់តាំងរបស់រដ្ឋបាលខណ្ឌ, បានចូលរួមវេនយាមប្រចាំការនៅក្នុងខណ្ឌបឹងកេងកងរាល់វេនយាម, ចូលរួមពិធីចែកអំណោយរបស់កាកបាទក្រហមកម្ពុជាក្រោមអធិបតីភាពលោក **ធីម សំអាន** អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង និងបានចូលរួមសហការអនុវត្តអនាម័យនៅតាមសាលារៀននៅក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។

- **វិស័យពាណិជ្ជកម្ម**

បានចុះជម្រុញ និងណែនាំដល់ម្ចាស់អាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ឱ្យមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្មរបស់ខ្លួននៅការិយាល័យច្រកចេញចូលតែមួយរបស់ខណ្ឌបឹងកេងកងក្នុងនោះរួមមាន ចុះជម្រុញ និងណែនាំក្នុងសង្កាត់បឹងកេងកងទី១ បានចំនួន ១៥៧ទីតាំង ហើយបានចុះជម្រុញ និងណែនាំក្នុងសង្កាត់បឹងកេងកងទី២ បានចំនួន ១១៩ទីតាំង រួមទាំងចុះជម្រុញ និងណែនាំក្នុងសង្កាត់បឹងកេងកងទី៣ បានចំនួន ១៤៤ទីតាំង ម្យ៉ាងវិញទៀតចុះជម្រុញ និងណែនាំក្នុងសង្កាត់ទួលស្វាយព្រៃទី១ បានចំនួន ១៣១ទីតាំង ហើយបានចុះជម្រុញ និងណែនាំក្នុងសង្កាត់ទួលស្វាយព្រៃទី២ បានចំនួន១៤២ទីតាំង ចុះជម្រុញ និងណែនាំក្នុងសង្កាត់អូឡាំពិក បានចំនួន ២៣២ទីតាំង ចុះជម្រុញ និងណែនាំក្នុងសង្កាត់ទំនប់ទឹក បានចំនួន ៩២ទីតាំង និងជាលទ្ធផលម្ចាស់អាជីវកម្មបានមកធ្វើលិខិតអនុញ្ញាតប្រកបអាជីវកម្មបាន ៦៥៣ទីតាំង ស្រី ៣៦៣នាក់។

- **វិស័យទេសចរណ៍**

បានចុះចែកលិខិតរបស់ក្រសួងទេសចរណ៍ រដ្ឋបាលរាជធានីភ្នំពេញ និងមន្ទីរទេសចរណ៍រាជធានីភ្នំពេញនៅក្នុងខណ្ឌ។ ចូលរួមសហការជាមួយរដ្ឋបាលរាជធានីភ្នំពេញ និងមន្ទីរទេសចរណ៍រាជធានីភ្នំពេញ ចុះអប់រំផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់ការការពារជម្ងឺកូវីដ១៩។ ចុះជម្រុញ និងស្រង់ស្ថិតិមូលដ្ឋានអាជីវកម្មទេសចរណ៍ជាប្រចាំ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។ បានចេញច្បាប់អនុញ្ញាតប្រកបអាជីវកម្មទេសចរណ៍ សង្កាត់បឹងកេងកងទី១ បានចំនួន ២៤ទីតាំងថ្មី បន្ត ១៥ទីតាំង, សង្កាត់បឹងកេងកងទី២ បានចំនួន ថ្មី ៥ទីតាំង បន្ត ៣ទីតាំង, សង្កាត់បឹងកេងកងទី៣ បានចំនួន ៧ទីតាំងថ្មី បន្ត ៤ទីតាំង, សង្កាត់អូឡាំពិក បានចំនួន ១ទីតាំងថ្មី, សង្កាត់ទួលស្វាយព្រៃទី១ បានចំនួន ៤ទីតាំងថ្មី បន្ត ២ទីតាំង, សង្កាត់ទួលស្វាយព្រៃទី២ បានចំនួន ១ទីតាំងថ្មី បន្ត ១ទីតាំង, សង្កាត់ទំនប់ទឹក បានចំនួន ៣ទីតាំង, ហើយសរុបការចេញអាជ្ញាប័ណ្ណក្នុងឆ្នាំ២០២១ បានសរុបចំនួន៧០ទីតាំង ក្នុងនោះថ្មីបានចំនួន ៤៥ទីតាំង និងបន្តបានចំនួន ២៥ទីតាំង។

### ៣.១.២.៣. វិស័យអប់រំ យុវជន និងកីឡា វប្បធម៌ និងវិចិត្រសិល្បៈ និងវិស័យសុខាភិបាល

- **វិស័យអប់រំ យុវជន និងកីឡា**

បានចូលរួមពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២០-២០២១ នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។ ណែនាំគណៈនាយកគ្រប់គ្រឹះស្ថានសិក្សាទាំងសាធារណៈ និងឯកជន ក្នុងការអនុវត្តនូវគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) និងវិធានការសុខាភិបាល។ ណែនាំ និងពង្រឹងការសិក្សាពីចម្ងាយ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច និងការដាក់កែកិច្ចការសិស្ស។ គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ត្រូវរៀបចំបង្កើតបន្ទប់ថតវីដេអូ (Video) បង្រៀនពីចម្ងាយដល់សិស្សតាមប្រព័ន្ធទូរស័ព្ទឆ្លាតវៃឱ្យសិស្សរៀនតាមទូរទស្សន៍នៅតាមផ្ទះ។

ប្រមូលបញ្ជីសិស្សក្រីក្រ ដែលទទួលបានអាហារូបករណ៍ ជាផ្លូការចុះត្រួតពិនិត្យបែងចែកថវិកាអាហារូបករណ៍សិស្សក្រីក្រ ជាពិសេសកូនយុទ្ធជន និងតាមដានការសិក្សាសិស្សមានអាហារូបករណ៍។ បំផុសចលនាប្រឡងប្រណាំងនាយកសាលាល្អ គ្រូបង្រៀនល្អ សាលារៀនកុមារមេត្រី បរិស្ថានស្អាត។ ទទួលពិនិត្យផែនការប្រតិបត្តិប្រចាំឆ្នាំ ប្រតិទិនការងារប្រចាំឆ្នាំ ផែនការអភិវឌ្ឍន៍សាលារៀន ផែនការសកម្មភាពសាលារៀន។ ការចុះពិនិត្យតាមដាន វាយតម្លៃការបង្រៀន នៅក្នុងសាលាការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចដល់សិស្សតាមសាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាសាធារណៈ និងឯកជនរួមបញ្ចូលរបាយការណ៍ផ្ញើមករដ្ឋបាលខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញរៀងរាល់ថ្ងៃ។ តាមដានបុគ្គលិកអប់រំសិស្សឆ្លងជម្ងឺកូវីដ១៩នៅសាលាសាធារណៈ និងឯកជនសរុបរបាយការណ៍ប្រចាំថ្ងៃផ្ញើជូនមករដ្ឋបាលខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ។

- **វិស័យវប្បធម៌ និងវិចិត្រសិល្បៈ**

បានចុះពិនិត្យ និងជម្រុញទីតាំងសាឡនហាងកាត់សក់ធ្វើក្រចកឱ្យមកស្នើសុំពាក្យនៅការិយាល័យច្រកចេញចូលតែមួយបានចំនួន១៥ទីតាំង មានច្បាប់ចំនួន២ទីតាំង។ បានចុះពិនិត្យ និងជម្រុញទីតាំងអាជីវកម្មដែលលើកស្លាកយីហោផ្ទាំង ផ្សព្វផ្សាយបានសរុបចំនួន១០ទីតាំង មានច្បាប់ចំនួន២ទីតាំង។ បានចូលរួមប្រជុំផ្សព្វផ្សាយអំពីការរៀបចំដាក់បញ្ចូលទីតាំងប្រវត្តិសាស្ត្រ ម១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនិងប្រល័យពូជសាសន៍ជើងឯកក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពលោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។

- **វិស័យសុខាភិបាល**

បានចុះពិនិត្យផ្ទៃពោះសរុបចំនួន ៣៨២នាក់។ ការផ្តល់ថ្នាំជាតិដែកចំនួន ៩០ គ្រាប់មុនពេលសម្រាលចំនួន ៣៨២នាក់។ កុមារចាក់ថ្នាំបង្ការគ្រប់មុខបានចំនួន ២៦៩នាក់។ ប្រជុំពង្រឹងការងារគាំពារមាតា និងទារកកុមារបានចំនួន១ដង។

### ៣.១.២.៤ .វិស័យសង្គមកិច្ច សុខុមាលភាព និងកិច្ចការនារី

- **វិស័យសង្គមកិច្ច និងសុខុមាលភាព**

បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌបឹងកេងកងចំនួន៧លើក។ បានចូលរួមកិច្ចប្រជុំ គ.ក.ស.ក បានចំនួន ៩លើក។ បានចុះបើកប្រាក់មរណសង្គ្រោះរបស់សមាគមអតីតយុទ្ធជនបានចំនួន ៧គ្រួសារ។ បានចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកងបានចំនួន១២លើក។ បានទទួលប័ណ្ណ ប.ស.ស ចំនួន១៩៨៥ ប័ណ្ណពីការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមខណ្ឌចំការមន។ បានសហការជាមួយ និងសង្កាត់ទាំង

៧ ចែកប័ណ្ណ ប.ស.ស ចំនួន ១៤១ប័ណ្ណ នៅសល់ចំនួន ៩៤៤ប័ណ្ណ។ បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីពង្រឹងការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំក្នុងអំឡុងពេលនៃការរីករាលដាលនៃជម្ងឺកូវីដ១៩ ក្រោមអធិបតីភាពឯកឧត្តម **នួន ផារ័ត្ន** អភិបាលរងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញបានចំនួន១លើក។ បានចុះអង្កេតរហ័សជនអនាថានៅតាមសង្កាត់ទាំង៧ ចំនួន២លើក។ បានសហការជាមួយអធិការ អធិការរងខណ្ឌបឹងកេងកង មេប៉ុស្តិ៍ ចៅសង្កាត់ទាំង៧ នាំគ្រួសារអតីតយុទ្ធជន ទៅចាក់វ៉ាក់សាំងកូវីដ១៩ នៅមន្ទីរពេទ្យកេតុមាលាបានចំនួន ៣លើក។ បានចូលរួមកម្មវិធីចែកអំណោយជូនចាស់ជរាចំនួន៩២គ្រួសារ ២លើក ក្រោមអធិបតីភាព លោក **ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកងនៅសាលាខណ្ឌបឹងកេងកង។ បានសហការជាមួយនិងក្រសួង ស.អ.យ មន្ទីរ ស.អ.យ និងសង្កាត់ទួលស្វាយព្រៃទី១ ក្នុងការចុះពិនិត្យអង្គការកុមារអាស៊ីដើម្បីផ្តល់ការគាំទ្របន្ត MOUបានចំនួន៤លើក។ បានចូលរួមជាមួយរដ្ឋបាលខណ្ឌចុះផ្សព្វផ្សាយ និងសម្អាតបរិស្ថាននៅតាមបណ្តាសង្កាត់ទាំង៧ក្នុងមូលដ្ឋានខណ្ឌបឹងកេងកងបានចំនួន ១លើក។ បានសហការជាមួយនឹងសង្កាត់ទាំង៧ ចុះអនុវត្តសម្ភាស៍ជនពិការភាពបានលទ្ធផល ជារបាយការណ៍បឋម បឹងកេងកងទី១ បានចំនួន២នាក់ បឹងកេងកងទី២ បានចំនួន ៤១នាក់ បឹងកេងកងទី៣ បានចំនួន ៥០នាក់ ទួលស្វាយព្រៃទី១ បានចំនួន ៣នាក់ ទួលស្វាយព្រៃទី២ បានចំនួន ៧នាក់ អូឡាំពិកបានចំនួន ១៧នាក់ ទំនប់ទឹកបានចំនួន ៩៦ នាក់ ចំនួនសរុប ២១៦នាក់ បានចំនួន ១លើក។ បានសហការជាមួយក្រសួង ស.អ.យ មន្ទីរ ស.អ.យ និងអធិការដ្ឋាននរគបាលខណ្ឌ ធ្វើបច្ចុប្បន្នភាពសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា តាមបណ្តាសង្កាត់ទាំង៧ បានចំនួន៣៧៨នាក់ បានចំនួន ១លើក។ បានចូលរួមប្រចាំការនៅតាមមណ្ឌលចាក់វ៉ាក់សាំង ជូនកុមារមានអាយុ ៥ឆ្នាំ។ ចូលរួមប្រចាំការវេនយាម ២៤ម៉ោង លើ២៤ម៉ោង ទៅតាមគោលដៅ តាមការដឹកនាំរបស់លោកអភិបាលខណ្ឌ។ បានចូលរួមកិច្ចប្រជុំស្តីពី វគ្គបណ្តុះបណ្តាលយុទ្ធសាស្ត្រទាំងពីរ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងការពារកុមារ ព្រមទាំងការថែទាំជំនួសបានចំនួន ២លើក។ បានសហការជាមួយសង្កាត់ទាំង៧ ធ្វើការទំនាក់ទំនងជាមួយគ្រួសារសព (តំណាងគ្រួសារសព) ដើម្បីបើកប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល។ ចូលរួមកិច្ចប្រជុំស្តីពី កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ដើម្បី បើកប្រាក់ឧបត្ថម្ភជូនគ្រួសារសព ដែលស្លាប់ដោយសារជំងឺកូវីដ១៩ នៅក្នុងតំបន់រាជធានីភ្នំពេញ ក្រោមអធិបតីភាព លោកស្រី **មុំ ចាន់ដានី** ប្រធានមន្ទីរ ស.អ.យ រាជធានីភ្នំពេញ ចំនួន ១លើក។

- **វិស័យកិច្ចការនារី**

បានចូលរួមវេទិកាផ្សព្វផ្សាយស្តីពី «ទំនៀមទម្លាប់ប្រពៃណី សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ» ក្រោមអធិបតីភាពឯកឧត្តម **ផន ដាវី** សមាជិកក្រុមប្រឹក្សារាជធានីលោកស្រី **កាន់ រតនឧប្បល** ប្រធានមន្ទីរ

កិច្ចការនារី រាជធានីភ្នំពេញ ចំនួន១លើក មានសមាជិកចូលរួមសរុបចំនួន ១២០នាក់ ស្រីចំនួន ៨០នាក់។ បានចូលរួមផ្សព្វផ្សាយណែនាំ រាល់វិធានការរបស់ក្រសួងសុខាភិបាលស្តីអំពី ការការពារជម្ងឺកូវីដ១៩ នៅតាមសង្កាត់ទាំង៧ ជាប្រចាំ។ បានចូលរួមផ្សព្វផ្សាយដល់ស្ត្រីទើបសម្រាលកូន ទៅចុះបញ្ជីអត្រានុកូលដ្ឋានក្នុងរយៈពេល ៣០ថ្ងៃ ក្រោយកំណើតបានចំនួន ៧លើក នៅក្នុងសង្កាត់ទាំង៧។ បានបំពេញបែបបទជូនគ្រួសារក្រីក្រដើម្បីរៀនជំនាញ ឆុងកាហ្វេ អ៊ុតសក់ និងជួសជុល ឡាន ម៉ូតូ បានចំនួន៩នាក់ ស្រីចំនួន១នាក់។ បានចូលរួមចែកអំណោយរបស់ ឯកឧត្តម **ហ៊ុន ម៉ាណែត** និងលោកជំទាវ **ពេជ្រ ចន្ទមុន្នី** ជូនដល់ប្រជាពលរដ្ឋដែលកំពុងធ្វើចត្តាឡីស័កបានសរុបចំនួន១០៩គ្រួសារ អំណោយអង្ករចំនួន២៥គីឡូក្រាម ទឹកស៊ីអ៊ីវចំនួន ១យួរ ម៉ាសចំនួន១០ ទឹកសុទ្ធចំនួន១កេស ស្ករសចំនួន១គីឡូក្រាម និងថ្នាំពេទ្យចំនួន១កញ្ចប់។ បានសហការជាមួយអ្នកទទួលបន្ទុកកិច្ចនារីសង្កាត់ទាំង៧ ដើម្បីស្រង់ស្ថិតិកុមារ អាយុក្រោម ១៨ឆ្នាំ ដែលឆ្លងជម្ងឺកូវីដ១៩ មានចំនួនសរុប ៤៨នាក់។ បានសហការជាមួយ អ.ក.ន.ក សង្កាត់អូឡាំពិក ចូលរួមកម្មវិធីផ្តល់អាហារករណ៍សិស្សថ្នាក់បឋមសិក្សាវត្តមហាមន្ត្រី ចំនួន ២២នាក់ ក្នុងមួយនាក់ទទួលបានថវិកាចំនួន ១៦០០០០រៀល ក្រោមការឧបត្ថម្ភរបស់រាជរដ្ឋាភិបាល។ បានសហការជាមួយនឹង អ.ក.ន.ក សង្កាត់ទាំង៧ ចុះសួរសុខទុក្ខគ្រួសារ ធ្វើចត្តាឡីស័កចំនួន៤ គ្រួសារ និងឧបត្ថម្ភ ១គ្រួសារ អង្ករចំនួន២០គីឡូក្រាម មីចំនួន ១កេស ទឹកត្រីចំនួន ២យួរ។ បានសហការជាមួយនិងសង្កាត់ទាំង៧ ចែកបន្លែ សាច់ជ្រូក អង្ករ ពងមាន់ និងគ្រឿងបរិភោគ ឧបភោគ មួយចំនួនដែលជាអំណោយរបស់ លោក **ធឹម សំអាន** អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង ជូនដល់ប្រជាពលរដ្ឋក្នុងកំឡុងពេលបិទខ្ទប់បាន ចំនួន១២១៩គ្រួសារ។ បានសហការជាមួយ អ.ក.ន.ក សង្កាត់ទាំង៧ ចូលរួមសម្របសម្រួលរៀបចំឯកសារ បំពេញបែបបទជូនគ្រួសារដែលមានជីវភាពខ្វះខាត ក្នុងកំឡុងពេលបិទខ្ទប់ដើម្បីបើកថវិការបស់រាជរដ្ឋាភិបាលកម្ពុជា បានចំនួន៥លើក។ លោកស្រី **ម៉ែន សុភាវី** ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង បានចូលរួមចែកអំណោយ ដល់សមាជិកសមាគមមនុស្សចាស់ជាសង្កាត់ទាំង៧ ចំនួន ៩១នាក់ ចំនួន ២លើក ក្រោមអធិបតីភាព លោក **គឹម ឈុនអ៊ូ** ប្រធានក្រុមប្រឹក្សាខណ្ឌ និងលោក **ធឹម សំអាន** អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង។ បានសហការជាមួយនិងសង្កាត់ទាំង៧ ចុះសួរសុខទុក្ខស្ត្រីក្រីក្រ គ្មានទីពឹង និងចាស់ជរាសរុបបានចំនួន៥១នាក់ ឧបត្ថម្ភថវិកាសរុបចំនួន១,៤៥០,០០០រៀល អង្ករ១០០០គីឡូក្រាម និងឃីតបាន៥១កញ្ចប់។

### ៣.៣.៣. វិស័យផ្សេងៗទៀត

#### ៣.៣.៣.១. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ចូលរួមចុះរៀបចំសណ្តាប់ធ្នាប់ នៅតាមបណ្តាផ្លូវផ្សេងៗ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។ ចុះរៀបចំសណ្តាប់ធ្នាប់លើបណ្តោយផ្លូវ២៧១ មុខមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត និងដាក់កម្លាំងប្រចាំការរៀបចំអ្នកលក់ដូរ

តាមរទេះដែលដាក់លក់មុខមន្ទីរពេទ្យ។ ដាក់កម្លាំងប្រចាំការតាមមណ្ឌលចាក់វ៉ាក់សាំងជាប្រចាំទាំង ៨ មណ្ឌល។ ចុះល្បាតក្នុងភូមិសាស្ត្រសង្កាត់ទាំង៧ដើម្បីទប់ស្កាត់ការជួបជុំ ចាក់ភ្លេង និងបញ្ហាផ្សេងៗ។ ចូលរួមពិធីទទួលអំណោយជាអង្ករចំនួន ១០តោន ពីកាកបាទក្រហមរាជធានីភ្នំពេញ។ ចូលរួមចែកអំណោយកាកបាទក្រហមដល់គ្រួសារសពជនរងគ្រោះ ដែលទទួលរងអគ្គីភ័យឆាបឆេះនៅបរិវេនវត្តស្ទឹងមានជ័យ ក្រោមអធិបតីភាពលោកស្រី **ស៊ិន រតនា** អភិបាលរងខណ្ឌបឹងកេងកង បានចូលរួមសំណេះសំណាល រួមទាំងបានសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះ ដោយអគ្គីភ័យចំនួន១០គ្រួសារនៅផ្លូវលេខ៣៤៨ សង្កាត់ទួលស្វាយព្រៃទី១ ក្រោមអធិបតីភាព លោក **ធឹម សំអាន** អភិបាលខណ្ឌបឹងកេងកង។ ចុះអប់រំផ្សព្វផ្សាយទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ១៩ ក្នុងព្រឹត្តិការណ៍ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានខណ្ឌបឹងកេងកងជាប្រចាំ។ ចុះពិនិត្យតាមគោលដៅចត្តាឡីស័កក្នុងមូលដ្ឋានខណ្ឌបឹងកេងកងជាប្រចាំ។ ចូលរួមវេនយាមប្រចាំការ២៤លើ២៤ម៉ោង។ ចុះសម្របសម្រួលដំណើរការចាក់វ៉ាក់សាំងការពារវីរុសកូវីដ១៩។ បានចូលរួមក្នុងយុទ្ធនាការបំរាមគោចរ ពីម៉ោង២០ ដល់ម៉ោង ៣ទៀបភ្លឺក្រោមអធិបតីភាព លោក **ហេង ពិសិដ្ឋ** និងលោក **គឹមណៃ វីរៈខេមា** អភិបាលរងខណ្ឌបឹងកេងកង។ ចុះផ្អាកជាបណ្តោះអាសន្នផ្សារដែលមិនមានរបៀបរៀបរយ នៅលើផ្លូវលេខ៣១០ និងផ្លូវលេខ១៩៣ សង្កាត់អូឡាំពិក ផ្លូវលេខ១១៣ ផ្សារលើលូ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ១៩។ ចុះសម្របសម្រួលដល់ការយកសំណាករបស់ប្រជាពលរដ្ឋ អាជីវករផ្សារបឹងកេងកង និងអ្នកពាក់ព័ន្ធនៅវិទ្យាល័យជាស៊ីមបឹងកេងកង អាជីវករនៅផ្សារអូឡាំពិក និងអ្នកពាក់ព័ន្ធនៅវិទ្យាល័យទួលស្វាយព្រៃ។ ចុះស្តាបស្ទង់មតិប្រជាពលរដ្ឋដែលកំពង់ធ្វើចត្តាឡីស័ក និងពិនិត្យសំណាកថ្ងៃចុងក្រោយនៅវិទ្យាល័យជាស៊ីមបឹងកេងកងក្រោមអធិបតីភាព លោក **ធឹម សំអាន** អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង។ ចូលរួមសម្របសម្រួលក្នុងការចាក់វ៉ាក់សាំងការពារជម្ងឺកូវីដ១៩ នៅមណ្ឌលសុខភាពទួលស្វាយព្រៃ។

### ៣.១.៣.២. ការបង្ក្រាបបទល្មើស ក្មេងទំនើង និងល្បែងស៊ីសង ការប្រើប្រាស់អាវុធខុសច្បាប់

#### ក. ការបង្ក្រាបបទល្មើស

ការបង្ក្រាបបទល្មើសព្រហ្មទណ្ឌៈ សរុបបានចំនួន ៤១លើក ឃាត់ខ្លួនជនសង្ស័យ ៦០នាក់ ប្រុស,ស្រី ៣នាក់។

- បទល្មើសឧក្រិដ្ឋ បាន ៥លើក ឃាត់ខ្លួនសរុបចំនួន ៨នាក់
- បទល្មើសមជ្ឈឹម បាន៣៦លើក ឃាត់ខ្លួនសរុបបានចំនួន ៥២នាក់ ស្រីចំនួន ៣នាក់
- ការបង្ក្រាបបទល្មើសគ្រឿងញៀនបានចំនួន ២លើក សរុប ១០លើកឃាត់ខ្លួនសរុបបានចំនួន ១៧នាក់ ស្រីចំនួន១នាក់។

**ខ. ការបង្ក្រាបក្មេងទំនើង**

ការបង្ក្រាបក្មេងទំនើងបានចំនួន ១៧លើក ឃាត់ខ្លួនបានចំនួន ៣១នាក់ ស្រីចំនួន ២នាក់

**គ. ការបង្ក្រាបការលេងល្បែងស៊ីសង ការប្រើប្រាស់អាវុធខុសច្បាប់**

មានតែមួយលើក នៅក្នុងសង្កាត់បឹងកេងទី២តែប៉ុណ្ណោះ។

**៣.១.៣.៣. ការចុះត្រួតពិនិត្យ និងរឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍**

**ការចុះត្រួតពិនិត្យ និងរឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក (ពេលថ្ងៃ) បានចំនួន៤៩លើក ៧ គោលដៅៈ**

- ឃាត់យានយន្តល្មើសច្បាប់ចរាចរណ៍សរុបបានចំនួន ៥,៦៤៨គ្រឿង
- ឃាត់បានរថយន្តចំនួន ១,៣៧២គ្រឿងមាន មិនបានពាក់ខ្សែក្រវ៉ាត់ ចំនួន ៨៥១នាក់, ប្រើប្រាស់ទូរសព្ទបានចំនួន ៥១៩នាក់ និងមិនគោរពផ្លាកសញ្ញាបានចំនួន ២គ្រឿង។
- ឃាត់ម៉ូតូសរុបចំនួន ៤,២៧៦ គ្រឿងមាន, បើកបរមិនពាក់មួកសុវត្ថិភាពបានចំនួន ៣,៩៧០នាក់, ប្រើប្រាស់ទូរសព្ទបានចំនួន ៣០០នាក់, ម៉ូតូគ្មានស្លាកលេខបានចំនួន ៥គ្រឿង និងមិនគោរពផ្លាកសញ្ញាបានចំនួន ១គ្រឿង។
- លទ្ធផលធ្វើការផាកពិន័យនៅអធិការដ្ឋានខណ្ឌសរុបអ្នកបើកបរបានចំនួន ៥,៦៤៨នាក់។

**ការរឹតបន្តឹងច្បាប់ចរាចរណ៍ផ្លូវគោក ត្រួតពិនិត្យជាតិអាកុល និងអាវុធជាតិផ្ទុះ (ពេលយប់)៖ ១៨៨លើក**

ឃាត់យានយន្តឆ្លងកាត់គោលដៅត្រួតពិនិត្យសរុបបានចំនួន៩,០៩៤គ្រឿង

- ឃាត់រថយន្តបានចំនួន ៤៥៨គ្រឿងមាន មិនពាក់ខ្សែក្រវ៉ាត់បានចំនួន ៣៤៧នាក់, ប្រើប្រាស់ទូរសព្ទបានចំនួន ៩៤នាក់, គ្មានប័ណ្ណបើកបរបានចំនួន ១នាក់, មិនគោរពស្លាកសញ្ញាបានចំនួន ១គ្រឿង, រថយន្តគ្មានស្លាកលេខបានចំនួន ២គ្រឿង និងអ្នកបើកបរមានជាតិស្រវឹងបានចំនួន ៨នាក់ បញ្ជូនទៅចរាចរណ៍ក្រុងចំនួន ៥នាក់។
- ឃាត់ម៉ូតូសរុបចំនួន ៨,៦៣៦គ្រឿងមាន បើកបរមិនពាក់មួកសុវត្ថិភាពចំនួន ៨,៤៥៨នាក់, បើកម៉ូតប្រើប្រាស់ទូរសព្ទចំនួន ៦៧នាក់, គ្មានស្លាកលេខបានចំនួន ១៤គ្រឿង, មិនគោរពស្លាកសញ្ញានិងចរាចរណ៍បានចំនួន ៣៥នាក់, ឃាត់អ្នកប្រើប្រាស់ទូរសព្ទបានចំនួន ៥៧នាក់, គ្មានស្លាកលេខបានចំនួន ១៤គ្រឿង មិនគោរពស្លាកសញ្ញា បានចំនួន៣៥គ្រឿង និងឃាត់អ្នកបើកបរមានជាតិស្រវឹងបានចំនួន ៣៥នាក់ បញ្ជូនទៅចរាចរណ៍ក្រុងបានចំនួន ២៧នាក់។
- ធ្វើការផាកពិន័យនៅអធិការដ្ឋានខណ្ឌសរុបអ្នកបើកបរបានចំនួន ៩,០៩៤នាក់

- សហការត្រួតពិនិត្យអាវុធជាតិផ្ទុះ ជាមួយគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកងបានចំនួន ៣៣លើក និង ៣គោលដៅ
- យានយន្តឆ្លងកាត់បានចំនួន ៣,៤៩៣គ្រឿង, រថយន្តបានចំនួន ១,៥៤៧គ្រឿង

**៣.១.៣.៤. ការងារសាធារណការ និងដឹកជញ្ជូន បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ**

ចុះពិនិត្យការជីកកប់បណ្តាញអគ្គិសនីនៅផ្លូវលេខ៣០២ ក្នុងសង្កាត់បឹងកេងកងទី១។ ចុះពិនិត្យការកាត់ខ្សែភ្លើង និងខ្សែកាបនៅផ្លូវលេខ២៩៤ ក្នុងសង្កាត់បឹងកេងកងទី១ ជាមួយលោកស្រីចៅសង្កាត់។ ចុះដោះស្រាយទំនាស់របស់ប្រជាពលរដ្ឋដែលនៅជិតខាងគ្នា ទាក់ទងផ្លូវចេញចូលនៅផ្លូវមហាវិថីព្រះមុនីវង្សក្នុងសង្កាត់បឹងកេងកងទី២ ជាមួយក្រុមការងារដែលមាន លោក **ហេង ពិសិដ្ឋ** គឺជាមេដឹកនាំ។ ចុះពិនិត្យការស្ទះអណ្តូងលូនៅផ្លូវលេខ ៣៥៨ ជាមួយលោកស្រី **ស៊ិន រតនា** អភិបាលរងខណ្ឌ។ ចូលរួមជួសជុលកំណាត់ផ្លូវលេខ ៣៦៤ សង្កាត់ទួលស្វាយព្រៃទី២។ ចូលរួមជួសជុលកំណាត់ផ្លូវលេខ១៩៩ កែងផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក។ ចុះត្រួតពិនិត្យស្លាកសញ្ញាចរាចរណ៍ នៅផ្លូវលេខ៣១០ សង្កាត់បឹងកេងកងទី១។ ចុះត្រួតពិនិត្យលូកកស្ទះនៅមហាវិថីព្រះសីហនុ សង្កាត់អូឡាំពិក។ ចុះត្រួតពិនិត្យការបើកការដ្ឋានចាក់កៅស៊ូអាស់ស្វាល់ផ្លូវលេខ៤០៤ នៅក្នុងសង្កាត់ទំនប់ទឹក។ ចុះត្រួតពិនិត្យការបើកការដ្ឋាន ចាក់កៅស៊ូអាស់ស្វាល់ផ្លូវបើកថ្មីក្នុងសង្កាត់ទំនប់ទឹក។ ចុះពិនិត្យការជីកដាក់លូនៅផ្លូវលេខ១៨៣ សង្កាត់ទំនប់ទឹក។ ចុះហាមឃាត់សំណង់សាងសង់ខុសប្លង់ នៅផ្លូវលេខ៤០២ សង្កាត់ទំនប់ទឹក។ ចុះត្រួតពិនិត្យការជីកខួងផ្លូវលេខ៥៨ និងចិញ្ចើមផ្លូវលេខ៣១០ ក្នុងសង្កាត់បឹងកេងកងទី១។ ចុះណែនាំហាងលក់ធូរ៉ែនយីហោស្រីមុំឱ្យអនុវត្តតាមសេចក្តីជូនដំណឹងលេខ០៦១ របស់រដ្ឋបាលខណ្ឌបឹងកេងកងឱ្យរុះរើសំយ៉ាប់ និងជញ្ជាំងដែលលយចូលមកលើចិញ្ចើមផ្លូវសាធារណៈ នៅក្នុងខណ្ឌបឹងកេងកង។ ចុះរៀបចំសណ្តាប់ធ្នាប់ និងបានកាប់ដើមឈើដែលដួលរលំដោយសារខ្យល់កន្ត្រាក់នៅផ្លូវលេខ២៨៤ សង្កាត់អូឡាំពិក។ ចុះណែនាំដល់ក្រុមហ៊ុនដឹកជញ្ជូននៅតាមបណ្តោយផ្លូវលេខ២១៧ ឱ្យចតយានយន្ត មានសណ្តាប់ធ្នាប់ ជៀសវាងការកកស្ទះដល់ការធ្វើដំណើររបស់អ្នកដទៃ។ ចុះពិនិត្យស្លាកសញ្ញាចរាចរណ៍។ ចុះពិនិត្យខ្សែបណ្តាញអគ្គិសនីខ្សែកាបអុបទិកក្នុងមូលដ្ឋាន។

**៣.២. បញ្ហាប្រឈម**

ដោយបានពិនិត្យនៅក្នុងសៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល របស់ខណ្ឌបឹងកេងកង និងបានចុះអង្កេតផ្ទាល់ដើម្បីបានស្វែងយល់អំពីស្ថានភាពរបស់ខណ្ឌបឹងកេងកងព្រម និងការជួបសម្ភាសន៍ផ្ទាល់ជាមួយមន្ត្រីដែលបានបំពេញការងារនៅក្នុងខណ្ឌ ដោយសង្កេតឃើញនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមនេះ៖

### ៣.២.១. ផ្នែកធនធានហិរញ្ញវត្ថុ

ថវិកា ជាផ្នែកមួយដ៏សំខាន់សម្រាប់ការទ្រទ្រង់ និងបំពេញតម្រូវការនៅក្នុងខណ្ឌបឹងកេងកងទាំងមូល ការចាត់ចែងថវិកា ការសិក្សា ការរៀបចំ និងការអនុវត្តគម្រោងនានា របស់ខណ្ឌបឹងកេងកង ជាការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល រួមទាំងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខណ្ឌ គឺជាភារកិច្ចរបស់ការិយាល័យផែនការ និងហិរញ្ញវត្ថុ ហើយថវិកានេះទៀតសោត ខណ្ឌបឹងកេងកងបានបែងចែកទៅឱ្យការិយាល័យនីមួយៗដែលចំណុះឱ្យខណ្ឌទាំងមូលក្នុងការប្រើប្រាស់ ហើយបានបែងចែកទៅឱ្យសង្កាត់ទាំងប្រាំពីរដែលចំណុះឱ្យខណ្ឌបឹងកេងកង ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខណ្ឌដើម្បីយកទៅប្រើប្រាស់ក្នុងការទិញសម្ភារៈ និងគ្រឿងបរិក្ខាទាំងឡាយដែលប្រើប្រាស់សម្រាប់បម្រើ ដល់សេវាសារធាណៈទាំងអស់ ចំណែលឯសង្កាត់វិញ គឺដើម្បីយកទៅអភិវឌ្ឍន៍ និងប្រើប្រាស់តាមតម្រូវការចាំបាច់នានាក្នុងនាមបម្រើផលប្រយោជន៍សាធារណៈ។ ជាក់ស្តែងថវិកា របស់ខណ្ឌបឹងកេងកងនៅមានកម្រិតនៅឡើយសម្រាប់បម្រើដំណើរការ និងការប្រព្រឹត្តរបស់ខណ្ឌបឹងកេងកងទាំងមូល។ ទាំងអស់នេះហើយ គឺជាបញ្ហាចោទមួយយ៉ាងធំសម្រាប់គោលដៅអភិវឌ្ឍន៍គ្រប់ផ្នែក និងគ្រប់វិស័យទាំងអស់ការជះឥទ្ធិពលផ្នែកហិរញ្ញវត្ថុធ្វើឱ្យមិនសូវមានភាពរីកចម្រើនលើគ្រប់ការិយាល័យទាំងអស់ និងសង្កាត់នៅក្នុងខណ្ឌបឹងកេងកង ឬអាចជាហេតុមកពីមានអំពើពុករលួយមួយចំនួនតូចផងដែរ។[55]

### ៣.២.២. ផ្នែកសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

នៅក្នុងខណ្ឌបឹងកេងកង ទោះបីជារដ្ឋបាលខណ្ឌបឹងកេងកង និងសង្កាត់ទាំង៧ បានខិតខំអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រេចបាននូវសមិទ្ធផលដ៏ធំយ៉ាងណាក៏ដោយ នៅតែមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវយកចិត្តទុកដាក់ និងត្រូវបន្តដោះស្រាយ ជាបន្តបន្ទាប់រួមមានដូចជាបញ្ហាគ្រឿងញៀន បញ្ហាក្មេងទំនើង បញ្ហាល្បែងស៊ីសង បញ្ហាអ្នកស្នាក់នៅបណ្តោះអាសន្ន និងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្រានុកូលដ្ឋាន និងការផ្តល់នូវសេវាផ្សេងៗជាច្រើនទៀតតាមរយៈការិយាល័យច្រកចេញចូលតែមួយ ហើយម្យ៉ាងវិញទៀតនូវមិនទាន់មានការចូលរួមពីប្រជាពលរដ្ឋបានល្អប្រសើរនៅឡើយ ទៅលើបញ្ហាញែកទុកដាក់ និងវេចខ្ចប់សម្រាមហើយនៅមានការបញ្ចេញសម្រាមខុសពេលវេលា និងការបោះចោលសម្រាមគ្មានសណ្តាប់ធ្នាប់ដោយអ្នកលក់ដូរចល័តតាមរទេះ រួមទាំងបញ្ហាអ្នករើសអេតចាយហែកធុងសម្រាមបណ្តាលឱ្យសម្រាមមានការរាយប៉ាយ។

[55] កិច្ចសម្ភាសជាមួយនិងអនុប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ នៅខណ្ឌបឹងកេងកង

### ៣.២.៣. ផ្នែកអប់រំ

នៅក្នុងខណ្ឌបឹងកេងកង ទោះបីជារដ្ឋបាលខណ្ឌបឹងកេងកង និងសង្កាត់ទាំង៧ បានខិតខំអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវសមិទ្ធផលយ៉ាងណាក៏ដោយ រួមទាំងមានគ្រឹះស្ថានសិក្សា យ៉ាងសម្បូរបែបក្តីនៅតែមានកុមារមួយចំនួនពុំបានរៀនចប់ទៅតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានតាមការកំណត់រយៈពេលសិក្សាយ៉ាងតិច៩ឆ្នាំបញ្ចប់ត្រឹមថ្នាក់ទី៩នៅឡើយទេ។ បញ្ហានេះ ដោយសារតែលោកឪពុក អ្នកម្តាយ រួមទាំងអ្នកអាណាព្យាបាលមួយចំនួនតូច មិនទាន់យល់ដឹងកាន់តែច្បាស់អំពីតម្លៃនៃការសិក្សា និងម៉្យាងវិញទៀតដោយសារកត្តាជីវភាពក្រីក្រ ខ្វះខាតផងនោះបាន ជម្រុញឱ្យកូនឈប់រៀន (ជាពិសេស គឺកុមារី) ដើម្បីជួយរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។ ទោះបីបានជួបប្រទះនូវបញ្ហាប្រឈមខ្លះៗក្តី ក៏រដ្ឋបាលខណ្ឌបានខិតខំអប់រំដល់ គ្រួសារប្រជាពលរដ្ឋទាំងនោះដោយសហការជាមួយការិយាល័យអប់រំខណ្ឌ និងគណៈកម្មាធិការកិច្ចការនារី កុមារ ក្នុងសង្កាត់ចុះឱ្យដល់លំនៅឋានសិស្សដែលបានបោះបង់ការសិក្សា ពន្យល់ណែនាំរួមទាំងលើកទឹកចិត្តដោយជួយឧបត្ថម្ភ ដូចជាសម្ភារៈសិក្សា និងសម្ភារៈ ប្រើប្រាស់មួយចំនួនឱ្យពួកគាត់បានចូលរៀនជាធម្មតាវិញ។

### ៣.២.៤. ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

នៅក្នុងខណ្ឌបឹងកេងកង ទោះបីជារដ្ឋបាលខណ្ឌបឹងកេងកង និងសង្កាត់ទាំង៧ បានខិតខំអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីសម្រេចបាននូវសមិទ្ធផលដ៏ធំយ៉ាងណាក៏ដោយនៅតែមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវយកចិត្តទុកដាក់ ដែលមានដូចជា ថែទាំជួសជុលផ្លូវដែលមានផ្លូវសំបុកមាន់ជាប្រចាំ និងចាក់បេតុងឆ្អឹងដែក ឬចាក់អ៊ុតកៅស៊ូបេទីមីណើឡើងវិញ ព្រមទាំងពង្រឹងនូវវិធានការត្រួតពិនិត្យបទល្មើសរថយន្តដឹកលើសទម្ងន់ ការតាំងលក់ផលិតផលនៅលើដងវិថី និងចិញ្ចើមផ្លូវដែលប៉ះពាល់ទៅដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងអ្នកថ្មើរជើងធ្វើដំណើរផងដែរមិនតែប៉ុណ្ណោះក៏នៅមានច្រកផ្លូវមួយចំនួនត្រូវបានប្រជាពលរដ្ឋសាងសង់លំនៅឋានថែមទៀតផង។

### ៣.២.៥. ផ្នែកសុខាភិបាល និងបរិស្ថាន

នៅក្នុងខណ្ឌបឹងកេងកង ទោះបីជារដ្ឋបាលខណ្ឌបឹងកេងកង និងសង្កាត់ទាំង៧ បានខិតខំអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវសមិទ្ធផលដ៏ធំយ៉ាងណាក៏ដោយនៅតែមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវយកចិត្តទុកដាក់ ផ្នែកសុខាភិបាលដែលមានដូចជាការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាក់ទងនិងបញ្ហាសុខភាព និងការទទួលសេវារដ្ឋដែលមានតម្លៃសមរម្យប្រជាពលរដ្ឋមានការយល់ដឹងខាងផ្នែកសុខាភិបាលនៅមានកម្រិត ហើយការទំនាក់ទំនងនៅកន្លែងខ្លះនៅ

មានកម្រិតដូចជាការផ្សព្វផ្សាយដល់សិស្សស្ដីពី អនាម័យស្អាតបី អនាម័យលំនៅដ្ឋាននៅមានកម្រិត និងពុំមានដៃគូជួយគាំទ្រ។

### ៣.២.៦. ផ្នែកវប្បធម៌ និងព័ត៌មាន

នៅក្នុងខណ្ឌបឹងកេងកង ទោះបីជារដ្ឋបាលខណ្ឌបឹងកេងកង និងសង្កាត់ទាំង៧ បានខិតខំអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីសម្រេចបាននូវសមិទ្ធផលដ៏ធំយ៉ាងណាក៏ដោយហើយមួយវិញទៀតថ្វីត្បិតតែមុខរបរនេះបានចូលរួមចំណែកធ្វើឱ្យប្រជាពលរដ្ឋមានជីវភាពធូរធារក៏ដោយយើងពិនិត្យឃើញនូវចំណុចអវិជ្ជមានមួយចំនួនដែលរដ្ឋបាលខណ្ឌបឹងកេងកង គឺត្រូវតែយកចិត្តទុកដាក់ខ្ពស់នៅក្នុងការលុបបំបាត់ឱ្យបាននូវរាល់ចរាចរស៊ីឌី(CD) វីស៊ីឌី(VCD) និងឌីវីឌី(DVD) នៅលើទីផ្សារគ្មានទិដ្ឋាការ ឬច្បាប់អនុញ្ញាតពីអង្គភាពជំនាញដែលបានរំលោភលើច្បាប់កម្មសិទ្ធិបញ្ញា ហើយនៅតាមហាងកាហ្វេមួយចំនួនតែងតែមានការលួចលាក់ចាក់បញ្ចាំងវីដេអូ អាសអាភាសដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ទំនៀមទម្លាប់ ប្រពៃណី សីលធម៌ សង្គម និងតម្លៃស្ត្រីខ្មែរ។

### ៣.២.៧. ផ្នែកការងារផែនការ និងអភិវឌ្ឍន៍

នៅក្នុងខណ្ឌបឹងកេងកងទោះបីជារដ្ឋបាលខណ្ឌបឹងកេងកង និងសង្កាត់ទាំង៧ គឺបានខិតខំអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីសម្រេចបាននូវសមិទ្ធផលធំយ៉ាងណា គឺនៅតែមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវយកចិត្តទុកដាក់ដែលបញ្ហាប្រឈមទាំងនោះ រួមមានដូចជាទាក់ទងទិន្នន័យមួយចំនួនមានភាពមិនទាន់ច្បាស់លាស់ និងអនុវត្តមិនទាន់ពេលវេលាកំណត់ដែលជាហេតុបណ្ដាលឱ្យការវិភាគទិន្នន័យមិនបានគ្រប់ជ្រុងជ្រោយ។ ដោយឡែកនៅតាមការិយាល័យ ឬអង្គភាពចំណុះរបស់រដ្ឋបាលខណ្ឌបឹងកេងកងនៅមិនទាន់យល់ច្បាស់អំពីនីតិវិធីក្នុងការស្រង់ព័ត៌មាននៅឡើយនោះទេ។

### ៣.២.៨. ផ្នែកសង្គមកិច្ច

នៅក្នុងខណ្ឌបឹងកេងកង ទោះបីជារដ្ឋបាលខណ្ឌបឹងកេងកង និងសង្កាត់ទាំង៧ បានខិតខំអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីសម្រេចបាននូវសមិទ្ធផលដ៏ធំយ៉ាងណានៅតែមានប្រជាពលរដ្ឋមួយចំនួនបានសាងសង់លំនៅឋានលើចិញ្ចើមផ្លូវ និងនៅលើដីសាធារណៈ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់កិត្យានុភាព និងសេចក្ដីថ្លៃថ្នូររបស់រាជធានីដូចជាប្រទេសជាតិផងដែរ។

## ៣.៤. ទិសដៅអនាគត

### ៣.៤.១. ការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

បន្ទាប់ពីការអនុវត្តការងារផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅអាណត្តិទី៥ ឆ្នាំ២០២១ សាលាខណ្ឌបឹងកេងកងមានទិសដៅការងារជាអាទិភាពសម្រាប់ឆ្នាំ២០២២ មានដូចជា៖

- បន្តរៀបចំសណ្តាប់ធ្នាប់តាមទីសាធារណៈ និងផ្លូវសំខាន់ៗឱ្យបានល្អ
- ចុះពិនិត្យការដ្ឋានសំណង់ ទប់ស្កាត់សំណង់គ្មានច្បាប់អនុញ្ញាត និងសំណង់ខុសប្លង់
- ចុះជម្រុញមូលដ្ឋានសិប្បកម្មផលិតស្បៀងអាហារ ភេសជ្ជៈ អំពីគុណភាពផលិត
- បន្តចុះពិនិត្យ និងជម្រុញម្ចាស់អាជីវកម្មដ្ឋានទេសចរណ៍ដែលអស់សុពលភាពរួមទាំងកើតថ្មីឱ្យចូលមកបំពេញបែបបទដើម្បីសុំអាជ្ញាប័ណ្ណទេសចរណ៍ប្រកបអាជីវកម្មឱ្យបានត្រឹមត្រូវ។

### ៣.៤.២. ពង្រឹងផ្នែកសណ្តាប់ធ្នាប់សាធារណៈ

បន្ទាប់ពីការអនុវត្តការងារផ្នែកសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងឆ្នាំ២០២១ បានរួចមក សាលាខណ្ឌបឹងកេងកងមានទិសដៅការងារជាអាទិភាពសម្រាប់អាណត្តិទី៥ ក្នុងឆ្នាំ២០២២ ដូចខាងក្រោមនេះ៖

- បន្តកាត់បន្ថយជនអនាថាតាមចិញ្ចើមផ្លូវ និងទីសាធារណៈ
- បន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីអំពីសីលធម៌ តម្លៃស្ត្រី និងគ្រួសារខ្មែរ
- បន្តការអប់រំ និងដាក់ពិន័យអ្នកបោះចោលសម្រាមគ្មានសណ្តាប់ធ្នាប់
- ពង្រឹងការគ្រប់គ្រងអាជីវកម្មមណ្ឌលកំសាន្តមនុស្សពេញវ័យ
- បន្តជម្រុញ និងណែនាំម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ឱ្យកត់ត្រាអត្តសញ្ញាណ ភ្ញៀវស្នាក់នៅប្រចាំថ្ងៃសំដៅពង្រឹងការគ្រប់គ្រងស្ថិតិភ្ញៀវឱ្យបានច្បាស់លាស់ និងការពារសន្តិសុខ សុវត្ថិភាពភ្ញៀវទេសចរណ៍ជាតិ និងភ្ញៀវអន្តរជាតិ
- ជម្រុញការងារសហការជាមួយក្រុមហ៊ុនប្រមូលសម្រាម ក្នុងការប្រមូលសម្រាម
- សហការជាមួយនិងមន្ទីរការងារជម្រុញដល់សហគ្រាសធុនតូច មធ្យម ឱ្យលើកលក្ខខណ្ឌការងារ និងសន្តិសុខ សុវត្ថិភាពការងាររបស់កម្មករនិយោជិត តាមសហគ្រាស និងគ្រឹះស្ថាន
- សហការជាមួយនិងមន្ទីរបរិស្ថានរាជធានីភ្នំពេញ ត្រួតពិនិត្យការបំពុលបរិស្ថាន។

### ៣.៤.៣. យន្តការសេវាសាធារណៈ

បន្ទាប់ពីការអនុវត្តការងារផ្នែកសេវាសាធារណៈ ក្នុងអាណត្តិទី៥ ឆ្នាំ២០២១ សាលាខណ្ឌបឹងកេងកងមានទិសដៅការងារជាអាទិភាពក្នុងឆ្នាំ២០២២

- បន្តការដោះស្រាយបញ្ហាអត្រានុកូលដ្ឋាន (ការកោសលុប)
- តាមដានការអនុវត្តការងាររបស់សង្កាត់ដែលចុះធ្វើអនាម័យរៀងរាល់សប្តាហ៍
- រៀបចំយុទ្ធនាការចាក់វ៉ាក់សាំង ដូសទី៣ និងដូសទី៤ ដល់កុមារអាយុ ១៥ឆ្នាំ ដល់១៨ឆ្នាំ
- អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីអំពីនីតិវិធី អត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងកំឡុងពេលវិបត្តិកូវីដ១៩
- តាមដានការអនុវត្តគម្រោងមូលនិធិរបស់សង្កាត់ទាំង៧
- បន្តចុះផ្សព្វផ្សាយវិធានការការពារជម្ងឺកូវីដ១៩ និងចែកជូនសម្ភារៈការពារជម្ងឺកូវីដ១៩ ព្រមទាំងគ្រឿងឧបភោគបរិភោគជូនដល់ប្រជាពលរដ្ឋក្រីក្រនៅមូលដ្ឋានខណ្ឌបឹងកេងកង
- សហការជាមួយនិងមន្ទីរការងារ ជម្រុញការគ្រប់គ្រងស្ថិតិសាលាបណ្តុះបណ្តាលវិជ្ជាជីវៈឯកជន ដែលមានកម្មវិធី បណ្តុះបណ្តាល ៣ខែចុះឱ្យបានច្បាស់លាស់
- រៀបចំវេទិការសាធារណៈអនុវត្តនូវគោលនយោបាយ ភូមិ សង្កាត់ មានសុវត្ថិភាព។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «**ការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកង ក្នុងឆ្នាំ២០២១**» នាងខ្ញុំអាចសន្និដ្ឋានបានថា ការគ្រប់គ្រងរដ្ឋបាលរបស់ខណ្ឌបឹងកេងកង គឺមានដំណើរការប្រព្រឹត្តិទៅយ៉ាងរលូន មានភាពល្អប្រសើរ និងប្រកបដោយភាពរស់រវើក ទាំងសកម្មភាពការងាររបស់ក្រុមប្រឹក្សា របស់គណៈអភិបាល ការិយាល័យ និងអង្គភាពចំណុះទាំងអស់ រួទាំងសកម្មភាពរបស់មន្ត្រី និងបុគ្គលិកដែលបានបម្រើការងារនៅសាលាខណ្ឌបឹងកេងកងផងដែរ។

ជាក់ស្តែងរដ្ឋបាលខណ្ឌបឹងកេងកង គឺជានីតិបុគ្គល នៃនីតិសាធារណៈដែលមានតួនាទីសំខាន់ៗដូចជាបម្រើផលប្រយោជន៍មូលដ្ឋាន (សង្កាត់ទាំង៧) និងជាភ្នាក់ងារតំណាងឱ្យរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។ រដ្ឋបាលខណ្ឌបឹងកេងកងត្រូវបានដឹកនាំ និងគ្រប់គ្រងដោយមានក្រុមប្រឹក្សាចំនួន១៧រូប មានប្រធានមួយរូប និងមានគណៈអភិបាលចំនួន៥រូប ដោយមានអភិបាលមួយរូប និងមានអភិបាលរងចំនួន៤រូប ស្រី១រូប។ នាងខ្ញុំសង្កេតឃើញថា រដ្ឋបាលខណ្ឌបឹងកេងកងបានខិតខំប្រឹងប្រែងបំពេញការងារ ក្នុងការផ្តល់នូវសេវារដ្ឋបាលជូនដល់ប្រជាពលរដ្ឋឱ្យស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

ខណ្ឌបឹងកេងកងតែងតែគិតគូរអំពី សុខទុក្ខរបស់ប្រជាពលរដ្ឋ ដោយមានកិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការនានា កិច្ចប្រជុំរបស់គណៈអភិបាល ដើម្បីពិភាក្សា និងលើកផែនការ និងរិះរកឱ្យឃើញនូវបញ្ហា មូលហេតុនៃបញ្ហា ជាតម្រូវការចំបាច់ត្រូវតែយកមកដោះស្រាយឱ្យទាន់ពេលវេលា។ ហើយការដោះស្រាយបញ្ហាទាំងនោះដោះស្រាយនូវបញ្ហាជាអាទិភាព និងបញ្ហាបន្ទាប់បន្សំ។ ម្យ៉ាងវិញទៀតខណ្ឌបឹងកេងកងបានខិតខំជម្នះពុះពាររាល់ការលំបាកស្មុកស្មាញ និងអនុវត្តគ្រប់វិធានការចាត់តាំងគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពបានកាន់តែល្អ គ្រប់គ្រងសភាពការណ៍ សន្តិសុខ នៅក្នុងខណ្ឌ ក្នុងនោះរួមមានដូចជា សកម្មភាពដែលបានបង្កចលាចលនយោបាយ ទប់ស្កាត់មិនឱ្យមានអំពើប្លន់ប្រដាប់អាវុធ អំពើអានាចារ្យ អំពើអបាយមុខបង្កដោយក្មេងទំនើង ល្បែងស៊ីសង និងគ្រឿងញៀន ជាពិសេសខណ្ឌបឹងកេងបានចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់ការរីករាលដាននៃជំងឺកូវីដ១៩ ដោយអនុវត្ត នូវវិធានការយ៉ាងមត់ចត់ របស់ក្រសួងសុខាភិបាល (៣កុំ ៣ការពារ) ហើយខណ្ឌបឹងកេងបានចូលរួមក្នុងការចុះចែកអំណោយ ជូនដល់ប្រជាពលរដ្ឋដែលបានជាប់បិទខ្ទប់ក្នុងកំឡុងនៃការរីករាលដាលនៃជំងឺកូវីដ១៩ ដោយពុំខ្លាចនឿយហត់នោះទេជាពិសេស គឺបានផ្សព្វផ្សាយនូវវិធានការរបស់ក្រសួងសុខាភិបាលជូនដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងកាន់តែច្បាស់។ អ្វីដែលសំខាន់រដ្ឋបាលខណ្ឌបឹងកេងកងបានអនុវត្តមុខងាររបស់ខ្លួនស្របតាមគោលនយោបាយវិសហមជ្ឈការ និងវិមជ្ឈការរបស់រាជរដ្ឋាភិបាលដែលបានផ្ទេរ និងប្រគល់ នូវមុខងារ សិទ្ធិអំណាច ធនធាន (ថវិកា សម្ភារៈ និងធនធានមនុស្ស) ជូនដល់រដ្ឋបាល

ខណ្ឌបឹងកេងកង ដើម្បីបំពេញទៅតាមតម្រូវការរបស់មូលដ្ឋាន ប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ គោលនយោបាយវិសហមជ្ឈការ និងវិមជ្ឈការ ជាមគ្គុទេសយ៉ាងចំណានក្នុងការដឹកនាំរដ្ឋបាល ដើម្បីឈានទៅរកវឌ្ឍនភាព និងនិរន្តរភាពនៃការងាររបស់រដ្ឋបាលខណ្ឌ។ តាមរយៈនយោបាយវិសហមជ្ឈការ និងវិមជ្ឈការ បានធ្វើអោយរដ្ឋបាលខណ្ឌបឹងកេងកង បម្រើសេវាជូនដល់ប្រជាពលរដ្ឋយ៉ាងល្អប្រសើរ និងបានលើកកម្ពស់ជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានខណ្ឌនោះផ្ទាល់ផងដែរ ជាពិសេស គឺនៅកៀកជាមួយប្រជាពលរដ្ឋតែម្តងធ្វើឱ្យប្រជាពលរដ្ឋមានការទុកចិត្ត និងមានទំនុកចិត្តក្នុងការទទួលយកនូវសេវានៅមូលដ្ឋាន។

តាមលទ្ធផលការងាររបស់រដ្ឋបាលខណ្ឌបឹងកេងកង ក្នុងអាណត្តិទី៥ ឆ្នាំ២០២១ បានបង្ហាញនូវការអនុវត្តមុខងារ ជាអ្នកបម្រើកិច្ចការមូលដ្ឋាន និងប្រជាពលរដ្ឋ រួមទាំងមុខងារជាភ្នាក់ងាររដ្ឋ សុទ្ធសឹងតែមានសកម្មភាពទាំងអស់។ ទន្ទឹមនិងនេះរួមមានការងារ រដ្ឋបាល ស្ថិតិ ការងារសេដ្ឋកិច្ច សង្គមកិច្ច និងការដោះស្រាយបញ្ហាផ្សេងៗទៀត មានដំណើរការល្អទទួលយកបាន តែក៏មិនទាន់មានភាពល្អប្រសើរនៅឡើយទេ។ ហេតុនេះហើយ បានជារដ្ឋបាលខណ្ឌបឹងកេងកងខិតខំបំពេញការងារកាន់តែសកម្មបន្ថែមទៀត ទន្ទឹមការបំពេញការងារសព្វថ្ងៃ។

សាលាខណ្ឌបឹងកេងកង បើទោះបីជាអនុវត្តន៍ការងាររបស់ខ្លួនបានល្អយ៉ាងណាក្តី ប្រសិនបើខ្វះខាតការចូលរួមពីសំណាក់ដៃគូអភិវឌ្ឍន៍នានា និងប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋាននោះទេ ក៏មិនអាចធ្វើឱ្យខណ្ឌបឹងកេងកងមានការអភិវឌ្ឍខ្លាំងដែរ។ ដូច្នេះ ការអនុវត្តគោលនយោបាយវិសហមជ្ឈការ និងវិមជ្ឈការទាមទារឱ្យមានចលនានៃការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានផ្ទាល់ឱ្យបានមុតមាំ និងច្រើនកុះករ គឺតាមរយៈការយល់ឃើញច្បាស់លាស់ មានសុភវិនិច្ឆ័យទើបនយោបាយវិសហមជ្ឈការ និងវិមជ្ឈការនៅខណ្ឌបឹងកេងកងទទួលបានប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងសេចក្តីសន្និដ្ឋានខាងលើរួចមក នាងខ្ញុំសូមចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល និងអាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាហើយជាពិសេស គឺអាជ្ញាធរខណ្ឌបឹងកេងកងផ្ទាល់ក្នុងការថែរក្សា ការពារបូរណភាពទឹកដី ការគ្រប់គ្រងរដ្ឋបាលដែនដីជាពិសេសគឺ ពង្រឹងលើការអនុវត្តនយោបាយវិសហមជ្ឈការ និងវិមជ្ឈការដោយមានគំនិតមួយចំនួនៈ

- អាជ្ញាធររដ្ឋបាលខណ្ឌបឹងកេងកង គួរពង្រឹងការផ្តល់នូវសេវាសាធារណៈ ជូនប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់
- អាជ្ញាធររដ្ឋបាលខណ្ឌគួរតែពង្រឹងសមត្ថភាព ភាពច្នៃប្រឌិតក្នុងការងារ ពិសេសពង្រឹងការងារជាក្រុម
- សូមអាជ្ញាធរខណ្ឌបឹងកេងកងបើកវេទិការ ជាសាធារណៈឱ្យបានញឹកញាប់ ដើម្បីទទួលនូវបញ្ហាប្រឈមនានាដែលកើតមាននៅក្នុងខណ្ឌបឹងកេងកង
- សូមអាជ្ញាធរខណ្ឌបឹងកេងកង បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានខណ្ឌ ចំពោះបញ្ហាការចោលសម្រាម អនាម័យ បរិស្ថាន ជាពិសេសរួមគ្នាប្រយុទ្ធប្រឆាំងនឹងជំងឺកូវីត១៩ ឱ្យបានទូលំទូលាយដើម្បីសុខភាពរបស់ប្រជាពលរដ្ឋក្នុងការរស់នៅ
- សូមឱ្យខណ្ឌ និងសង្កាត់ទាំង៧ គួរតែចុះជួបប្រជាពលរដ្ឋ នៅតាមមូលដ្ឋាន ឱ្យបានញឹកញាប់ ដើម្បីដឹងពីសុខទុក្ខ និងតម្រូវការជាចាំបាច់របស់ប្រជាពលរដ្ឋ
- សូមឱ្យអាជ្ញាធរនៅខណ្ឌពន្យល់ណែនាំប្រជាពលរដ្ឋតាមគ្រប់រូបភាព ទាក់ទងការទទួលបានសេវាគ្រប់ផ្នែក តាមរយៈការិយាល័យច្រកចេញចូលតែមួយ ដែលមិនមានគិតតម្លៃ សេវាឱ្យបានទូលំទូលាយ
- សូមឱ្យនៅក្នុងខណ្ឌបឹងកេងកងគួរតែ មានការបន្ថែមមន្ត្រីនៅតាមការិយាល័យដែលមានការខ្វះខាត
- សូមឱ្យខណ្ឌស្នើសុំទៅខាងក្រុមហ៊ុន ស៊ិន ទ្រី លើការប្រមូលសម្រាមនៅតាមផ្សារនីមួយៗ ដែលស្ថិតនៅក្នុងខណ្ឌបឹងកេងកងព្រោះនៅពេលមានភ្លៀងធ្លាក់វាធ្វើឱ្យមានក្លិនអាក្រក់ជុំវិញផ្សារ ធ្វើឱ្យមានការកកស្ទះតាមបណ្តាលលូ ឬប្រឡាយនានា និងបាត់បង់សោភ័ណ្ឌភាពទីក្រុង
- ខណ្ឌគួរតែបង្កើនសកម្មភាព ក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើសមត្ថភាពការងាររបស់សង្កាត់ទាំង៧ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខណ្ឌ ដើម្បីធានាដល់កិច្ចអភិវឌ្ឍន៍ ឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព
- ក្រុមប្រឹក្សាគួរតែអនុម័តថវិកាបន្ថែមទៀតសម្រាប់ការចំណាយ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

# គន្លិឡេស

## គន្ថនិទ្ទេស


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨
- អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពីការបង្កើតខណ្ឌបឹងកេងកង ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩
- អនុក្រឹត្យលេខ២១៦ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- អនុក្រឹត្យលេខ៦៧៧ អនក្រ.តក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌបឹងកេងកង
- វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត
- របាយការណ៍ប្រចាំឆ្នាំ និងទិសដៅអនាគតរបស់ខណ្ឌបឹងកេងកងក្នុងឆ្នាំ២០២១
- សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌបឹងកេងកងឆ្នាំ២០២០ ដល់២០២២
- តារាងបែងចែកការងារ អភិបាល អភិបាលរងខណ្ឌបឹងកេងកង
- នីតិរដ្ឋបាល របស់ឧត្តមសិក្សាជាន់ខ្ពស់ ង៉ុយ ធឿន ឆ្នាំ២០១៧
- សៀវភៅស្តីពីស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា សាស្ត្រាចារ្យ ឥន យឿន ឆ្នាំ២០១៣
- នីតិរដ្ឋបាល បណ្ឌិត សុខ ទូច ឆ្នាំ២០០៩
- UNDP Practice: Public Administration Refor
- Organisation de la Cammune Cambodgienne, 1919
- https://www.khsearch.com/qna/16901

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១.

# ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧

# ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨

# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល
## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
## អំពីបទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.–**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**មាត្រា ៣.–**

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ហាទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.–**

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

**មាត្រា ៥.–**

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**មាត្រា ៦.–**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការកំណត់ព្រំប្រទល់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.–**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៨.–**

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

**មាត្រា ៩.–**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ ។

**មាត្រា ១០.–**

នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

**មាត្រា ១១.–**

នីតិបុគ្គលនីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១២.–**

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន :

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.-**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២
## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១
### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

**មាត្រា ១៦.-**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមាន សិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខ-ជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨.-**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិង កត្តាភូមិសាស្ត្រ ដូចខាងក្រោម :

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

**មាត្រា ១៩.-**

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២០.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២១.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានសញ្ជាតិខ្មែរពីកំណើត

-មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត

-មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ២២.-**

សមាជិកក្រុមប្រឹក្សាម្នាក់ ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីណាមួយ ដូចខាងក្រោម :

-សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

-សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពីពីរ(០២)ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬបទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណីដូចខាងលើនេះ ។

**មាត្រា ២៣.-**

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសក្នុងរយៈពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៤.-**

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សានោះឱ្យគោរព និងអនុវត្តបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់ និងសមហេតុផល ។

ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំសាយក្រុមប្រឹក្សានោះដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប" ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម ៖

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីររយសែសិប (២៤០) ថ្ងៃ

-ក្រុមប្រឹក្សាដែលត្រូវរំសាយតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០) ថ្ងៃ ។

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

**មាត្រា ២៦.-**

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

**មាត្រា ២៧.-**

ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

**មាត្រា ២៨.-**

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

**មាត្រា ២៩.-**

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ ។

**មាត្រា ៣០.-**

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ។

**មាត្រា ៣១.–**

ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត ។

**មាត្រា ៣២.–**

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា ស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ២ នៃច្បាប់នេះ ។

**មាត្រា ៣៣.–**

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្តីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ។

**មាត្រា ៣៤.–**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាលនិងអភិបាល ។

**មាត្រា ៣៥.–**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ។

**មាត្រា ៣៦.–**

រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬ ដីកាតាមការចាំបាច់ទាក់ទិនទៅនឹង :

-ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ

-កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

**មាត្រា ៣៧.-**

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ។

**មាត្រា ៣៨.-**

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ :

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

នីតិវិធីនៃការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣៩.-**

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ ដែលរួមមាន :

-ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន :

+ តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ

+ សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា

+ ការកាត់បន្ថយភាពក្រីក្រ

+ តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះរួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

-ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ

-ផែនការគ្រប់គ្រងគ្រោះមហន្តរាយ

-ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ(១២)ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី (៣)ឆ្នាំចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាពនិងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-សូចនាករបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាត្រូវកំណត់ឱ្យដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ។

បែបបទ នីតិវិធីជាក់ស្ដែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## មាត្រា ៤០.-

ក្រុមប្រឹក្សា ត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

-ក្រុមប្រឹក្សាប្រភេទរួមគ្នា

-ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា។

## មាត្រា ៤១.-

ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍបន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។

សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬ អាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម ។

## មាត្រា ៤២.-

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដែលផ្ដោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

-តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំសម្រាប់ទទួលមុខងារ ភារកិច្ច និងធនធានថ្មីៗ

-សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់

-ការកាត់បន្ថយភាពក្រីក្រ

-តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះដោយរួមបញ្ចូលទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

**មាត្រា ៤៣.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុ ឱ្យមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ៤៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់របស់ខ្លួន ដែលហៅកាត់ថាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។

ខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី ។

សង្កាត់ចំណុះក្រុង ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង ។

ក្រុមប្រឹក្សាត្រូវអនុម័តលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីនិងប្រតិទិននៃការកសាងថវិការដ្ឋជារៀងរាល់ឆ្នាំ ។

ក្រុមប្រឹក្សាត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

ការគ្រប់គ្រងនិងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ថវិកាត្រូវរៀបចំឡើងដោយគោរពតាមគោលការណ៍សំខាន់ៗទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែមានតុល្យភាពរវាងចំណូល និងចំណាយ ។

**មាត្រា ៤៥.-**

ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ ក្រុមប្រឹក្សាត្រូវធានាអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធី ដែលបានកំណត់ទាក់ទិនទៅនឹង :

-ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា

-គណនេយ្យ និងរបាយការណ៍

-ទ្រព្យសកម្ម និងទ្រព្យអកម្ម

-តម្លាភាព និងគណនេយ្យភាព

-ការគ្រប់គ្រង :

+ ចំណូលផ្ទាល់

+ ចំណូលដែលចែករំលែក មូលនិធិផ្ទេរពីថវិកាជាតិ និងថ្លៃសេវាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល

+ ចំណូលពីប្រភពផ្សេងៗទៀត ។

-លទ្ធកម្មសាធារណៈ

-ការធ្វើសវនកម្មផ្ទៃក្នុង

-ការធ្វើសវនកម្មផ្ទៃក្រៅ

-តម្រូវការផ្នែកហិរញ្ញវត្ថុសាធារណៈផ្សេងៗទៀត ។

បទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៦.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យ

សម្បត្តិរដ្ឋដែលបានផ្ទេរមកឱ្យខ្លួន ឬ ដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួនផ្សេងទៀតឱ្យមានប្រសិទ្ធភាព ។

នីតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៧.-**

ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ការរំលោភអំណាចកើតឡើងនៅពេលដែលអ្នកជាប់ឆ្នោតណាម្នាក់ ឬ អ្នកដែលបានទទួលការតែងតាំងនៅក្នុងក្រសួង ស្ថាប័ន ឬ ភ្នាក់ងាររបស់រដ្ឋ ឬ ក្នុងក្រុមប្រឹក្សាណាមួយ ឬ ជនណាម្នាក់ ដែលបានប្រព្រឹត្តអំពើដោយចេតនា ហើយដែលមិនអាចធ្វើយុត្តិកម្មបានដូចជា :

-ការប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈណាមួយ

-ការមិនបានប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ជនម្នាក់ទៀតដែលស្ថិតនៅក្រោមអំណាច ឬ ការត្រួតពិនិត្យរបស់ខ្លួន នៅពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះ ដែលបានកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈ ។

**មាត្រា ៤៩.-**

ការរំលោភអំណាច រួមមានសកម្មភាពណាមួយ ដូចខាងក្រោម :

-ការរំលោភសិទ្ធិស្របច្បាប់ ឬ សិទ្ធិមនុស្សរបស់ជនណាម្នាក់

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

-ការកាន់កាប់ ឬ ការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬ ទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិមកធ្វើជារបស់ខ្លួនដោយខុសច្បាប់

-ការធ្វើឱ្យអន្តរាយដល់បរិស្ថាន ធនធានធម្មជាតិ

-ការដកយកថវិកា ឬ ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬ ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមិនត្រឹមត្រូវ

-ការស្នើសុំ ឬ ការទទួលប្រាក់ ឬ រង្វាន់អ្វីមួយជាថ្នូរនឹងការធ្វើ ឬ មិនធ្វើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការរបស់ជននោះ ហើយដែលការចំណាយ ឬ រង្វាន់ នោះមិនបានកំណត់នៅក្នុងច្បាប់

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬប្រកាស

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តដីការបស់ក្រុមប្រឹក្សា

-ការធ្វើសេចក្តីសម្រេចនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ផលប្រយោជន៍គ្រួសាររបស់ខ្លួន ។

## មាត្រា ៥០.-

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំដែលពាក់ព័ន្ធ :

-ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញ

-សកម្មភាពនានាដែលបានអនុវត្ត

-របាយការណ៍ហិរញ្ញវត្ថុ

-ការវាយតម្លៃការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា

-លទ្ធផលនៃការតាមដាន និងវាយតម្លៃ ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ

-វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំខាងលើនេះ មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំ ។

## មាត្រា ៥១.-

ក្រុមប្រឹក្សា ត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារណជនក្នុងការជូនព័ត៌មានជា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

សាធារណៈអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ដែលពាក់ព័ន្ធនឹងក្រុមប្រឹក្សា និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សា ។

**មាត្រា ៥២.–**

ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬ មធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។

## ផ្នែកទី ៣
## ដីការបស់ក្រុមប្រឹក្សា

**មាត្រា ៥៣.–**

ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សា ។

យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួន តាមការធ្វើសេចក្តីសម្រេចដើម្បីដាក់ចេញនូវដីកាតាមការចាំបាច់ ។

**មាត្រា ៥៤.–**

ដីការបស់ក្រុមប្រឹក្សា មានវិសាលភាពដើម្បីកំណត់ ដើម្បីហាមឃាត់ ឬ ដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬ លើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ ភារកិច្ច និងធនធានរបស់ក្រុមប្រឹក្សារួមមាន :

-តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលប្រគល់ឱ្យក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សា ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះ មិនបានដកចេញនូវសិទ្ធិអំណាចខ្លះ ឬ ទាំងអស់ដើម្បីដាក់ចេញដីកា ឬ កិច្ចការណាមួយដែលច្បាប់នេះ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសដទៃទៀត តម្រូវឱ្យក្រុមប្រឹក្សាដាក់ចេញដីកា ។

## មាត្រា ៥៥.-

ដីកាដែលដាក់ចេញដោយក្រុមប្រឹក្សា ត្រូវប្រតិបត្តិ និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចទាំងមូលរបស់ខ្លួន លើកលែងតែដីកាចែងផ្សេងពីនេះ ឬ លើកលែងតែច្បាប់ណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់ ។

## មាត្រា ៥៦.-

ដីកាដែលក្រុមប្រឹក្សាបានអនុម័តរួច ត្រូវចូលជាធរមាននៅថ្ងៃដែលក្រុមប្រឹក្សាប្រកាសផ្សាយដីកានោះ ។

ដីកា អាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគត សម្រាប់ការចូលជាធរមាននូវដីកាទាំងមូល ឬ ផ្នែកខ្លះនៃដីកា ។

ដីកា មិនអាចមានប្រតិសកម្ម និងមិនអាចចូលជាធរមានមុនពេលដែលដីកាត្រូវបានអនុម័ត និងប្រកាសផ្សាយនោះឡើយ ។

## មាត្រា ៥៧.-

ដីកា ដែលចែងផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ដីកានោះនឹងមិនមានសុពលភាពបានឡើយ ។

## មាត្រា ៥៨.-

ដីកាណាមួយដែលធ្វើឡើងដោយមានការរើសអើងក្នុងន័យជាអវិជ្ជមាន ឬ អនុវត្តចំពោះតែបុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយ ដោយផ្អែកលើកត្តាជាតិសាសន៍ សាសនា ភេទ អាយុ ពណ៌សម្បុរ ជាតិ ឬ ជាតិកំណើត ឬ អសមត្ថភាពខាងស្មារតី ឬ ខាងកាយសម្បទា ដីកានោះមិនមានសុពលភាពបានឡើយ ។

## មាត្រា ៥៩.-

ដីកាអាចបង្កើតបទប្បញ្ញត្តិសម្រាប់ការពិន័យជាប្រាក់ចំពោះការប្រព្រឹត្តល្មើស ឬ ការមិនគោរពតាមបទប្បញ្ញត្តិមួយ ឬ ច្រើននៃដីកានោះបាន ។

បែបបទ នីតិវិធីនៃការរៀបចំបទប្បញ្ញត្តិ សម្រាប់ការពិន័យជាប្រាក់ដោយដីការបស់

ក្រុមប្រឹក្សា និងកម្រិតនៃប្រាក់ពិន័យនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦០.-**

ក្រុមប្រឹក្សានីមួយៗត្រូវអនុវត្តទៅតាមនីតិវិធីក្នុងការរៀបចំតាក់តែង ការកែប្រែ ឬ ការលុបចោលដីការបស់ខ្លួន ។

ការកែប្រែដីកា ឬ ការលុបចោលដីការបស់ក្រុមប្រឹក្សា ត្រូវសម្រេចដោយដីការបស់ក្រុមប្រឹក្សា ។

នីតិវិធីនៃការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សា ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦១.-**

ក្រុមប្រឹក្សា ត្រូវអនុវត្ត និងពង្រឹងការអនុវត្តដីកាទាំងអស់របស់ខ្លួន ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចពង្រឹងការអនុវត្តដីការបស់ខ្លួនតាមរយៈ ឬ ដោយមានកិច្ចសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវជួយក្រុមប្រឹក្សា ដើម្បីពង្រឹងការអនុវត្តដីការបស់ក្រុមប្រឹក្សា នៅពេលដែលមានការស្នើសុំជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សា ។

## ផ្នែកទី ៤

## អង្គប្រជុំ និង បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សា

**មាត្រា ៦២.-**

អង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ត្រូវប្រារព្ធធ្វើឡើងនៅក្នុងរយៈពេលមិនឱ្យលើសពីដប់បួន(១៤)ថ្ងៃ បន្ទាប់ពីថ្ងៃដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

ក្រសួងមហាផ្ទៃ ត្រូវចាត់តាំងមន្ត្រីមួយរូបឱ្យធ្វើជាអធិបតីក្នុងអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ។

## មាត្រា ៦៣.-

ប្រធានក្រុមប្រឹក្សា គឺជាប្រធានអង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សា ។

## មាត្រា ៦៤.-

ប្រធានអង្គប្រជុំរបស់ក្រុមប្រឹក្សា មានភារកិច្ច :

-ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សា ដោយមិនលំអៀង

-គោរព អនុវត្តច្បាប់ និងបទបញ្ជាផ្ទៃក្នុងសម្រាប់អង្គប្រជុំរបស់ក្រុមប្រឹក្សា ។

## មាត្រា ៦៥.-

ក្នុងករណីប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាធ្វើជាអធិបតីនៃអង្គប្រជុំ ។

ក្នុងករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតក្នុងលំដាប់លេខរៀងបន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលជាប់ឆ្នោតលំដាប់ទី ២ ក្នុងក្រុមប្រឹក្សា ដើម្បីធ្វើជាអធិបតីនៃអង្គប្រជុំ ។

ករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលជាប់ឆ្នោតលំដាប់ទី ២ ក្នុងក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតក្នុងលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយនោះឱ្យធ្វើជាអធិបតីនៃអង្គប្រជុំ ។

## មាត្រា ៦៦.-

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សានឹងមានសុពលភាពទៅបាន លុះត្រាតែមានវត្តមានសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល ។

សមាជិកក្រុមប្រឹក្សាគ្រប់ៗរូបដែលមានវត្តមាននៅក្នុងអង្គប្រជុំ មានសិទ្ធិបោះឆ្នោតមួយសំឡេងដើម្បីអនុម័តរាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ។

ក្រុមប្រឹក្សាត្រូវអនុម័តដីកា ឬ សេចក្ដីសម្រេច ដោយសំឡេងលើសពីពាក់កណ្ដាល

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ។

**មាត្រា ៦៧.-**

ក្នុងករណីមានសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាមានឧត្តមានុភាព ។

**មាត្រា ៦៨.-**

អង្គប្រជុំរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងជាសាធារណៈ ។

ក្រុមប្រឹក្សាអាចប្រជុំជាសម្ងាត់បាន ។

កិច្ចដំណើរការនៃការប្រជុំជាសម្ងាត់ ត្រូវកំណត់ដោយសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៩.-**

អង្គប្រជុំរបស់ក្រុមប្រឹក្សាត្រូវអនុវត្តទៅតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំអំពីគំរូបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

**មាត្រា ៧០.-**

អង្គប្រជុំសាមញ្ញលើកទី ១ របស់ក្រុមប្រឹក្សា ត្រូវប្រារព្ធឡើងមិនឱ្យហួសពីដប់ប្រាំ (១៥)ថ្ងៃ បន្ទាប់ពីអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ។

**មាត្រា ៧១.-**

ក្នុងកិច្ចប្រជុំលើកទី ២ របស់ខ្លួន ក្រុមប្រឹក្សាត្រូវចាត់វិធានការដើម្បីអនុម័តបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំរបស់ខ្លួនតាមទម្រង់ជាដីកា ។

ក្រុមប្រឹក្សាអាចអនុម័តយកគំរូបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំ តាមការណែនាំរបស់ក្រសួងមហាផ្ទៃ ដោយមានការកែប្រែ ឬ ដោយមិនមានការកែប្រែ ។

**មាត្រា ៧២.-**

ក្រុមប្រឹក្សា ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំរបស់ខ្លួន ។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំរបស់ក្រុមប្រឹក្សា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ ។

**មាត្រា ៧៣.-**

សមាជិកក្រុមប្រឹក្សា មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន ។

គ្មានសមាជិកក្រុមប្រឹក្សាណាម្នាក់ត្រូវបានចាប់ខ្លួន ឬ ឃុំខ្លួន ឬ ប្រឈមនឹងសកម្មភាព ឬ ចំណាត់ការណាមួយដោយសារតែហេតុផលនៃការបញ្ចេញមតិ ឬ ការបោះឆ្នោតរបស់ខ្លួនក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាឡើយ ។

**មាត្រា ៧៤.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រជុំសាមញ្ញនៅក្នុងដែនដីរបស់ខ្លួនយ៉ាងហោចណាស់ចំនួនដប់ពីរ(១២)ដង ជារៀងរាល់ឆ្នាំ ។

អង្គប្រជុំសាមញ្ញក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រារព្ធឡើងមិនឱ្យមុនម្ភៃប្រាំ(២៥)ថ្ងៃ ឬ លើសពីសាមសិបប្រាំ(៣៥)ថ្ងៃ បន្ទាប់ពីអង្គប្រជុំសាមញ្ញលើកមុនរបស់ក្រុមប្រឹក្សាបានឡើយ ។

**មាត្រា ៧៥.-**

ក្រុមប្រឹក្សា ត្រូវអនុម័តប្រតិទិននៃការប្រជុំសាមញ្ញរបស់ខ្លួន សម្រាប់រយៈពេលដប់ពីរ (១២)ខែ មិនឱ្យហួសពីអង្គប្រជុំសាមញ្ញលើកទី ២ និងសម្រាប់រយៈពេលជាបន្តបន្ទាប់ទៀតក្នុងរយៈពេលដប់ពីរ(១២)ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់ ។

**មាត្រា ៧៦.-**

ក្រុមប្រឹក្សា ត្រូវផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវប្រតិទិននៃការប្រជុំសាមញ្ញរបស់ខ្លួន ។

**មាត្រា ៧៧.-**

ក្រុមប្រឹក្សា អាចកោះប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬ ពិសេសណាមួយ ។

## ផ្នែកទី ៥
## ទង្វើមិនស្របច្បាប់ ដោយក្រុមប្រឹក្សា ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សា

**មាត្រា ៧៨.-**

សកម្មភាព ឬ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សា ឬ សមាជិកក្រុមប្រឹក្សា ឬ គណៈកម្មាធិការ ឬ គណៈអភិបាល ឬ អភិបាល ឬ បុគ្គលិក ដែលធ្វើឡើងហួសពីសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា ឬ ហួសពីសិទ្ធិអំណាចរបស់សមាជិកក្រុមប្រឹក្សា ឬ របស់គណៈកម្មាធិការ ឬ របស់គណៈអភិបាល ឬ របស់អភិបាល ឬ របស់បុគ្គលិករបស់ក្រុមប្រឹក្សា គឺជាទង្វើមិនស្របច្បាប់ ។

**មាត្រា ៧៩.-**

សកម្មភាព ឬ សេចក្តីសម្រេចទាំងឡាយណាដែលខុសច្បាប់ សកម្មភាព ឬ សេចក្តីសម្រេចនោះ ពុំមានសុពលភាពឡើយ ។

**មាត្រា ៨០.-**

ការចំណាយទាំងឡាយណាដែលធ្វើឡើងដោយក្រុមប្រឹក្សា ឬ ក្នុងនាមក្រុមប្រឹក្សា ដើម្បីអនុវត្តសកម្មភាព ឬ សេចក្តីសម្រេចណាមួយដែលមិនស្របច្បាប់ គឺជាការចំណាយមិនស្របច្បាប់ ។

**មាត្រា ៨១.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា និងគណៈអភិបាលអំពីសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់ណាមួយ ដែលធ្វើឡើងដោយក្រុមប្រឹក្សា ឬ សមាជិកក្រុមប្រឹក្សា ឬ គណៈកម្មាធិការ ឬ គណៈអភិបាល ឬ អភិ-

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

បាល ឬ បុគ្គលិកក្រុមប្រឹក្សានោះ ។

ក្រោយទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា ឬ គណៈអភិបាល ត្រូវឆ្លើយបំភ្លឺតបវិញក្នុងរយៈពេលយ៉ាងយូរមួយ (០១)ខែ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបវិញក្នុងរយៈពេលយ៉ាងយូរមួយ(០១)ខែ បើសិនក្រសួងយល់ឃើញថាទង្វើនោះមិនស្របច្បាប់ ។

### មាត្រា ៨២.-

មុនពេលចេញដីកា ឬ សេចក្តីសម្រេច ឬ កិច្ចព្រមព្រៀងណាមួយ ក្រុមប្រឹក្សា ឬ គណៈអភិបាលអាចលើកសំណើជាលាយលក្ខណ៍អក្សរសុំយោបល់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រសិនបើយល់ឃើញថាបញ្ហាទាំងនោះជាបញ្ហារសើប ឬ មិនច្បាស់លាស់ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបវិញនៅក្នុងរយៈពេលមួយ(០១)ខែ បន្ទាប់ពីបានទទួលសំណើនោះ ។

### មាត្រា ៨៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលអំពីវិធានការចាំបាច់ដើម្បីឱ្យក្រុមប្រឹក្សា ឬ គណៈអភិបាលធ្វើសកម្មភាព ឬ ធ្វើសេចក្តីសម្រេចឱ្យបានស្របច្បាប់ឡើងវិញ ។

### មាត្រា ៨៤.-

ក្នុងករណីដែលក្រុមប្រឹក្សាបានអនុវត្តរួចហើយនូវសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សា ឱ្យចាត់វិធានការចាំបាច់នានានៅក្នុងក្របខ័ណ្ឌសិទ្ធិអំណាចរបស់ខ្លួន ដើម្បីធ្វើសកម្មភាព ឬ សេចក្តីសម្រេចឱ្យបានស្របច្បាប់ឡើងវិញនៅក្នុងរយៈពេលមួយ(០១)ខែ ។

ក្រុមប្រឹក្សា ត្រូវផ្សព្វផ្សាយជាសាធារណៈភ្លាមនូវការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទាក់ទងនឹងបញ្ហានេះ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## មាត្រា ៨៥.-

ក្នុងករណីដែលក្រុមប្រឹក្សាមិនអាចធ្វើឱ្យសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់ឱ្យស្របតាមច្បាប់ឡើងវិញនៅក្នុងសិទ្ធិអំណាចរបស់ខ្លួននោះ ក្រុមប្រឹក្សាត្រូវលុបចោលសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់នៅក្នុងអង្គប្រជុំរបស់ខ្លួន និងត្រូវផ្សព្វផ្សាយជាសាធារណៈពីការលុបចោលនោះ ។

ជនណា ឬ បុគ្គលណាដែលបានទទួលរងនូវការខូចខាត ឬ បានបង់ពន្ធ ឬ កម្រៃដោយសារតែសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់នោះ អាចទាមទារឱ្យក្រុមប្រឹក្សាផ្តល់សំណង និងការបង់ប្រាក់មកវិញឱ្យបានគ្រប់ចំនួន ។

ជនណាដែលត្រូវបានក្រុមប្រឹក្សាបដិសេធមិនផ្តល់សំណង ឬ ការបង់ប្រាក់មកឱ្យវិញនៅក្នុងរយៈពេលពីរ(០២)ខែ ជននោះអាចជូនដំណឹង និងអាចប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីសម្របសម្រួលដោះស្រាយ ។

ក្នុងករណីដែលជនណាមិនឯកភាពតាមការសម្របសម្រួលដោះស្រាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជននោះមានសិទ្ធិប្តឹងទៅតុលាការ ។

## មាត្រា ៨៦.-

ការចំណាយ ឬ ផលប៉ះពាល់ពីសេចក្តីសម្រេចមិនស្របច្បាប់ណាមួយ ដែលធ្វើឡើងដោយក្រុមប្រឹក្សា ឬ ក្នុងនាមក្រុមប្រឹក្សានោះ ក្រុមប្រឹក្សាត្រូវទទួលសងនូវការចំណាយ ឬ សងការខូចខាតដែលមានផលប៉ះពាល់ពីសេចក្តីសម្រេច ឬ សកម្មភាពមិនស្របច្បាប់នោះមកវិញ នៅក្នុងរយៈពេលមួយ(០១)ខែ ។

## មាត្រា ៨៧.-

ក្នុងករណីដែលការចំណាយមិនស្របច្បាប់ធ្វើឡើង ដើម្បីអនុវត្តសេចក្តីសម្រេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សាឬគណៈកម្មាធិការណាមួយ ឬ គណៈអភិបាល ហើយដែលសមាជិកក្រុមប្រឹក្សា ឬ គណៈអភិបាលទាំងមូលបានគាំទ្រសកម្មភាព ឬ សេចក្តីសម្រេចនោះ សមាជិកក្រុមប្រឹក្សាម្នាក់ៗ ឬ គណៈអភិបាលម្នាក់ៗនោះ ត្រូវទទួលសងការចំណាយដែលមិនស្របច្បាប់ឱ្យបានគ្រប់ចំនួនមកវិញក្នុងចំណែកស្មើៗគ្នា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ក្នុងករណីដែលការចំណាយមិនស្របច្បាប់ មិនបានធ្វើឡើងដើម្បីអនុវត្តសេចក្តីសម្រេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សា ឬ គណៈកម្មាធិការណាមួយ ឬ គណៈអភិបាលទេនោះ ការចំណាយមិនស្របច្បាប់ទាំងអស់ ត្រូវទទួលសងឱ្យបានគ្រប់ចំនួនពីសមាជិកក្រុមប្រឹក្សាជាក់លាក់ណាមួយ ឬ ពីអភិបាល ឬ អភិបាលរង ឬ ពីបុគ្គលិកជាក់លាក់ណាមួយដែលទទួលខុសត្រូវចំពោះសកម្មភាព ឬ សេចក្តីសម្រេចនោះ ។

**មាត្រា ៨៨.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សាស្រុក ដើម្បីពិនិត្យនីត្យានុកូលភាពនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

## ផ្នែកទី ៦

## ការដោះស្រាយវិវាទនៅមូលដ្ឋាន

**មាត្រា ៨៩.-**

ក្រុមប្រឹក្សាត្រូវចាត់វិធានការសមស្រប ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៩០.-**

វិវាទនៅមូលដ្ឋាន គឺជាវិវាទមានលក្ខណៈឯកជនរវាងប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាមួយគ្នា ឬ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាផ្សេងគ្នា ។

**មាត្រា ៩១.-**

ការដោះស្រាយវិវាទ ត្រូវផ្អែកតាមពាក្យបណ្តឹងរបស់ភាគីណាមួយ ឬ ភាគីទាំងសងខាងនៅក្នុងវិវាទទៅក្រុមប្រឹក្សាដែលភាគីនោះស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

## មាត្រា ៩២.-

ក្រុមប្រឹក្សាត្រូវសម្រុះសម្រួលដោះស្រាយវិវាទនៅមូលដ្ឋាន ដោយផ្អែកតាមលក្ខណៈដែលអាចទទួលយកបានដោយភាគីនៅក្នុងវិវាទទាំងសងខាង ។

ក្នុងករណីភាគីណាមួយនៅក្នុងវិវាទ មិនអាចទទួលយកបាននូវការសម្រុះសម្រួលដោះស្រាយ ក្រុមប្រឹក្សាត្រូវណែនាំភាគីនោះអំពីនីតិវិធីតាមផ្លូវច្បាប់សម្រាប់បន្តដោះស្រាយវិវាទនោះ ។

## មាត្រា ៩៣.-

ក្នុងករណីមានសំណូមពរ ឬ ការតវ៉ានានាពីប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវពិនិត្យ និងដោះស្រាយសំណូមពរ ឬ ការតវ៉ានោះឱ្យបានសមស្រប ។

ក្នុងករណីសំណូមពរ ឬ ការតវ៉ានោះស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវចាត់វិធានការដោះស្រាយ រួចហើយត្រូវជូនដំណឹងទៅប្រជាពលរដ្ឋវិញ ។

ករណីសំណូមពរ ឬ ការតវ៉ានោះមិនស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬ ក្រុមប្រឹក្សាដែលពាក់ព័ន្ធ ដើម្បីដោះស្រាយ ។

## មាត្រា ៩៤.-

ក្នុងការសម្រុះសម្រួលដោះស្រាយវិវាទនៅមូលដ្ឋាន ក្រុមប្រឹក្សាមិនត្រូវធ្វើសេចក្តីសម្រេចទៅលើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធ ករណីដូចខាងក្រោម :

-ការលែងលះ

-អំពើហិង្សាក្នុងគ្រួសារដែលមានលក្ខណៈជាបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម

-បទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬ ករណីដែលស្ថិតនៅក្នុងក្របខ័ណ្ឌសណ្តាប់ធ្នាប់សាធារណៈ

-វិវាទដែលកំពុងដោះស្រាយដោយតុលាការ ឬ ដែលមានសេចក្តីសម្រេចពីតុលាការ

-វិវាទដែលច្បាប់ ឬ ដែលរាជរដ្ឋាភិបាលបានកំណត់ឱ្យស្ថាប័ន ឬ យន្តការ

ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL

ដាក់លាក់ណាមួយសម្រុះសម្រួលដោះស្រាយ ។

**មាត្រា ៩៥.-**

នីតិវិធីក្នុងការដោះស្រាយវិវាទនៅមូលដ្ឋាន ត្រូវផ្អែកតាមច្បាប់ ឬ អនុក្រឹត្យ ។

## ផ្នែកទី ៧
## បទប្បញ្ញត្តិពិសេសសម្រាប់ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ដែលស្ថិតក្នុងស្រុក

**មាត្រា ៩៦.-**

ក្រុមប្រឹក្សាស្រុក ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងស្រុករបស់ខ្លួន ។

**មាត្រា ៩៧.-**

ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងស្រុក ក្រុមប្រឹក្សាស្រុកត្រូវ :

-ជួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នីមួយៗឱ្យបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាព សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

-រួមជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណជន នៅក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់

-ស្វែងយល់និងឆ្លើយតប ចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងសំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ។

**មាត្រា ៩៨.-**

ក្រុមប្រឹក្សាស្រុកត្រូវមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់និងប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុកអំពីជម្រើស សេចក្ដីសម្រេច ការអនុវត្តរបស់ខ្លួន ព្រមទាំងផលប៉ះពាល់នៃជម្រើស សេចក្ដីសម្រេច និងការអនុវត្តទាំងនោះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៩៩.-**

ក្រុមប្រឹក្សាស្រុក ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់និង អ្នកពាក់ព័ន្ធនានា ដើម្បីវាយតម្លៃឱ្យបានទៀងទាត់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងធ្វើការបណ្តុះបណ្តាល កសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ព្រមទាំងធ្វើការអប់រំបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗឱ្យបានទៀងទាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលស្គាល់គុណភាពនៃការអប់រំបណ្តុះបណ្តាល ដែលស្របជាមួយខ្លឹមសារនៃច្បាប់នេះ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ១០០.-**

ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ ត្រូវដាក់បញ្ចូលយុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាពដែលបានកំណត់ សម្រាប់ឆ្លើយតបទៅនឹងតម្រូវការនិងសំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ទៅក្នុងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំរបស់ស្រុក និងរបស់ឃុំ សង្កាត់ព្រមទាំងគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ស្រុក និងឃុំ សង្កាត់ ។

**មាត្រា ១០១.-**

បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ក្រុមប្រឹក្សាស្រុកត្រូវសម្របសម្រួល និងគាំទ្រដល់ការបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលដែលចាំបាច់ដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ មានសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលគ្រប់គ្រាន់ និងជាអចិន្ត្រៃយ៍ដើម្បី :

-ជំរុញ ឬ ធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ឬ បំពេញមុខងារ ភារកិច្ចចាំបាច់មួយ ឬ ច្រើន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-បំពេញសមត្ថភាពផ្នែករដ្ឋបាល និងធនធានផ្នែករដ្ឋបាល រួមទាំងបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិ និងសម្ភារៈចាំបាច់នានា ។

**មាត្រា ១០២.-**

ការរៀបចំចាត់ចែងបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលនៅក្នុងឃុំ សង្កាត់ អាចធ្វើឡើងដោយអនុញ្ញាតឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពីរ ឬ ច្រើនប្រើប្រាស់រួមគ្នានូវបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិ ឬ សម្ភារៈខ្លះ ឬ ទាំងអស់តាមការចាំបាច់ ។

**មាត្រា ១០៣.-**

ក្នុងករណីដែលក្រុមប្រឹក្សាស្រុកបានប្រឹងប្រែងសម្របសម្រួលបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់រួចហើយ ប៉ុន្តែក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នោះនៅតែមិនអាចបំពេញភារកិច្ចជាមូលដ្ឋាន និងចាំបាច់របស់ខ្លួនបាន ឬ មិនអាចជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យឱ្យបានគ្រប់គ្រាន់ ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

របាយការណ៍ខាងលើនេះ ត្រូវដាក់បញ្ចូលនូវអនុសាសន៍សម្រេបអំពីសំណើកែតម្រូវកង្វះខាតទាំងនេះ ។

**មាត្រា ១០៤.-**

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឯកភាពតាមរបាយការណ៍របស់ក្រុមប្រឹក្សាស្រុក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ដើម្បីរៀបចំផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ឱ្យមានសមត្ថភាពក្នុងការជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យឱ្យមានប្រសិទ្ធភាព ។

ROYAUME DU CAMBODGE * LE MINISTRE du PALAIS ROYAL

## មាត្រា ១០៥.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាខេត្ត និងគណៈ-អភិបាលខេត្តដើម្បីអនុវត្តបទប្បញ្ញត្តិចាំបាច់មួយចំនួនក្នុងផ្នែកទី ៧ នៃច្បាប់នេះ ។

# ផ្នែកទី ៨
# រាជធានីភ្នំពេញ

## មាត្រា ១០៦.-

ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវមានដែនសមត្ថកិច្ចនៅក្នុងតំបន់របស់ខ្លួន សម្រាប់បង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

## មាត្រា ១០៧.-

ក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សាខណ្ឌ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ។

## មាត្រា ១០៨.-

ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

## មាត្រា ១០៩.-

តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

# ផ្នែកទី ៩
# ក្រុងក្រៅពីរាជធានីភ្នំពេញ

## មាត្រា ១១០.-

ក្រុមប្រឹក្សាក្រុងត្រូវមានដែនសមត្ថកិច្ចក្នុងតំបន់របស់ខ្លួនសម្រាប់បង្កើត ជំរុញនិង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១១១.-**

ក្រុមប្រឹក្សាសង្កាត់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង ។

**មាត្រា ១១២.-**

ក្រុមប្រឹក្សាក្រុងត្រូវធ្វើប្រតិភូកម្មមុខងារ ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាសង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១១៣.-**

តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## អំពីគណៈកម្មាធិការក្រុមប្រឹក្សា និងគណៈអភិបាល
### ផ្នែកទី ១
### គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

**មាត្រា ១១៤.-**

ក្រុមប្រឹក្សា មានកាតព្វកិច្ចរៀបចំឱ្យមានគណៈកម្មាធិការដូចខាងក្រោម :

-គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

-គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-គណៈកម្មាធិការលទ្ធកម្ម ។

**មាត្រា ១១៥.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការផ្សេងទៀត ដើម្បីជួយការងាររបស់ក្រុមប្រឹក្សាតាមការចាំបាច់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រុមប្រឹក្សាអាចតែងតាំងសមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង បុគ្គលិកក្រុមប្រឹក្សាជាសមាជិកគណៈកម្មាធិការបាន ។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីរបស់ក្រុមប្រឹក្សា ឬ តួនាទី ភារកិច្ចរបស់គណៈអភិ-បាលឡើយ ។

**មាត្រា ១១៦.–**

ក្រុមប្រឹក្សា ត្រូវសម្រេចអំពីចំនួនសមាជិកគណៈកម្មាធិការនីមួយៗ អំពីការតែងតាំងប្រធាន អនុប្រធាន និងអំពីការកំណត់តួនាទី ភារកិច្ច សកម្មភាពរបស់គណៈកម្មា-ធិការនីមួយៗដែលខ្លួនបានបង្កើតឡើង ។

**មាត្រា ១១៧.–**

ក្រុមប្រឹក្សា អាចអនុញ្ញាតឱ្យគណៈកម្មាធិការនីមួយៗជ្រើសរើសបុគ្គល ដែលមិនមែនជាសមាជិកក្រុមប្រឹក្សា ធ្វើជាទីប្រឹក្សាតាមការចាំបាច់ ។

**មាត្រា ១១៨.–**

ក្រុមប្រឹក្សា ត្រូវធានាឱ្យមានតំណាងស្ត្រីនៅក្នុងគណៈកម្មាធិការរបស់ខ្លួនរួមទាំងប្រធាន ឬ អនុប្រធានគណៈកម្មាធិការផង ។

**មាត្រា ១១៩.–**

គណៈកម្មាធិការនីមួយៗនៃក្រុមប្រឹក្សា ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនឱ្យបានទៀងទាត់ឱ្យក្រុមប្រឹក្សា និងគណៈអភិបាល ។

**មាត្រា ១២០.–**

ក្រុមប្រឹក្សា អាចបញ្ឈប់សមាជិកណាមួយពីគណៈកម្មាធិការដែលខ្លួនបានបង្កើតឡើង ។

ក្នុងករណីដែលសមាជិកគណៈកម្មាធិការនោះ ជាសមាជិកក្រុមប្រឹក្សា សមាជិកនោះនៅតែជាសមាជិកក្រុមប្រឹក្សាដដែល ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ១២១.-**

ក្រុមប្រឹក្សា ត្រូវទទួលខុសត្រូវរាល់សេចក្ដីសម្រេច និងសកម្មភាពរបស់គណៈកម្មាធិការនានា ដែលខ្លួនបានបង្កើតឡើង និងទទួលខុសត្រូវចំពោះផលវិបាកពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ ។

**មាត្រា ១២២.-**

ក្រុមប្រឹក្សា ត្រូវផ្ដល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន និងការគាំទ្រដទៃទៀត ដល់គណៈកម្មាធិការនានាដែលខ្លួនបានបង្កើតឡើង ។

## ផ្នែកទី ២

## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

**មាត្រា ១២៣.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានសមាសភាព :

- អភិបាល ជាប្រធាន
- ប្រធានអង្គភាពទាំងអស់របស់ក្រុមប្រឹក្សា
- ប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា
- ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រដ្ឋាភិបាលដែលផ្ដល់សេវាសម្ភារៈ ឬ ហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។
- តំណាងផ្សេងៗទៀតតាមការចាំបាច់ ។

**មាត្រា ១២៤.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវខិតខំជានាឱ្យបានថា ផែនការអភិវឌ្ឍ និងថវិការបស់ក្រសួង ស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រដ្ឋាភិបាលដែលផ្ដល់សេវាសម្ភារៈ ឬ ហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ត្រូវបានដាក់បញ្ចូលយ៉ាងត្រឹមត្រូវទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកា

ប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១២៥.-**

ក្រសួងមហាផ្ទៃ អាចកំណត់ឱ្យក្រុមប្រឹក្សាពីរ ឬ ច្រើនប្រើប្រាស់រួមគ្នានូវគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ។

**មាត្រា ១២៦.-**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ផ្នែកទី ៣

## គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

**មាត្រា ១២៧.-**

សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាស្ត្រីនៅក្នុងក្រុមប្រឹក្សានោះ ឬ ស្ត្រី និងបុរស នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១២៨.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សា លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី និងកុមារដែលស្ថិតនៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១២៩.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការនានា និងគណៈអភិបាល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១៣០.-**

ក្នុងការចូលរួមក្នុងកិច្ចប្រជុំខាងលើនេះ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ មានសិទ្ធិទទួលបាននូវរបៀបវារៈប្រជុំ និងឯកសារសម្រាប់កិច្ចប្រជុំដូចសមាជិកអង្គប្រជុំដទៃទៀតដែរ ។

**មាត្រា ១៣១.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាចចាត់តាំងសមាជិករបស់ខ្លួនយ៉ាងច្រើនពីរ(០២)រូប ដើម្បីចូលរួមក្នុងរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈអភិ-បាល និងកិច្ចប្រជុំនៃគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ។

សមាជិកដែលបានចាត់តាំងទាំងនេះ មានសិទ្ធិបញ្ចេញយោបល់ក្នុងកិច្ចប្រជុំនានាដូចគ្នានឹងសមាជិកដទៃទៀតនៃអង្គប្រជុំដែរ ។

**មាត្រា ១៣២.-**

ក្នុងករណីសមាជិកដែលត្រូវបានចាត់តាំងឱ្យចូលរួមក្នុងកិច្ចប្រជុំ ដូចមានចែងក្នុងមាត្រា ១៣១ ជាសមាជិកក្រុមប្រឹក្សា សមាជិកនោះមានសិទ្ធិបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំរបស់គណៈអភិ-បាលបានឡើយ ។

**មាត្រា ១៣៣.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដើម្បីដាក់បញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៣៤.-**

របាយការណ៍ប្រចាំឆ្នាំខាងលើនេះ ត្រូវរួមបញ្ចូលនូវ :

-ស្ថានភាពរួមនៃការចូលរួមរបស់ស្ត្រី ក្នុងការលើកកម្ពស់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ និងស្ថានភាពរបស់កុមារ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

-លទ្ធផល និងបញ្ហាប្រឈមរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ស្ត្រី និងកុមារ និងអនុសាសន៍ ដើម្បីពង្រឹងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-អនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រីក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១៣៥.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញប្រកាសណែនាំអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារតាមការចាំបាច់ ដោយផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ផ្នែកទី ៤

## គណៈកម្មាធិការលទ្ធកម្ម

**មាត្រា ១៣៦.-**

គណៈកម្មាធិការលទ្ធកម្មមានសិទ្ធិ និងភារកិច្ចធានាឱ្យសកម្មភាពកិច្ចលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព្រឹត្តធ្វើឡើងប្រកបដោយភាពស្មោះត្រង់ បើកចំហតម្លាភាព មិនលំអៀង ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ១៣៧.-**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥

## គណៈអភិបាល

**មាត្រា ១៣៨.-**

ត្រូវរៀបចំឱ្យមានគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ១៣៩.-**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.-**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៣.-**

អភិបាលរងរាជធានី អភិបាលរងខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃដែលមានលក្ខណៈសម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិ ចាប់ពីវរមន្ត្រីឡើងទៅ

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៤.-**

អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង

-មានអាយុ ចាប់ពីសាមសិប(៣០)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៥.-**

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុង

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

ចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

-មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង

-មានអាយុចាប់ពីម្ភៃប្រាំ(២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនបី(០៣)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្ររងដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជននិងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៦.-**

ក្នុងករណីចាំបាច់ អភិបាល អភិបាលរង អាចជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រៅពីក្របខ័ណ្ឌក្រសួងមហាផ្ទៃបាន ប៉ុន្តែមន្ត្រីនោះត្រូវមានលក្ខណសម្បត្តិ សមស្របតាមមាត្រា ១៤២ មាត្រា ១៤៣ មាត្រា ១៤៤ និងមាត្រា ១៤៥ នៃច្បាប់នេះ ។

**មាត្រា ១៤៧.-**

អភិបាល អភិបាលរង មានអាណត្តិការងារមិនលើសពីបួន(០៤)ឆ្នាំ ។

អភិបាល អភិបាលរងអាចត្រូវបានតែងតាំងបានបួន(០៤)ឆ្នាំទៀត សម្រាប់អាណត្តិទី ២ របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល ។

**មាត្រា ១៤៨.-**

អភិបាល អភិបាលរងមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ ។

**មាត្រា ១៤៩.-**

អភិបាល អភិបាលរងអាចចូលរួមគ្រប់អង្គប្រជុំ និងមានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាបាន តែមិនអាចធ្វើការបោះឆ្នោតបានឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ១៥០.-**

អភិបាល អភិបាលរង ត្រូវបញ្ឈប់ពីមុខតំណែងនៅមុនពេលបញ្ចប់អាណត្តិការងារ ប្រសិនបើសាមីខ្លួន :

-ដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ

-ត្រូវបានដកហូតពីមុខតំណែង ។

**មាត្រា ១៥១.-**

អភិបាល អភិបាលរងណាមួយ ត្រូវដកហូតពីមុខតំណែងមុនពេលបញ្ចប់អាណត្តិការងារ ក្នុងករណីណាមួយដូចខាងក្រោម :

-បាត់បង់លក្ខណសម្បត្តិជាអភិបាល ឬ អភិបាលរង

-អសមត្ថភាព

-បំពេញការងារមិនបានល្អ

-មានបញ្ហាសុខភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច

-បោះបង់ចោលការងារ

-ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ ។

**មាត្រា ១៥២.-**

ក្រុមប្រឹក្សា អាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញពីមុខដំណែង ដោយផ្អែកតាមករណីណាមួយក្នុងចំណោមករណីដូចមានចែងក្នុងមាត្រា ១៥១ នៃច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់នូវសំណើខាងលើនេះ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យសម្រេចចំពោះអភិបាលរាជធានី អភិបាលខេត្ត អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ។

ចំពោះអភិបាលរងក្រុង ស្រុក ខណ្ឌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេតនិងដោះស្រាយជាបន្ទាន់ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ១៥៣.-**

អភិបាល អភិបាលរង ត្រូវទទួលប្រាក់បៀវត្ស និងអាចទទួលកម្រៃផ្សេងៗទៀតដែលសមស្របនឹងមុខតំណែងនេះ ។

ប្រាក់បៀវត្ស និងកម្រៃផ្សេងៗទៀតរបស់អភិបាល អភិបាលរងត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៥៤.-**

អភិបាល មានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំ សម្របសម្រួល តម្រង់ទិសមន្ទីរ អង្គភាព ខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

អភិបាល ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារ សន្តិសុខ សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាល ត្រូវមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចស្នើរាជរដ្ឋាភិបាលចេញអនុក្រឹត្យដើម្បីកំណត់តួនាទី សិទ្ធិអំណាចរបស់អភិបាលក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា តាមការចាំបាច់ ។

**មាត្រា ១៥៥.-**

គណៈអភិបាល ត្រូវផ្ដល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ។

គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្ត

មុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១៥៦.-**

គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សាក្នុងការពិនិត្យមើលមុខងារ ភារកិច្ច និងធនធានទាំងអស់ ដែលបានបែងចែក ឬ បានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ រួចហើយត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពីរបៀបបំពេញមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ ។

**មាត្រា ១៥៧.-**

ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យសកម្មភាព និងការអនុវត្តរបស់គណៈអភិបាល និងអភិបាល ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬ អភិបាល និងបុគ្គលដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៥៨.-**

គណៈអភិបាល ឬ អភិបាលដែលបានសម្រេច ឬ បានអនុវត្តកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬ សកម្មភាពនោះ ពុំមានសុពលភាពបានឡើយ ។

**មាត្រា ១៥៩.-**

គណៈអភិបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ក្នុងចន្លោះអង្គប្រជុំសាមញ្ញមួយទៅអង្គប្រជុំសាមញ្ញមួយទៀតរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦០.-**

គណៈអភិបាលត្រូវផ្តល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាពីការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សា ដើម្បីទទួលយក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

មុខងារ ភារកិច្ច និងធនធាន ដែលនឹងត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាដោយច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ ។

**មាត្រា ១៦១.-**

គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា ត្រូវមានវិធានការដើម្បីធានាឱ្យមន្ត្រី អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សាបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងបំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ព្រមទាំងអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព ។

**មាត្រា ១៦២.-**

គណៈអភិបាល ត្រូវផ្ដល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សា ដើម្បីពិភាក្សាសម្រេចអំពី :

-ការបង្កើត ឬរំសាយអង្គភាព

-ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក

-ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក ដោយផ្អែកតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា

-ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន ។

**មាត្រា ១៦៣.-**

គណៈអភិបាល ត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តនូវ :

-កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំ

-ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំនិង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ និង

-របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដូចមានចែងក្នុងមាត្រា ៥០ នៃច្បាប់នេះ ដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ១៦៤.-**

គណៈអភិបាល ត្រូវលើកសំណើទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និង របៀបនៃការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗរួមទាំងផែនការអភិវឌ្ឍជាមួយ :

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

-ផ្នែកផ្សេងទៀតរបស់ក្រុមប្រឹក្សាដែលអនុវត្តមុខងារ និងភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋាភិបាល

-ដៃគូពាក់ព័ន្ធដទៃទៀត ។

ការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗ រួមទាំងផែនការអភិវឌ្ឍដែលត្រូវធ្វើឡើងដោយក្រុមប្រឹក្សាផ្ទាល់ ឬ ដោយគណៈអភិបាលក្នុងនាមក្រុមប្រឹក្សា ។

**មាត្រា ១៦៥.-**

គណៈអភិបាលត្រូវរាយការណ៍ជូនគ្រប់អង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាមួយនឹងអនុសាសន៍ចាំបាច់នានា សម្រាប់លើកកម្ពស់ការអនុវត្ត :

-មុខងារជាកាតព្វកិច្ចដែលបានផ្ទេរឱ្យក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥) ឆ្នាំរបស់ក្រុមប្រឹក្សា រួមទាំងសមាសភាគនៃផែនការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

+ ក្រុមប្រឹក្សារួមគ្នា

+ ប្រភេទក្រុមប្រឹក្សាផ្សេងៗ

+ ក្រសួង ស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល

+ ដៃគូពាក់ព័ន្ធនានា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-ដំណើរការរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦៦.-**

គណៈអភិបាល ត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឱ្យផែនការសកម្មភាព និងថវិការបស់បណ្ដាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលផ្ដល់សេវា សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា បានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១៦៧.-**

គណៈអភិបាល ត្រូវលើកទឹកចិត្ត សម្របសម្រួល និងគាំទ្រដល់សមាជិកក្រុមប្រឹក្សា បុគ្គលិករបស់ក្រុមប្រឹក្សា ដើម្បីរាយការណ៍ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់ នៅពេលដែលបានឃើញ ឬ ដែលបានសង្ស័យដោយមានហេតុផល ឬ ដែលមានការប្ដឹងតវ៉ា ឬ ប្ដឹងបរិហារ អំពីការរំលោភអំណាចដោយបុគ្គលណាម្នាក់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦៨.-**

គណៈអភិបាល ត្រូវផ្ដល់អនុសាសន៍ជូនក្រុមប្រឹក្សាពីការបង្កើតគណៈកម្មាធិការនានាតាមការចាំបាច់ ដើម្បីជួយដល់ក្រុមប្រឹក្សាក្នុងការអនុវត្តការងារអនុលោមតាមច្បាប់នេះ ។

**មាត្រា ១៦៩.-**

គណៈអភិបាលត្រូវធានាឱ្យមានក្ដារបិទផ្សាយព័ត៌មាន និងមធ្យោបាយផ្សព្វផ្សាយ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ព័ត៌មានផ្សេងៗទៀត តាមតម្រូវការរបស់ក្រុមប្រឹក្សារបស់ខ្លួន ។

រាល់ឯកសារទាំងអស់ដែលបានបោះពុម្ពផ្សាយស្របតាមច្បាប់នេះ ត្រូវតែបិទផ្សាយនៅលើក្តារព័ត៌មាន ឬ ត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៧០.-**

គណៈអភិបាល ត្រូវធានាឱ្យសាធារណជនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពិនិត្យមើលព័ត៌មាននានានៅលើក្តារបិទផ្សាយព័ត៌មាន ហើយត្រូវធានាថែរក្សាការពារសុវត្ថិភាពក្តារព័ត៌មាន ដែលមានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៧១.-**

គណៈអភិបាល ត្រូវធ្វើការបែងចែកភារកិច្ចជាលាយល័ក្ខណ៍អក្សរនូវកិច្ចការដែលស្ថិតនៅក្នុងសិទ្ធិអំណាចរបស់ខ្លួន ។

**មាត្រា ១៧២.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីកំណត់នូវតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## អំពីបុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា

### ផ្នែកទី ១
### បុគ្គលិករបស់ក្រុមប្រឹក្សា

**មាត្រា ១៧៣.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានបុគ្គលិកក្រុមប្រឹក្សារបស់ខ្លួន ។

បុគ្គលិកក្រុមប្រឹក្សា គឺជាបុគ្គលិករបស់ក្រុមប្រឹក្សាដែលបានតែងតាំងដោយក្រុមប្រឹក្សា ឬ ជាបុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា ឬ ជា

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញទៅឱ្យក្រុមប្រឹក្សាស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

សមាជិកក្រុមប្រឹក្សា មិនមែនជាបុគ្គលិករបស់ក្រុមប្រឹក្សាឡើយ ។

**មាត្រា ១៧៤.-**

បុគ្គលិករបស់ក្រុមប្រឹក្សា ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យដោយផ្ទាល់របស់គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

**មាត្រា ១៧៥.-**

បុគ្គលិកក្រុមប្រឹក្សា មិនត្រូវរាប់បញ្ចូលនូវមន្ត្រីនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ឬ មន្ត្រីដទៃទៀតដែលអនុវត្តភារកិច្ចពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងនាមរាជរដ្ឋាភិបាលឡើយ ។

**មាត្រា ១៧៦.-**

បុគ្គលិកដែលត្រូវបានជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សា ត្រូវដំណើរការតាមការប្រកួតប្រជែងដែលមានតម្លាភាព ។

ក្នុងដំណើរការជ្រើសរើស និងតែងតាំងបុគ្គលិករបស់ក្រុមប្រឹក្សា ត្រូវធានាឱ្យមានចំនួនស្ត្រីសមស្របនៅមុខតំណែងប្រធាន ឬ អនុប្រធាន អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា ។

ការជ្រើសរើស និងការតែងតាំងនេះ ត្រូវធ្វើឱ្យស្របទៅតាមបទប្បញ្ញត្តិស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១៧៧.-**

ក្រុមប្រឹក្សាត្រូវសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀត សម្រាប់មុខតំណែងបុគ្គលិករបស់ខ្លួន ។

ការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗរបស់បុគ្គលិកក្រុមប្រឹក្សា ត្រូវធ្វើឡើងឱ្យស្របទៅតាមបទប្បញ្ញត្តិស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ១៧៨.-**

បុគ្គលិកទាំងអស់ ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានគ្រប់គ្រងផ្ទាល់របស់ខ្លួន និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយប្រយោលចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម ។

**មាត្រា ១៧៩.-**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវមានប្រធានហិរញ្ញវត្ថុមួយរូប ។

ប្រធានហិរញ្ញវត្ថុនេះ ត្រូវបានតែងតាំងដោយក្រុមប្រឹក្សា ដើម្បីបំពេញភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៨០.-**

ប្រធានហិរញ្ញវត្ថុត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ការងារលទ្ធកម្ម និងធានាដល់ការធ្វើសវនកម្មឱ្យ បានត្រឹមត្រូវស្របតាមច្បាប់នេះ និងលិខិតបទដ្ឋាននានា ដែលធ្វើឡើងស្របតាមច្បាប់នេះ ។

**មាត្រា ១៨១.-**

ក្រុមប្រឹក្សាស្រុក ត្រូវមានអង្គភាពមួយសម្រាប់គាំទ្រឃុំ សង្កាត់ ។

អង្គភាពគាំទ្រឃុំ សង្កាត់ត្រូវមានប្រធានមួយរូប ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពគាំទ្រឃុំ សង្កាត់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៨២.-**

បុគ្គលិកក្រុមប្រឹក្សា ត្រូវបំពេញកិច្ចការប្រចាំថ្ងៃ ក្រោមការដឹកនាំរបស់ប្រធានអង្គភាពរបស់ខ្លួន ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ។

# ផ្នែកទី ២
## នាយករដ្ឋបាល

**មាត្រា ១៨៣.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមាននាយករដ្ឋបាលមួយរូបដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៨៤.-**

នាយករដ្ឋបាល មានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

ក្នុងតួនាទីខាងលើនេះ នាយករដ្ឋបាលត្រូវធ្វើសេចក្ដីរាយការណ៍ និងមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

**មាត្រា ១៨៥.-**

នាយករដ្ឋបាល មានតួនាទី ភារកិច្ចដូចខាងក្រោម :

-អនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល

-ធានាឱ្យអង្គភាព បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន

-អនុវត្តដីការបស់ក្រុមប្រឹក្សា

-ចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតបានឡើយ

-ផ្ដល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

-ផ្ដល់យោបល់ដល់គណៈអភិបាល ដើម្បីគណៈអភិបាលអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

**មាត្រា ១៨៦.-**

គណៈអភិបាល អាចធ្វើប្រតិភូកម្មការងារទៅឱ្យនាយករដ្ឋបាលនូវកិច្ចការណាមួយ ដែលស្ថិតក្នុងវិសាលភាពការងាររបស់គណៈអភិបាល ដើម្បីលើកយោបល់ជូនគណៈអភិបាលសម្រេច ។

**មាត្រា ១៨៧.-**

នាយករដ្ឋបាល ត្រូវធានាឱ្យប្រធានហិរញ្ញវត្ថុបំពេញភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ។

**មាត្រា ១៨៨.-**

ល័ក្ខខ័ណ្ឌនៃការតែងតាំង តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់នាយករដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ផ្នែកទី ៣
## អង្គភាពរបស់ក្រុមប្រឹក្សា

**មាត្រា ១៨៩.-**

ក្រុមប្រឹក្សាត្រូវមានអង្គភាពនានារបស់ខ្លួន តាមការចាំបាច់ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវលើកសំណើដាក់ចេញអនុក្រឹត្យដើម្បីឱ្យក្រុមប្រឹក្សាកំណត់នូវការរៀបចំអង្គភាព ការកំណត់មុខងារ ភារកិច្ច និងការរៀបចំមុខតំណែងបុគ្គលិកក្នុងអង្គភាពនានារបស់ខ្លួនឱ្យបានសមស្រប ។

**មាត្រា ១៩០.-**

អង្គភាពរបស់ក្រុមប្រឹក្សានីមួយៗ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

**មាត្រា ១៩១.-**

អង្គភាពនីមួយៗ ត្រូវស្ថិតក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានអង្គភាព ។

ប្រធានអង្គភាពនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល ។

## ជំពូកទី ៥
## អំពីដំណើរការអនុវត្ត
## ផ្នែកទី ១
## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**មាត្រា ១៩២.–**

ត្រូវបង្កើតឱ្យមានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហៅកាត់ថា "គ.ជ.អ.ប" ដែលកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៩៣.–**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ មានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១៩៤.–**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវមានអនុគណៈកម្មាធិការមុខងារ និងធនធាន អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និង ហិរញ្ញវត្ថុ និងអនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងអនុគណៈកម្មាធិការផ្សេងៗទៀតជាជំនួយការ ។

តួនាទី ភារកិច្ច និងសមាសភាពនៃអនុគណៈកម្មាធិការខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

### មាត្រា ១៩៥.-

អនុគណៈកម្មាធិការ ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល មុនពេលផ្តល់អនុសាសន៍ដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

### មាត្រា ១៩៦.-

អនុគណៈកម្មាធិការនីមួយៗ អាចបង្កើតក្រុមការងារមួយ ឬ ច្រើនតាមការចាំបាច់ ដើម្បីសិក្សា និងរាយការណ៍អំពីការងារដែលស្ថិតនៅក្នុងភារកិច្ច និងសិទ្ធិអំណាចរបស់អនុគណៈកម្មាធិការ ។

### មាត្រា ១៩៧.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការ ។

លេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិស្ថិតនៅក្នុងក្រសួងមហាផ្ទៃ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

### មាត្រា ១៩៨.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវប្រជុំយ៉ាងតិចពីរ(០២)ខែម្តង ។

### មាត្រា ១៩៩.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២០០.-**

ផ្អែកតាមលក្ខខណ្ឌនានាដែលបានចែងក្នុងច្បាប់នេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវ និងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារសម្រាប់ផ្ទេរដល់ក្រុមប្រឹក្សានានានៅថ្នាក់ក្រោមជាតិ ។

ការកំណត់ និងការផ្ទេរមុខងារខាងលើនេះ ត្រូវធ្វើឡើងដោយរួមជាមួយនឹង :

-ការផ្ទេរធនធានរួមមាន ចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាពដើម្បីគ្រប់គ្រង និងអនុវត្តមុខងារនីមួយៗ

-ការផ្តល់លទ្ធភាព និងអំណាច ដើម្បីទទួលបានធនធានចាំបាច់រួមមាន ចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាពសម្រាប់គ្រប់គ្រង និងអនុវត្តមុខងារនីមួយៗនោះ

-ការផ្តល់អំណាច និងភារកិច្ច ដើម្បីគ្រប់គ្រង និងអនុវត្តរាល់មុខងាររបស់ខ្លួនតាមគោលការណ៍ស្វ័យភាពមូលដ្ឋាន និងគណនេយ្យភាពនៅមូលដ្ឋានក្នុងកម្រិតជាអតិបរមា ។

**មាត្រា ២០១.-**

ក្នុងពេលដែលរង់ចាំការផ្ទេរមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សានានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវធានាឱ្យបានថា ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិបានធ្វើសមាហរណកម្មនូវផែនការអភិវឌ្ឍ និងថវិការបស់ខ្លួននៅថ្នាក់ក្រោមជាតិទៅក្នុងផែនការអភិវឌ្ឍ និង ថវិការបស់ក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ។

**មាត្រា ២០២.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវធានាឱ្យច្បាប់នេះ ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៅថ្នាក់ជាតិ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សានានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

### មាត្រា ២០៣.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវធានាឱ្យគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់នានាមានសង្គតិភាពជាមួយច្បាប់នេះ ។

### មាត្រា ២០៤.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ អាចផ្តល់អនុសាសន៍ដោយផ្ទាល់ដល់រាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាលអំពីការតាក់តែង ឬ ការធ្វើវិសោធនកម្មច្បាប់ ឬ លិខិតបទដ្ឋាននានា ដើម្បីឱ្យស្របតាមច្បាប់នេះ ។

### មាត្រា ២០៥.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អាចដោះស្រាយ ឬ លើកសំណើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាលលើការមិនចុះសម្រុងគ្នា ដែលអាចកើតមានឡើងទាក់ទងនឹងការអនុវត្តច្បាប់នេះ ។

### មាត្រា ២០៦.-

អនុគណៈកម្មាធិការនានានៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ មន្ទីរ អង្គភាពនានា និងក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

### មាត្រា ២០៧.-

ករណីក្រសួង ស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាល មិនអនុវត្តតាមការសម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ជាតិ ត្រូវរាយការណ៍ ដើម្បីសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ២០៨.-**

ករណីក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអនុវត្តតាមការសម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវស្នើដល់ក្រសួងមហាផ្ទៃដើម្បីអនុវត្តទៅតាមនីតិវិធីដែលបានកំណត់ក្នុងច្បាប់នេះ ។

**មាត្រា ២០៩.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធ្វើសេចក្តីរាយការណ៍ជាលាយល័ក្ខណ៍អក្សរអំពីការអនុវត្តច្បាប់នេះ ជូនរាជរដ្ឋាភិបាលយ៉ាងតិចប្រាំមួយ(០៦)ខែម្តង ។

**មាត្រា ២១០.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវមានថវិការបស់ខ្លួន ។

ថវិការបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិត្រូវគិតបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២១១.-**

ដើម្បីអនុវត្តច្បាប់នេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ នៅថ្នាក់ក្រោមជាតិត្រូវអនុម័ត :

-កម្មវិធីជាតិពីរយៈពេលមធ្យមទៅរយៈពេលវែង សម្រាប់គាំទ្រដល់ការអនុវត្តច្បាប់នេះ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-ផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយផ្អែកលើកម្មវិធីជាតិ

-របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តច្បាប់នេះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

### មាត្រា ២១២.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានសិទ្ធិទទួលមូលនិធិ និងការគាំទ្រពីដៃគូអភិវឌ្ឍនានា និងពីប្រភពផ្សេងៗទៀតដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។

## ផ្នែកទី ២
## មុខងារ

### មាត្រា ២១៣.-

រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសម្រេចឱ្យបាននូវគោលបំណងរួមក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមាននិរន្តរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

### មាត្រា ២១៤.-

ក្រុមប្រឹក្សាប្រភេទនីមួយៗ ត្រូវរួមចំណែកក្នុងការសម្រេចឱ្យបាននូវគោលបំណងរួមនេះ ដោយធ្វើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរឱ្យអនុលោមតាមច្បាប់នេះប្រកបដោយប្រសិទ្ធភាព ។

### មាត្រា ២១៥.-

ក្នុងការពិនិត្យមើលឡើងវិញនូវមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានានិងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវផ្តល់អាទិភាពដល់បញ្ហាដែលទាក់ទងនឹងផ្នែកនានាដូចខាងក្រោម :

- កសិកម្ម
- អប់រំ
- ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

-សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច

-ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច

-ការប្រើប្រាស់ដីធ្លី

-ការផលិត និងការចែកចាយអគ្គិសនី

-ការគ្រប់គ្រងទឹក

-ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយ សម្ភារៈចាំបាច់ ដើម្បីគាំទ្រ និងចាត់ចែងការទទួលខុសត្រូវទាំងនេះ និង

-តម្រូវការពិសេស ឬ តម្រូវការដែលបានកំណត់ជាក់លាក់ សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រនិងកេរដំណែលវប្បធម៌ផងដែរ ។

**មាត្រា ២១៦.-**

ក្នុងការត្រួតពិនិត្យមើលឡើងវិញនូវមុខងារ និងការទទួលខុសត្រូវនីមួយៗដូចមានចែងក្នុងមាត្រា ២១៥ នៃច្បាប់នេះ ត្រូវផ្តល់អាទិភាពដល់ការពិនិត្យមើលឡើងវិញនូវមុខងារជាមូលដ្ឋាន និងចាំបាច់ដែលមានផលប៉ះពាល់ផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ និងការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

**មាត្រា ២១៧.-**

គោលបំណងនៃការពិនិត្យមើលឡើងវិញនូវមុខងារ និងការទទួលខុសត្រូវទាំងនេះ គឺដើម្បីកំណត់មុខងារ និងការទទួលខុសត្រូវដែលនឹងត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សាឃុំ ឱ្យក្រុមប្រឹក្សាសង្កាត់ ឱ្យក្រុមប្រឹក្សាស្រុក ឱ្យក្រុមប្រឹក្សាក្រុង ឱ្យក្រុមប្រឹក្សាខេត្ត ឱ្យក្រុមប្រឹក្សារាជធានី ឬ ត្រូវរក្សាទុកជាមុខងារ និងការទទួលខុសត្រូវរបស់ថ្នាក់ជាតិ ។

ការកំណត់ឡើងវិញនូវមុខងារ និងការទទួលខុសត្រូវខាងលើនេះ ត្រូវធានាឱ្យបានថា មុខងារ និងការទទួលខុសត្រូវដែលបានផ្ទេរ ត្រូវធ្វើឡើងជាមួយនឹងការផ្ទេរធនធានសមស្របដើម្បីគ្រប់គ្រង និងចាត់ចែងមុខងារ និងការទទួលខុសត្រូវទាំងនោះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

### មាត្រា ២១៨._

ការផ្ទេរមុខងារ និងធនធាន ត្រូវធ្វើឡើងដោយមានការគ្រោងទុក មានដំណាក់កាល មានសនិទានភាព មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានតម្លាភាព និងមានការរំខានជាអប្បបរមាទៅលើប្រតិបត្តិការដែលកំពុងដំណើរការរបស់រាជរដ្ឋាភិបាល និងការគាំទ្រពីអ្នកពាក់ព័ន្ធនានា ។

### មាត្រា ២១៩._

យុទ្ធសាស្ត្រ និងកម្មវិធីជាតិ ត្រូវមានសង្គតិភាពជាមួយមុខងារ និងធនធាន ដែលត្រូវបានផ្ទេរស្របតាមច្បាប់នេះ ។

### មាត្រា ២២០._

ដើម្បីធ្វើការផ្ទេរមុខងារឱ្យបានសមស្របសម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ ជាបឋមត្រូវធ្វើការពិនិត្យមើលមុខងារទាំងនោះ ដោយផ្អែកតាមគោលការណ៍ដូចខាងក្រោម :

-ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ

-អាចគ្រប់គ្រង និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ

-បម្រើ ឬ ផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាជននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ

-មានផលប៉ះពាល់ជាចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ ។

ផ្អែកតាមគោលការណ៍ខាងលើនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបញ្ជាក់ហេតុផលឱ្យបានច្បាស់លាស់ក្នុងការផ្ទេរមុខងារទៅឱ្យថ្នាក់រដ្ឋបាលដែលសមស្រប ដោយឈរលើគោលការណ៍មានប្រសិទ្ធភាព ។

### មាត្រា ២២១._

ក្នុងការផ្ទេរមុខងារដូចមានចែងក្នុងមាត្រា ២១៥ មាត្រា ២១៧ និងមាត្រា ២២០ នៃច្បាប់នេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវកំណត់មុខងារណាមួយមានលក្ខណៈជាមុខងារជាកាតព្វកិច្ច ឬ មុខងារជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជម្រើស និងត្រូវកំណត់មុខងារណាមួយមានលក្ខណៈជាមុខងារដែលត្រូវប្រគល់ ឬ ជាមុខងារដែលត្រូវធ្វើប្រតិភូកម្ម ។

## ផ្នែកទី ៣

## មុខងារជាកាតព្វកិច្ច

### មាត្រា ២២២.-

មុខងារជាកាតព្វកិច្ច គឺជាមុខងារដែលកំណត់ដោយច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសខាងលើនេះ ត្រូវចែងអំពីតម្រូវការជាកាតព្វកិច្ចច្បាស់លាស់ និងជាក់លាក់សម្រាប់គ្រប់គ្រង និងអនុវត្តមុខងារដោយបញ្ជាក់ច្បាស់អំពីក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តបទដ្ឋាន និងនីតិវិធី ។

### មាត្រា ២២៣.-

មុខងារជាកាតព្វកិច្ច ដែលគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយប្រភេទក្រុមប្រឹក្សាណាមួយ ហើយមិនតម្រូវឱ្យមានការរួមចំណែកជាប្រចាំពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប៉ុន្តែក្រសួង ស្ថាប័នទាំងនោះ ត្រូវផ្ទេរធនធានដើម្បីឱ្យក្រុមប្រឹក្សាគ្រប់គ្រង ចាត់ចែង និង អនុវត្តមុខងារនោះ ។

មុខងារជាកាតព្វកិច្ចខាងលើនេះ ត្រូវប្រគល់ឱ្យប្រភេទក្រុមប្រឹក្សាដែលសមស្រប ។

### មាត្រា ២២៤.-

មុខងារជាកាតព្វកិច្ច ដែលអនុវត្តដោយប្រភេទក្រុមប្រឹក្សាសមស្របណាមួយ តម្រូវឱ្យមានការចូលរួមចំណែកជាប្រចាំពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ទោះបីធនធានចាំបាច់ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនោះ បានផ្ទេរឱ្យរួចហើយក្តី ។

មុខងារជាកាតព្វកិច្ចខាងលើនេះ ត្រូវធ្វើប្រតិភូកម្មដល់ប្រភេទក្រុមប្រឹក្សា ដែលសមស្រប ។

**មាត្រា ២២៥.-**

ការប្រគល់ ឬ ការធ្វើប្រតិភូកម្ម មុខងារជាកាតព្វកិច្ច ត្រូវជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយ :

-ផ្តល់ទៅឱ្យក្រុមប្រឹក្សានូវអំណាចជាអតិបរមា ដើម្បីឱ្យក្រុមប្រឹក្សាធ្វើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះ

-តម្រូវឱ្យក្រុមប្រឹក្សាគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះដោយមានការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២២៦.-**

មុខងារជាកាតព្វកិច្ចដែលបានធ្វើប្រតិភូកម្ម ក្រុមប្រឹក្សាត្រូវមានការទទួលខុសត្រូវចំពោះក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដោយអនុលោមទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ ។

## ផ្នែកទី ៤

## មុខងារជាជម្រើស

**មាត្រា ២២៧.-**

មុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច គឺជាមុខងារដែលមានលក្ខណៈជាជម្រើស ។

**មាត្រា ២២៨.-**

មុខងារដែលមានលក្ខណៈជាជម្រើស ត្រូវប្រគល់ឱ្យប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្រប ។

**មាត្រា ២២៩.-**

ក្រុមប្រឹក្សាត្រូវបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសបន្តពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល បន្ទាប់ពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលបានផ្ទេរឱ្យក្រុមប្រឹក្សា ។

### មាត្រា ២៣០.-

ក្រុមប្រឹក្សា ត្រូវគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសក្នុងកម្រិតអតិបរ-មានៃលទ្ធភាព និងធនធានដែលបានផ្ទេរឱ្យខ្លួន ។

ក្នុងករណីដែលមុខងារជាជម្រើស មិនក្លាយទៅជាមុខងារជាកាតព្វកិច្ច ក្រុមប្រឹក្សាអាចស្នើទៅគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធ្វើការកែប្រែ ឬ បញ្ឈប់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនោះ ។

ធនធានទាំងអស់ដែលបានផ្ទេរឱ្យក្រុមប្រឹក្សាដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ត្រូវរក្សាទុកជាធនធានរបស់ក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាអាចចាត់ចែងធនធានទាំងនោះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

### មាត្រា ២៣១.-

ក្រុមប្រឹក្សាមានសិទ្ធិក្នុងការធ្វើសេចក្ដីសម្រេចទៅលើរបៀបគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ដោយអនុលោមទៅតាមបទដ្ឋាន និងនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសជាធរមាន ។

### មាត្រា ២៣២.-

ក្នុងករណីដែលក្រុមប្រឹក្សាសម្រេចធ្វើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសដែលមិនធ្លាប់បានគ្រប់គ្រង ចាត់ចែង និងអនុវត្តពីមុនមក ដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល បទដ្ឋាន នីតិវិធី និងធនធានសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនោះ ត្រូវសម្រេចដោយឆន្ទានុសិទ្ធិផ្ទាល់របស់ក្រុមប្រឹក្សា ។

## ផ្នែកទី ៥

## ការប្រគល់ និងការធ្វើប្រតិភូកម្មមុខងារ

### មាត្រា ២៣៣.-

ការផ្ទេរមុខងារឱ្យប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្របតាមការប្រគល់ ឬ តាមការធ្វើប្រតិភូកម្មត្រូវធ្វើឡើងតាមគោលការណ៍នៃការប្រគល់ ឬ ការធ្វើប្រតិភូកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជាលក្ខណៈអចិន្ត្រៃយ៍ ដោយមិនត្រូវធ្វើការប្រគល់ ឬ ធ្វើប្រតិភូកម្មជាលក្ខណៈបណ្ដោះអាសន្នឡើយ ។

### មាត្រា ២៣៤.–

ការផ្ទេរធនធានដែលចាំបាច់ឱ្យប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្រប ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារណាមួយ ត្រូវធ្វើឡើងតាមគោលការណ៍ជាលក្ខណៈអចិន្ត្រៃយ៍ ដោយមិនត្រូវធ្វើការផ្ទេរជាលក្ខណៈបណ្ដោះអាសន្នឡើយ ។

### មាត្រា ២៣៥.–

ក្នុងការប្រគល់ ឬ ការធ្វើប្រតិភូកម្មមុខងារជាកាតព្វកិច្ច ឬ មុខងារជាជម្រើសដែលក្រសួង ស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាលធ្លាប់បានគ្រប់គ្រង ចាត់ចែង និងអនុវត្តពីមុនមកទៅឱ្យប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្រប គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវកំណត់ជាមុននូវធនធាន និងការអភិវឌ្ឍសមត្ថភាព ដើម្បីក្រុមប្រឹក្សាបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនោះ ។

### មាត្រា ២៣៦.–

ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារណាមួយឱ្យមានប្រសិទ្ធភាព និងមានចីរភាព គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឬ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលអាចប្រគល់ ឬ ធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាពីរ ឬ ច្រើន ដោយកំណត់អំពីធនធានដែលត្រូវចែករំលែកជាមួយគ្នា និងត្រូវរួមចំណែកជាមួយគ្នា ដោយរួមទាំងបុគ្គលិកជំនាញនៅក្នុងចំណោមក្រុមប្រឹក្សាទាំងនោះផង ។

### មាត្រា ២៣៧.–

មុខងារដែលបានប្រគល់ ឬ ដែលបានធ្វើប្រតិភូកម្ម គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវពិនិត្យឡើងវិញ ដើម្បីធ្វើការកែសម្រួលនូវមុខងារណាមួយ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន

របស់រាជរដ្ឋាភិបាល និងជាមួយក្រុមប្រឹក្សាពាក់ព័ន្ធក្នុងករណីដែល ៖

-មុខងារដែលបានប្រគល់ គួរត្រូវបានធ្វើប្រតិភូកម្ម

-មុខងារដែលបានធ្វើប្រតិភូកម្ម គួរត្រូវបានប្រគល់

-មុខងារជាកាតព្វកិច្ច គួរ ឬ បានក្លាយទៅជាមុខងារជាជម្រើស ឬ

-មុខងារជាជម្រើស គួរ ឬ បានក្លាយទៅជាមុខងារជាកាតព្វកិច្ច ។

**មាត្រា ២៣៨.-**

ការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ ត្រូវធ្វើឡើងដោយច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាស ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវពិនិត្យមើលឡើងវិញនូវច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ដែលពាក់ព័ន្ធនឹងការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ ដើម្បីបំពេញបែបបទធ្វើវិសោធនកម្មឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ២៣៩.-**

ការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីដាក់ចេញសេចក្តីសម្រេចដែលបញ្ជាក់ ៖

-ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសដែលបានធ្វើការប្រគល់ ឬ ធ្វើប្រតិភូកម្ម

-កាលបរិច្ឆេទចូលជាធរមាននូវការប្រគល់ ឬ ការធ្វើប្រតិភូកម្ម

-កំណត់បញ្ជាក់មុខងារនោះ មានលក្ខណៈជាកាតព្វកិច្ច ឬ ជាជម្រើស

-កំណត់បញ្ជាក់មុខងារនោះ ជាមុខងារត្រូវបានប្រគល់ ឬ ធ្វើប្រតិភូកម្ម ។

**មាត្រា ២៤០.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវផ្តល់ច្បាប់ចម្លងនៃច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាស និងសេចក្តី

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

សម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដល់ៈ

-ក្រុមប្រឹក្សាដែលត្រូវបានប្រគល់មុខងារ ឬ ធ្វើប្រតិភូកម្មមុខងារ

-ក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលបានគ្រប់គ្រងលើមុខងារនោះពីមុនមក

-ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

## ផ្នែកទី ៦

## របបហិរញ្ញវត្ថុរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### មាត្រា ២៤១.-

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅទៅលើថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា ៤៤ នៃច្បាប់នេះ ។

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរួមចំណែកដល់ការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

### មាត្រា ២៤២.-

ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ត្រូវមានធនធានហិរញ្ញវត្ថុសមស្រប ដើម្បីៈ

-គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចរបស់ខ្លួន

-ធ្វើការជ្រើសរើសក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសរបស់ខ្លួន

-អនុវត្តតួនាទី ភារកិច្ចតាមច្បាប់កំណត់

-ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង

-អនុវត្តមុខងារ ភារកិច្ច សម្រាប់ជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ២៤៣.-**

ក្រុមប្រឹក្សា ត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាពនិង គណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល ។

**មាត្រា ២៤៤.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកមានសិទ្ធិទទួលបានចំណូលពីប្រភពនៅមូលដ្ឋាន ពីប្រភពនៅថ្នាក់ជាតិ និងពីប្រភពផ្សេងៗទៀតដោយអនុលោមទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ត្រូវមានថវិកាសម្រាប់អនុវត្តមុខងារភារកិច្ចរបស់ខ្លួន ដែលស្ថិតនៅក្នុងថវិការាជធានី និងថវិកាក្រុង ។

**មាត្រា ២៤៥.-**

អភិបាល គឺជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

គណៈអភិបាលមានភារកិច្ចក្នុងការរៀបចំផែនការអភិវឌ្ឍកម្មវិធីវិនិយោគបី(០៣) ឆ្នាំរំកិលប្រចាំឆ្នាំ គម្រោងថវិកា និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត ។

បែបបទ និងនីតិវិធីនៃការរៀបចំ ការអនុម័ត ការអនុវត្ត និងការទូទាត់ថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

**មាត្រា ២៤៦.-**

ចំណូលពីប្រភពនៅមូលដ្ឋានរួមមាន :

-ពន្ធនៅមូលដ្ឋាន

-ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

-ចំណូលរបស់ក្រុមប្រឹក្សាស្រុក បានមកពីពន្ធ ឈ្នួល និងកម្រៃ ដែលត្រូវចែករំលែករវាងក្រុមប្រឹក្សាស្រុក ជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក

-អំណោយស្ម័គ្រចិត្ត

-ប្រភពផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬ អនុក្រឹត្យ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ។

ពន្ធ និងអាករនៅថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីច្បាប់សារពើពន្ធ ។

**មាត្រា ២៤៧.–**

ចំណូលពីថ្នាក់ជាតិ រួមមាន :

-ចំណូលចែករំលែក

-មូលនិធិផ្ទេរពីថវិការដ្ឋ និង

-ថ្លៃសេវា បានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៤៨.–**

ការបែងចែកចំណូលដែលបានមកពីថ្លៃចេញអាជ្ញាប័ណ្ណអាជីវកម្ម ពីកម្រៃសេវានិងពីចំណូលមិនមែនសារពើពន្ធដទៃទៀតរវាងស្រុក ឃុំ និងសង្កាត់ក្នុងស្រុក ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២៤៩.–**

ក្រុមប្រឹក្សាមានសិទ្ធិទទួលពីចំណូលជាតិនូវមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌនិងមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ។

ការផ្ទេរមូលនិធិពីថវិការដ្ឋ រួមមានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌនិងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថ្នាក់ជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងជាដំណាក់កាលៗ សម្រាប់ឆ្នាំនីមួយៗ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ២៥០.-**

មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌគឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ :

-ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចមួយ ឬ ច្រើនដែលត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា តាមការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ ឬ

-ដើម្បីបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយ ឬ ច្រើនដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ឬ

-សម្រាប់គោលបំណងជាកាតព្វកិច្ចមួយ ឬ ច្រើនដែលបានកំណត់ ។

**មាត្រា ២៥១.-**

មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌគឺជាមូលនិធិដែលក្រុមប្រឹក្សា ត្រូវប្រើប្រាស់ដើម្បី :

-បំពេញភារកិច្ចតាមផ្លូវច្បាប់

-បំពេញមុខងារ ភារកិច្ច ក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

-ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង

-ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា ។

**មាត្រា ២៥២.-**

ក្រុមប្រឹក្សាគ្មានសិទ្ធិខ្ចីប្រាក់ បោះផ្សាយសញ្ញាប័ណ្ណ ឬ/និងមូលប័ត្រ ធានាគ្រប់កិច្ចសន្យា និងប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុណាមួយដែលនាំឱ្យកើតជាបំណុល ។

**មាត្រា ២៥៣.-**

ក្នុងការរៀបចំរបបហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បែបបទ និងនីតិវិធីនៃការរៀបចំ ការអនុម័ត និងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំប្រភពចំណូលរួមមាន ចំណូលពីថ្នាក់ជាតិ និងចំណូលនៅមូលដ្ឋាន ការផ្ទេរការឧបត្ថម្ភថវិការួមមានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថ្នាក់ជាតិទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ ការចាត់ចែង ការគ្រប់គ្រងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដែលប្រគល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនិងទ្រព្យសម្បត្តិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ដែលក្រុមប្រឹក្សារកបានដោយខ្លួនឯង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវធ្វើការពិគ្រោះពិភាក្សាសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាតាមការចាំបាច់ ដើម្បីបំពេញការងារខាងលើនេះ ដោយមានផែនការជាជំហានៗមានសនិទានភាព មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានតម្លាភាព និងមានគណនេយ្យភាព ។

## ផ្នែកទី ៧
## ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ២៥៤.-**

ដើម្បីធានាឱ្យក្រុមប្រឹក្សាមានលទ្ធភាពអនុវត្តមុខងារភារកិច្ចរបស់ខ្លួន ផ្អែកតាមច្បាប់នេះ ចាំបាច់ត្រូវផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាទទួលបាននូវទ្រព្យសម្បត្តិចាំបាច់នានា ។

ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរឱ្យ និងទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង ដែលក្នុងផ្នែកនេះហៅថាទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២៥៥.-**

ទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងនិងប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ ។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យគ្រប់គ្រងឱ្យបានគង់វង្ស ហើយរដ្ឋបាលថ្នាក់ក្រោមជាតិគ្មានសិទ្ធិលក់ដូរ ឬ ផ្ទេរកម្មសិទ្ធិ ឬ ផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

ការត្រួតពិនិត្យ ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ២៥៦.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលឱ្យមានការផ្ទេរទ្រព្យសម្បត្តិ ស្របពេលជាមួយនឹងការពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ និងត្រូវធ្វើឡើងទៅតាមរបៀបដែលមានផែនការ មានវិចារណភាព មានការពិគ្រោះយោបល់ និងមានតម្លាភាព ។

**មាត្រា ២៥៧.-**

ក្នុងការផ្ទេរទ្រព្យសម្បត្តិ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអាចកំណត់ឱ្យក្រុមប្រឹក្សាពីរ ឬ ច្រើនប្រើប្រាស់រួមគ្នានូវទ្រព្យសម្បត្តិណាមួយ ដើម្បីក្រុមប្រឹក្សាទាំងនោះបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

**មាត្រា ២៥៨.-**

ក្នុងករណីដែលក្រុមប្រឹក្សាបានទទួលមុខងារមួយ ឬ ច្រើន ប៉ុន្តែទ្រព្យសម្បត្តិចាំបាច់សម្រាប់ចាត់ចែងមុខងារនោះមានបរិមាណមិនគ្រប់គ្រាន់ ឬ គ្មានតែម្តង ក្រុមប្រឹក្សាត្រូវទទួលបានធនធានហិរញ្ញវត្ថុ ដើម្បីដោះស្រាយមធ្យោបាយចាំបាច់សម្រាប់បំពេញសេចក្តីត្រូវការរបស់ខ្លួន ។

**មាត្រា ២៥៩.-**

ការផ្ទេរទ្រព្យសម្បត្តិត្រូវមានឯកសារផ្លូវច្បាប់សម្រាប់ផ្ទេរសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិទៅឱ្យក្រុមប្រឹក្សា ប្រសិនបើទ្រព្យសម្បត្តិនោះមានប័ណ្ណសម្គាល់កម្មសិទ្ធិ ។

ក្នុងករណីដែលទ្រព្យសម្បត្តិណាមួយមិនមានប័ណ្ណសម្គាល់កម្មសិទ្ធិ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដែលគ្រប់គ្រងទ្រព្យសម្បត្តិនោះរួចហើយ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវដាក់ចេញសេចក្តីសម្រេចដែលកំណត់អំពី :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

-ទ្រព្យសម្បត្តិដែលត្រូវផ្ទេរ

-ប្រភេទក្រុមប្រឹក្សាដែលទទួលទ្រព្យសម្បត្តិ

-ក្រុមប្រឹក្សាជាក់លាក់ដែលទទួលទ្រព្យសម្បត្តិ

-ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ មន្ទីរ អង្គភាពនានាថ្នាក់ក្រោមជាតិដែលត្រូវប្រគល់ទ្រព្យសម្បត្តិដល់ក្រុមប្រឹក្សា និង

-កាលបរិច្ឆេទដែលត្រូវប្រគល់ទ្រព្យសម្បត្តិឱ្យក្រុមប្រឹក្សា ។

សេចក្តីសម្រេចខាងលើនេះ អាចផ្ទេរទ្រព្យសម្បត្តិមួយ ឬ ច្រើន ឬ អាចផ្ទេរទ្រព្យសម្បត្តិទាំងអស់ក្នុងប្រភេទណាមួយក៏បាន ។

## មាត្រា ២៦០.-

ក្នុងករណីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ មន្ទីរ អង្គភាពនានាថ្នាក់ក្រោមជាតិមិនបានប្រគល់ទ្រព្យសម្បត្តិ ស្របតាមការកំណត់ក្នុងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឬ មិនបានរៀបចំឯកសារផ្លូវច្បាប់ឱ្យបានត្រឹមត្រូវសម្រាប់ផ្ទេរកម្មសិទ្ធិ ក្រុមប្រឹក្សាត្រូវរាយការណ៍បញ្ហានេះជាបន្ទាន់ជូន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## មាត្រា ២៦១.-

ក្រុមប្រឹក្សាត្រូវរៀបចំគម្រោងថែទាំទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ ។

ក្រុមប្រឹក្សាត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ផ្នែកទី ៨
# បុគ្គលិក

## មាត្រា ២៦២.-

ដើម្បីឱ្យក្រុមប្រឹក្សាមានលទ្ធភាពគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារ ភារកិច្ច ដែលបានផ្ទេរតាមច្បាប់នេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវពិនិត្យ និងធ្វើការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ស្របពេលជាមួយនឹងការផ្ទេរមុខងារ និងភារកិច្ចក្នុងគោលបំណងបង្កើតឱ្យមានក្របខ័ណ្ឌបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## មាត្រា ២៦៣.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវមានការទទួលខុសត្រូវក្នុងការកំណត់គោលនយោបាយ យុទ្ធសាស្ត្រសម្រាប់ធានាឱ្យការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិកឱ្យបានសមស្រប ។

## មាត្រា ២៦៤.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវកំណត់អំពីប្រភេទបុគ្គលិកសម្រាប់ក្រុមប្រឹក្សា និងកំណត់អំពីរបៀប និងមធ្យោបាយក្នុងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិកនេះ ដោយធានាមិនឱ្យមានការបង្កើនចំនួនបុគ្គលិកមុខងារសាធារណៈ ។

ការគ្រប់គ្រងបុគ្គលិកមុខងារសាធារណៈ ដែលបំពេញការងារសម្រាប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

## មាត្រា ២៦៥.-

ការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ត្រូវធ្វើឡើងផ្អែកតាមគោលការណ៍ដូចខាងក្រោម ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

-ត្រូវស្របជាមួយនឹងការពិនិត្យមើលឡើងវិញនូវមុខងារ និងការទទួលខុសត្រូវនានា ដូចមានចែងនៅក្នុងច្បាប់នេះ

-ត្រូវរៀបចំទៅតាមរបៀបដែលមានផែនការ មានកម្មវិធី មានសនិទានភាព មានការពិគ្រោះយោបល់ និងមានតម្លាភាព ដោយអនុលោមតាមច្បាប់នេះ

-ត្រូវគិតគូរអំពីផលប្រយោជន៍របស់ក្រុមប្រឹក្សា និងរបស់បុគ្គលិក ។

**មាត្រា ២៦៦.–**

ក្នុងករណីមុខងារ ភារកិច្ចណាមួយត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សា បុគ្គលិកដែលធ្លាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារភារកិច្ចនោះ ក៏ត្រូវធ្វើការផ្ទេរទៅឱ្យក្រុមប្រឹក្សានោះដែរ ។

**មាត្រា ២៦៧.–**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអាចធ្វើសេចក្ដីសម្រេចលើការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិកម្នាក់ ឬ ច្រើននាក់ទៅតាមប្រភេទមុខតំណែង ។

បុគ្គលិកដែលបានកែសម្រួលឡើងវិញនោះ ត្រូវមានលក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត មិនទាបជាងលក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដែលបុគ្គលិកទាំងនោះធ្លាប់បានទទួលមុនពេលរៀបចំឡើងវិញឡើយ ។

**មាត្រា ២៦៨.–**

ក្នុងករណីដែលមុខងារ ភារកិច្ចណាមួយត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សា ហើយបុគ្គលិកចាំបាច់មានចំនួនមិនគ្រប់គ្រាន់ ឬ គ្មានតែម្ដង ក្រុមប្រឹក្សាត្រូវបានទទួលធនធានហិរញ្ញវត្ថុ ដើម្បីជ្រើសរើសបុគ្គលិកមកបម្រើការងារតាមការចាំបាច់ ។

**មាត្រា ២៦៩.–**

ប្រសិនបើការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក តម្រូវឱ្យបុគ្គលិកណាម្នាក់ប្ដូរទីលំនៅរបស់ខ្លួន ហើយបុគ្គលិកនោះមិនយល់ព្រមតាមការរៀបចំ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

នេះ សាមីខ្លួនត្រូវធ្វើការបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការមិនយល់ព្រមនោះ នៅក្នុងរយៈពេលមួយ(០១)ខែ បន្ទាប់ពីទទួលបានសេចក្តីសម្រេច ។

បុគ្គលិកដែលមិនយល់ព្រមតាមការសម្រេចខាងលើនេះ អាចបន្តស្ថិតនៅជាបុគ្គលិករបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលជាបន្តទៀត ប៉ុន្តែត្រូវប្រគល់ភារកិច្ចផ្សេង ។

**មាត្រា ២៧០.–**

សេចក្តីសម្រេចរៀបចំបុគ្គលិកឡើងវិញ ត្រូវចូលជាធរមាននៅពេលគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលកំពុងគ្រប់គ្រងបុគ្គលិកនោះ ដាក់ចេញសេចក្តីសម្រេចដែលកំណត់អំពី :

-បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញ

-ប្រភេទក្រុមប្រឹក្សាដែលបុគ្គលិកនោះត្រូវទៅបំពេញការងារ

-កាលបរិច្ឆេទដែលបុគ្គលិកនោះត្រូវចូលបម្រើការងារ ។

សេចក្តីសម្រេចខាងលើនេះ អាចរៀបចំឡើងវិញនូវបុគ្គលិកម្នាក់ ឬ ច្រើននាក់ទៅតាមការចាំបាច់ ។

**មាត្រា ២៧១.–**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ទេរដល់ក្រុមប្រឹក្សានូវប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់បុគ្គលិកដែលបានផ្ទេរឱ្យក្រុមប្រឹក្សា ដោយគិតចាប់ពីថ្ងៃដែលបុគ្គលិកនោះបានចូលបំពេញការងាររបស់ក្រុមប្រឹក្សា ។

**មាត្រា ២៧២.–**

ក្រុមប្រឹក្សាត្រូវរាយការណ៍ជាបន្ទាន់ដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងករណីដែលបុគ្គលិកណាម្នាក់ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សារួចហើយ តែបុគ្គលិកនោះខកខានមិនបានចូលបម្រើការងារតាមការកំណត់នៅក្នុងសេចក្តីសម្រេច ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ២៧៣.–**

បែបបទ និងនីតិវិធីនៃការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## ជំពូកទី ៦
## អំពីទោសប្បញ្ញត្តិ

**មាត្រា ២៧៤.–**

សមាជិកក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលវិន័យដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។

**មាត្រា ២៧៥.–**

វិន័យដែលត្រូវអនុវត្តចំពោះសមាជិកក្រុមប្រឹក្សាដែលបានប្រព្រឹត្តនូវកំហុស ត្រូវផ្អែកតាមគោលការណ៍នៃបទប្បញ្ញត្តិដូចមានចែងក្នុងចំណុចទី ៤ ចំណុចទី ៥ មាត្រា ២២ នៃច្បាប់នេះ ។

**មាត្រា ២៧៦.–**

វិន័យដែលត្រូវអនុវត្ត ចំពោះគណៈអភិបាល នាយករដ្ឋបាល បុគ្គលិកក្រុមប្រឹក្សា ត្រូវផ្អែកតាមគោលការណ៍នៃបទប្បញ្ញត្តិដូចមានចែងក្នុងចំណុចទី ៣ និងចំណុចទី ៦ មាត្រា ១៥១ នៃច្បាប់នេះ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលក្ខន្តិកៈដោយឡែករបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៧

# អំពីអន្តរប្បញ្ញត្តិ

## ផ្នែកទី ១

## ការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវ

**មាត្រា ២៧៧.–**

រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌដែលត្រូវបានបង្កើតឡើងដោយច្បាប់នេះនឹងជំនួសរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នាពេលបច្ចុប្បន្ននេះ ។

**មាត្រា ២៧៨.–**

អភិបាលរាជធានី អភិបាលខេត្ត អភិបាលក្រុង អភិបាលខណ្ឌ អភិបាលស្រុកដែលបានតែងតាំងឡើងនៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តស្ថិតក្នុងមុខតំណែងនិងបំពេញការងាររហូតដល់មានក្រុមប្រឹក្សា និងគណៈអភិបាលដែលបានរៀបចំឡើងស្របតាមច្បាប់នេះមកជំនួស ។

**មាត្រា ២៧៩.–**

ការតែងតាំងគណៈអភិបាលសម្រាប់ក្រុមប្រឹក្សាអាណត្តិទី ១ នេះ ត្រូវធ្វើឡើងយ៉ាងយូរដប់បួន(១៤)ថ្ងៃ បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប." ប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗនោះ ។

**មាត្រា ២៨០.–**

ដីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀង ការងារ ទ្រព្យសម្បត្តិ បំណុល និងប្រាក់ទាំងអស់ដែលអនុវត្ត ឬ ដែលបានកាន់កាប់ដោយ ឬ ក្នុងនាមរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នៅមុនពេលច្បាប់នេះចូលជាធរមាន ដីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀង ការងារ ទ្រព្យសម្បត្តិ បំណុល និងប្រាក់ទាំងអស់នោះត្រូវអនុវត្ត និងចាត់ចែងបន្តដោយរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២៨១.-**

អង្គភាព និងមន្ត្រីបុគ្គលិកដែលបំពេញការងារក្នុងអង្គភាពរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តជាអង្គភាព និងជាមន្ត្រីបុគ្គលិក នៃអង្គភាពទាំងនោះរបស់រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រហូតដល់មានការរៀបចំជាថ្មី ។

**មាត្រា ២៨២.-**

ក្រសួងមហាផ្ទៃ ត្រូវធ្វើការកំណត់ និងកត់ត្រានូវការផ្ទេរ និងការទទួលយកនូវសិទ្ធិ កាតព្វកិច្ចទាំងអស់ កម្មសិទ្ធិ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ ព្រមទាំងអង្គភាព បុគ្គលិក ពីរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្នជូនទៅរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាល ក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ឱ្យបានសមស្រប និងមានតម្លាភាព ។

## ផ្នែកទី ២

## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ២៨៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបន្តអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា លើកលែងតែគោលការណ៍ដូចមានចែងក្នុងមាត្រា ៨៨ គោលការណ៍នៃផ្នែកទី ៦ ផ្នែកទី ៧ ផ្នែកទី ៨ ផ្នែកទី ៩ នៃជំពូកទី ២ និងគោលការណ៍ នៃជំពូកទី ៥ នៃច្បាប់នេះ ។

**មាត្រា ២៨៤.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម ជាតិ ត្រូវរៀបចំលិខិតបទដ្ឋានសម្រាប់គាំទ្រឃុំ សង្កាត់ ដើម្បីអនុវត្តបទប្បញ្ញត្តិដូចមាន ចែងក្នុងមាត្រា ៨៨ គោលការណ៍នៃផ្នែកទី ៦ ផ្នែកទី ៧ ផ្នែកទី ៨ ផ្នែកទី ៩ នៃជំពូកទី ២ និងគោលការណ៍នៃជំពូកទី ៥ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨

៣រល.០៥០៥.៥៩៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥៥៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# សន្ទានុក្រម

# LEXICON



**កសាងសមត្ថភាព** (Capacity Building)៖ គឺជាការអភិវឌ្ឍចំណេះដឹង ជំនាញ សមត្ថភាពរបស់បុគ្គលិក ឬ ស្ថាប័ន ដើម្បីបំពេញកិច្ចការដោយមានប្រសិទ្ធភាព ។ ការកសាងសមត្ថភាពអាចធ្វើឡើងតាមរយៈការអប់រំ វគ្គបណ្តុះបណ្តាល (Training Courses) ជាផ្លូវការ ឬ តាមរយៈការរៀនបណ្តើរធ្វើបណ្តើរ (On-job-training) ។

**ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** (Democratic Development) ៖គឺជាការអភិវឌ្ឍដែលដំណើរការដោយមានលក្ខណៈដូចខាងក្រោម ៖

-ភាពជាតំណាងសាធារណៈ (Public Representation) ៖ ក្រុមប្រឹក្សាត្រូវអនុវត្តការងារក្នុងនាម និងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ស្វ័យភាពរបស់មូលដ្ឋាន (Local Autonomy) ៖ ស្ថានភាពដែលក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែង គ្រប់គ្រងនូវកិច្ចការដែលបានប្រគល់ ឬ ធ្វើប្រតិភូកម្មឱ្យដោយច្បាប់នេះប្រកបដោយប្រសិទ្ធភាព ។

-ការពិគ្រោះយោបល់ និងការចូលរួម (Consultation and Participation)៖ ជាដំណើរការនៃការអនុវត្តការងារ និងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដែលក្រុមប្រឹក្សាត្រូវ ៖

- ជួប និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន
- លើកទឹកចិត្ត និងសម្របសម្រួលឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន នៅគ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ច ដើម្បីស្វែងយល់និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ ។

- ឆ្លើយតប និងគណនេយ្យភាព (Responsiveness and Accountability) ៖ ក្នុងនាមជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត ។ ក្រុម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ប្រឹក្សាក៏ទទួលខុសត្រូវផងដែរចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា ។

-លើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន (Promotion of Life Quality of the Local Residents) សំដៅទៅលើកិច្ចខិតខំប្រឹងប្រែងដើម្បី :

◆ បង្កើត និងធ្វើឱ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាព

◆ លើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និង

◆ លើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

-លើកស្ទួយសមធម៌ (Promotion of Equity) : ការគិតគូរ និងយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារព្រមទាំងតម្រូវការខុសៗគ្នារបស់ក្រុមជនងាយរងគ្រោះ រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច ។

-តម្លាភាព និងសុច្ចរិតភាព (Transparency and Integrity) : គឺជាការចាត់ចែង និងគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុច្ចរិតភាព និងច្បាប់ក្នុងលក្ខណៈបើកចំហ តម្លាភាព ភាពចូលរួម ភាពឆ្លើយតប ។

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច (Measures to Fight Corruption and Abuse of Power) : គឺជាការប្រកាន់យកនូវវិធាននៃច្បាប់ព្រមទាំងការប្រឆាំង និងរាយការណ៍អំពីអំពើពុករលួយ និងការរំលោភអំណាច ។

**កែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក** (Redeployment of Personnel) : សំដៅលើការពិនិត្យឡើងវិញនូវបុគ្គលិករបស់ក្រសួង-ស្ថាប័ននានា ដើម្បីធ្វើការរៀបចំឡើងវិញនូវបុគ្គលិកសម្រាប់បម្រើការងារឱ្យប្រភេទក្រុមប្រឹក្សាសមស្រប ដែលការងារនេះត្រូវធ្វើឡើងស្របពេលជាមួយការផ្ទេរមុខងារ ធនធាន និងការទទួលខុសត្រូវទៅឱ្យក្រុមប្រឹក្សាទាំងនោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**ក្របខណ្ឌចំណាយរយៈពេលមធ្យម** (Medium Term Expenditure Framework)៖ ការធ្វើផែនការចំណាយសាធារណៈដែលមានរយៈពេលពីបី(០៣) ដល់ប្រាំ(០៥)ឆ្នាំ ដែលកំណត់តម្រូវការធនធាននាពេលអនាគតសម្រាប់សេវាកម្ម និងការអភិវឌ្ឍដែលស្ថិតក្នុងបរិបទនៃការប៉ាន់ស្មានធនធានសរុបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីប្រភពក្នុងមូលដ្ឋាន និងប្រភពពីខាងក្រៅ ។

**ក្រុង** (Municipality) ៖ គឺជារដ្ឋបាលក្រុងដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ។

**ខេត្ត** (Province)៖ គឺជារដ្ឋបាលខេត្ត ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ។

**ខណ្ឌ** (Khan) ៖គឺជារដ្ឋបាលខណ្ឌដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ ។

**ឃុំ** (Commune)៖គឺជារដ្ឋបាលឃុំដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ ។

## ដ . ត . ថ . ទ . ន

**ដែនសមត្ថកិច្ច** (Juridiction)៖ គឺជាតំបន់ ជាមុខងារ និងជាភារកិច្ច ដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា ។

**ដីកា** (By-law) ៖ គឺជាវិធានច្បាប់ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាក្នុងព្រំដែននៃសិទ្ធិអំណាចរបស់ខ្លួន ដើម្បីអនុវត្តតែក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**ត្រួតពិនិត្យនីត្យានុកូលភាព** (Legality Control)៖ គឺជាការធានាឱ្យបានថាក្រុមប្រឹក្សាមិនធ្វើសកម្មភាពក្រៅពីសិទ្ធិអំណាចរបស់ខ្លួន ហើយអនុវត្តតាមតែនីតិវិធីដែលតម្រូវដោយវិធានច្បាប់ជាធរមាន ។

**ទ្រព្យសម្បត្តិ** (Asset) ៖ ក្នុងន័យទូទៅគឺសំដៅទៅលើគ្រឿងម៉ាស៊ីន យានយន្ត ឧបករណ៍

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

គ្រឿងសង្ហារឹម សម្ភារៈការិយាល័យ លិខិតស្នាម ឯកសារ និងដីសាធារណៈ អចលនទ្រព្យសាធារណៈ សំណង់សាធារណៈ ឬ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដូចជា ស្ពាន អគារ ព្រែក ផ្លូវ ឬ វត្ថុប្រហាក់ប្រហែលគ្នានេះ ។

**ទ្រព្យសកម្ម** (Asset)៖ គឺជាការកត់ត្រាក្នុងផ្នែកគណនេយ្យសំដៅទៅលើទ្រព្យសម្បត្តិនានាជាកម្មសិទ្ធិរបស់ក្រុមប្រឹក្សាដែលមានតម្លៃមួយពិតប្រាកដរួមទាំងប្រាក់កាសផង ។

**ទ្រព្យអកម្ម** (Liability)៖ គឺជាការកត់ត្រាក្នុងផ្នែកគណនេយ្យដែលសំដៅទៅលើកាតព្វកិច្ចទូទាត់ដែលត្រូវបានកត់ត្រា ។ ការទូទាត់នោះមិនទាន់បានធ្វើនៅឡើយទេ ។

**ធនធាន** (Resources)៖ រួមមានទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ ចំណូល បុគ្គលិក និងសមត្ថភាព ។

**ធនធានផ្នែករដ្ឋបាល** (Administrative Resources)៖ រួមមានមុខងារ សិទ្ធិអំណាច ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បុគ្គលិក និងសមត្ថភាព សម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារ ។

**នីតិបុគ្គលនៃនីតិសាធារណៈ** (Public Legal Entity) ៖ គឺជាក្រុមមនុស្សដែលច្បាប់បានអនុញ្ញាតឱ្យធ្វើសកម្មភាព ដូចជាបុគ្គល ដើម្បីជាផលប្រយោជន៍សាធារណៈ ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានផ្តល់នីតិបុគ្គលដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ប . ផ . ម

**បទប្បញ្ញត្តិចាំបាច់** (Compulsory Provision) ៖ បទប្បញ្ញត្តិដែលតម្រូវឱ្យក្រុមប្រឹក្សាអនុវត្តដោយខានមិនបាន ។ បទប្បញ្ញត្តិនេះ កំណត់ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ។

**បទបញ្ជាផ្ទៃក្នុង**(Internal Rule)៖ វិធានដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសម្រាប់កំណត់របៀបរបបធ្វើការងារ ការរៀបចំ និងដំណើរការប្រជុំរបស់ក្រុមប្រឹក្សា ។

**ប្រគល់មុខងារ** (Assignment of Function)៖ គឺជាការផ្ទេរភាពជាម្ចាស់នៃមុខងារការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារ ។

**ប្រតិភូកម្មមុខងារ** (Delegation of Function) ៖ គឺការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្ម នៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម ។

**ប្រភេទក្រុមប្រឹក្សា** (Category of Council) ៖ មានដូចជាក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សារាជធានី។

**ផ្ទេរ** (Transfer) ៖ គឺជាការប្រគល់ ឬ ការធ្វើប្រតិភូកម្មមុខងារ ។

**មុខងារ** (Function)៖ គឺជាអំពើ ឬ សកម្មភាពដែលរាប់បញ្ចូលទាំងការផ្ដល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងទៀត ។

## រ . ១

**រដ្ឋបាលថ្នាក់ក្រោមជាតិ** (Sub-National Administration)៖ ជាទូទៅសំដៅលើរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ សូមមើលពាក្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ បទប្បញ្ញត្តិមួយចំនួននៃច្បាប់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅត្រឹមតែរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តែប៉ុណ្ណោះ ។

**រដ្ឋបាលឯកភាព** (Unified Administration)៖ គឺជាការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន ហើយក្រុមប្រឹក្សានីមួយៗនោះមានសមត្ថភាពសម្របសម្រួល ប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្ដល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការផ្ដល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលសំដៅឆ្លើយតបសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។

**រាជធានី** (Capital)៖ គឺជារដ្ឋបាលរាជធានីដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ។ ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL

**វិមជ្ឈការ** (Decentralization)៖ រាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបសេចក្ដីត្រូវការរបស់មូលដ្ឋាន ។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ ។

**វិសហមជ្ឈការ** (Deconcentration)៖ រាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬ ទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័ន ។ អង្គភាព ឬ ក្រុមប្រឹក្សានោះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័នស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ ។

## ស

**សមត្ថភាពផ្នែករដ្ឋបាល** (Administrative Capacity) ៖ គឺជាលទ្ធភាពក្នុងការគ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារ ធនធានប្រកបដោយសមធម៌ មានតម្លាភាព មានគណនេយ្យភាព និងមានប្រសិទ្ធភាព ។

**សង្កាត់** (Sangkat)៖ គឺជារដ្ឋបាលសង្កាត់ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាសង្កាត់ ។

**ស្រុក** (District)៖ គឺជារដ្ឋបាលស្រុកដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក ។

**សិទ្ធិអំណាច** (Authority)៖ គឺជាលទ្ធភាពតាមផ្លូវច្បាប់ក្នុងការធ្វើអ្វីមួយ ។

**សិទ្ធិអំណាចប្រតិបត្តិ** (Executive Power)៖ គឺជាការធ្វើសេចក្ដីសម្រេចចិត្តផ្នែកគ្រប់គ្រង និងរដ្ឋបាល។ ឧទាហរណ៍៖ ការធ្វើសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាលើគម្រោងដែលត្រូវអនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ។

**សិទ្ធិអំណាចបញ្ញត្តិ** (Legislative Power)៖គឺជាសមត្ថភាពក្នុងការធ្វើលិខិតបទដ្ឋាន ។ ឧទាហរណ៍៖ ក្រុមប្រឹក្សាខេត្តមានសិទ្ធិអំណាចក្នុងការដាក់ចេញដីកា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ឧបសម្ព័ន្ធ ២.
# របាយការណ៍ប្រចាំឆ្នាំ២0២១ និងទិសដៅ
# អនាគតរបស់ខណ្ឌបឹងកេងកង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌបឹងកេងកង
លេខៈ.........................................

# របាយការណ៍

## ប្រចាំឆ្នាំ២០២១ និងទិសដៅការងារខែមករា ឆ្នាំ២០២២

## ស្តីពី
## ការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌបឹងកេងកង

# សេចក្តីផ្តើម

ខណ្ឌបឹងកេងកង ជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ របស់រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅកណ្តាលរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងកើតជាប់នឹងខណ្ឌចំការមន ខាងលិចជាប់ខណ្ឌទួលគោក ខាងត្បូងជាប់នឹងខណ្ឌមានជ័យ និងខណ្ឌចំការមន និងខាងជើងជាប់នឹងខណ្ឌ៧មករា និងខណ្ឌដូនពេញ។

| ល.រ | ការបរិយាយ | សរុប | ឯកត្តា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ៣,៩៧៦ | គីឡូម៉ែត្រការ៉េ |
| ២ | ចំនួនសង្កាត់ | ០៧ | សង្កាត់ |
| ៣ | ចំនួនភូមិ | ៥៤ | ភូមិ |
| ៤ | ចំនួនគ្រួសារ | ៩,០១៦ | គ្រួសារ |
| ៥ | ចំនួនប្រជាពលរដ្ឋ | ៥១,០១៩ | នាក់ |
| ៦ | ចំនួនស្ត្រីសរុប | ២៥,៩២៩ | នាក់ |

របាយការណ៍ប្រចាំឆ្នាំ២០២១ ការបរិយាយអំពីសមិទ្ធផលការងារប្រចាំឆ្នាំទី២ នៃអាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌដើម្បីឆ្លើយតបនូវផែនការអភិវឌ្ឍរយៈ ៥ឆ្នាំ (២០២០-២០២៤)។ របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌបឹងកេងកង មាន០៦ ផ្នែកដែលក្នុងនោះ៖

**ផ្នែកទី១៖ ការគ្រប់គ្រងរដ្ឋបាលខណ្ឌ**

បរិយាយអំពីលទ្ធផល នៃការអនុវត្តការងាររដ្ឋបាល ផែនការ និងការគាំទ្រសង្កាត់ ការគ្រប់គ្រងធនធានមនុស្ស និងការងារហិរញ្ញវត្ថុរបស់រដ្ឋបាលខណ្ឌ។

**ផ្នែកទី២៖ ការងាររដ្ឋបាលសង្កាត់**

បរិយាយសង្ខេបអំពីលទ្ធផលនៃការអនុវត្តការងាររបស់រដ្ឋបាលសង្កាត់ និងបញ្ហាប្រឈមដែលសង្កាត់បានជួបប្រទះ ព្រមទាំងសំណើរដំណោះស្រាយបញ្ហាប្រឈមទាំងនោះ។

**ផ្នែកទី៣៖ ការងាររបស់ការិយាល័យ និងអង្គភាពជំនាញ**

បរិយាយអំពីលទ្ធផល នៃការអនុវត្តការងាររបស់ការិយាល័យ អង្គភាពជំនាញនានា ដែលមានទីតាំងក្នុងដែនសមត្ថកិច្ចខណ្ឌ។

**ផ្នែកទី៤៖ បញ្ហាប្រឈម និងដំណោះស្រាយ**

បរិយាយអំពីបញ្ហាប្រឈមនានា ដែលរដ្ឋបាលខណ្ឌ និងការិយាល័យ បានជួបប្រទះ និងសំណើរដំណោះស្រាយបញ្ហាប្រឈមទាំងនោះ។

**ផ្នែកទី៥៖ ទិសដៅការងារឆ្នាំបន្ទាប់**

បរិយាយអំពីសកម្មភាពជាអាទិភាព ដែលរដ្ឋបាលខណ្ឌ និងការិយាល័យ អង្គភាពជំនាញបានគ្រោងសម្រាប់ឆ្នាំបន្ទាប់។

**ផ្នែកទី៦៖ សេចក្តីសន្និដ្ឋាន**

បរិយាយសង្ខេបអំពីការសេន្និដ្ឋាន នៃការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌ។

# ផ្នែកទី១
# ការគ្រប់គ្រងរដ្ឋបាលខណ្ឌ

## ១.១. ការងាររដ្ឋបាល

### ១.១.១.ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

- ដីកាអមដែលបានដាក់ចេញ ៥០លិខិត
- សេចក្ដីសម្រេចដែលបានដាក់ចេញ ០១លិខិត
- លិខិតរដ្ឋបាលដែលបានដាក់ចេញ ៨២លិខិត
- លិខិតដែលបានទទួល ២៤១លិខិត
- ផ្ដល់សៀវភៅស្នាក់នៅជូនប្រជាពលរដ្ឋ ២៤សៀវភៅ

**តារាងទី១៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ដីកាដែលបានដាក់ចេញ | ០០ | ០០ | ០០ |
| ២ | ដីកាអមដែលបានដាក់ចេញ | ៣៣៧ | ៥០ | ៣៨៧ |
| ៣ | សេចក្ដីសម្រេចដែលបានដាក់ចេញ | ១៥ | ០១ | ១៦ |
| ៤ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ១២១០ | ៨២ | ១២៩២ |
| ៥ | លិខិតដែលបានទទួល | ១៧៨៦ | ២៤១ | ២០២៧ |
| ៦ | ផ្ដល់សៀវភៅស្នាក់នៅជូនប្រជាពលរដ្ឋ | ១៨៧ | ២៤ | ២១១ |

### ១.១.២. ការគ្រប់គ្រងប្រជាពលរដ្ឋ

- ស្ថិតិប្រជាពលរដ្ឋមានចំនួន ៩,០១៦គ្រួសារ
- ប្រជាពលរដ្ឋសរុប ៥១,០១៩នាក់, ស្ត្រី ២៥,៩២៩នាក់
- ប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើង ៤០,២៤៥នាក់
- ប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើងជាស្ត្រី ២០,៣១៨នាក់

**តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | គ្រួសារសរុប | ៩,០១៦ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៨,៣៤៣ |
| ៣ | គ្រួសារបណ្ដោះអាសន្ន | ៦៧៣ |
| ៤ | ប្រជាពលរដ្ឋសរុប | ៥១,០១៩ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ២៥,៩២៩ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើងសរុប | ៤០,២៤៥ |
| ៧ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើងជាស្ត្រី | ២០,៣១៨ |
| ៨ | ប្រជាពលរដ្ឋចំណាកស្រុក | ០០ |

### ១.១.៣. ការងារអត្រានុកូលដ្ឋាន

ការចម្លងសំបុត្រអត្រានុកូលដ្ឋានអនុវត្តបាន៖

១-សេចក្ដីចម្លងសំបុត្រកំណើត ចំនួន ២១៩ នាក់

២-សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតបាន ចំនួន ៦៨៨ នាក់

៣-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍បាន ចំនួន ១២៣ នាក់

៤-សេចក្តីចម្លងសំបុត្រមរណភាពបាន ចំនួន ១៣ នាក់

**តារាងទី៣៖ ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | សេចក្តីចម្លងសំបុត្រកំណើត | ១៣១៣ | ២១៩ | ១៥៣២ |
| ២ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ៤៨២០ | ៦៨៨ | ៥៥០៨ |
| ៣ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៩២១ | ១២៣ | ១០៤៤ |
| ៤ | សេចក្តីចម្លងសំបុត្រមរណភាព | ៩៥ | ១៣ | ១០៨ |

### ១.១.៤. ការផ្សព្វផ្សាយព័ត៌មាន

**តារាងទី៤៖ ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ក). ការផ្សព្វផ្សាយព័ត៌មាន | | | | |
| ១ | វិទ្យុ | ០០ | ០០ | ០០ |
| ២ | ទូរទស្សន៍ | ០៤ | ០០ | ០៤ |
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | ៦៥ | ០៧ | ៧២ |
| ៤ | ព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តី សារព័ត៌មាន | ០០ | ០០ | ០០ |
| ៥ | ផ្សេងៗ | ០០ | ០០ | ០០ |
| ខ). ទំនាក់ទំនងសាធារណៈ | | | | |
| ១ | សាធារណជនមកទំនាក់ទំនងសាលាខណ្ឌ | ១០៩ | ១០ | ១១៩ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | ៣៤ | ៣ | ៣៧ |

### ១.១.៥. ការងារគណៈអភិបាល(រួមទាំងការអនុវត្តតួនាទីជាតំណាងក្រសួង ស្ថាប័ន)

- ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងលោក-លោកស្រីអភិបាលរងខណ្ឌ រួមជាមួយប្រធាន-អនុប្រធានការិយាល័យ បានចូលរួមដោះស្រាយករណីបាតុកម្មតវ៉ារបស់បុគ្គលិកក្រុមហ៊ុនហ្វូតផែនដា (Food Panda) និងអ្នកគ្រប់គ្រងក្រុមហ៊ុន។
- ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ **លោកជំទាវ គឹម សុវណ្ណា** សមាជិការដ្ឋសភាមណ្ឌលភ្នំពេញ និងជាអនុប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខណ្ឌបឹងកេងកង **លោកស្រី ស៊ុយ សែនសកាដ** ភរិយាលោកអភិបាលខណ្ឌ និងជាប្រធានអនុសាខាសមាគមនារីខណ្ឌ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** លោក ៣ ហាន ចៅសង្កាត់អូឡាំពិក បានដឹកនាំមន្ត្រីក្រោមឱវាទ ចុះសួរសុខទុក្ខ និងនាំយកនូវអំណោយមួយចំនួនដល់លោកស្រី មុំ ហ៊ត និងលោក យន់ សាមឿន ដែលជាជនចាស់ជរា និងមានជំងឺប្រចាំកាយ ក្នុងសង្កាត់អូឡាំពិក។
- ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ូ ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជា លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានគណៈកម្មាធិការអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង សូមថ្លែងអំណរគុណដល់ **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ និងលោកជំទាវ នៅទីស្នាក់ការសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ ដែលបាននាំអំណោយជាអង្ករចំនួន១០តោន ដែលជាអំណោយដ៏ថ្លៃថ្លា

របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដើម្បីចែកជូនបន្តដល់បងប្អូនប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះក្នុងដំណាក់កាលការរីករាលដាលជម្ងឺកូវីដ១៩ ក្នុងខណ្ឌបឹងកេងកង។

- ព្រឹកថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** ទទួលបន្ទុកការិយាល័យច្រកចេញចូលតែមួយ តំណាងលោកអភិបាលខណ្ឌ ប្រធានការិយាល័យច្រកចេញចូលតែមួយ បានទទួលពិភាក្សាជាមួយក្រុមការងារ អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ស្តីពីការចុះត្រួតពិនិត្យមើលការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធទូទាត់ថ្លៃសេវារបស់ក្រុមហ៊ុន លី ហួរ ផេប្រ៉ូ ភីអិល ស៊ី ក្នុងវិស័យសាធារណការ និងដឹកជញ្ជូននៅការិយាល័យច្រកចេញចូលតែមួយ។
- ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី** និង**លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានដឹកនាំមន្ត្រីក្រោមឱវាទ និងរដ្ឋបាលសង្កាត់ទួលស្វាយព្រៃទី១ បាននាំយកនូវបច្ច័យ និងអង្ករ ព្រមទាំងសម្ភារៈមួយចំនួន ដើម្បីចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំដល់គ្រួសារនៃសពឧបាសក លឹម លី អតីតសមាជិកក្រុមប្រឹក្សាសង្កាត់ទួលស្វាយព្រៃទី១ ដែលស្ថិតនៅផ្លូវលេខ៣១៨ ក្នុងភូមិ៣ សង្កាត់ទួលស្វាយព្រៃទី១។
- ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ **លោកជំទាវ គឹម សុវណ្ណា** សមាជិការដ្ឋសភាមណ្ឌលភ្នំពេញ និង **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** សមាជិកក្រុមប្រឹក្សាខណ្ឌ លោកនាយករដ្ឋបាលខណ្ឌ លោក-លោកស្រីចៅសង្កាត់ ប្រធានផ្សារទាំង២ និងមន្ត្រីក្រោមឱវាទ បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ម្តាយរបស់លោក គឹម ឈុនអ៊ួ ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង។
- ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌ** តំណាងលោកអភិបាលខណ្ឌ បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការពង្រឹង និងទប់ស្កាត់ការបិទស្ទឹកយ៉រ ចងបដាអនាធិបតេយ្យតាមបង្គោលភ្លើង ដើមឈើរបងការដ្ឋាន របងសាលារៀន និងនៅតាមទីសាធារណៈ ក្នុងរាជធានីភ្នំពេញនៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **លោកជំទាវ ឃួង ស្រេង អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោក អភិបាលខណ្ឌ បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការស្នើសុំអនុញ្ញាតឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ចុះធ្វើការវាស់វែងលើផ្ទៃដីដែលកំពុងកាន់កាប់ នៅទីតាំងរបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងទីតាំងរបស់មូលដ្ឋានកងរាជអាវុធហត្ថខណ្ឌទាំង១៣ ដើម្បីសុំធ្វើប័ណ្ណសម្គាល់សិទ្ធិ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ស៊ុយ សេរិទ្ធ** និង**ឯកឧត្តម កើត ឆែ អភិបាលរងរាជធានីភ្នំពេញ**។
- រសៀលថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំ «គណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង ដោយមានការចូលរួមពី លោក-លោកស្រីអភិបាលរងខណ្ឌ លោកនាយក-នាយករងរដ្ឋបាលខណ្ឌ តំណាងអធិការនគរបាលខណ្ឌ មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ លោក-លោកស្រីប្រធាន-អនុប្រធានការិយាល័យ លោក-លោកស្រីចៅសង្កាត់ទាំង០៧ និងមន្ត្រីពាក់ព័ន្ធ។
- ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការកំណត់ព្រំប្រទល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលមិនទាន់មានភាពច្បាស់លាស់ សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ។
- ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល ក្នុងនាមប្រធានគណៈកម្មាធិការអនុសាខាកាកបាទក្រហមកម្ពុជា ខណ្ឌបឹងកេងកង** បានអញ្ជើញជួបសំណេះសំណាល និងចែកអំណោយមនុស្សធម៌របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ជូនដល់គ្រួសារដែលមានជីវភាពខ្វះខាតចំនួន ២០គ្រួសារ ក្នុងសង្កាត់បឹងកេងកងទី២។
- ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ **លោកជំទាវ គឹម សុវណ្ណា** សមាជិការដ្ឋសភាមណ្ឌលភ្នំពេញ **លោកស្រី ស៊ុយ សែនសករាជ** ភរិយាលោកអភិបាលខណ្ឌ និងជាប្រធានអនុសាខាសមាគមនារីខណ្ឌបឹងកេងកង លោកស្រី **ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** លោក ឡូយ សារឿន ចៅសង្កាត់ទំនប់ទឹក បានដឹកនាំមន្ត្រីក្រោមឱវាទ ចុះសួរសុខទុក្ខ និងបាននាំយកនូវអំណោយមួយចំនួនជូនដល់លោកស្រី ជី យីម និងលោកស្រី អ៊ួន សុភាព ដែលជាជនចាស់ជរា ក្នុងសង្កាត់ទំនប់ទឹក។

- ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការងារសន្តិសុខ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**។
- ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានធ្វើកិច្ចអន្តរាគមន៍ទៅអគ្គិសនីកម្ពុជា ដើម្បីពិនិត្យករណីបង្គោលអគ្គិសនីបំភ្លឺសាធារណៈ ដែលមានសភាពប្រេះ ០១ដើម ស្ថិតនៅផ្លូវលេខ១៧៣ កែងផ្លូវព្រះមុន្នីវ៉ែត សង្កាត់អូឡាំពិក តាមសំណើរបស់សង្កាត់អូឡាំពិក។
- ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានធ្វើកិច្ចអន្តរាគមន៍ទៅ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីជួសជុលទឹកធ្លាយ នៅផ្លូវលេខ២០៥ កែងផ្លូវលេខ៣៨៨ មុខផ្ទះលេខ៣៧ សង្កាត់ទួលស្វាយព្រៃទី២ តាមសំណើរបស់សង្កាត់ទួលស្វាយព្រៃទី២។
- ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានចូលរួមក្នុងកិច្ចប្រជុំស្តីពីបទប្បញ្ញត្តិសុវត្ថិភាពក្នុងការដ្ឋានសំណង់ក្នុងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ស៊ុយ សេរិទ្ធ អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការផ្តល់ឯកសារ និងទិន្នន័យពាក់ព័ន្ធសម្រាប់រៀបចំផែនការយុទ្ធសាស្រ្តជាតិអភិវឌ្ឍន៍ទេសចរណ៍ ២០២១-២០៣៥ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ព្រមទាំងលោក-លោកស្រីអភិបាលរងខណ្ឌ ចុះត្រួតពិនិត្យការដាក់ប្រព័ន្ធលូ តាមបណ្តោយផ្លូវលេខ១៨៣ ក្នុងសង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង។
- ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ **ឯកឧត្តម សំហេង បុរស** ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានខណ្ឌបឹងកេងកង និង**លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមពិធីបុណ្យសព ៧ថ្ងៃ របស់ម្តាយលោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង និងបាននាំយកសាររំលែកទុក្ខ ព្រមទាំងថវិកាពី **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ ជូនដល់គ្រួសារសព។
- ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ គណៈអភិបាល នាយករដ្ឋបាល ប្រធានការិយាល័យ ចៅសង្កាត់ មេភូមិ និងមន្ត្រីក្រោមឱវាទ រួមជាមួយកម្លាំងប្រជាការពារខណ្ឌ ចុះធ្វើសណ្តាប់ធ្នាប់ អនាម័យ ជូនបងប្អូនប្រជាពលរដ្ឋតាមបណ្តោយផ្លូវលេខ១៦៣ មហាវិថីសម្តេចព្រះសីហនុ និងផ្លូវលេខ១៤៣ ក្នុងសង្កាត់អូឡាំពិក និងសង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង។
- ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការជួបជុំគ្នាដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធលោក ជា វិជ្ជា អតីតប្រធានសហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលមរណភាពគម្រប់ខួប ១៧ឆ្នាំ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម កើត ឆែ អភិបាលរងរាជធានីភ្នំពេញ** និង**ឯកឧត្តម មាន ចាន់យ៉ាដា អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការចាត់តាំងអនុវត្តសេចក្តីណែនាំលេខ០០១ សណន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្តីពីការលុបបំបាត់ការបង្កសំឡេងរំខានលើសកម្រិត ដោយយានយន្តគ្រប់ប្រភេទ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ។
- ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំ "គណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង" ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានគណៈបញ្ជាការឯកភាពខណ្ឌ។
- ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ី ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជា លោក ធឹម សំអាន ប្រធានគណៈកម្មាធិការអនុសាខាកាកបាទក្រហមកម្ពុជា ខណ្ឌបឹងកេងកង** បានអញ្ជើញជួបសំណេះសំណាល

និងចែកអំណោយមនុស្សធម៌របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ជូនដល់គ្រួសារដែលមានជីវភាពខ្វះខាតចំនួន ២០គ្រួសារ ក្នុងសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង។

- ថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំសាមញ្ញលើកទី១៧ ក្រោមអធិបតីភាព **លោកស្រី ម៉ែន សុភារី ប្រធានគ.ក.ស.ក ខណ្ឌ** និង **លោកស្រី ប៉ា សុខា អនុប្រធានគ.ក.ស.ក ខណ្ឌ និងលោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង**។
- ថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានធ្វើកិច្ចអន្តរាគមន៍ទៅទូរគមនាគមន៍កម្ពុជា ដើម្បីរៀបចំខ្សែបណ្តាញទូរគមនាគមន៍ ដែលធ្លាក់រយ៉េរយៃ នៅលើចិញ្ចើមផ្លូវព្រះមុន្នីវ៉ង្ស កែងផ្លូវលេខ ២៨៦ សង្កាត់ទួលស្វាយព្រៃទី២ តាមសំណើរបស់សង្កាត់ទួលស្វាយព្រៃទី២។
- ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានរៀបចំកិច្ចប្រជុំសំណេះសំណាលជាមួយលោក/លោកស្រីមេភូមិទាំង៥៤រូប ក្នុងមូលដ្ឋានខណ្ឌ ស្តីពីបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ បរិស្ថាន បញ្ហាផ្សេងៗ ក្នុងភូមិនីមួយៗ ក្នុងសង្កាត់ទាំង៧។
- ព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំសាមញ្ញលើកទី២០ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ី** ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម សេខ រតនៈ** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ និងសមាជិក-សមាជិកាក្រុមប្រឹក្សាខណ្ឌ លោក-លោកស្រីអភិបាលរងខណ្ឌ នាយករដ្ឋបាលខណ្ឌ លោកអធិការរងនគរបាលខណ្ឌ មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ យោធភូមិភាគខណ្ឌ ការិយាល័យចំណុះ-ជំនាញជុំវិញខណ្ឌ ចៅសង្កាត់ទាំង០៧ និងមន្ត្រីពាក់ព័ន្ធ។
- នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានជួបសំណេះសំណាលជាមួយភ្នាក់ងារអនាម័យ សង្កាត់ទាំង៧ ក្នុងមូលដ្ឋានខណ្ឌ ដោយមានការអញ្ជើញចូលរួមពី លោកប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ លោកពូ អ្នកមីង ដែលជាភ្នាក់ងារអនាម័យទាំង០៧សង្កាត់។
- រសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ សហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ បានចុះត្រួតពិនិត្យការបូម និងស្តារលូដែលស្ទះ នៅតាមបណ្តោយផ្លូវលេខ២០៥ ក្នុងសង្កាត់ទំនប់ទឹក។
- រសៀលថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ **លោកជំទាវ គឹម សុវណ្ណា** សមាជិការដ្ឋសភាតំណាងរាស្ត្រមណ្ឌលភ្នំពេញ **លោក គឹម ឈុនអ៊ី** ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌ រួមជាមួយ **លោក ជឹម សំអាន** ប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌ និង**លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រី ចុះសួរសុខទុក្ខ និងនាំយកអំណោយផ្តល់ជូនគ្រួសារបងប្អូនប្រជាពលរដ្ឋទីទ័លក្រ ដែលជួបការលំបាកក្នុងអំឡុងពេលជំងឺកូវីដ១៩ ក្នុងសង្កាត់បឹងកេងកងទី៣ ចំនួន៣០គ្រួសារ។
- យប់ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ និង លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** ក្រោមការចង្អុលបង្ហាញផ្ទាល់របស់លោកអភិបាលខណ្ឌ បានដឹកនាំកម្លាំងចម្រុះចុះធ្វើរដ្ឋបាលត្រួតពិនិត្យនៅតាមទីតាំងផ្ទះសំណាក់ បន្ទប់ជួលមួយចំនួន ក្នុងមូលដ្ឋានខណ្ឌ ដើម្បីថែរក្សាសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋ។
- ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាករណី ការដាំបង្គោលដែកលើចិញ្ចើមផ្លូវសាធារណៈនៅជុំវិញមន្ទីរពេទ្យ នៅសាលប្រជុំសាលាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង**។
- ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** និង**លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និង**លោកស្រីស៊ិន រតនា អភិបាលរងខណ្ឌ** បានចូលរួមពិធីដង្ហែបុណ្យមាឃបូជា ព្រមទាំងចូលរួមបច្ច័យមួយចំនួន នៅវត្តមហាមន្ត្រី ក្នុងសង្កាត់អូឡាំពិក និងវត្តលង្កាព្រះកុសុមារាម ក្នុងសង្កាត់បឹងកេងកងទី១។
- ព្រឹកថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ដឹកនាំដោយ **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ដោយមានការចូលរួមអន្តរាគមន៍ពី ឯកឧត្តមអភិបាលរងរាជធានីភ្នំពេញ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** អភិបាលរងខណ្ឌ មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ ព្រមទាំងមន្ត្រីពន្លត់អគ្គីភ័យ

បានចុះអន្តរាគមន៍ អគ្គីភ័យឆាបឆេះឃ្លាំងស្តុកឥវ៉ាន់ និងផ្ទះប្រជាពលរដ្ឋ នៅផ្លូវលេខ៣៥៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង។

- ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងពិធីប្រគល់ទទួលកិច្ចសន្យាស្តីពីការផ្តល់សេវាប្រមូលសំរាម និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។**
- ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បាននាំយកនូវអំណោយរបស់ឯកឧត្តមអភិបាលរាជធានីភ្នំពេញ ជូនដល់ក្រុមគ្រួសារសពទាំង ០២រូប ដែលបានឆេះស្លាប់ក្នុងហេតុការឆេះឃ្លាំងនៅផ្លូវលេខ៣៥៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង ក្នុងមួយគ្រួសារសពទទួលបាន៖ ថវិកា ចំនួន២លានរៀល, ក្នុងមួយសពទទួលបានក្តារមឈូសចំនួន១ អង្ករចំនួន៥០គីឡូ, មី២កេស,ទឹកសុទ្ធ១កេស។
- ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ូ ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជា ខណ្ឌបឹងកេងកង** បានអញ្ជើញជួបសំណេះសំណាល និងចែកអំណោយមនុស្សធម៌របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ជូនដល់គ្រួសារដែលមានជីវភាពខ្វះខាតចំនួន ២០គ្រួសារ ក្នុងសង្កាត់ទួលស្វាយព្រៃទី២។
- ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីប្រគល់ និងទទួលគ្រឿងឧបភោគ បរិភោគ ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលជាអំណោយរបស់សប្បុរសជន លោក ហេង សុផារ័ត្ន និងលោកស្រី អ៊ឹង លីតាំង អាជីវករផ្សារអូឡាំពិក សង្កាត់អូឡាំពិក។
- ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ូ ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជា លោក ធឹម សំអាន ក្នុងនាមជាប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង** បាននាំយកអំណោយដ៏ថ្លៃថ្លា របស់ **ឯកឧត្តម ឃួង ស្រេង** ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជា រាជធានីភ្នំពេញ និងមានការចូលរួមពី **ឯកឧត្តម សួន ស៊ីទៀង** អនុប្រធានក្រុមការងារ តំណាង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រធានក្រុមការងារចុះជួយមូលដ្ឋានសង្កាត់ទួលស្វាយព្រៃទី១ ក៏បានចូលរួមឧបត្ថម្ភក្នុងម្នាក់ ២៥០,០០០៛។
- ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានចុះពិនិត្យមើលការប្រមូលកាកសំណល់អគ្គីភ័យឆាបឆេះឃ្លាំងស្តុកឥវ៉ាន់ និងផ្ទះប្រជាពលរដ្ឋ នៅផ្លូវលេខ៣៥៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង។
- ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និង**លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានអញ្ជើញចូលរួមដោះស្រាយបណ្តឹងទប់ស្កាត់ឈ្មោះ ប៊ុន ថា ផ្លូវលេខ១០៤ ភូមិ០២ សង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង។
- ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានអញ្ជើញចូលរួមបើកវគ្គវេទិកាអប់រំផ្សព្វផ្សាយស្តីពី "ទំនៀមទម្លាប់ប្រពៃណី សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ" ក្រោមប្រធានបទ "សីលធម៌ ប្រពៃណីទំនៀមទម្លាប់ និងផលប៉ះពាល់សម្រាប់យុវវ័យ" ក្រោមអធិបតីភាព **ឯកឧត្តម ផន ដាវី** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ។
- ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និង**លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានអញ្ជើញចូលរួមចែកអំណោយជាលើកទី២ ជាមួយនឹងសប្បុរសជនដែលបានឧបត្ថម្ភសម្ភារៈមួយចំនួនមករដ្ឋបាលខណ្ឌ ហើយរដ្ឋបាលខណ្ឌបានចែកជូនបន្តដល់បងប្អូនប្រជាពលរដ្ឋដែលរងគ្រោះដោយអគ្គីភ័យចំនួន ១០គ្រួសារ ក្នុងសង្កាត់ទួលស្វាយព្រៃទី១។
- ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ក្រសួងសុខាភិបាល និងមន្ទីរទេសចរណ៍រាជធានីភ្នំពេញ សហការជាមួយរដ្ឋបាលខណ្ឌបឹងកេងកង រដ្ឋបាលសង្កាត់បឹងកេងកងទី១ និងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់បឹងកេងកងទី១ ក្រោមការដឹកនាំ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍វិធានសុវត្ថិភាពសុខាភិបាល តាមភោជនីយដ្ឋាន និងអាហារដ្ឋានមួយចំនួន ស្ថិតនៅក្នុងសង្កាត់បឹងកេងកងទី១។
- ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ូ ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជា** ខណ្ឌបឹងកេងកង និង **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានអញ្ជើញជួបសំណេះសំណាល និងចែកអំណោយមនុស្សធម៌របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ជូនដល់គ្រួសារដែលមានជីវភាពខ្វះខាតចំនួន ១៥គ្រួសារ ក្នុងសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង។

- ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និង**លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានអញ្ជើញចូលរួមដោះស្រាយបញ្ហាជាប់ព្រំរវាងលោកស្រី សេក វិច្ឆិកា និងលោកស្រី កែវ សុម៉ាលី នៅភូមិ៥ សង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង។
- ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**។
- រសៀលថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានគណៈបញ្ជាការឯកភាពខណ្ឌ ដឹកនាំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខណ្ឌ ដែលមានការអញ្ជើញចូលរួមពីអភិបាលរងខណ្ឌ អធិការនគរបាលខណ្ឌ បញ្ជាការរងកងរាជអាវុធហត្ថខណ្ឌ នាយករដ្ឋបាលខណ្ឌ ប្រធានការិយាល័យ លោក/លោកស្រីចៅសង្កាត់ទាំង៧ និងមន្ត្រីពាក់ព័ន្ធ។
- ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងាររបស់ក្រុមការងារតុបតែងដងផ្លូវ និងទីកន្លែងប្រជុំ នៃគណៈកម្មការទី៣ ឡជីស្ទីក ពិធីការ និងបដិសណ្ឋារកិច្ច រៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ ឆ្នាំ២០២១ ក្រោមអធិបតីភាព**ឯកឧត្តម នួន ផារ័ត្ន អភិបាលរងអភិបាលរាជធានីភ្នំពេញ**។
- ថ្ងៃទី០៤ និងទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោក**អភិបាលខណ្ឌ** បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការត្រៀម និងឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់នៃគ្រោះមហន្តរាយ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **លោកជំទាវ កែវ សុខពិសី អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ** ។
- ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការត្រៀមរៀបចំផែនការការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីប្រគល់-ទទួលវ៉ាក់សាំងកូវីដ១៩ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម មាន ចាន់យ៉ាដា អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ** ។
- ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានរៀបចំជួបសំណេះសំណាលជាមួយអាជីវករលក់ដូរ នៅលើចិញ្ចើមផ្លូវសាធារណៈ នៅតាមបណ្តោយផ្លូវលេខ៤៣០ និងបណ្តោយផ្លូវលេខ៤០២ ក្នុងសង្កាត់ទំនប់ទឹក។
- ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រី និងកម្លាំងប្រជាការពារចុះត្រួតពិនិត្យសណ្តាប់ធ្នាប់តាមបណ្តោយផ្លូវលេខ៤៣០ និងផ្លូវលេខ៤០២ ក្នុងសង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង។
- ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង និង លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានចូលរួមក្នុងកិច្ចប្រជុំស្តីពីសំណើសុំបន្តការគាំទ្រកម្មវិធីអភិវឌ្ឍន៍តំបន់រាជធានីភ្នំពេញ នៃអង្គការទស្សនៈពិភពលោក សម្រាប់រយៈពេល៥ឆ្នាំ បន្ថែមទៀត ចាប់ពីឆ្នាំ២០២១-២០២៥ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ**។
- ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងពិធីរៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ក្រោមអធិបតីភាព **លោកជំទាវ មឹន មាណវី** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។
- ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ **ឯកឧត្តម ម៉ម វាសនា** ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ សហការជាមួយរដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** លោកប្រធាន អនុប្រធានការិយាល័យខណ្ឌបឹងកេងកង រដ្ឋបាលសង្កាត់ទួលស្វាយព្រៃទី១ និងប៉ុស្តិ៍នគរបាលសង្កាត់ទួលស្វាយព្រៃទី១

បានចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍វិធានសុវត្ថិភាពសុខាភិបាល តាមភោជនីយដ្ឋាន និងអាហារដ្ឋានមួយចំនួន ស្ថិតនៅក្នុងសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង។

- ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីកម្លាំងបញ្ជាការពារខណ្ឌ ដោយមានការចូលរួមពីលោកចៅសង្កាត់ទំនប់ទឹក ចុះត្រួតពិនិត្យ សណ្តាប់ធ្នាប់ការលក់ដូររបស់បងប្អូនអាជីវករ ដែលលក់ដូរនៅតាមបណ្តោយផ្លូវលេខ៤០២ និងកាប់ដើមឈើដែលងាប់នៅលើផ្លូវលេខ១៨៧ កែងផ្លូវលេខ៤០២។
- យប់ថ្ងៃអង្គារ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ **ឯកឧត្តម ម៉ម វាសនា** ប្រធានមន្ទីរទេសចរណ៍ រាជធានីភ្នំពេញ នាយកដ្ឋានបណ្តុះបណ្តាលទេសចរណ៍ សហការជាមួយរដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** លោកប្រធាន អនុប្រធានការិយាល័យខណ្ឌបឹងកេងកង សហការជាមួយរដ្ឋបាលសង្កាត់ទួលស្វាយព្រៃទី២ និងប៉ុស្តិ៍នគរបាលសង្កាត់ទួលស្វាយព្រៃទី២ បានចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពសុខាភិបាលតាមភោជនីយដ្ឋាន និងអាហារដ្ឋានមួយចំនួន ស្ថិតនៅក្នុងសង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង។
- ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំ "គណៈបញ្ជាការឯកភាព" ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការអញ្ជើញចូលរួមពីអភិបាលរងខណ្ឌ លោកអធិការនគរបាលខណ្ឌ លោកមេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ លោក/លោកស្រីប្រធានការិយាល័យ និងចៅសង្កាត់ទាំង៧។
- ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំ ដែលមានរបៀបវារៈ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងអំឡុងពេលចូលឆ្នាំចិន ដែលមានការចូលរួមពីគណៈអភិបាលខណ្ឌ លោកអធិការខណ្ឌ លោកនាយករដ្ឋបាល ប្រធានការិយាល័យ លោក-លោកស្រីចៅសង្កាត់ទាំង៧ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ **លោក កឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីសំណើសុំអនុញ្ញាតឡុកម៉ុងសាយ ម៉ុងឡេង អបអរសាទរ ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីចិន របស់សហគមន៍សម្ព័ន្ធខ្មែរចិន ក្រោមអធិបតីភាព **ឯកឧត្តម មាន ចាន់យ៉ាដា អភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ **លោក កឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំស្តីពីសំណើសុំជួយសហការកំណត់ទីតាំងចំនួន០៤ នៅក្នុងរាជធានីភ្នំពេញ ដើម្បីដាក់បញ្ចូលទីតាំងចំនួន ១០០ នៃគម្រោងតេជោភូមិ១០០ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម កើត ឆែ** អភិបាលរងរាជធានីភ្នំពេញ។
- ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងអភិបាលខណ្ឌ បានអញ្ជើញជួបសំណេះសំណាល ជាមួយនឹងកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ ក្នុងឱកាសចូលឆ្នាំប្រពៃណីចិន និងវៀតណាម ដោយមានការចូលរួមពី លោកប្រធានការិយាល័យផែនការ និងកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ។
- យប់ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ **ឯកឧត្តម ម៉ម វាសនា ប្រធានមន្ទីរទេសចរណ៍ រាជធានីភ្នំពេញ** នាយកដ្ឋានបណ្តុះបណ្តាលទេសចរណ៍ សហការជាមួយ រដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** លោកប្រធាន អនុប្រធានការិយាល័យខណ្ឌបឹងកេងកង សហការជាមួយរដ្ឋបាលសង្កាត់ទំនប់ទឹក និងប៉ុស្តិ៍នគរបាលសង្កាត់ទំនប់ទឹក បានចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពសុខាភិបាល តាមភោជនីយដ្ឋាន និងអាហារដ្ឋានមួយចំនួន ស្ថិតនៅក្នុងសង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង។
- ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ **លោកជំទាវ គឹម សុវណ្ណា** អនុប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខណ្ឌបឹងកេងកង លោកស្រី ស៊ុយ សែនសករាជ ភរិយាលោកអភិបាល និងជាប្រធានអនុសាខាសមាគមនារីខណ្ឌ **លោកស្រី ស៊ិន រតនា** អនុប្រធានអនុសាខាសមាគមននារីខណ្ឌ លោក យន់ ចាន់ ចៅសង្កាត់ទួលស្វាយព្រៃទី២ បានដឹកនាំមន្ត្រីក្រោមឱវាទ ចុះសួរសុខទុក្ខ និងនាំយកនូវអំណោយមួយចំនួនជូនដល់អ្នកមានជំងឺ និងចាស់ជរា។
- ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំតាមដានវឌ្ឍនភាព ការងារធ្វើបច្ចុប្បន្នភាពប្លង់គោលប្រព័ន្ធដឹកជញ្ជូន ក្នុងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ ក្រោម

អធិបតីភាព **ឯកឧត្តម ស៊ុយ សេរិទ្ធ អភិបាលរងរាជធានីភ្នំពេញ** និង**ឯកឧត្តម នួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ** ។

- ព្រឹកថ្ងៃចន្ទ ទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្តីពី «ប្រជុំត្រៀមការរៀបចំកិច្ចការស្ត្រី ០៨ មីនា ទិវាសិទ្ធនារីអន្តរជាតិនាពេលខាងមុខ» ក្រោមអធិបតីភាព **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** និងមានការចូលរួមពី លោកស្រីប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក និងបងប្អូននារីជាមន្ត្រីរដ្ឋបាលខណ្ឌបឹងកេងកង។
- ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្តីពី «ការចុះស្រង់ស្ថិតិធ្វើបច្ចុប្បន្នភាពអាជីវកម្ម សេវាកម្ម និងពាណិជ្ជកម្មក្នុងមូលដ្ឋានខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព**លោក គឹមណៃ វីរៈ ខេមរា អភិបាលរងបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី លោក~លោកស្រីចៅសង្កាត់ ចៅសង្កាត់រងទាំង០៧ លោកប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ និងមន្ត្រីពាក់ព័ន្ធមួយចំនួន។
- ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ **លោកជំទាវ គឹម សុវណ្ណា** សមាជិការដ្ឋសភា និងជាអនុប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខណ្ឌបឹងកេងកង លោកស្រី ស៊ុយ សែនសករាជ ភរិយាលោកអភិបាល និងជាប្រធានអនុសាខាសមាគមនារីខណ្ឌ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** និងជាអនុប្រធានអនុសាខាសមាគមនារីខណ្ឌ លោក ព្រំ សុខឿន ចៅសង្កាត់បឹងកេងកងទី៣ បានដឹកនាំមន្ត្រីក្រោមឱវាទ ចុះសួរសុខទុក្ខ និងនាំយកនូវអំណោយមួយចំនួនជូនដល់លោកស្រី ប៉ាវ អួន ,លោកស្រី គឹម អួន ដែលជាចាស់ជរា និងមានជំងឺ។
- ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំ« ណែនាំពីការប្រមូលតម្រូវការអាទិភាព» ក្រោមអធិបតីភាព**លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** ដែលមានការអញ្ជើញចូលរួមពីលោកលោកស្រីប្រធាន-ការិយាល័យទាំង១១ សង្កាត់ទាំង៧ និងមន្ត្រីដែលពាក់ព័ន្ធ ។
- នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ គ.ក.ស.ក ខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំសាមញ្ញលើកទី១៨ ក្រោមអធិបតីភាព លោកស្រី ម៉ែន សុភារី ប្រធាន គ.ក.ស.ក ខណ្ឌ លោកស្រី ប៉ា សុខា អនុប្រធានគ.ក.ស.ក ខណ្ឌ និង **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ**។
- យប់ថ្ងៃសៅរ៍ ទី២០ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំកិច្ចប្រជុំស្តីពី «ការងារបង្ការទប់ស្កាត់ ការពារការឆ្លងរីករាលដាលនៃជម្ងឺកូវីដ១៩ នៅក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ» ដែលមានការអញ្ជើញចូលរួមពីគណៈអភិបាល ប្រធានការិយាល័យទាំង១១ សង្កាត់ទាំង៧ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំ រដ្ឋបាលសង្កាត់ទាំង៧ ចុះធ្វើការផ្សព្វផ្សាយតាមខ្នងផ្ទះប្រជាពលរដ្ឋ ស្តីពីវិធានការការពារ និងទប់ស្កាត់ជំងឺកូវីដ-១៩។
- ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា** អភិបាលរងខណ្ឌបឹងកេងកង បានសហការជាមួយអនុគណៈកម្មការកូវីដ-១៩ និងកម្លាំងអធិការដ្ឋានបឹងកេងកង បានចុះដល់ទីតាំង ក្លិប អិនប្រាំបី នៅលើផ្លូវកែងលេខ២៨៦ មហាវិថីមុន្នីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដើម្បីយកប្រអប់កាមេរ៉ាសុវត្ថិភាព ទៅពិនិត្យរកអ្នកពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ២០កុម្ភៈ។
- ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារខណ្ឌបឹងកេងកង ដឹកនាំដោយ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** រួមជាមួយលោក អធិការរងនគរបាលខណ្ឌ លោកនាយប៉ុស្តិ៍នគរបាលសង្កាត់ កម្លាំងរដ្ឋបាលសង្កាត់បឹងកេងកងទី១ បានសហការជាមួយ ក្រុមគ្រូពេទ្យសម្តេចតេជោ បានចុះមកយកសំណាកដើម្បីពិនិត្យរកជំងឺ កូវីដ១៩ ភ្ញៀវស្នាក់នៅ និងបុគ្គលិក នៅសណ្ឋាគាររីឡាកាសា។
- ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** តំណាងលោកអភិបាលខណ្ឌ បានរៀបចំកិច្ចប្រជុំស្តីពីការទប់ស្កាត់ជំងឺកូវីដ១៩ ក្នុងមូលដ្ឋាន និងទូទាំងសកល ដោយមានការអញ្ជើញចូលរួមពីប្រធានការិយាល័យទាំង១១ និងមន្ត្រីដែលពាក់ព័ន្ធ។
- យប់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា** អភិបាលរងខណ្ឌបឹងកេងកង សហការជាមួយក្រុមពេទ្យស្ម័គ្រចិត្តតេជោ បានចុះដល់ទីតាំង អេច អេច កម្ពុជា មាន ៤៨បន្ទប់ ក្នុងនោះកំពុងស្នាក់ចំនួន ២០បន្ទប់ មនុស្សមានចំនួន ២៦នាក់ ដែលស្ថិតនៅលើផ្លូវលេខ២៤២ និងភូមិ៥ សង្កាត់បឹកេងកងទី១ ដើម្បីធ្វើការយកសំណាកអ្នកពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ២០កុម្ភៈ។

- ព្រឹកថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំសាមញ្ញ លើកទី២១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ូ** ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម បណ្ឌិត ឡី សុភាព សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ និងសមាជិក~សមាជិកាក្រុមប្រឹក្សាខណ្ឌ លោក~លោកស្រី អភិបាលរងខណ្ឌ នាយករដ្ឋបាលខណ្ឌ លោកអធិការរងនគរបាលខណ្ឌ មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ យុទ្ធភូមិភាគខណ្ឌ ការិយាល័យចំណុះ~ជំនាញជុំវិញខណ្ឌ ចៅសង្កាត់ទាំង០៧ និងមន្ត្រីពាក់ព័ន្ធ។
- ថ្ងៃទី២៤ ខែកុម្ភ :ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ បន្តចលនាយុទ្ធនាការចុះចែកម៉ាស ជូនដល់បងប្អូនប្រជាពលរដ្ឋដែលធ្វើដំណើរលើមហាវិថីម៉ៅសេទុង ទល់មុខសាលាខណ្ឌបឹងកេងកង ក្នុងសង្កាត់បឹងកេងកងទី៣។
- ព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីប្រគល់ និងទទួលគ្រឿងឧបភោគ ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលជាអំណោយរបស់បងប្អូនអាជីវករលក់ដូរនៅមុខសាលាភូមិ៧ ស្ថិតនៅលើផ្លូវលេខ៤០២ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង។
- រសៀលថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំ «គណៈបញ្ជាការឯកភាព» ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។**
- ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំក្នុងការពិភាក្សាជាមួយក្រុមការងារទីក្រុងគីតាក្យូស៊ូ នៃប្រទេសជប៉ុន ស្តីពីគម្រោងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំណល់រឹង តាមរយៈ( Video Conference ) នៅសាលប្រជុំរាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរង នៃគណៈអភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងកែសម្រួលចុងក្រោយលើសេចក្តីណែនាំ ស្តីពីការអនុវត្តប្រព័ន្ធនៃការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម កើត ឆែ និង ឯកឧត្តម ហួត ហៃ អភិបាលរងអភិបាលរាជធានីភ្នំពេញ។**
- ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្តីពីទិសដៅបែងចែកតាមគោលដៅនានាក្នុងមូលដ្ឋានខណ្ឌបឹងកេងកងក្នុងកំឡុងពេលកូវីដ១៩ ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង។**
- ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីប្រគល់ និងទទួលគ្រឿងឧបភោគ បរិភោគ **លោកស្រីស៊ិន រតនា** អភិបាលរងខណ្ឌ បានឧបត្ថម្ភទឹកសុទ្ធចំនួន៥០កេស តំណាងលោកស្រីចាវ ថារី ទីប្រឹក្សាផ្ទាល់ លោកជំទាវឧកញ៉ា។
- ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ រដ្ឋបាលសង្កាត់ទាំង៧ ខណ្ឌបឹងកេងកង បានចុះធ្វើការចែកម៉ាស និងផ្សព្វផ្សាយតាមខ្នងផ្ទះប្រជាពលរដ្ឋ ស្តីពីវិធានការការពារ និងទប់ស្កាត់ជំងឺកូវីដ-19 ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។**
- រសៀលថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំ«ពាក់ព័ន្ធនឹងបញ្ហាប្រឈមនានា ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី គណៈអភិបាល គណៈនាយក ប្រធានការិយាល័យទាំង១១ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ ដោយមានការដឹកនាំពី **លោក ធឹម សំអាន** ប្រធានអនុសាខាកាកបាទក្រហមខណ្ឌ និង**លោកស្រី ស៊ិន រតនា** អនុប្រធានអនុសាខាស្ម័គ្រចិត្ត បានដឹកនាំយុវជនស្ម័គ្រចិត្តនិងមន្ត្រីក្រោមឱវាទ សហការជាមួយលោកស្រី ហង្ស ណារីមន្ត្រីសាខាកាកបាទក្រហមរាជធានីភ្នំពេញចុះធ្វើយុទ្ធនាការអប់រំផ្សព្វផ្សាយ ពីវិធីកាត់បន្ថយហានិភ័យអំពីការឆ្លងជម្ងឺកូវីដ១៩ ជូនដល់ប្រជាជនក្នុងមូលដ្ឋានខណ្ឌ។
- ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចាត់ឱ្យយុវជនស្ម័គ្រចិត្តរបស់អនុសាខាខណ្ឌ នាំយកថវិកាទៅជួយឧបត្ថម្ភដល់គ្រួសារមន្ត្រីដែលបានប្រសូតបុត្រចំនួន០៣គ្រួសារ ដែលមាន៖ គ្រួសារលោក សុខ បាន ប្រធានយោធាខណ្ឌចំនួន៣០០ដុល្លារ គ្រួសារលោកអ៊ឹម ដារិន ប្រជាការពារខណ្ឌ ១០០ដុល្លារ និង គ្រួសារលោក កាន់ សុផាត ប្រជាការពារខណ្ឌចំនួន ១០០ដុល្លារ។

- ព្រឹកថ្ងៃពុធ ទី២១ ខែមេសា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានធ្វើការបន្តត្រួតពិនិត្យ និងណែនាំកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ ដើម្បីបន្តថែរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងអនុវត្តការបិទខ្ទប់ តាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ទទួលបានប្រសិទ្ធិភាពខ្ពស់ ជូនប្រជាពលរដ្ឋ រដ្ឋបាលខណ្ឌបឹងកេងកង។
- ព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងលោក-លោកស្រីអភិបាលរង បានដឹកនាំមន្ត្រីក្រោមឱវាទ និងកម្លាំងប្រជាការពារខណ្ឌ ចុះធ្វើការណែនាំ សម្របសំរួលដល់បងប្អូនអាជីវករដែលធ្វើការលក់ដូរនៅផ្លូវលេខ៣០០ កែង១១៣ ក្នុងសង្កាត់បឹងកេងកងទី២ អោយផ្អាកអាជីវកម្មជាបណ្តោះអាសន្ន ជៀសវាងការរីករាលដាលនៃជំងឺកូវីដ១៩។
- រសៀលថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីចែកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់ប្រជាពលរដ្ឋក្រីក្រក្នុងសង្កាត់បឹងកេងកងទី១ (៤៣គ្រួសារ) សង្កាត់បឹងកេងកងទី២ (៥០គ្រួសារ) និងសង្កាត់ទួលស្វាយព្រៃទី១ (១០០គ្រួសារ)។
- ព្រឹកថ្ងៃសុក្រ ទី២៣ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីចែកអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់ប្រជាពលរដ្ឋក្រីក្រក្នុងសង្កាត់អូឡាំពិក (១០០គ្រួសារ) និងសង្កាត់ទំនប់ទឹក (៥០គ្រួសារ)។
- ព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានរាជធានីភ្នំពេញ** និង **លោកជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារ ចុះសំណេះសំណាលនិងចែកអំណោយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និងចែកជានិមិត្តរូប ៣០០គ្រួសារ លើចំនួន ៣១៦០គ្រួសារ ដែលរដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំក្នុងថ្ងៃនេះ ជូនដល់ប្រជាពលរដ្ឋអំឡុងពេលបិទខ្ទប់ ស្ថិតនៅក្នុងសង្កាត់អូឡាំពិក (នៅក្នុងបរិវេណភោជនីយដ្ឋាន ឡោរទីហ្វាង) ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
- រសៀលថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានធ្វើការបន្តរៀបចំជិះចុះចែកបន្លែស្រស់ ត្រីខ និងមីកញ្ចប់ ជូនដល់បងប្អូនប្រជាពលរដ្ឋក្នុងសង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋ។
- រសៀលថ្ងៃសៅរ៍ ទី២៤ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីចែកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់ប្រជាពលរដ្ឋក្រីក្រក្នុងសង្កាត់បឹងកេងកង១ (៨៧គ្រួសារ) និងសង្កាត់ទួលស្វាយព្រៃទី១ (២៦៥គ្រួសារ)។
- ព្រឹកថ្ងៃអាទិត្យ ទី២៥ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំពិធីចែកអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់ប្រជាពលរដ្ឋក្រីក្រក្នុងសង្កាត់បឹងកេងកងទី២(១៣០គ្រួសារ) និងសង្កាត់សង្កាត់ទំនប់ទឹក (៣០០គ្រួសារ)។
- ព្រឹកថ្ងៃចន្ទ ទី២៦ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំពិធីចែកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់ប្រជាពលរដ្ឋក្រីក្រក្នុងសង្កាត់បឹងកេងកងទី៣ ចំនួន ២៣៥គ្រួសារ។
- ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានធ្វើការបន្តរៀបចំចុះចែកបន្លែស្រស់ ជូនដល់បងប្អូនប្រជាពលរដ្ឋក្នុងសង្កាត់អូឡាំពិក សង្កាត់បឹងកេងកងទី៣ និងសង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង ក្រោមអធិបតីភាព**លោកជំទាវ គឹម សុវណ្ណា** តំណាងរាស្ត្រមណ្ឌលភ្នំពេញ លោក គឹម ឈុនអ៊ូ ប្រធានក្រុមប្រឹក្សាខណ្ឌ និង**លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការអញ្ជើញចូលរួមពីគណៈអភិបាលខណ្ឌ លោកស្រីអនុប្រធានអនុសាខាសមាគមនារីខណ្ឌ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេលខ្លី។
- ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំស្តីពី «ការផ្សព្វផ្សាយខ្លឹមសារសេចក្តីសម្រេច លេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលស្តីពីការបន្តបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល

ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩» ក្រោមអធិបតីភាព **ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** តាមរយៈការបញ្ជូនរូបភាព និងសម្លេង ( Video Conference )។

- ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំចុះចែកសាច់មាន់ និងបន្លែស្រស់ ជូនដល់បងប្អូនប្រជាពលរដ្ឋក្នុង សង្កាត់បឹងកេងកងទី២ និងសង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង ក្រោមអធិបតីភាព លោកជំទាវ គឹម សុវណ្ណា តំណាងរាស្ត្រមណ្ឌលភ្នំពេញ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការអញ្ជើញចូលរួមពី លោកស្រី ស៊ុយ សែនសករាជ ប្រធានអនុសាខាសមាគមនារីខណ្ឌ គណៈអភិបាលខណ្ឌ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល ។
- ព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចាត់ឱ្យរដ្ឋបាលសង្កាត់ទាំង០៧ បន្តរៀបចំចុះចែកអំណោយសប្បុរសធម៌ ជូនដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋានសង្កាត់ទាំង០៧ ក្នុងខណ្ឌបឹងកេងកង ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល។
- រសៀលថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំចុះចែកសាច់ជ្រូក ស៊ុត មី និងអង្ករ ជូនដល់បងប្អូនប្រជាពលរដ្ឋក្នុង សង្កាត់បឹងកេងកងទី៣ និងសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង ក្រោមអធិបតីភាព**លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការអញ្ជើញចូលរួមពី លោកស្រី ស៊ុយ សែនសករាជ ភរិយាលោកអភិបាលខណ្ឌ និងជាប្រធានអនុសាខាសមាគមនារីខណ្ឌ គណៈអភិបាលខណ្ឌ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល។
- ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំចុះចែកម្ហូប (មានបន្លែ សាច់ ក្នុងកញ្ចប់តែមួយ) មីកញ្ចប់ និងអង្ករ ដែលជាការចូលរួមឧបត្ថម្ភរបស់សប្បុរសជន ចែកជូនដល់បងប្អូនប្រជាពលរដ្ឋក្នុងសង្កាត់ទំនប់ទឹក និងសង្កាត់បឹងកេងកងទី៣ ក្រោមអធិបតីភាពលោកស្រី ស៊ុយ សែនសករាជ ប្រធានអនុសាខាសមាគមនារីខណ្ឌ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** តំណាង **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងមានការអញ្ជើញចូលរួមពីសប្បុរសជន និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល ។
- ព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំចុះចែកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់បងប្អូនប្រជាពលរដ្ឋក្រីក្រក្នុង សង្កាត់ទួលស្វាយព្រៃទី១ និងសង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង ក្រោមអធិបតីភាព**លោក គឹម ឈុនអ៊ី** ប្រធានក្រុមប្រឹក្សាខណ្ឌ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការអញ្ជើញចូលរួមពី លោកស្រី ស៊ុយ សែនសករាជ ភរិយាលោកអភិបាលខណ្ឌ និងជាប្រធានអនុសាខាសមាគមនារីខណ្ឌ គណៈអភិបាលខណ្ឌ លោកចៅសង្កាត់ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល ។
- ថ្ងៃសុក្រ ទី៣០ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង **លោកធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះកាយវិការដ៏ល្អប្រពៃ របស់ លោក ជា មិន ដែលបានឧបត្ថម្ភនៅ អង្ករចំនួន មួយតោន មី១០០កេសតូច ស៊ីអៀវ១០០ យួរ ជូនដល់សាលាខណ្ឌដើម្បីចែកជូនបន្តដល់ប្រជាពលរដ្ឋផ្ទាល់។
- ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំចុះចែកសាច់ជ្រូក និងបន្លែស្រស់ ជូនដល់បងប្អូនប្រជាពលរដ្ឋក្នុង ផ្លូវលេខ២៨៨ សង្កាត់បឹងកេងកងទី២ និងផ្លូវលេខ៣៥០ សង្កាត់បឹងកេងកងទី៣ ដែលមានការអញ្ជើញចូលរួមពីលោកជំទាវ គឹម សុវណ្ណា តំណាងរាស្ត្រមណ្ឌលភ្នំពេញ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** លោកស្រី ស៊ុយ សែនសករាជ ប្រធានអនុសាខាសមាគមនារីខណ្ឌ គណៈអភិបាលខណ្ឌ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល។
- ថ្ងៃសុក្រ ទី៣០ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង **លោកធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះកាយវិការដ៏ល្អប្រពៃ របស់ លោក តេង គីមហេង និងលោកស្រី តេង មុយលី ដែលបានឧបត្ថម្ភនៅ អង្ករចំនួន ២តោន ជូនដល់សាលាខណ្ឌដើម្បីចែកជូនបន្តដល់ប្រជាពលរដ្ឋផ្ទាល់។

- ព្រឹកថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំចុះចែកបន្លែស្រស់ ជូនដល់បងប្អូនប្រជាពលរដ្ឋក្នុងសង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង ដែលមានការអញ្ជើញចូលរួមដឹកនាំចែកផ្ទាល់ពី**លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងលោកស្រី ស៊ុយ សែនសករាជ ភរិយាលោកអភិបាលខណ្ឌ និងជាប្រធានអនុសាខាសមាគមនារីខណ្ឌ គណៈអភិបាលខណ្ឌ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល ។
- ព្រឹកថ្ងៃសៅរ៍ ទី០១ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានទទួលអំណោយពី លោក សុខ ហុង និងលោកស្រី ជា សុគន្ធរ័ត្ន ម្ចាស់សិប្បកម្មប្រហិត សុខ ហុង ដែលបានឧបត្ថម្ភថវិកាចំនួន ១០លានរៀល និងប្រហិតសាច់គោចំនួន ២០គីឡូក្រាម ដើម្បីផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ក្នុងការចូលរួមចំណែកជាមួយនឹងប្រមុខរាជរដ្ឋាភិបាល ទប់ស្កាត់ការរីករាលដាលនឹងជម្ងឺកូវីដ-១៩ ។
- រសៀលថ្ងៃសៅរ៍ ទី០១ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានទទួលអំណោយពីសប្បុរសជនមានដូចខាងក្រោម៖១.លោក ប៊ុន ធឿន ក្រុមហ៊ុន Zando co.ltd ឧបត្ថម្ភ អាល់កុលចំនួន ១០កាន ,ថវិកា២,០០០,០០០រៀល ។ ២.ក្រុមហ៊ុន អ៊ី-ម៉ាន់នី ផេមិន សឺលូសិន ម.ក ឧបត្ថម្ភ អង្ករ ១៥០០គីឡូ, មីជាតិ ១៥០កេស, ត្រីខ ១៥០យួរ, ថវិកា ២.០០០.០០០រៀល។ ៣.លោកវីរសេនីយ៍ឯក ចេង សាយ័ន្ត និងលោកស្រី លុយ ឡូតារ៉េហ៊្សុន ឧបត្ថម្ភ អង្ករ ៥បាវ, មី ១០កេស, ទឹកសុទ្ធ ១០កេស, ត្រីខ ១០០កំប៉ុងតូច, ទឹកត្រី ៦០ដប, ទឹកស៊ីអ៊ីវ ៦០ដប ដើម្បីផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ក្នុងការចូលរួមចំណែកជាមួយប្រមុខរាជរដ្ឋាភិបាល ទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ-១៩ ។
- ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំលើរបៀបវារៈចំនួន ០២គឺ១.ប្រជុំពិភាក្សា ណែនាំ ការចេញសារាចរបិទខ្ទប់តំបន់មួយចំនួនរបស់រាជរដ្ឋាភិបាល ២. ការកំណត់បែកចែកទីតាំងចុះចែកអំណោយជូនសង្កាត់ទាំង០៧ ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី លោកអភិបាលរងខណ្ឌ លោកនាយករងរដ្ឋបាលខណ្ឌ ចៅសង្កាត់ទាំង០៧ និងមន្ត្រីក្រោមឱវាទ។
- ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំចុះចែកបន្លែស្រស់ៗ ជូនដល់បងប្អូនប្រជាពលរដ្ឋតាមបណ្តោយផ្លូវលេខ៣៧៦ សង្កាត់បឹងកេងកងទី៣ ដែលមានការអញ្ជើញចូលរួមដឹកនាំចែកផ្ទាល់ពីលោកជំទាវ គឹម សុវណ្ណា តំណាងរាស្ត្រមណ្ឌលភ្នំពេញ លោក គឹម ឈុនអ៊ួ ប្រធានក្រុមប្រឹក្សាខណ្ឌ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និង**លោកស្រី ស៊ុយ សែនសករាជ** ភរិយាលោកអភិបាលខណ្ឌ និងជាប្រធានអនុសាខាសមាគមនារីខណ្ឌ គណៈអភិបាលខណ្ឌ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល ក្នុងអំឡុងពេលបិទខ្ទប់រាជធានីភ្នំពេញ។
- ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តចែកបន្លែស្រស់ៗ មី ស៊ុត និងអំបិល ជូនដល់បងប្អូនប្រជាពលរដ្ឋតាមបណ្តោយផ្លូវលេខ៩៥ សង្កាត់បឹងកេងកងទី៣ ដែលមានការអញ្ជើញចូលរួមដឹកនាំចែកផ្ទាល់ពី **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** អភិបាលរងខណ្ឌ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល ក្នុងអំឡុងពេលបិទខ្ទប់រាជធានីភ្នំពេញ។
- ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំចុះចែកបន្លែស្រស់ៗ ជូនដល់បងប្អូនប្រជាពលរដ្ឋតាមបណ្តោយផ្លូវលេខ៣០៤, ២៩២ និង ២៧៦ សង្កាត់បឹងកេងកងទី២ ដែលមានការអញ្ជើញចូលរួមដឹកនាំចែកផ្ទាល់ពីលោកជំទាវ គឹម សុវណ្ណា តំណាងរាស្ត្រមណ្ឌលភ្នំពេញ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងលោកស្រី ស៊ុយ សែនសករាជ ភរិយាលោកអភិបាលខណ្ឌ និងជាប្រធានអនុសាខាសមាគមនារីខណ្ឌ គណៈអភិបាលខណ្ឌ និងមន្ត្រីក្រោមឱវាទ។
- ថ្ងៃទី០៣ ខែមេសាឆ្នាំ២០២១ **លោកគឹម ឈុនអ៊ួ ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមខណ្ឌបឹងកេងកេង លោកធឹម សំអាន** ប្រធានអនុសាខាកាកបាទក្រហមខណ្ឌបឹងកេងកង លោកស្រីស៊ិន រតនា អនុប្រធានអនុសាខា និងមន្ត្រីសាលាខណ្ឌក្រោមឱវាទ បាននាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប៊ុន រ៉ានី ហ៊ុន សែន ទៅចែកជូនប្រជាពលរដ្ឋចំនួន១៨គ្រួសារ រស់នៅបន្ទប់ជួលផ្ទះលេខ២០A ផ្លូវលេខ១០៥ សង្កាត់បឹងកេងកងទី២ ដែលជាប់កាតព្វកិច្ចធ្វើចត្តាឡីស័កនៅគេហដ្ឋាន។

- ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំស្តីពី«ការត្រួតពិនិត្យការបិទខ្ទប់ភូមិសាស្ត្រ រាជធានីភ្នំពេញ និងការត្រៀមរៀបចំសម្រាប់ការបិទខ្ទប់បន្តក្រោយថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** តាមរយៈការបញ្ជូនរូបភាព និងសម្លេង (Video conference) ដោយកិច្ចប្រជុំនេះផ្តោតសំខាន់លើការងារគ្រប់គ្រងសភាពការណ៍ និងអនុវត្តតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទចុះធ្វើ «យុទ្ធនាការផ្សព្វផ្សាយពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ »ដល់បងប្អូនប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។
- ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តរៀបចំចុះចែកបន្លែស្រស់ៗ ជូនដល់បងប្អូនប្រជាពលរដ្ឋតាមបណ្តោយផ្លូវលេខ៣៧៦ ផ្លូវលេខ១១៣ និងផ្លូវលេខ៣៩៦ សង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង ដែលមានការអញ្ជើញចូលរួមដឹកនាំចែកផ្ទាល់ពីលោកជំទាវ គឹម សុវណ្ណា តំណាងរាស្ត្រមណ្ឌលភ្នំពេញ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងលោកស្រី ស៊ុយ សែនសករាជ ភរិយាលោកអភិបាលខណ្ឌ និងជាប្រធានអនុសាខាសមាគមនារីខណ្ឌ គណៈអភិបាលខណ្ឌ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល ក្នុងអំឡុងពេលបិទខ្ទប់រាជធានីភ្នំពេញ។
- រសៀលថ្ងៃអង្គារ ទី០៤ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង **លោកជំទាវ គឹម សុវណ្ណា** តំណាងរាស្ត្រមណ្ឌលភ្នំពេញ និងជាអនុប្រធានក្រុមការងារចុះជួយខណ្ឌបឹងកេងកង លោក ស្រីស៊ិន រតនា អភិបាលរង តំណាងលោកអភិបាលខណ្ឌ បានទទួលអំណោយពីលោក ទួន សារ៉េត និងលោកស្រី លឹម គីមហួយ ដែលបានឧបត្ថម្ភនៅអង្ករចំនួន១តោន ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ក្នុងការចូលរួមចំណែកជាមួយនឹងប្រមុខរាជរដ្ឋាភិបាល ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។
- ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបន្តចុះចែកអំណោយដ៏ថ្លៃថ្លារបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី និងសម្តេចកត្តិព្រឹទ្ធបណ្ឌិត** ជូនដល់បងប្អូនប្រជាពលរដ្ឋចំនួន៥៦គ្រួសារ ក្នុងភូមិទី៤ សង្កាត់បឹងកេងកងទី៣ ក្រោមអធិបតីភាព **លោកជំទាវ គឹម សុវណ្ណា** តំណាងរាស្ត្រមណ្ឌលភ្នំពេញ **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌ លោក គីមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកេង** តំណាងលោកអភិបាលខណ្ឌ ដែលមានការអញ្ជើញចូលរួមពី **លោកស្រី ស៊ុយ សែនសករាជ** ប្រធានអនុសាខាសមាគមនារីខណ្ឌ លោកចៅសង្កាត់ និងមន្ត្រីក្រោមឱវាទ ដើម្បីសម្រាលការខ្វះខាតដល់បងប្អូនប្រជាពលរដ្ឋបានមួយរយៈពេល ។
- ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌនឹងកេងកង** បានដឹកនាំគណៈបញ្ជាការឯកភាពខណ្ឌ និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំស្តីពី«ការរៀបចំផែនការការងារបិទខ្ទប់ក្រោយថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** តាមរយៈការបញ្ជូនរូបភាព និងសម្លេង ( Video Conference ) ដោយកិច្ចប្រជុំនេះផ្តោតសំខាន់លើការងារគ្រប់គ្រងសភាពការណ៍ និងអនុវត្តតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្តីពី«ការរៀបចំទីតាំងចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋតាមសង្កាត់ទាំង០៧ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** និងមានការអញ្ជើញចូលរួមពី លោក~លោកស្រី អភិបាលរងខណ្ឌ គណៈនាយករដ្ឋបាលខណ្ឌ លោក~លោកស្រី ប្រធានការិយាល័យទាំង១១ និងចៅសង្កាត់ទាំង០៧។
- រសៀលថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងឱ្យលោកអភិបាលខណ្ឌ បានទទួលអំណោយពីលោក ស្រេង ទ្រី និងលោកស្រី តាំង ស៊ុយអេង ដែលបានឧបត្ថម្ភនៅអង្ករចំនួន១តោន ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ក្នុងការចូលរួមចំណែកជាមួយនឹងប្រមុខរាជរដ្ឋាភិបាល ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។
- យប់ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ **លោកធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** លោកបានដឹកនាំកម្លាំងចុះកាប់ដើមឈើដែលរលំដោយសារភ្លៀងធ្លាក់លាយឡំ និងខ្យល់កន្ត្រាក់បណ្តាលឱ្យបាក់រលំមកលើបណ្តោយផ្លូវម៉ៅសេទុង ក្នុងសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង។

- រសៀលថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានទទួលអំណោយពីហាង សុខ ឆេង កាហ្វេ(រ៉ាន់ដា) ដែលបានឧបត្ថម្ភ អង្ករចំនួន១ តោន, ទឹកសុទ្ធចំនួន៥០ កេស, កាហ្វេចំនួន៣០ កែវ(សម្រាប់មន្ត្រីខណ្ឌ)ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ក្នុងការចូលរួមចំណែកជាមួយនឹងប្រមុខរាជរដ្ឋាភិបាល ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។
- ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំ«ស្តីពីការរៀបចំសណ្តាប់ធ្នាប់ដល់បងប្អូនអាជីវករ លក់ម្ហូបអាហារ» ក្រោមអធិបតីភាព **លោកធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី លោកនាយករង ប្រធានការិយាល័យ និងលោក-លោកស្រីចៅសង្កាត់ទាំង៧។
- ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានជួបទទួលអំណោយពីលោកឧកញ៉ា អ៊ឹង ប៊ុនហួរ និងលោកជំទាវ ហេង សុខា ដែលបានឧបត្ថម្ភ ទឹកសុទ្ធចំនួន១០០កេស ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ក្នុងការចូលរួមចំណែកជាមួយនឹងប្រមុខរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។
- ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានជួបទទួលអំណោយពី លោក ភិន ចិន្ត្រា និងលោក ឈិន ហោសៀន តំណាង លោក យ៉ាង ហួយ ប្រធានក្រុមហ៊ុន ហុង លាន គ្រុប បានឧបត្ថម្ភ អង្ករ៥០០ គីឡូ និងមី១០០កេស ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ក្នុងការចូលរួមចំណែកជាមួយនឹងប្រមុខរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។
- យប់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង បន្តដាក់គោលដៅបម្រាមគោចរ និងចុះល្បាតត្រួតពិនិត្យតាមភូមិសាស្រ្តសង្កាត់ទាំង០៧ ក្នុងខណ្ឌបឹងកេងកង ដើម្បីបន្តថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពជូនបងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។
- ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល លោកចៅសង្កាត់អូឡាំពិក ព្រមទាំងក្រុមការងារ បាននាំយកទេយ្យទានប្រគេនជូនព្រះសង្ឃដែលគង់នៅវត្តមហាមន្ត្រី មានដូចជា៖ អង្ករ១តោន, ម៉ាស២កេស, ដែល២កេស, មី៣០កេស ព្រមទាំងចូលរួមបច្ច័យមួយចំនួនដោយក្នុងមួយកុដិទទួលបានបច្ច័យ ២០ម៉ឺនរៀល សរុប៣១កុដិ។
- ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងគណៈអភិបាល គណៈនាយក បានអញ្ជើញជួបសំណេះសំណាលជាមួយកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ ព្រមទាំងឧបត្ថម្ភនូវវិទ្យុទាក់ទងថ្មី ក្នុង០១នាក់ ០១គ្រឿងដល់កម្លាំងសណ្តាប់ធ្នាប់ខណ្ឌ ដើម្បីលើកទឹកចិត្ត និងប្រើប្រាស់ក្នុងការបំពេញការងារប្រចាំថ្ងៃ។
- យប់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌ** និងលោក **កឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌ** បានបន្តដាក់គោលដៅការអនុវត្តបម្រាមគោចរ ក្នុងភូមិសាស្ត្រសង្កាត់ទាំង០៧ នៃមូលដ្ឋានខណ្ឌបឹងកេងកង។
- ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌបឹងកេងកង បានអញ្ជើញចុះត្រួតពិនិត្យការអនុវត្តបម្រាមគោចរ ក្នុងភូមិសាស្ត្រសង្កាត់ទាំង០៧ នៃមូលដ្ឋានខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។
- ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានទទួលអំណោយពីលោក វឿន ចំណាប់ តំណាងអោយក្រុមហ៊ុន តានីជូ ដែលបានឧបត្ថម្ភ អង្ករចំនួន ២តោន, មីចំនួន ៦០កេសតូច, ត្រីខចំនួន ១៥យួរ, ទឹកត្រីចំនួន ១៥យួរ, ទឹកស៊ីអៀវចំនួន ១៥យួរ ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ក្នុងការចូលរួមចំណែកជាមួយនឹងប្រមុខរាជរដ្ឋាភិបាល ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។
- ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំ « គណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការអញ្ជើញចូលរួមពី គណៈអភិបាលខណ្ឌ គណៈនាយករដ្ឋបាល ប្រធានការិយាល័យទាំង១១ ចៅសង្កាត់ទាំង០៧ និងមន្ត្រីដែលពាក់ព័ន្ធ។

- យប់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយលោក-លោកស្រីអភិបាលរងខណ្ឌបឹងកេងកង បានបន្តចុះត្រួតពិនិត្យការអនុវត្តបម្រាមគោចរ និងចុះល្បាត ក្នុងភូមិសាស្ត្រសង្កាត់ទាំង០៧ នៃមូលដ្ឋានខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។
- ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** រួមទាំងមន្ត្រីក្រោមឱវាទ បានអញ្ជើញចែកអំណោយនូវគ្រឿងឧបភោគបរិភោគមួយចំនួនរួមមាន អង្ករ ត្រីខកំប៉ុង មី ទឹកត្រី ទឹកស៊ីអៀវ ជូនដល់បងប្អូនប្រជាពលរដ្ឋក្រីក្រចំនួន២០គ្រួសារ ដែលរស់នៅតាមបណ្តោយផ្លូវលេខ៣៩៦ ក្នុងសង្កាត់បឹងកេងកងទី៣។
- ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១ កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌបឹងកេងកង លោក-លោកស្រីអភិបាលរងខណ្ឌបឹងកេងកង បានបន្តចុះត្រួតពិនិត្យការអនុវត្តបម្រាមគោចរ ក្នុងភូមិសាស្ត្រសង្កាត់ទាំង០៧ នៃមូលដ្ឋានខណ្ឌបឹងកេងកង រាជធានីភ្នំពេញ រដ្ឋបាលខណ្ឌបឹងកេងកង។
- កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយ **គណៈអភិបាលខណ្ឌ** បានចុះត្រួតពិនិត្យការអនុវត្តបម្រាមគោចរ ក្នុងភូមិសាស្ត្រសង្កាត់ទាំង០៧ នៃមូលដ្ឋានខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជាប្រចាំ។
- យប់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌបឹងកេងកង បន្តចុះត្រួតពិនិត្យការអនុវត្តបម្រាមគោចរ ក្នុងភូមិសាស្ត្រសង្កាត់ទាំង ០៧ នៃមូលដ្ឋានខណ្ឌបឹងកេងកង។
- ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំ "គណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ" ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** តាមរយៈការបញ្ជូនរូបភាព និងសម្លេង ( Video Conference ) ស្តីពីការត្រួតពិនិត្យការងារ នៃការបិទខ្ទប់ក្នុងមូលដ្ឋាន និងកិច្ចការបង្រួមតំបន់ក្រហមដោយកន្លែងមកជាខ្នងផ្ទះ កែប្រែតំបន់លឿងទុំ មកជាតំបន់លឿង ដើម្បីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង និងការចូលរួមអនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាល និងចូលរួមគោរពតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- យប់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌបឹងកេងកង បានបន្តចុះត្រួតពិនិត្យការអនុវត្តបម្រាមគោចរ ក្នុងភូមិសាស្ត្រសង្កាត់ទាំង០៧ នៃមូលដ្ឋានខណ្ឌបឹងកេងកង។
- ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ **លោកជំទាវ ឱ វណ្ណឌីន** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការចំពោះកិច្ចការចាក់វ៉ាក់សាំង បានចុះត្រួតពិនិត្យដំណើរការ ការចាក់វ៉ាក់សាំងនៅវិទ្យាល័យជាស៊ីមបឹងកេងកង ក្នុងសង្កាត់បឹងកេងកងទី១។ ក្នុងនោះដែរក៏មានការអមដំណើរដោយ **ឯកឧត្តម ហួត ហៃ** អភិបាលរងរាជធានីភ្នំពេញ និង **លោក ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង រួមទាំងក្រុមការងារ។
- យប់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា** អភិបាលរងខណ្ឌបឹងកេងកង បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌបឹងកេងកង បានបន្តចុះត្រួតពិនិត្យការអនុវត្តបម្រាមគោចរ និងចុះល្បាត ក្នុងភូមិសាស្ត្រសង្កាត់ទាំង០៧ នៃមូលដ្ឋានខណ្ឌបឹងកេងកង។
- ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំស្តីពី "ផែនការបិទខ្ទប់ តំបន់លឿង លឿងទុំ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ" ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ តាមរយៈការបញ្ជូនរូបភាព និងសម្លេង(Video Conference) ស្តីពីការត្រួតពិនិត្យការងារនៃការបិទខ្ទប់ក្នុងមូលដ្ឋាន និងកិច្ចការបង្រួមតំបន់ក្រហមដោយកន្លែងមកជាខ្នងផ្ទះ កែប្រែតំបន់លឿងទុំ មកជាតំបន់លឿង ដើម្បីផ្តល់ភាពងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង។
- ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង បានដឹកនាំមន្ត្រី និងកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ ចុះកាត់មែកឈើដែលធ្លាក់នៅតាមបណ្តោយ មហាវិថីម៉ៅសេទុង ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង ។

- ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ **លោកជំទាវ ពេជ ចន្ទមុន្នី** ប្រធានក្រុមប្រឹក្សាភិបាល សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ(TYDA) រួមជាមួយ លោក-លោកស្រី អភិបាលរងខណ្ឌបឹងកេងកង បានចុះត្រួតពិនិត្យដំណើរការ ការចាក់វ៉ាក់សាំង និងជួបសំណេះសំណាល ជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តព្រមទាំងក្រុមការងារ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង ចំនួនពីរមណ្ឌលរួមមាន៖ មណ្ឌលទី១ អនុវិទ្យាល័យទួលស្លែង ក្នុងសង្កាត់ទួលស្វាយព្រៃទី១, មណ្ឌលទីពីរ វត្តមហាមន្ត្រី ក្នុងសង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង។
- រសៀលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំ "ផ្សព្វផ្សាយខ្លឹមសាររបស់រដ្ឋបាលរាជធានីភ្នំពេញ" ក្រោមអធិបតីភាព **លោក ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង ដែលមានការចូលរួមពីគណៈអភិបាល គណៈនាយករដ្ឋបាល ប្រធានការិយាល័យ ចៅសង្កាត់ទាំង៧ ផ្សារទាំង២ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យ នៃការដាក់ចេញវិធានការរដ្ឋបាលសម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងវិធានការអនុវត្តបន្តក្រោយថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ តាមរយៈការបញ្ជូនរូបភាព និងសម្លេង (Video Conference) ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។
- ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ **លោក ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង បានដឹកនាំក្រុមការងារ សហការជាមួយចៅសង្កាត់បឹងកេងកងទី៣ ចុះធ្វើការស្តារប្រឡាយ-លូតាមបណ្តោយផ្លូវលេខ៣៩៦(ចាប់ពីផ្លូវ១៦៣ ដល់ផ្លូវ១០៥) ក្នុងសង្កាត់បឹងកេងកងទី៣ ក្នុងគោលបំណងដោះស្រាយបញ្ហាជូនបងប្អូនប្រជាពលរដ្ឋពីការកកស្ទះលូ-ប្រឡាយ ក្នុងភូមិសាស្ត្រខណ្ឌបឹងកេងកង ដើម្បីជានាមិនឱ្យមានការជន់លិច នៅពេលមានភ្លៀងធ្លាក់មកម្តងៗ។
- ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំសាមញ្ញលើកទី២៤ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ូ** ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង **លោក ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីប្រគល់ថវិកាមរណៈសង្គ្រោះរបស់សមាគមអតីតយុទ្ធជនកម្ពុជាចំនួន ៤,០០០,០០០រៀល ជូនដល់ក្រុមគ្រួសារសពលោក វិញ គីម (ជនពិការ) ជាសមាជិកសមាគមអតីតយុទ្ធជនកម្ពុជារាជធានីភ្នំពេញ ក្រោមអធិបតីភាព **លោក ម៉ៅ កុលម៉ារឌី** អភិបាលរងខណ្ឌបឹងកេងកង តំណាងលោកអភិបាលខណ្ឌ ដោយមានការអញ្ជើញចូលរួមពីលោកអធិការរងនគរបាលខណ្ឌ តំណាងមេបញ្ជាការរងកងរាជអាវុធហត្ថខណ្ឌ តំណាងយោធភូមិភាគពិសេសខណ្ឌ ប្រធានការិយាល័យសង្គមកិច្ចខណ្ឌ ចៅសង្កាត់រងអូឡាំពិក នាយរងប៉ុស្តិ៍នគរបាលសង្កាត់អូឡាំពិក ក្រុមគ្រួសារសព និងមន្ត្រីដែលពាក់ព័ន្ធ។
- ព្រឹកថ្ងៃពុធ ទី០២ ខែមិថុនា ឆ្នាំ២០២១ **លោកជំទាវ គឹម សុវណ្ណារ៉ា** តំណាងរាស្ត្រមណ្ឌលភ្នំពេញ និងជាអនុប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខណ្ឌបឹងកេងកង **លោក ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង **លោកស្រី ស៊ុយ សែនសករាជ** ជាប្រធានអនុសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខណ្ឌ **លោកស្រី ស៊ិន រតនា** អភិបាលរងខណ្ឌ បានចុះសួរសុខទុក្ខ និងបានឧបត្ថម្ភថវិកាមួយចំនួន ជូនក្រុមការងារសមាគមនារី ក៏ដូចជាក្រុមការងារខណ្ឌ-សង្កាត់ ដែលប្រចាំការសម្របសម្រួល តាមមណ្ឌលចាក់វ៉ាក់សាំង ទាំង០៨មណ្ឌល ក្នុង០៧សង្កាត់ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។
- រសៀលថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១ **លោក ធឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំ«ការដាក់ចេញវិធានការរដ្ឋបាលបន្ត សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងវិធានការអនុវត្តបន្ត» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ តាមរយៈការបញ្ជូនរូបភាព និងសម្លេង(Video Conference)។
- ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ **លោក គីមណៃ វីរៈខេមរា** អភិបាលរងខណ្ឌបឹងកេងកង តំណាងលោកអភិបាលខណ្ឌ បានដឹកនាំកិច្ចប្រជុំសំណេះសំណាល និងណែនាំបន្ថែមដល់កម្លាំងសណ្តាប់ធ្នាប់ខណ្ឌ ដើម្បីបន្តថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងអនុវត្តតាមសេចក្តីសម្រេចរបស់សាលារាជធានីភ្នំពេញ ដើម្បីទទួលបានប្រសិទ្ធិភាពខ្ពស់ជូនប្រជាពលរដ្ឋ ពិសេសក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩។

- ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ **លោក ជឹម សំអាន** អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង(Video Conference) «ស្តីពីការងារពាក់ព័ន្ធការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ លើកម្មករ-កម្មការិនី ដែលកំពុងតែបំរើការងារលើវិស័យកាត់ដេរ តាមរោងចក្រកាត់ដេរទាំងអស់ក្នុងរាជធានីភ្នំពេញ»ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ដើម្បីស្វែងរកដំណោះស្រាយ និងបច្ចេកទេស ការធ្វើបច្ចុប្បន្នភាពរបស់បងប្អូនកម្មករ-កម្មការិនីរស់នៅ ដែលបង្កភាពងាយស្រួលក្នុងការគ្រប់គ្រង ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ តាមរោងចក្រ តាមបន្ទប់ជួលដែលបងប្អូនកម្មករ-កម្មការិនីរស់នៅទាំងអស់ក្នុងរាជធានីភ្នំពេញ។
- ព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ **លោក ជឹម សំអាន** អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង បានដឹកនាំមន្ត្រីក្រោមឱវាទ សហការណ៍ជាមួយរដ្ឋបាលសង្កាត់ទួលស្វាយព្រៃទី១ ចុះចែកអំណោយជូនបងប្អូនដែលខ្វះខាតតាមខ្នងផ្ទះមួយចំនួនក្នុងកំឡុងពេលកូវីដ-១៩ ដែលស្ថិតនៅភូមិ៦ និង៧ ក្នុងសង្កាត់ទួលស្វាយព្រៃទី១។
- ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានចូលរួមកិច្ចប្រជុំស្តីពី «កិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ» តាមរយៈការបញ្ជូនរូបភាព និងសម្លេង( Video Conference) ក្រោមអធិបតីភាព **ឯកឧត្តម ប្រាក់ សំអឿន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ។
- ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីទទួលថ្នាំពេទ្យចំនួនប្រាំបីរយកញ្ចប់តូច (៨០០កញ្ចប់តូច) រួមនឹងទឹកកកអនាម័យម៉ាកEVA ក្រោមអធិបតីភាព **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និង លោក APICHART DUANG-ART ប្រធានក្រុមហ៊ុន EVA។
- ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** សហការជាមួយក្រុមការងារ ក្រសួងសុខាភិបាល លោក ហុក ខៀវ ប្រធាន នាយកដ្ឋាននីតិកម្ម បាននាំយកថវិការបស់រាជរដ្ឋាភិបាលជូនដល់ក្រុមគ្រួសារសព ដែលស្លាប់ដោយជំងឺកូវីដ១៩ ដោយក្នុងមួយគ្រួសារ ទទួលបានថវិកា ចំនួន ៥.០០០.០០០៛ ក្នុងនោះមានចំនួន២គ្រួសារៈ ១.ក្រុមគ្រួសារសព ឈ្មោះ ទ្រី ហ៊ី អាយុ ៨២ ឆ្នាំ ក្នុងសង្កាត់ទំនប់ទឹក ២.ក្រុមគ្រួសារសព ឈ្មោះ សៀក លីន អាយុ៧០ឆ្នាំ ក្នុងសង្កាត់បឹងកេងកងទី២។
- ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរង** តំណាង **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានរៀបចំកិច្ចប្រជុំ«ស្តីពីការត្រួតពិនិត្យទៅលើគ្រឿងចក្រ និងរ៉ឺម៉កកង់បីដឹកសំរាមតាមមូលដ្ឋានទាំង១៤ខណ្ឌ នៅរាជធានីភ្នំពេញ តាមរយៈប្រព័ន្ធវីដេអូZoom ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ**។
- ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និង **អភិបាលរងខណ្ឌ** បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី «ការត្រួតពិនិត្យដាក់ចេញសេចក្តីសម្រេចលេខ ១៦០/២១ សសរ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ និងការងារចាក់វ៉ាក់សាំង សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ តាមរយៈ (Video Zoom Meetings)» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**។
- ព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញទទួលអំណោយពីលោក លី កងវង អគ្គនាយកក្រុមហ៊ុន ចិមកលគ្រុប ដែលបានឧបត្ថម្ភដូចជាៈ ទឹកសុទ្ធចំនួន ១០០កេស និងអាល់កុលចំនួន ៣០០លីត្រ ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ដើម្បីចូលរួមចំណែកក្នុងសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងមូលដ្ឋានខណ្ឌ។
- ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ នាំយកនូវអំណោយមួយចំនួនរួមមាន អង្ករចំនួន ១១បាវ ត្រីខចំនួន ៥០យួរ មីចំនួន ១០០កេស ទឹកត្រីចំនួន ១១យួរ ទឹកស៊ីអ៊ីវចំនួន ១១យួរ ម៉ាសចំនួន ២៥០០ និងទឹកសុទ្ធចំនួន ៧០កេស ដើម្បីចែកជូនដល់បងប្អូនកម្មករ ចំនួន ២៣៩នាក់ ដែលកំពុងធ្វើចត្តាឡីស័កនៅវិទ្យាល័យ ជា ស៊ីម បឹងកេងកង ដែលមានការខ្វះខាតព្រោះខាងក្រុមហ៊ុនមិនទាន់បានចាត់ចែងស្បៀងអាហារជូនដល់កម្មករនៅឡើយ។
- ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយ **ឯកឧត្តម នួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះត្រួតពិនិត្យ

សណ្តាប់ធ្នាប់ និងទីតាំងពិនិត្យសំណាករបស់បងប្អូនអាជីវករនៅផ្សារបឹងកេងកង ដែលស្ថិតនៅវិទ្យាល័យ ជា ស៊ីម បឹងកេងកង ក្នុងសង្កាត់បឹងកេងកងទី១។

- ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ក្រុមប្រឹក្សាខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំសាមញ្ញលើកទី២៥ អាណត្តិទី៣ ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ី** ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង ដោយមានការអញ្ជើញចូលរួមពី គណៈអភិបាលខណ្ឌ គណៈនាយក ចៅសង្កាត់ទាំង៧ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង លោកស្រី ស៊ិន រតនា អភិបាលរង លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌ** បានចូលរួមកិច្ចប្រជុំ សិក្ខាសាលាផ្សព្វផ្សាយតាមអនឡាញស្តីពី«កាតព្វកិច្ចពន្ធលើប្រាក់ចំណេញមូលធន» តាមរយៈវីដេអូZoom ក្រោមអធិបតីភាព **ឯកឧត្តម ភើត ឆៃ អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** សហការជាមួយក្រុមការងារ ក្រសួងសុខាភិបាល លោក ហុក ខៀវ ប្រធាននាយកដ្ឋាននីតិកម្ម បាននាំយកថវិការបស់រាជរដ្ឋាភិបាល ជូនដល់ក្រុមគ្រួសារសព ដែលស្លាប់ដោយជំងឺកូវីដ១៩ ដោយក្នុងមួយគ្រួសារទទួលបានថវិកា ចំនួន ៥,០០០,០០០ រៀល ក្នុងនោះមានចំនួន ២គ្រួសារ៖១.សង្កាត់បឹងកេងកងទី៣ សពឈ្មោះ ប្រាក់ ស៊ីវន អាយុ ៧៤ឆ្នាំ ២.សង្កាត់ទួលស្វាយព្រៃទី១ សពឈ្មោះ ខេង ហៀង អាយុ ៧២ឆ្នាំ។
- ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌ** តំណាងលោកអភិបាលខណ្ឌ បានរៀបចំពិធីប្រគល់ថវិកាមរណៈសង្គ្រោះរបស់សមាគមអតីតយុទ្ធជនកម្ពុជាចំនួន ៤,០០០,០០០រៀល ជូនដល់ក្រុមគ្រួសារសពលោក ឈុំ គឹមវាសនា( និវត្តជន ) ជាសមាជិកសមាគមអតីតយុទ្ធជនកម្ពុជារាជធានីភ្នំពេញ។
- ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយ **ឯកឧត្តម នួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** លោកបានអញ្ជើញចុះត្រួតពិនិត្យសណ្តាប់ធ្នាប់ និងទីតាំងពិនិត្យសំណាករបស់បងប្អូនអាជីវករនៅផ្សារអូឡាំពិក ដែលស្ថិតនៅវិទ្យាល័យទួលស្វាយព្រៃ ក្នុងសង្កាត់ទួលស្វាយព្រៃទី២។
- ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង (Video Conference)« ស្តីពីផែនការត្រួតពិនិត្យការផ្តល់ការព្យាបាលអ្នកជំងឺកូវីដ-១៩នៅតាមផ្ទះ» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ។
- ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ នៅសាលប្រជុំសាលាខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំ «សាមញ្ញរដ្ឋបាលខណ្ឌបឹងកេងកង ស្តីពីការពង្រឹងយន្តការរដ្ឋបាលការិយាល័យទាំង១១ និងបន្តពង្រឹងវេនប្រចាំបញ្ហាការរបស់រដ្ឋបាលខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការអញ្ជើញចូលរួមពី គណៈអភិបាលខណ្ឌ គណៈនាយករដ្ឋបាល ប្រធានការិយាល័យទាំង១១ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌ** តំណាងលោកអភិបាលខណ្ឌ បានចូលរួមក្នុងកិច្ចប្រជុំដកបទពិសោធន៍ស្តីពីការផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងនៅរាជធានីភ្នំពេញ របស់ប្រតិបត្តិករថ្មីទាំង៣ ដែលបានចាប់ផ្តើមផ្តល់សេវាចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ តាមរយៈ ZOOM ក្រោមអធិបតីភាព **ឯកឧត្តម ភើត ឆៃ** និង**ឯកឧត្តម ហួត ហៃ អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ**។
- ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីសំណេះសំណាល និងចែកអំណោយ របស់មូលនិធិ រ៉ក់ កម្ពុជា(Rock Foundation Cambodia) ជូនដល់បងប្អូនប្រជាពលរដ្ឋចំនួន ២៥០គ្រួសារ ក្នុងមូលដ្ឋានសង្កាត់ទាំង៧ ក្នុងខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងលោក ប្រេដ មេដលីន ប្រធានមូលនិធិ រ៉ក់ កម្ពុជា (Mr. BRETT MEDLIN) ដើម្បីរួមចំណែកក្នុងការងារសង្គមកិច្ច និងមនុស្សធម៌ តាមរយៈសកម្មភាពរបស់រដ្ឋបាលខណ្ឌបឹងកេងកង។
- ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង (Video Conference)

«ស្តីពីការគ្រប់គ្រងការព្យាបាលអ្នកជំងឺកូវីដ-១៩នៅតាមផ្ទះ» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ។**

- ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការគ្រប់គ្រងការព្យាបាលអ្នកជំងឺកូវីដ១៩ នៅតាមផ្ទះ តាមរយៈប្រព័ន្ធ Zoom ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។**
- ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ ដោយយោងតាមកិច្ចប្រជុំរបស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការគ្រប់គ្រងការព្យាបាលអ្នកជំងឺកូវីដ-១៩នៅតាមផ្ទះ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំ «ស្តីពីការផ្តល់នីតិវិធីព្យាបាលអ្នកជំងឺកូវីដ-១៩នៅតាមផ្ទះ» ក្រោមអធិបតីភាព **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី គណៈអភិបាល គណៈនាយក លោកអធិការនគរបាលខណ្ឌ លោក-លោកស្រី ប្រធាន អនុប្រធានការិយាល័យ លោក-លោកស្រីចៅសង្កាត់ទាំង០៧ និងមន្ត្រីក្រោមឱវាទ។
- ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌ** បានធ្វើកិច្ចអន្តរាគមន៍ទៅរដ្ឋាករទឹកស្វយតក្រុងភ្នំពេញ ដើម្បីធ្វើការជួសជុលប្រព័ន្ធទឹកស្អាតមួយកន្លែង ដែលបានលេចធ្លាយនៅចំណុច មុខសាខាកាកបាទក្រហមរាជធានីភ្នំពេញ ផ្លូវលេខ៣៦៤ សង្កាត់ទួលស្វាយព្រៃទី២ តាមសំណើរបស់លោក យន់ ចាន់ ចៅសង្កាត់ទួលស្វាយព្រៃទី២ (រដ្ឋាករទឹកបានជួសជុលរួចហើយ)។
- ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្តីពី« សំណើ/បញ្ហានានា លើកឡើងក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ នៅខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ី** ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង ដោយមានការអញ្ជើញចូលរួមពី លោក-លោកស្រី អភិបាលរងខណ្ឌ គណៈនាយករដ្ឋបាលខណ្ឌ តំណាងមេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ យុទ្ធភូមិភាគ ប្រធានការិយាល័យ ចៅសង្កាត់ទាំង០៧ និងមន្ត្រីពាក់ព័ន្ធ។
- ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង (Video Conference) «ស្តីពីការរៀបចំយន្តការអនុវត្តលិខិតលេខ ៣៣៩ សខល ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ស្តីពីការអប់រំណែនាំបន្ថែម អំពីសុវត្ថិភាពក្នុងការគ្រប់គ្រង និងចាត់ចែងសាកសពដែលមានផ្ទុកវីរុសកូវីដ-១៩ នៅរាជធានីភ្នំពេញ» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ។**
- ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានធ្វើកិច្ចអន្តរាគមន៍ ទៅមន្ទីរសាធារណការ ដឹកជញ្ជូន រាជធានីភ្នំពេញ ដើម្បីកាប់ដើមឈើ ០១ដើម ស្ថិតនៅចន្លោះផ្ទះលេខ១២៨ និងផ្ទះលេខ១៣១ ផ្លូវម៉ៅសេទុង សង្កាត់បឹងកេងកងទី៣ តាមសំណើរស្នើសុំរបស់ប្រជាពលរដ្ឋ។ (មន្ទីរសាធារណការ បានមកកាប់ចេញរួចហើយ)
- ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង «ក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការត្រួតពិនិត្យនៃការដាក់ចេញសេចក្តីសម្រេចលេខ២០៩/២១ សសរ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។**
- **ព្រឹកថ្ងៃអង្គារ ទី២០ ខែកក្កដា ឆ្នាំ២០២១** លោក ហេង **ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាទំនាស់ជាប់ព្រំវាំងផ្ទះលេខ១០ហ្សិត និងផ្ទះលេខ៦៥ ផ្លូវលេខ៤៣០ សង្កាត់ទំនប់ទឹក» ដោយមានការ ចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់ទំនប់ទឹក និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ក្រោមការចង្អុលបង្ហាញរបស់លោកអភិបាលខណ្ឌ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌ** បានដឹកនាំមន្ត្រី និងកម្លាំងប្រជាការពារចុះរៀបចំសណ្តាប់ធ្នាប់ នៅតាមបណ្តោយផ្លូវលេខ៣១០ សង្កាត់ទួលស្វាយព្រៃទី១ និងផ្លូវលេខ៣០០ កែងផ្លូវលេខ១១៣ សង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង។
- ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានធ្វើកិច្ចអន្តរាគមន៍ទៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ដើម្បីកាប់ដើមឈើមួយដើម ស្ថិតនៅផ្លូវលេខ៣១០ សង្កាត់បឹងកេងកងទី១ តាមសំណើរបស់លោកស្រីចៅសង្កាត់បឹងកេងកងទី១។ (មន្ទីរសាធារណការ បានមកកាប់ចេញរួចហើយ)

- ព្រឹកថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយគម្រោង «ការឆ្លើយតបចម្រុះលើការបង្ការ និងការគាំពារចំពោះជម្ងឺកូវីដ១៩ សម្រាប់សហគមន៍ងាយរងគ្រោះក្នុងរាជធានីភ្នំពេញ» តាមរយៈការបញ្ជូនរូបភាព និងសម្លេង (Zoom) ដែលរៀបចំដោយអង្គការភើន។
- ព្រឹកថ្ងៃសុក្រ ទី២៣ ខែកក្កដា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាទំនាស់ជាប់ព្រំរវាងម្ចាស់ផ្ទះលេខ៧០ដេ និងម្ចាស់ផ្ទះលេខ៧២អាអឺ ផ្លូវលេខ៣២៨ សង្កាត់ទួលស្វាយព្រៃទី២» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់ទួលស្វាយព្រៃទី២ និងភាគីដែលពាក់ព័ន្ធ។
- រសៀលថ្ងៃសុក្រ ទី២៣ ខែកក្កដា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ចុះពិនិត្យទីតាំងវិវាទ «មានបណ្តឹងអ្នកជិតខាង ពីការសាងសង់រោងដែកលើច្រកផ្លូវពុំមានលិខិតអនុញ្ញាត នៅចំនុចដីឡូត៏លេខ៣៨ ផ្លូវលេខ៣៥០ ភូមិ៣ សង្កាត់បឹងកេងកងទី៣» ។
- ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង (Zoom) «ស្តីពីការរៀបចំការងារចាក់វ៉ាក់សាំងបង្កាជំងឺកូវីដ-១៩ ជូនកុមារ និងយុវវ័យដែលមានអាយុ១២ឆ្នាំ ដល់ក្រោម១៨ឆ្នាំ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។
- ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ «ការរៀបចំការងារចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនកុមារ និងយុវវ័យដែលមានអាយុ១២ឆ្នាំ ដល់ក្រោម១៨ឆ្នាំ» នៅក្នុងសង្កាត់ទាំង០៧ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពីលោកនាយករង លោក-លោកស្រីប្រធានការិយាល័យ និងចៅសង្កាត់ទាំង០៧។
- ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំ តាមរយៈការបញ្ជូនរូបភាព និងសម្លេង ( Video Conference ) អនុវត្តសេចក្តីសម្រេចលេខ២៤៩/២១ សសរ ស្តីពីការដាក់ចេញនូវវិធានការរដ្ឋបាល នៅក្នុងមូលដ្ឋានខណ្ឌបឹងកេងកង សម្រាប់រយៈពេល១៤ថ្ងៃ គិតចាប់ពីម៉ោង ២៣:៥៩នាទី នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។
- ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និង**លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានចុះត្រួតពិនិត្យទីតាំងក្លឹបN8 ស្នើសុំឱ្យជួយជួសជុល ស្ថិតលើផ្លូវលេខ២៨៦ សង្កាត់ទួលស្វាយព្រៃទី២។
- ព្រឹកថ្ងៃព្រហស្បតិ៍ ទី២៩ ខែកក្កដា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី«បញ្ហាទំនាស់ជាប់ព្រំរវាងម្ចាស់ផ្ទះលេខ៣អា និងម្ចាស់ផ្ទះលេខ៣ស៊ី សង្កាត់បឹងកេងកងទី៣» ដោយមានការ ចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់បឹងកេងកងទី៣ និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំសាមញ្ញលើកទី២៦ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ូ ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី សមាជិក~សមាជិកាក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ នាយករងរដ្ឋបាលខណ្ឌ លោក~លោកស្រីប្រធានការិយាល័យ ចៅសង្កាត់ទាំង០៧ និងមន្ត្រីពាក់ព័ន្ធ។
- ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រី និងកម្លាំងគណៈបញ្ជាការខណ្ឌ ចុះរៀបចំ និងត្រួតពិនិត្យទីតាំងចាក់វ៉ាក់សាំងបង្កាជំងឺកូវីដ-១៩ ដល់កុមារ និងយុវវ័យដែលមានអាយុ១២ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ដែលនឹងចាប់ផ្តើមនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១ នៅមណ្ឌលសុខភាពទួលស្វាយព្រៃ ក្នុងសង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង។
- ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំកម្លាំងមន្ត្រីក្រោមឱវាទ ចុះល្បាត អនុវត្តបម្រាមគោចរ តាមសេចក្តីសម្រេចលេខ ២៤៩/២១ សសរ របស់រដ្ឋបាលរាជធានីភ្នំពេញចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ តាមគោលដៅត្រួតពិនិត្យវិធានការរដ្ឋបាល នៅក្នុងមូលដ្ឋាន

ខណ្ឌបឹងកេងកង ដោយផ្អាកជាបណ្ដោះអាសន្ននូវរាល់ការធ្វើចរាចរណ៍ និងរាល់សកម្មភាព ការងារ មុខរបរ ឬ អាជីវកម្ម នៅចន្លោះម៉ោង២១ ដល់ម៉ោង៣ទាបភ្លឺ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

- យប់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំកម្លាំងមន្ត្រីក្រោមឱវាទ បន្តចុះល្បាត អនុវត្តបម្រាមគោចរ តាមសេចក្តីសម្រេចលេខ ២៤៩/២១ សសរ របស់រដ្ឋបាលរាជធានីភ្នំពេញចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ តាមគោលដៅត្រួតពិនិត្យវិធានការរដ្ឋបាល នៅក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។
- ព្រឹកថ្ងៃអាទិត្យ ទី០១ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញ ចុះប្រកាសបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនកុមារ និងយុវវ័យដែលមានអាយុ១២ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ស្ថិតនៅមណ្ឌលសុខភាពទួលស្វាយព្រៃ ផ្លូវលេខ៣៦៤ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង។
- ព្រឹកថ្ងៃចន្ទ ទី០២ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញទទួលអំណោយពី លោក ឃ្លោក វីរៈ និងលោកស្រី លី រ៉េនលីដា ម្ចាស់អាជីវកម្មលក់ម៉ូតូ វីរៈ២៨៩ ដែលបានឧបត្ថម្ភ ទឹកសុទ្ធចំនួន ២០យួរ, មី ២០កេស, ទឹកត្រី២០យួរ, ទឹកស៊ីអ៊ីវ ២០យួរ, អង្ករ ១តោន ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ដើម្បីចូលរួមចំណែកក្នុងសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ការការឆ្លងរីករាលនៃជំងឺកូវីដ-១៩ នៅក្នុងមូលដ្ឋានខណ្ឌ។
- ល្ងាចថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យសេចក្តីព្រាងតារាងតម្លៃថ្មី លើសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ តាមរយៈវីដេអូ Zoom ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ។**
- ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំ តាមរយៈការបញ្ចូនរូបភាព និងសម្លេង ( Video Conference ) "ស្តីពីកិច្ចប្រជុំដកពិសោធន៍ការត្រួតពិនិត្យការអនុវត្តវិធានការរដ្ឋបាលពីថ្ងៃទី២៩ ខែកក្កដា ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ និងត្រួតពិនិត្យការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនកុមារ និងយុវវ័យ ដែលមានអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ សម្រាប់ជុំសទី១ ចាប់ផ្តើមពីថ្ងៃទី០១ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១" ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។**
- ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំ «គណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការអញ្ជើញចូលរួមពី អភិបាលរងខណ្ឌ គណៈនាយករដ្ឋបាល យោធភូមិភាគខណ្ឌ លោក~លោកស្រីប្រធានការិយាល័យ ចៅសង្កាត់ទាំង០៧ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ៩:០០ព្រឹក **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកេង** បានចូលរួមក្នុងកិច្ចពិភាក្សាប្រជុំស្តីពី ការឆ្លងសេចក្តីព្រាងតារាងតម្លៃសេវាប្រមូលសំរាមក្នុងរាជធានីភ្នំពេញ នៅសាលប្រជុំជាន់ទី២ សាលាខណ្ឌបឹងកេងកង។
- ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ៨:០០នាទីព្រឹក **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមប្រជុំតាម ZOOM ស្តីពីវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយបន្ត ស្តីពីកម្មវិធីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចុះថ្លែងអំណរគុណ ចំពោះប្រជាពលរដ្ឋរស់នៅអមសងខាងកំណាត់ផ្លូវលេខ២៧៨ ចន្លោះផ្លូវលេខ៥៧ និងផ្លូវលេខ៦៣ ដែលបានសហការជាមួយរដ្ឋបាលខណ្ឌ-សង្កាត់ និងក្រុមគ្រូពេទ្យ TYDA ចុះយកសំណាក ករណីសង្ស័យមានឆ្លងវីរុសកូវីដ-១៩ បំលែងថ្មី ដែលតា (Delta) ក្នុងសហគមន៍ ជាលទ្ធផលចំនួន ៥៦នាក់ (ស្រី ២១នាក់) អវិជ្ជមានទាំងអស់។
- ព្រឹកថ្ងៃសុក្រ ទី០៦ ខែសីហា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាទំនាស់រវាងម្ចាស់ផ្ទះលេខ៤៥០បេ និងអ្នកជួលផ្ទះផ្លូវលេខ១៦៣ សង្កាត់បឹងកេងកងទី៣» ដោយមាន ការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់បឹងកេងកងទី៣ និងភាគីដែលពាក់ព័ន្ធ។

- ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ **លោកគឹម ឈុនអ៊ួ ប្រធានក្រុមប្រឹក្សាខណ្ឌ** និង **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានបន្តអញ្ជើញចុះត្រួតពិនិត្យសកម្មភាពចាក់វ៉ាក់សាំងជូនកុមារ និងយុវវ័យ ដែលមានអាយុចាប់ពីកុមារ និងយុវវ័យដែលមានអាយុ១២ឆ្នាំ ដល់ក្រោម១៨ឆ្នាំ នៅមណ្ឌលសុខភាពទួលស្វាយព្រៃ ផ្លូវលេខ៣៦៤ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង។
- ព្រឹកថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** រួមជាមួយលោក-លោកស្រី អភិបាលរងខណ្ឌបឹងកេងកង បានចុះត្រួតពិនិត្យការដ្ឋាន The Flora suites ស្ថិតនៅលើផ្លូវលេខ៧១ កែងផ្លូវលេខ៣៩២ ក្នុងសង្កាត់បឹងកេងកងទី១។
- ព្រឹកថ្ងៃចន្ទ ទី០៩ ខែសីហា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ ចុះពិនិត្យទីតាំងសំណង់ «ការដ្ឋានសំណង់អគារស្នាក់នៅរួម ឌីផ្លូរ៉ាស្វីត ដែលមានករណីបាក់ស្រុតផ្លូវ ផ្លូវលេខ៧១ ភូមិ៩ សង្កាត់បឹងកេងកងទី១»។
- ព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្តីពី «វគ្គបណ្តុះបណ្តាលបន្តស្តីពីកម្មវិធី ពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ» ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង**។
- ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំកម្លាំងមន្ត្រីក្រោមឱវាទ អញ្ជើញចុះត្រួតពិនិត្យការដ្ឋានមួយកន្លែងដែលកំពុងតែសាងសង់ ស្ថិតនៅលើផ្លូវលេខ៧១ កែងផ្លូវលេខ៣៩២ ក្នុងសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង។
- ព្រឹកថ្ងៃព្រហស្បតិ៍ ទី១២ ខែសីហា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាទំនាស់ជាប់ព្រំរវាងម្ចាស់ផ្ទះលេខ៤អឺ០ និងម្ចាស់ផ្ទះលេខ៤អឺ១ សង្កាត់អូឡាំពិក» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់អូឡាំពិក និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ៣:00 នាទីល្ងាច **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមប្រជុំតាមZOOM ក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការផ្តល់ជំនួយសេវាសង្គម ដល់គ្រួសារដែលមានសមាជិកស្លាប់ដោយសារកូវីដ-១៩ នៅរាជធានីភ្នំពេញ។
- ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ វេលម៉ោង ៩:០០នាទីព្រឹក **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមតាម ZOOM ក្នុងកិច្ចប្រជុំពិភាក្សាជកពិសោធន៍ ការត្រួតពិនិត្យ ការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់នៃការអនុវត្តបម្រាបគោចរ នៅក្នុងភូមិសាស្រ្តរាជធានីភ្នំពេញ។
- ព្រឹកថ្ងៃសុក្រ ទី១៣ ខែសីហា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី«បញ្ហាទំនាស់ជាប់ព្រំរវាងម្ចាស់ផ្ទះលេខ១៣៧ និងម្ចាស់ផ្ទះលេខ១៣៥ សង្កាត់ទួលស្វាយព្រៃទី១» ដោយ មានការចូលរួមពី ប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល សង្កាត់ទួលស្វាយព្រៃទី១ និងភាគីដែលពាក់ព័ន្ធ។
- ព្រឹកថ្ងៃសៅរ៍ ទី១៤ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំ មន្ត្រីជំនាញ និងរដ្ឋបាលសង្កាត់ បានចុះពិនិត្យទីតាំង «ការដ្ឋានសាងសង់ពុំមានច្បាប់អនុញ្ញាតហើយរំលោភលើដីសាធារណៈ របស់រដ្ឋក្នុងបរិវេណសាលាវិទ្យាល័យព្រះយុគន្ធរ សង្កាត់បឹងកេងកងទី២»។
- ព្រឹកថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ួ ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** និង**លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយចំនួន ២ទីតាំង ទីតាំងទី១ នៅសាលាទួលស្វាយព្រៃ ដែលមានប្រជាពលរដ្ឋចំនួន ៤០គ្រួសារ ដែលអញ្ជើញមកពីភូមិទាំង១១ ក្នុងសង្កាត់ទួលស្វាយព្រៃទី២។ ក្នុងមួយគ្រួសារទទួលបាន អង្ករ ចំនួន ២៥គីឡូ, មីម៉ាម៉ាចំនួន ០១កេសតូច, ថវិកាចំនួន ២០,០០០រ។ ទីតាំងទី២ នៅវត្តមហាមន្ត្រី ស្ថិតនៅសង្កាត់អូឡាំពិក អំណោយរួមមាន៖ អង្ករចំនួន ១តោនកន្លះ។
- យប់ថ្ងៃអាទិត្យ ទី១៥ ខែសីហា ឆ្នាំ២០២១ គណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង និង លោក-លោកស្រីអភិបាលរងខណ្ឌ** បានបន្តដឹកនាំកម្លាំងមន្ត្រីក្រោមឱវាទ ចុះល្បាតអនុវត្តបម្រាមគោចរជារៀងរាល់ថ្ងៃ តាមសេចក្តីសម្រេចលេខ ២៥៩/២១ សសរ របស់រដ្ឋបាលរាជធានីភ្នំពេញចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ តាមគោលដៅត្រួតពិនិត្យវិធានការរដ្ឋបាល នៅក្នុង

មូលដ្ឋានខណ្ឌបឹងកេងកង ចាប់ពីម៉ោង ២២:០០យប់ ដល់ម៉ោង៣ទៀបភ្លឺ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

- ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានចូលរួមប្រជុំស្តីពីការចាត់វិធានការលុបបំបាត់ការលួចសេពគ្រឿងស្រវឹង នៅតាមភោជនីយដ្ឋានមួយចំនួនក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាព**ឯកឧត្តម មាន ចាន់យ៉ាដា** អភិបាលរងរាជធានីភ្នំពេញ តាមរយៈវីដេអូបញ្ជូនសម្លេង (Zoom Video)។
- ព្រឹកថ្ងៃចន្ទ ទី១៦ ខែសីហា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាភ្លើងឆេះឃ្លាំង នៅផ្លូវលេខ៣៥៨ សង្កាត់ទួលស្វាយព្រៃទី១» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់ទួលស្វាយព្រៃទី១ និងភាគីដែលពាក់ព័ន្ធ ។
- ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង និង លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយជូនដល់ប្រជាពលរដ្ឋចំនួន ៤០គ្រួសារ ស្ថិតនៅអង្គការផ្ទះបាយកុមារ ក្នុងសង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ ក្នុងមួយគ្រួសារទទួលបាន ៖ អង្ករ ២៥គីឡូ, មីម៉ាម៉ា ០១កេសតូច,ទឹកស៊ីអ៊ីវ ០១ដប,ទឹកត្រី ០១ដប, នំ ១០កញ្ចប់, ប្រេងឆា ០១ដប, ដែល ០៥ដបតូច,ម៉ាស ១០សន្លឹក។
- ព្រឹកថ្ងៃអង្គារ ទី១៧ ខែសីហា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាការសាងសង់ផ្ទះនៅក្នុងបរិវេណវិទ្យាល័យព្រះយុគន្ធរ» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល និងចៅសង្កាត់បឹងកេងកងទី២ និងភាគីដែលពាក់ព័ន្ធ។
- យប់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ម៉ោង១៧:០០នាទី **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាលខណ្ឌ មន្ត្រីក្រោមឱវាទ កម្លាំងសណ្តាប់ធ្នាប់ខណ្ឌ សហការជាមួយសង្កាត់ទាំង៧ បានចុះធ្វើការណែនាំបន្ថែមសេចក្តីសម្រេចលេខ០២០/២១ សណន របស់សាលារាជធានីភ្នំពេញ ស្តីពី« ការរឹតបន្តឹងការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ចំពោះការដ្ឋានគ្រប់ប្រភេទ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ » តាមការដ្ឋានសំណង់ក្នុងមូលដ្ឋានសង្កាត់ទាំង០៧ ក្នុងខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ដើម្បីចូលរួមប្រយុទ្ធប្រឆាំងកាត់ផ្តាច់ការរីករាលដាលជំងឺកូវីដ-១៩ បម្លែងថ្មី(Delta) ក្នុងសហគមន៍នាពេលបច្ចុប្បន្ន។
- ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយជូនដល់បងប្អូនមន្ត្រីសង្កាត់ និងកងកម្លាំងសណ្តាប់ធ្នាប់ ចំនួន ៤០គ្រួសារ ក្នុងសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២៥គីឡូ, ម៉ាស ១ប្រអប់ ត្រីខ ១យួរ, ថ្នាំដុសធ្មេញ ១ឡ។
- ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** គណៈអភិបាលខណ្ឌ មន្ត្រីរដ្ឋបាលខណ្ឌ បានអញ្ជើញទទួលវ៉ាក់សាំងបង្ការលើកទី៣(ដូសជំរុញ) នៅមណ្ឌលសុខភាពទួលស្វាយព្រៃ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង។
- ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានចូលរួមកិច្ចប្រជុំស្តីពីការងារប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ របស់ប្រតិបត្តិករថ្មីទាំង០៣ តាមរយៈប្រព័ន្ធ zoom ក្រោមអធិបតីភាព **ឯកឧត្តម កើត ឆែ** និង **ឯកឧត្តម ហួត ហៃ** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ។
- ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយជូនដល់បងប្អូនប្រពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន ៤០គ្រួសារ ក្នុងសង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង ដើម្បីដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃបានរយៈពេល។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២៥គីឡូ ចំនួន ០១បាវ, មី ចំនួន១កេស, ម៉ាស ចំនួន៦០ម៉ាស, ប្រេងឆា ០១ដប, ត្រីខ ចំនួន ៣កំប៉ុង។
- ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីរដ្ឋបាលខណ្ឌ អញ្ជើញទទួលនូវផ្លែមៀនប៉ៃលិន ដែលជាអំណោយរបស់លោកជំទាវ ហ៊ុន ស៊ីណាត តាមរយៈក្រុមការងារ ជូនមករដ្ឋបាលខណ្ឌបឹងកេងកង អំណោយ រួមមាន៖ផ្លែមៀនប៉ៃលិនចំនួន ២០គីឡូ,ថវិកា

ចំនួន ១,០០០,០០០លានរៀល ជាមួយគ្នានោះផងដែរ លោក ធឹម សំអាន ក៏បានជូននូវផ្លែឈើមួយចំនួន ដល់លោកជំទាវវិញផងដែរ។

- ព្រឹកថ្ងៃចន្ទ ទី២៣ ខែសីហា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាទំនាស់ជាប់ព្រំរវាងម្ចាស់ផ្ទះលេខ១៣៧ និងម្ចាស់ផ្ទះលេខ១៣៥ ផ្លូវលេខ៣១០ សង្កាត់ទួលស្វាយព្រៃទី១» ដោយមានការចូលរួមពី ប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់ទួលស្វាយព្រៃទី១ និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** រួមជាមួយក្រុមគ្រូពេទ្យនៃមន្ទីរសុខាភិបាលរាជធានីភ្នំពេញ របស់ក្រុមការងារព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ បានចុះធ្វើកំណត់ហេតុ និងប្រគល់ជូនលិខិតអនុញ្ញាតបញ្ចប់ការថែទាំ និងព្យាបាលជំងឺកូវីដ-១៩ នៅតាមផ្ទះ ដែលបានជាសះស្បើយ នៅសង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង។
- ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំ «គណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការអញ្ជើញចូលរួមពី គណៈអភិបាលខណ្ឌ គណៈនាយករដ្ឋបាល តំណាងអធិការនគរបាលខណ្ឌ កងរាជអាវុធហត្ថខណ្ឌ ប្រធានការិយាល័យទាំង១១ ចៅសង្កាត់ទាំង០៧ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រី និងកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ ចុះសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ និងរៀបចំសណ្តាប់ធ្នាប់នៅតាមបណ្តោយផ្លូវលេខ៤០២ ក្នុងសង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ដើម្បីងាយស្រួលដល់បងប្អូនប្រជាពលរដ្ឋធ្វើដំណើរតាមដងផ្លូវ ក្នុងការជៀសវាងការកកស្ទះចរាចរណ៍។
- ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ខណ្ឌបឹងកេង កង បានរៀបចំកិច្ចប្រជុំសាមញ្ញលើកទី២៤ ប្រចាំខែសីហា ឆ្នាំ២០២១ ក្រោមអធិបតីភាព **លោកស្រី ម៉ែន សុភាវី** ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង និង**លោកស្រី ប៉ា សុខា** សមាជិកក្រុមប្រឹក្សាខណ្ឌ និងជាអនុប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** ដែលមានការចូលរួមពី តំណាងមេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ ប្រធាន-អនុប្រធានការិយាល័យ និងសមាជិក~សមាជិកា គ.ក.ស.កខណ្ឌ និង អ.ក.ន.ក សង្កាត់។
- ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញទទួល អំណោយពី លោក ព្រហ្ម សុវណ្ណ ម្ចាស់ភោជនីដ្ឋាន Diamond Region ដែលបានឧបត្ថម្ភៈ ទឹកសុទ្ធ ៥០កេស, ម៉ាស ២កេស,ទឹកក្រូច ២០កេស, មី ២កេសធំ,អាល់កុល ៥កាន រួមនឹងថវិកា ២,០០០,០០០លានរៀល ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ដើម្បីចូលរួមចំណែកក្នុងសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ការឆ្លងរីករាលនៃជំងឺកូវីដ-១៩ នៅមូលដ្ឋានខណ្ឌ។
- រសៀលថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង(Video Conference) «កិច្ចប្រជុំស្តីពីការរឹតបន្តឹងការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ចំពោះការដ្ឋានសំណង់គ្រប់ប្រភេទក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។
- ព្រឹកថ្ងៃព្រហស្បតិ៍ ទី២៦ ខែសីហា ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញចុះពិនិត្យទីតាំងវិវាទស្តីពី «បញ្ហាឃ្លាំងទំនិញបង្កផលប៉ះពាល់ និងមានសម្លេងរំខានដល់អ្នកជិតខាងផ្លូវលេខ៤០២ សង្កាត់ទំនប់ទឹក» ដោយមានការចូលរួមពី ប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័ភូមិបាល មន្ត្រីបរិស្ថាន ចៅសង្កាត់ទំនប់ទឹក និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រី និងកម្លាំងប្រជាការពារខណ្ឌបឹងកេងកង ចុះរៀបចំសណ្តាប់ធ្នាប់នៅតាមបណ្តោយមហាវិថីមុន្នីរ៉េត ហូតដល់កំណាត់មហាវិថីព្រះសីហនុ ស្ថិតនៅក្នុងសង្កាត់ទួលស្វាយព្រៃទី២ និងសង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

- ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំសាមញ្ញលើកទី២៧ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ួ ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម សេង រតនៈ** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ សមាជិក-សមាជិកា ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ នាយករដ្ឋបាលខណ្ឌ ចៅសង្កាត់ទាំង០៧ និងមន្ត្រីពាក់ព័ន្ធ។
- ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ **លោក ធីម សំអាន អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមក្នុងពិធីប្រកាសចូលកាន់មុខតំណែងអភិបាល នៃគណៈអភិបាលខណ្ឌទួលគោក និងអភិបាល នៃគណៈអភិបាលខណ្ឌឫស្សីកែវ នៃរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ សាលប្រជុំជាន់ទី១១ អគារ គ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ា សុជាតិវង្ស** ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ និង **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។
- ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំ «ស្តីពីការចុះត្រួតពិនិត្យកិច្ចការលទ្ធកម្ម» ក្រោមអធិបតីភាព **លោក ខៀវ ខេមរជាតិ** ប្រធានគណៈប្រតិភូ និង **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង។**
- ព្រឹកថ្ងៃសុក្រ ទី២៧ ខែសីហា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ រួមសហការជាមួយក្រុមគ្រូពេទ្យក្រសួងសុខាភិបាលបានចុះផ្អាកទីតាំង«ការដ្ឋានសំណង់ ផ្សារអូឡាំពិក ដែលមានករណីកម្មករឆ្លងជំងឺកូវីដ-១៩ នៅទីតាំងផ្សារអូឡាំពិក ផ្លូវលេខ១៩៩ សង្កាត់អូឡាំពិក» ។
- ព្រឹកថ្ងៃច័ន្ទ ទី៣០ ខែសីហា ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាទំនាស់ជាប់ព្រំ ផ្លូវលេខ៣៣៨ សង្កាត់ទួលស្វាយព្រៃទី២» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់ទួលស្វាយព្រៃទី២ និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ **លោកធីម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** រួមជាមួយលោកចៅសង្កាត់អូឡាំពិក បានចុះសួរសុខទុក្ខនិងនាំយកអំណោយជូនដល់ លោក អ៊ុំ វិចិត្រ ជាប្រធានភូមិ៥ សង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង ដែលមានជំងឺប្រចាំកាយសម្រាកព្យាបាលនៅផ្ទះ។ អំណោយរួមមាន៖ ថវិកាចំនួន ២០០$, អង្ករចំនួន ២៥គីឡូ, មីចំនួន ១កេស, ត្រីខចំនួន ១យួរ,ទឹកត្រីចំនួន ១យួរ, ទឹកស៊ីអ៊ីវចំនួន ១យួរ,ទឹកសុទ្ធចំនួន ១កេស។
- ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ **លោក ធីម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីដំណើរការរៀបចំដាក់បញ្ចូលទីតាំងប្រវត្តិសាស្ត្រមណ្ឌលទី១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ក្នុងបញ្ជីបេតកិកណ្ឌពិភពលោក។
- ព្រឹកថ្ងៃអង្គារ ទី៣១ ខែសីហា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំក្រុមមន្ត្រីជំនាញ និងរដ្ឋបាលសង្កាត់ចុះពិនិត្យទីតាំង «បាក់ស្រុត និងប្រេះ ផ្ទះលេខ១៦៥ ផ្លូវព្រះនរោត្តម និងការដ្ឋានអគារ ស្នាក់នៅរួមដែលបង្កផលប៉ះពាល់ដោយសារកាយគ្រឹះ ស្ថិតនៅផ្លូវលេខ៣១០ កែងផ្លូវព្រះនរោត្តម សង្កាត់បឹងកេងកងទី១»។
- ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានអញ្ជើញទទួល អំណោយពី លោក លី ឧត្តម អគ្គនាយក ជេ ស៊ី មេឌីខល ( JC Medical ) ដែលបានឧបត្ថម្ភនូវអាល់កុលចំនួន ៤០កាន រួមនឹងថវិកា៤,០០០,០០០លានរៀល ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ដើម្បីចូលរួមចំណែកក្នុងសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ការការឆ្លងរីករាលនៃជំងឺកូវីដ-១៩ នៅមូលដ្ឋានខណ្ឌ។
- ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ **លោក ធីម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង (Video Zoom) «ស្តីពីពង្រឹងការធ្វើចត្តាឡីស័កក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។**

- ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយជូនដល់បងប្អូនប្រពលរដ្ឋដែលកំពុងធ្វើចត្តាឡីស័ក និងមានជីវភាពខ្វះខាត ចំនួន ២៥គ្រួសារ ស្ថិតនៅភូមិ១ ផ្លូវលេខ១៦៣ សង្កាត់បឹងកេងកង៣ ដើម្បីដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃបានមួយរយៈពេល។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២៥គីឡូ ចំនួន ០១បាវ, មី ចំនួន១០កញ្ចប់, ម៉ាស ចំនួន១០ម៉ាស, ទឹកត្រី២ដប, ទឹកស៊ីអ៊ីវ២ដប, ដែល៥ដប។
- ព្រឹកថ្ងៃព្រហស្បតិ៍ ទី០២ ខែកញ្ញា ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាឃ្លាំងទំនិញបង្កផលប៉ះពាល់ និងមានសម្លេងរំខានដល់អ្នកជិតខាង ផ្លូវលេខ៤០២ សង្កាត់ទំនប់ទឹក» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់ទំនប់ទឹក មន្រ្តីបរិស្ថាន និងភាគីដែលពាក់ព័ន្ធ។
- ព្រឹកថ្ងៃព្រហស្បតិ៍ ទី០២ ខែកញ្ញា **ឆ្នាំ២០២១ លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំមន្រ្តីជំនាញ និងរដ្ឋបាលសង្កាត់បានចុះពិនិត្យ «ការអនុវត្តសេចក្តីជូនដំណឹងលេខ២០/២១ របស់សាលារាជធានីភ្នំពេញ លើការដ្ឋានអាគារស្នាក់នៅរួម(J-Tower2) និងអាគារស្នាក់នៅរួម (Epic) ស្ថិតនៅផ្លូវលេខ៣៩៨ ភូមិ៩ សង្កាត់បឹងកេងកងទី១»។
- ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្រ្តីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង (Video Conference) «ស្តីពីការផ្សព្វផ្សាយអំពីដំណើរការរៀបចំដាក់បញ្ចូលទីតាំងប្រវត្តិសាស្ត្រម-១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាស្ត្រទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក» ក្រោមអធិបតីភាព **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្រ្តីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។
- ព្រឹកថ្ងៃសុក្រ ទី០៣ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំមន្រ្តីជំនាញចុះពិនិត្យ «ការដ្ឋានសំណង់អាគារមន្ទីរពេទ្យអ៊ីសាប៊ែល ស្ថិតនៅផ្លូវលេខ៣៦០ សង្កាត់ទួលស្វាយព្រៃទី១ និងទីតាំងការដ្ឋានអាគារការិយាល័យ(Apex) ស្ថិតនៅផ្លូវព្រះមុនីវង្ស សង្កាត់បឹងកេងកងទី៣ ដែលបានចាក់ដណ្តើរលើផ្លូវសាធារណៈ» ។
- ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២១ **លោកស្រី ស៊ុយ សែនសករាជ** ប្រធានអនុសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខណ្ឌបឹងកេងកង និងលោកស្រី **ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំសមាជិក-សមាជិកាអនុសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍខណ្ឌបឹងកេងកង ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង(Video Conference) « ស្តីពីជីវភាពប្រចាំខែសីហា និងទិសដៅខែបន្ទាប់ ឆ្នាំ២០២១» ក្រោមអធិបតីភាព **លោកជំទាវ កែវ សុខពិសី** ប្រធានគណៈកម្មាធិការសាខាសមាគមន៍នារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍រាជធានីភ្នំពេញ។
- ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១ **លោកធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំចៅសង្កាត់ គណៈកម្មការផ្សារ និងមន្រ្តីក្រោមឱវាទ សហការជាមួយនាយកវិទ្យាល័យ ជា ស៊ីម បឹងកេងកង រួមទាំងសិស្សានុសិស្ស បានចុះធ្វើអនាម័យ ពលកម្ម សម្អាត និងបាញ់ថ្នាំសម្លាប់មេរោគដោយប្រើ(ត្រួន) នៅក្នុងទីធ្លាសាលា ដើម្បីត្រៀមបើកដំណើរការសាលារៀនឡើង។
- ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំអភិបាលរង នាយករងខណ្ឌ លោកស្រីចៅសង្កាត់បឹងកេងកងទី១ ចុះសួរសុខទុក្ខ និងនាំយកអំណោយជូន លោក សំរិត សាមឿន ចៅសង្កាត់រងទី១ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង ដែលកំពុងមានជំងឺប្រចាំកាយ។ អំណោយមានដូចជា៖ អង្ករ ៥០គីឡូ, មី ៥កេស, ត្រីខ ២យួរ, ទឹកត្រី ១យួរ, ទឹកស៊ីអីវ ១យួរ, ទឹកដោះគោខាប់ ៥ កំប៉ុង, ថវិកា ២០០ដុល្លារ។
- ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ **លោកធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំចៅសង្កាត់ គណៈកម្មការផ្សារ និងមន្រ្តីក្រោមឱវាទ សហការជាមួយនាយកវិទ្យាល័យទួលស្វាយព្រៃ ចុះធ្វើអនាម័យ ពលកម្ម សម្អាត និងបាញ់ថ្នាំសម្លាប់មេរោគនៅក្នុងទីធ្លាសាលា ដើម្បីបើកដំណើរការសាលារៀនឡើងវិញ។

- ព្រឹកថ្ងៃចន្ទ ទី០៦ ខែកញ្ញា ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាទំនាស់ជាប់ព្រំក្បាលដីលេខ១៩៧ ផ្លូវលេខ១០៥ សង្កាត់បឹងកេងកងទី៣» ដោយមានការចូលរួមពី ប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់បឹងកេងកងទី៣ និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំ«ការចុះត្រួតពិនិត្យ និងវាយតម្លៃគ្រឹះស្ថានសិក្សាអប់រំ ដើម្បីត្រៀមបើកដំណើរការឡើងវិញ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង រាជធានីភ្នំពេញ» ក្រោមអធិបតីភាព **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ ដែលមានការចូលរួមពីលោកប្រធាន-អនុប្រធានការិយាល័យអប់រំខណ្ឌ ចៅសង្កាត់ទាំង០៧ និងមន្ត្រីដែលពាក់ព័ន្ធ។
- ព្រឹកថ្ងៃអង្គារ ទី០៧ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាបាក់ស្រុតផ្ទះលេខ១៦៥ ផ្លូវព្រះនរោត្តម សង្កាត់បឹងកេងកងទី១» ដោយមានការចូលរួមពី ប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់បឹងកេងកងទី១ និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំចៅសង្កាត់ គណៈកម្មការផ្សារ និងមន្ត្រីក្រោមឱវាទ សហការជាមួយនាយកសាលាវិទ្យាល័យព្រះយុគន្ធរ បានចុះធ្វើអនាម័យ ពលកម្ម សម្អាត និងបាញ់ថ្នាំសម្លាប់មេរោគនៅក្នុងទីធ្លាសាលា ដើម្បីបើកដំណើរការសាលាឡើងវិញ។
- ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំលើការយកសំណាកក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ តាមរយៈប្រព័ន្ធ ZOOM ។
- ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានបន្តអញ្ជើញចុះត្រួតពិនិត្យសកម្មភាពចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ វ័យចាប់ពីអាយុ៦០ឆ្នាំឡើង (ដូសជំរុញ AstraZeneca) នៅមណ្ឌលសុខភាពទួលស្វាយព្រៃ ផ្លូវលេខ៣៦៤ សង្កាត់ទួលស្វាយទី២ ខណ្ឌបឹងកេងកង ។
- ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមចែកអំណោយកាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាព **លោកជំទាវ ម៉ែន នារីសោភ័គ** អគ្គលេខាធិការរងទី១ កាកបាទក្រហមកម្ពុជា ជូនដល់«អង្គការផ្ទះបាយកុមារ» មានទីតាំងនៅសង្កាត់បឹងកេងកងទី៣។
- ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល គណៈនាយក និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង (Video Zoom Meeting) «ស្តីពីការត្រួតពិនិត្យ និងវាយតម្លៃការបើកដំណើរការឡើងវិញនូវគ្រឹះស្ថានសិក្សាចំណេះដឹងទូទៅគ្រប់កម្រិតក្នុងភូមិសាស្ត្រ ដែលមានហានិភ័យទាបក្នុងរាជធានីភ្នំពេញ» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ។
- ព្រឹកថ្ងៃសុក្រ ទី១០ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្រុះសម្រួលវិវាទស្តីពី «បញ្ហាការស្នើសុំចូលជួសជុលទីតាំងដែលបង្កការខូចខាតដោយអគ្គីភ័យ ផ្ទះលេខ៥៣៩ ផ្លូវព្រះមុនីវង្ស សង្កាត់បឹងកេងកងទី២» ដោយមានការចូលរួមពី ប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់បឹងកេងកងទី២ និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំស្តីពីវិធីសាស្ត្រស្ទង់ការដឹកជញ្ជូន និងការប្រើប្រាស់ ទិន្នន័យស្ទង់មតិ តាមរយៈប្រព័ន្ធវីដេអូ ZOOM ក្រោមអធិបតីភាព **ឯកឧត្តម ស៊ុយ សេរិទ្ធ** និង **ឯកឧត្តម នួន ផារ័ត្ន** អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ។
- ថ្ងៃសុក្រ ទី១០ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីជំនាញ និងរដ្ឋបាលសង្កាត់ ចុះពិនិត្យទីតាំងវិវាទដែលមាន «ពាក្យបណ្តឹងការដ្ឋានសំណង់ផ្ទះល្វែងបានសាងសង់ ខុសពីកិច្ចសន្យា ស្ថិតនៅដីឡូត៍លេខ៣៣c ផ្លូវលេខ៣៥០ សង្កាត់បឹងកេងកងទី៣»។
- ថ្ងៃអាទិត្យ ទី១២ ខែកញ្ញា ឆ្នាំ២០២១ ម៉ោង០២ និង៣០នាទីរសៀល មានករណីបាក់ដើមឈើដួលរលំ នៅបណ្តោយផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង។ ក្រោមការចង្អុលបង្ហាញរបស់លោកអភិបាល

ខណ្ឌ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** បានដឹកនាំកម្លាំងប្រជាការពារ ចុះធ្វើការកាប់ និងទាញចេញពីលើដងផ្លូវ ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍។

- ថ្ងៃចន្ទ ទី១៣ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទមូលដ្ឋាន ដើម្បីចូលរួមសហការចុះអនុវត្តដីកាសម្រេចបើអូសជាបណ្តោះអាសន្នលេខ១៤១ "គ" ជ.រ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ នៅផ្ទះលេខ៥៨ ផ្លូវលេខ៣២២ ភូមិ១ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
- ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ក្នុងកិច្ចប្រជុំស្តីពីការបើកដំណើរការឡើងវិញសាលាអន្តរជាតិ នៅរាជធានីភ្នំពេញ តាមរយៈZOOM។
- ថ្ងៃអង្គារ ទី១៤ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីជំនាញ និង រដ្ឋបាលសង្កាត់ចុះពិនិត្យទីតាំងវិវាទដែលមាន«ការដ្ឋានសំណង់ខុសពីលិខិតអនុញ្ញាត និងមានពាក្យបណ្តឹងអ្នកជិតខាងស្ថិតនៅដីឡូត៍លេខ២៤ ផ្លូវលេខ២៨៨ ភូមិ៦ សង្កាត់បឹងកេងកងទី១»។
- ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ព្រមទាំងលោក-លោកស្រីអភិបាលរងខណ្ឌ លោក-លោកស្រីចៅសង្កាត់ ព្រមទាំង មន្ត្រីក្រោមឱវាទ បានអមដំណើរលោក សេង វណ្ណៈ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ បានអញ្ជើញចុះពិនិត្យការបើកដំណើរការឡើងវិញនូវវិទ្យាល័យព្រះយុគន្ធរ ក្នុងសង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
- ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ព្រមទាំងអភិបាលរងខណ្ឌ លោក លោកស្រីចៅសង្កាត់ ព្រមទាំង មន្ត្រីក្រោមឱវាទ បានអមដំណើរលោក សេង វណ្ណៈ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ បានអញ្ជើញចុះពិនិត្យការបើកដំណើរការឡើងវិញ វិទ្យាល័យព្រះយុគន្ធរ ក្នុងសង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
- ថ្ងៃពុធ ទី១៥ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្របសម្រួលវិវាទស្តីពី «បញ្ហាករណីអគ្គីភ័យ ស្ថិតនៅទីតាំងឃ្លាំងស្តុកទំនិញបណ្តាលឱ្យរងផលប៉ះពាល់ដល់អ្នកជិតខាងលើ ដីឡូត៍លេខ៥ ផ្លូវលេខ៣៥៨ សង្កាត់ទួលស្វាយព្រៃទី១» ដោយមានការចូលរួមពី ប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់ទួលស្វាយព្រៃទី១ និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំពិធីប្រគល់ថវិកាមរណៈសង្គ្រោះរបស់សមាគមអតីតយុទ្ធជនកម្ពុជាចំនួន ៤,០០០,០០០រៀល ជូនដល់ក្រុមគ្រួសារសពលោក ធឿន គឹមសាន ជាសមាជិកសមាគមអតីតយុទ្ធជនកម្ពុជារាជធានីភ្នំពេញ ក្រោមអធិបតីភាព **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ ដោយមានការអញ្ជើញចូលរួមពីលោកអធិការរងនគរបាលខណ្ឌ មេបញ្ជាការរងកងរាជអាវុធហត្ថខណ្ឌ តំណាងយោធភូមិភាគពិសេស ប្រធានការិយាល័យសង្គមកិច្ចខណ្ឌ នាយរងប៉ុស្តិ៍នគរបាលសង្កាត់បឹងកេងកងទី៣ ក្រុមគ្រួសារសព និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយជូនដល់បងប្អូនប្រពលរដ្ឋដែលកំពុងមានជីវភាពខ្វះខាតចំនួន៣០គ្រួសារ ក្នុង ភូមិ៣ ភូមិ៤ និងភូមិ៦ សង្កាត់ទួលស្វាយព្រៃទី១ ក្នុងបរិវេណក្រុមហ៊ុនស៊ុបពើហ្វិត។ អំណោយក្នុងមួយគ្រួសារទទួលបាន ៖ អង្ករ ១០គីឡូ មី ១០កញ្ចប់ ទឹកត្រី ២ដប ទឹកស៊ីអុីវ ២ដប ត្រីខ ៣កំប៉ុង។
- ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្របសម្រួលវិវាទស្តីពី បញ្ហាផ្នែកខាងលើដំបូលតេរ៉ាស ផ្លូវលេខ៣៥ សង្កាត់ទួលស្វាយព្រៃទី២ ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល សង្កាត់ទួលស្វាយព្រៃទី២ និងភាគីដែលពាក់ព័ន្ធ។
- ព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្របសម្រួលវិវាទស្តីពី បញ្ហាបាក់ស្រុតផ្ទះលេខ១៦៥ ផ្លូវព្រះនរោត្តម សង្កាត់បឹងកេងកងទី១ ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល សង្កាត់បឹងកេងកងទី៣ និងភាគីដែលពាក់ព័ន្ធ។

- ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងលោក-លោកស្រីអភិបាលរងខណ្ឌ បានជួបទទួលអំណោយពី លោក លី កងវង អគ្គនាយកក្រុមហ៊ុន ចិមគលគ្រុប អំណោយរួមមាន៖ មី ៥០កេសតូច និងទឹកសុទ្ធ ៧៥កេស ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ដើម្បីចូលរួមចំណែកក្នុងសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ការការឆ្លងរីករាលនៃជម្ងឺកូវីដ១៩។
- ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** និង **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានបន្តអញ្ជើញ ចុះពិនិត្យយុទ្ធនាការចាក់វ៉ាក់សាំងបង្ការដូសទី១ ជូនកុមារដែលមានអាយុចាប់ពី ០៦ឆ្នាំ ដល់១២ឆ្នាំ នៅមណ្ឌលសុខភាពទួលស្វាយព្រៃ ក្នុងសង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង។
- ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** និង **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយជូនដល់បងប្អូនប្រពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន ៤០គ្រួសារ នៅភូមិ៤ សង្កាត់ទំនប់ទឹក។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ១០គីឡូ មី ១០កញ្ចប់ ម៉ាស ១០ ប្រេងឆា ០១ដប ទឹកត្រី ២ដប ទឹកស៊ីអ៊ីវ ២ដប។
- ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ ចុះពិនិត្យទីតាំងសំណង់ កំពុងធ្វើខឿន និងរៀបការ៉ូឡាលើដីចំណីផ្លូវសាធារណៈ ស្ថិតនៅផ្លូវលេខ ១៨៧ កែងផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក។
- ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្តីពី «ពិធីដេញថ្លៃការផ្គត់ផ្គង់សម្ភារសម្អាត និងអនាម័យ សម្ភារការិយាល័យ ស្បៀង គ្រឿងសង្ហារឹម និងសម្ភារបច្ចេកទេសពត៌មានវិទ្យា ជូនរដ្ឋបាលខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** ដោយមានការចូលរួមពី លោក សែន វ៉ាន់ណាក់ នាយករងរដ្ឋបាលខណ្ឌ ប្រធាន-អនុប្រធានការិយាល័យ លោក-លោកស្រីតំណាងក្រុមហ៊ុន ចំនួន ៣។
- ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្របសម្រួលវិវាទស្តីពី បញ្ហាទំនាស់ជាប់ព្រំ ផ្លូវលេខ៣៥០ ភូមិ២ សង្កាត់បឹងកេងកងទី៣ ដោយមានការចូលរួមពី ប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល សង្កាត់បឹងកេងកងទី៣ និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ តាមរយៈការបញ្ជូនរូបភាព និងសម្លេង (Zoom) ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**។
- ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញជួប និងទទួលអំណោយពីអ្នកឧកញ៉ា អឹង ប៊ុនហូវ និងលោកជំទាវ ដែលបានឧបត្ថម្ភ៖ ទឹកសុទ្ធ ១០០០យួរ និងអង្ករ ២តោន ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ដើម្បីចូលរួមចំណែកក្នុងសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ការការឆ្លងរីករាលនៃជម្ងឺកូវីដ១៩ ក្នុងមូលដ្ឋានខណ្ឌ។
- ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្របសម្រួលវិវាទស្តីពី បញ្ហាករណីអគ្គីភ័យឆេះឃ្លាំងទំនិញរបស់ក្រុមហ៊ុន ឡុង គឿង ប៉ះពាល់ផ្ទះប្រជាពលរដ្ឋ ៦គ្រួសារ ផ្លូវលេខ៣៥៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល សង្កាត់ទួលស្វាយព្រៃទី១ និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយជូនដល់បងប្អូនប្រពលរដ្ឋដែលកំពុងមានជីវភាពខ្វះខាតចំនួន ២០ គ្រួសារ ផ្លូវលេខ៣០៤ សង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ១០គីឡូ មី ១កេស និង ១០កញ្ចប់ ទឹកត្រី ២ដប ទឹកស៊ីអ៊ីវ ២ដប។
- ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ចុះពិនិត្យទីតាំងសំណង់ អគារពហុជំនាញកំពុងចាក់គ្រឹះ និងមានជំឡើងដងសន្ទូចលើផ្លូវសាធារណៈ ស្ថិតនៅផ្លូវលេខ៥១ កែងផ្លូវលេខ៣២២ ភូមិ៨ សង្កាត់បឹងកេងកងទី១។

- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយជូនដល់បងប្អូនប្រពលរដ្ឋដែលកំពុងមានជីវភាពខ្វះខាតចំនួន ៤០គ្រួសារ ផ្លូវលេខ២៨៨ សង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ១០គីឡូ មី ចំនួន១០កញ្ចប់ ទឹកត្រី ២ដប ទឹកស៊ីអ៊ីវ ២ដប ត្រីខ ៥កំប៉ុង ស្ករស ១គីឡូ។
- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានបន្តអញ្ជើញចុះពិនិត្យសកម្មភាពចាក់វ៉ាក់សាំងជូនកុមារដែលមានអាយុចាប់ពី ០៦ឆ្នាំ ដល់ ១២ឆ្នាំ និងដូសជំរុញ (ដូសទី៣) ព្រមទាំងប្រជាពលរដ្ឋដែលសេសសល់ពុំទាន់បានចាក់ដូសទី១ នៅមណ្ឌលសុខភាពទួលស្វាយព្រៃ ផ្លូវលេខ៣៦៤ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង។
- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការត្រៀមអនុវត្តសេចក្តីណែនាំលេខ០២៥២/១ សណន ចុះថ្ងៃទៅ១៦ ខែកញ្ញា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការអនុវត្តប្រព័ន្ធថ្មី នៃការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ តាមរយៈវីឌេអូ ZOOM ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរង នៃគណៈអភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ចុះពិនិត្យទីតាំងសំណង់ អគារផ្ទះល្វែង មានសភាពចាស់ទ្រុឌទ្រោមខ្លាំង ប្រេះស្រាំ និងស្រុតដោយផ្នែក ស្ថិតលើផ្លូវព្រះសីហនុ ភូមិ៤ សង្កាត់អូឡាំពិក។
- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំសាមញ្ញលើកទី២៥ ប្រចាំខែកញ្ញា ឆ្នាំ២០២១ ក្រោមអធិបតីភាព **លោកស្រី ម៉ែន សុភាវី ប្រធាន គ.ក.ស.ក ខណ្ឌ លោកស្រី ប៉ា សុខា អនុប្រធាន គ.ក.ស.ក ខណ្ឌ** និង **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** ដែលមានការចូលរួមពី ប្រធាន-អនុប្រធានការិយាល័យ និងសមាជិក-សមាជិកា គ.ក.ស.ក។
- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំកម្លាំងមន្ត្រី និងសណ្តាប់ធ្នាប់ខណ្ឌ ចុះបាញ់ទឹកលាងសម្អាតទ្រូងពុះចែកផ្លូវ តាមបណ្តោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង។
- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បាននាំយកអំណោយទៅចែកជូនបងប្អូនប្រជាពលរដ្ឋមួយចំនួនដែលកំពុងខ្វះខាត ក្នុងសង្កាត់បឹងកេងកងទី២ រួមមាន ៤០ គ្រួសារ ។
- ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចុះចែកអំណោយជូនដល់ប្រជាពលរដ្ឋចំនួន ៥០គ្រួសារ នៅភូមិ៤ និងភូមិ៦ សង្កាត់បឹងកេងកងទី៣ បរិវេណអង្គការផ្ទះបាយកុមារ និងប្រជាពលរដ្ឋ ចំនួន៣៨គ្រួសារ នៅភូមិ៦ សង្កាត់ទួលស្វាយព្រៃទី១ បរិវេណក្រុមហ៊ុនស៊ុបពើហ្វីត។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ១៥គីឡូ មី ១០កញ្ចប់ ទឹកស៊ីអ៊ីវ ០២ដប ទឹកត្រី ០២ដប តែ ០៣កញ្ចប់ ដែលលាងដៃ ០៥ដបតូច ទឹកដោះគោខាប់ ០១កំប៉ុង ត្រីខ ០៥កំប៉ុង។
- ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចូលរួមកិច្ចប្រជុំ «ការងារពិសេស» តាមរយៈការបញ្ជូនរូបភាព និងសម្លេង (video conference) ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។**
- ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីការិយាល័យច្រកចេញតែមួយ ចូលរួមវគ្គបណ្តុះបណ្តាល តាមរយៈការបញ្ជូនរូបភាព និងសម្លេង (video meeting) ស្តីពី "គោលការណ៍បែបបទ និងនីតិវិធី នៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ" ក្រោមអធិបតីភាព **ឯកឧត្តម ប្រាក់ សំអឿន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។**
- ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំសាមញ្ញ លើកទី២៨ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ួ ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម សេង រតនៈ** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ សមាជិក-សមាជិកា

ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ នាយករដ្ឋបាលខណ្ឌ ការិយាល័យចំណុះ-ជំនាញជុំវិញខណ្ឌ ចៅសង្កាត់ទាំង៧ និងមន្ត្រីពាក់ព័ន្ធ។

- ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញជួប និងទទួលអំណោយពី Misters Patrice Vignes Country Manager ក្រុមហ៊ុន food panda ដែលបានឧបត្ថម្ភមានដូចជា៖ អាល់កុល ១០០ដបតូច ផ្ទ័ត្រ ៥ ម៉ាស ២០០ប្រអប់ ធុងសំរាមអនាម័យ ដែលបែកចែកប្រភេទសំរាម ៥ ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ដើម្បីចូលរួមចំណែកក្នុងសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ការការឆ្លងរីករាលនៃជំងឺកូវីដ១៩ ក្នុងមូលដ្ឋានខណ្ឌ។
- ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បាននាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ចែកជូនដល់បងប្អូនប្រជាពលរដ្ឋចំនួន ៥៦គ្រួសារ ទាំង៧សង្កាត់ ដោយក្នុងមួយសង្កាត់មានចំនួន០៨គ្រួសារ។ ក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២៥គីឡូ មី ១០កញ្ចប់ ទឹកស៊ីអ៊ីវ ០២ដប ទឹកត្រី ០២ដប តែ ០៣កញ្ចប់ ដែលលាងដៃ ០១ដប ត្រីខ ១យួរ ម៉ាស ១កញ្ចប់។
- ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ **លោកស្រី ម៉ែន សុភារី ប្រធាន** គ.ក.ស.ក **ខណ្ឌបឹងកេងកង** និង **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** បានដឹកនាំសមាជិក សមាជិកា អនុសាខាសមាគមន៍នារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខណ្ឌបឹងកេងកង ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង (video meeting) «ស្តីពីការផ្សព្វផ្សាយផែនការកិច្ចការពារកុមារថ្នាក់រាជធានី ផ្តោតលើការថែទាំជំនួស និងអំពើហឹង្សាលើកុមាររាជធានីភ្នំពេញ» ក្រោមអធិបតីភាព **លោកជំទាវ កែវ សុខពិសី** ប្រធានគណៈកម្មាធិការសាខាសមាគមន៍នារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍រាជធានីភ្នំពេញ។
- ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញជាអធិបតី ក្នុងកម្មវិធីចែកអំណោយ ជូនដល់ប្រជាពលរដ្ឋចំនួន ៣០គ្រួសារ នៅបរិវេណសាលាខណ្ឌបឹងកេងកង។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ១០គីឡូ មី ចំនួន ១០កញ្ចប់ ទឹកស៊ីអ៊ីវ ០២ដប ត្រីខ ០២កំប៉ុង ម៉ាស ០១កញ្ចប់ ថ្នាំពេទ្យ ០១កញ្ចប់ ដែល ០៥ដបតូច។
- ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានជួបសំណេះសំណាលជាមួយនឹងកម្លាំងប្រជាការពារខណ្ឌ ដើម្បីពង្រឹងការងារសណ្តាប់ធ្នាប់ឱ្យកាន់តែរីកចំរើនទៅមុខទៀត។
- ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២១**លោក គឹម ឈុនអ៊ូ ប្រធានក្រុមប្រឹក្សាខណ្ឌ និង លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌ** បានអញ្ជើញជាអធិបតីក្នុងកម្មវិធី ប្រគេនអង្ករ ១តោន និងថវិកា ១០.០០០.០០០រៀល (ដប់លានរៀល) ជូនដល់វត្តមហាមន្ត្រី និងវត្តលង្កាព្រះកុសុមារាម។
- ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ូ ប្រធានក្រុមប្រឹក្សាខណ្ឌ** បានបន្តចុះចែកអំណោយជូន ដល់បងប្អូនប្រជាពលរដ្ឋក្រីក្រចំនួន ៤០គ្រួសារ ទាំង១១ភូមិ ក្នុងសង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង។ ក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២៥គីឡូ មី ២០កញ្ចប់ ទឹកស៊ីអ៊ីវ ០២ដប ម៉ាស ១កញ្ចប់ ទឹកត្រី ០១ដប ត្រីខ ២កំប៉ុង ថវិកា ២០០០០រៀល។
- ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចូលរួមកិច្ចប្រជុំ «គណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ» តាមរយៈការបញ្ជូនរូបភាព និងសម្លេង(video meeting) ក្រោមអធិបតីភាព**ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។**
- ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារ ជំនាញ និងមន្ត្រីសង្កាត់បានចុះពិនិត្យទីតាំងសំណង់ ការដ្ឋានអគារពហុមុខងារ ដែលដំឡើងដងសន្ទូចលើផ្លូវសាធារណៈ ស្ថិតនៅផ្លូវលេខ៥១ កែងផ្លូវលេខ៣២២ ភូមិ៨ សង្កាត់បឹងកេងកងទី១។
- ថ្ងៃទី១១ខែតុលា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំលើកដំបូងរបស់គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ (zoom) ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។
- ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញទៅទទួលអំណោយពី សម្តេចព្រះធម្មលិខិតបណ្ឌិត សៅរ៍ ចន្ទថុល្ល ព្រះចៅអធិការវត្តលង្កាព្រះកុសុមារាម ប្រគល់ជូន

អនុសាខាកាកបាទក្រហមកម្ពុជា ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ សម្ភារៈទទួលបានរួមមាន៖ ទឹកដោះគោខាប់ ៤កេសធំ ទឹកក្រូច ៥០កេស ទឹកសុទ្ធ ៥០កេស ស្ករស ៤៨៥គីឡូក្រាម មីម៉ាម៉ា ១៦៨កេសតូច តែ ៧៣០កញ្ចប់ សម្ភារៈផ្ទះបាយ ១៧ឈុត អង្ករ ២តោន ថវិកា ៤លានរៀល។

- ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ជូនរូបភាព និងសម្លេង (video conference) កិច្ចប្រជុំស្តីពី "ការអនុវត្តសេចក្តីណែនាំ ស្តីពីការបង្ហាញបណ្ណចាក់វ៉ាក់សាំងកូវីដ១៩ រាល់ពេលចេញចូលគ្រឹះស្ថានសិក្សា ផ្សារ និងទីតាំងអាជីវកម្មនានាក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ"។
- ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពី«ការពង្រឹងការងាររដ្ឋបាល» ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី អភិបាលរងខណ្ឌ នាយក-នាយករងរដ្ឋបាលខណ្ឌ និងលោក លោកស្រីប្រធាន អនុប្រធានការិយាល័យ។
- ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំម្របសម្រួលវិវាទស្តីពី បញ្ហាការដ្ឋានធ្វើឱ្យមានការប្រេះស្រាំសសរផ្ទះអ្នកជិតខាង រវាងម្ចាស់ក្បាលដីលេខ៤អ៊ី០ និងម្ចាស់ផ្ទះលេខ១៥៣ សង្កាត់អូឡាំពិក ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យ ភូមិបាល សង្កាត់អូឡាំពិក និងភាគីដែលពាក់ព័ន្ធ។
- ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានបន្តអញ្ជើញចុះពិនិត្យសកម្មភាពចាក់វ៉ាក់សាំងដូសជំរុញលើកទី៣ ជូនប្រជាពលរដ្ឋ និងដូសទី២ ជូនកុមារដែលមានអាយុចាប់ពី ០៦ឆ្នាំ ដល់ ១២ឆ្នាំ នៅមណ្ឌលសុខភាពទួលស្វាយព្រៃ ផ្លូវលេខ៣៦៤ សង្កាត់ទួលស្វាយព្រៃទី២ និងសាលាបឋមសិក្សាវត្តមហាមន្ត្រី សង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង។
- ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បាននាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ផ្តល់ជូនតាមរយៈ ឯកឧត្តម ឃួង ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ចែកជូនដល់បងប្អូនប្រជាពលរដ្ឋចំនួន ៧០គ្រួសារ ទាំង៧សង្កាត់ ដោយក្នុងមួយសង្កាត់មានចំនួន១០គ្រួសារ ក្នុងខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវ គឹម សុវណ្ណា សមាជិការដ្ឋសភា និងជាអនុប្រធានក្រុមការងារចុះជួយខណ្ឌបឹងកេងកង លោកស្រី ស៊ុយ សែនសករាជ ប្រធានសមាគមន៍នារីខណ្ឌ លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ និង លោក លោកស្រីចៅសង្កាត់ទាំង៧។
- ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងលោក **ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្របសម្រួលវិវាទស្តីពី «បញ្ហាផ្លូវសេវភាព ផ្ទះលេខ៥៣៩ ផ្លូវព្រះមុនីវង្ស សង្កាត់បឹងកេងកងទី២» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់បឹងកេងកងទី២ និងភាគីដែលពាក់ព័ន្ធ។ (លទ្ធផលទទួលបានគឺ ភាគីទាំងពីរស្នើសុំដកឃ្លាទៅពិចារណារកដំណោះស្រាយ ដើម្បីសម្របសម្រួលគ្នានៅពេលក្រោយម្តងទៀត) ។
- ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមកិច្ចប្រជុំស្តីពីការចាក់វ៉ាក់សាំងជម្រុញដូសទី៣ ជូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ តាមរយៈប្រព័ន្ធ Zoom meeting ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំលោកស្រីអភិបាលរងខណ្ឌ នាយក-នាយករង លោក-លោកស្រីប្រធាន-អនុប្រធានការិយាល័យ ចូលរួមកិច្ចប្រជុំស្តីពីការ «ស្វែងរកទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ក្រោយពេលបើកសាលាបឋមសិក្សាឡើងវិញ» តាមរយៈការបញ្ជូនរូបភាព និងសម្លេង(Video Zoom Meeting) ក្រោមអធិបតិភាព **ឯកឧត្តម តើត ឆៃ អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំកម្លាំងមន្ត្រី អញ្ជើញចុះត្រួតពិនិត្យការដ្ឋានជួសជុស និងអ៊ុតកៅស៊ូផ្លូវមួយកន្លែង ស្ថិតនៅបណ្តោយផ្លូវព្រះមុន្នីវង្ស និងផ្លូវលេខ៣១០ កែងផ្លូវព្រះមុន្នីវង្ស សង្កាត់បឹងកេងកងទី១ និងសង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង។
- ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ **លោកជំទាវ គឹម សុវណ្ណា** តំណាងរាស្ត្រមណ្ឌលភ្នំពេញ និងជាអនុប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខណ្ឌបឹងកេងកង ដោយមានការចូលរួមអមដំណើរដោយ **លោកស្រី ស៊ុយ សែន**

**សករាជ** ប្រធានអនុសាខាសមាគមន៍នារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខណ្ឌបឹងកេងកង **លោកស្រី ម៉ែន សុភារី ប្រធានគ.ក.ស.ក ខណ្ឌ និង លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** រួមជាមួយសមាជិកាអនុសាខាសមាគមន៍នារី បានចុះសួរសុខទុក្ខក្រុមការងារ នៅទីតាំងចាក់វ៉ាក់សាំង ទាំង៤ មណ្ឌលៈ មណ្ឌលសុខភាពទួលស្វាយព្រៃ, សាលាបឋមសិក្សាទួលស្វាយព្រៃ, សាលាបឋមសិក្សាចៅពញាហុក និងសាលាបឋមសិក្សាវត្តមហាមន្ត្រី។ ក្នុងឱកាសនោះដែរ លោកជំទាវ គឹម សុវណ្ណា បានឧបត្ថម្ភថវិកាចំនួន ១០ម៉ឺនរៀល និង លោកស្រី ស៊ុយ សែនសករាជ ឧបត្ថម្ភថវិកា ១០ម៉ឺនរៀល ជូនក្រុមការងារក្នុងមណ្ឌលនីមួយៗ។

- ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចូលរួមកិច្ចប្រជុំ "ពិភាក្សាបញ្ហាការយកថ្លៃទឹកក្នុងតម្លៃខ្ពស់សម្រាប់កម្មករ កម្មការិនី និងសិស្ស និស្សិត ជួលផ្ទះឬបន្ទប់ជួល ក្នុងរាជធានីភ្នំពេញ" តាមរយៈការបញ្ចូនរូបភាព និងសម្លេង(Video Zoom Meeting) ក្រោមអធិបតីភាព **ឯកឧត្តម ខួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទចុះរៀបចំសណ្តាប់ធ្នាប់លើចិញ្ចើមផ្លូវ តាមបណ្តោយផ្លូវព្រះមុនីវ៉េត ក្នុងសង្កាត់ទួលស្វាយព្រៃទី២ និងបន្តចុះត្រួតពិនិត្យការជួសជុសអ៊ុតកៅស៊ូ លើមហាវិថីព្រះមុនីវង្ស ក្នុងសង្កាត់បឹងកេងកងទី១។
- ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ៩:០០នាទី **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមកិច្ចប្រជុំស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា(ប.ស.ប.ក) តាមរយៈប្រព័ន្ធវីដេអូ Zoom ក្រោមអធិបតីភាព **លោកជំទាវ កែវ សុខពិសី អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង និង លោក រឿង សេរីតារា អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ** រួមជាមួយអភិបាលរងខណ្ឌ បានប្រារព្ធពិធីអបអរសាទរ ទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ២០២១ និងចែកអំណោយជូនដល់ចាស់ជរាចំនួន ២១គ្រួសារ ទាំង៧សង្កាត់ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។ ក្នុងមួយគ្រួសារទទួលអំណោយរួមមានៈ ថវិកា ៥០,០០០រៀល, អង្ករ ២៥គីឡូ ,មី ១កេស, ម៉ាស ១០, ជែល ១ដបតូច, ទឹកដោះគោឆៅ ២យួរ, ស្ករស ១កញ្ចប់, ក្រមា ០១។
- ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំសាមញ្ញលើកទី២៦ ប្រចាំខែតុលា ឆ្នាំ២០២១ ក្រោមអធិបតីភាព **លោកស្រី ម៉ែន សុភារី** ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង និង**លោកស្រី ប៉ា សុខា** អនុប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** ដែលមានការចូលរួមពី ប្រធាន-អនុប្រធានការិយាល័យ និងសមាជិក-សមាជិកា គ.ក.ស.កខណ្ឌ និង អ.ក.ន.ក សង្កាត់។
- ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ចូលរួមកិច្ចប្រជុំតាមរយៈការបញ្ចូនរូបភាព និងសម្លេង ( Video Conference ) «កិច្ចប្រជុំស្តីពីការទប់ស្កាត់ការវាយកម្ទេច និងបំផ្លិចបំផ្លាញសំណង់អគារបេតិកភណ្ឌ» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**។
- រសៀលថ្ងៃអាទិត្យ ទី២៤ ខែតុលា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងមន្ត្រីក្រោមឱវាទ បានអមដំណើរ **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ បានអញ្ជើញចុះត្រួតពិនិត្យការដ្ឋានជួសជុលផ្លូវ និងអ៊ុតកៅស៊ូ នៅបណ្តោយផ្លូវព្រះសីហនុ សង្កាត់បឹងកេងកងទី១។
- ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ចុះត្រួតពិនិត្យទីតាំងសំណង់ «អាគារស្នាក់នៅរួម ដែលបានសាងសង់ខុសលិខិតអនុញ្ញាតនៅលើដីឡូតិ៍លេខ២៩៣ ផ្លូវលេខ៤៣០ កែងផ្លូវលេខ១៨៧ សង្កាត់ទំនប់ទឹក» ។ (ក្រុមការងារសម្រេចផ្អាក ការសាងសង់ជាបណ្តោះអាសន្ន និងណែនាំឱ្យម្ចាស់ការដ្ឋានរៀបចំឯកសារដាក់ជូន រដ្ឋបាលខណ្ឌពិនិត្យ) ។
- ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** តំណាងលោកអភិបាលខណ្ឌ បានរៀបចំកិច្ចប្រជុំ «ស្តីពីការចាក់វ៉ាក់សាំង ដូសជម្រុញជូនប្រជាពលរដ្ឋ ដែលខកខានពុំទាន់បានចាក់ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង មុនបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ ខាងមុខនេះ» ដោយមានការ

អញ្ជើញចូលរួមពី លោក-លោកស្រី ប្រធាន-អនុប្រធានការិយាល័យទាំង១១ ចៅសង្កាត់ទាំង៧ ប្រធានផ្សារទាំង២ និងមន្ត្រីពាក់ព័ន្ធ។

- ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ចុះពិនិត្យទីតាំងសំណង់ «កំពុងចាក់បណ្តុះដែកសសរធ្វើរោងដែកជាប់របងផ្ទះ ពុំមានលិខិតអនុញ្ញាត ស្ថិតនៅផ្ទះលេខ១៥៥ ផ្លូវលេខ១១៣ កែងផ្លូវលេខ៣៩០ ភូមិ៤ សង្កាត់បឹងកេងកងទី៣»។ (ក្រុមការងារសម្រេច ផ្អាកការសាងសង់ជាបណ្តោះអាសន្ន និងបានណែនាំម្ចាស់សំណង់ត្រូវរៀបចំលិខិតអនុញ្ញាត ឱ្យបានត្រឹមត្រូវទើបអាចសាងសង់បន្ត)។
- ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំសាមញ្ញលើកទី២៩ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី សមាជិក-សមាជិកាក្រុមប្រឹក្សាខណ្ឌ អភិបាលរងខណ្ឌ នាយក-នាយករង ការិយាល័យចំណុះ-ជំនាញជុំវិញខណ្ឌ ចៅសង្កាត់ទាំង០៧ និងមន្ត្រីពាក់ព័ន្ធ ហើយជាមួយគ្នានោះផងដែរ ក៏បានប្រកាសតែងតាំងកញ្ញា សាញ់ ណារី ជាស្មៀនសង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង ជាបណ្តោះអាសន្ន។
- ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** ការិយាល័យផែនការ និងហិរញ្ញវត្ថុ ការិយាល័យសង្គមកិច្ច សុខុមាលភាពសង្គម និងការិយាល័យរដ្ឋបាល បានចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្តីពី «ការបែងចែកថវិកាជូនដល់ក្រុមគ្រួសារសព ដែលបានទទួលមរណភាពក្នុងរាជធានីភ្នំពេញ» តាមរយៈការបញ្ជូនរូបភាព និងសម្លេង(Video Zoom Meeting) ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** លោកប្រធាន-អនុប្រធានការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ បានចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្តីពី «ការរៀបចំការត្រៀមអនុវត្តការពិន័យអន្តរកាលថ្នាក់រាជធានី ថ្នាក់ខណ្ឌ និងថ្នាក់សង្កាត់ ចំពោះប្រជាពលរដ្ឋដែលមិនញែកសំរាម និងបញ្ចេញសំរាមខុសម៉ោងពេល និងទីតាំងដែលបានកំណត់» តាមរយៈការបញ្ជូនរូបភាព និងសម្លេង(Video Zoom Meeting) ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់បានចុះពិនិត្យទីតាំងសំណង់ ចំនួន០២កន្លែង គឺការដ្ឋាន «កំពុងរុះរើ និងជួសជុលផ្ទះពុំមានលិខិតអនុញ្ញាតនៅផ្លូវលេខ១៤៣ កែងផ្លូវលេខ៣៥០ ភូមិ២ សង្កាត់បឹងកេងកងទី៣» និងការដ្ឋានសំណង់ «អាគារ ជីឡូតិ៍ ជួសជុល និងសាងសង់កំពុងចាក់ជើងតាង សង់ពង្រីកផ្ទៃក្រឡាពុំមានលិខិតអនុញ្ញាត ស្ថិតលើផ្លូវលេខ៥១ សង្កាត់បឹងកេងកងទី១»។ (ក្រុមការងារសម្រេច ផ្អាកសកម្មភាពសាងសង់របស់ម្ចាស់សំណង់ទាំងពីរ ជាបណ្តោះអាសន្ន និងបានណែនាំឱ្យរៀបចំលិខិតអនុញ្ញាត ឱ្យបានត្រឹមត្រូវទើបអាចសាងសង់ និងរុះរើជួសជុលបន្ត)។
- រសៀលថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមកិច្ចប្រជុំស្តីពី «ការរៀបចំបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា ឆ្នាំ២០២១ » ក្រោមអធិបតីភាព **ឯកឧត្តម នួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ ។**
- ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំ "គណៈកម្មការសម្របសម្រួលការអនុវត្តគម្រោង Joint Coordinating Committee (JCC) លើកទី២ សម្រាប់គម្រោងអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលរាជធានីភ្នំពេញ និងក្រសួង សាធារណការ និងដឹកជញ្ជូន ក្នុងការគ្រប់គ្រងប្រព័ន្ធលូទឹកកខ្វក់ ដែលជាគម្រោង សហប្រតិបត្តិការបច្ចេកទេសជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន JICA" តាមរយៈប្រព័ន្ធវីដេអូ Zoom ក្រោមអធិបតីភាព **ឯកឧត្តម តូច ចាន់កុសល** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាសហប្រធាន នៃគណៈកម្មការសម្របសម្រួលការអនុវត្តគម្រោង, **ឯកឧត្តម ស៊ុយ សេរិទ្ធ អភិបាលរងរាជធានីភ្នំពេញ** និង **ឯកឧត្តម នួន ផារ័ត្ន** អភិបាលរងជានីភ្នំពេញ និងជាអនុប្រធាន នៃគណៈកម្មការសម្របសម្រួលការអនុវត្តគម្រោង។
- ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំ «គណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដែលមានការ

អញ្ជើញចូលរួមពី អភិបាលរងខណ្ឌ នាយក-នាយករង អធិការនគរបាលខណ្ឌ មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ ប្រធានការិយាល័យទាំង១១ ចៅសង្កាត់ទាំង៧ និងមន្ត្រីដែលពាក់ព័ន្ធ។

- ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ តាមការចង្អុលបង្ហាញរបស់លោកអភិបាលខណ្ឌ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌ** បានដឹកនាំអាជ្ញាធរសង្កាត់ និងប្រធានប្រជាការពារខណ្ឌ ជួបពិភាក្សាសំណេះសំណាល និងសួរសុខទុក្ខជាមួយបងប្អូនប្រជាពលរដ្ឋដែលជាម្ចាស់ផ្ទះរស់នៅតាមបណ្តោយផ្លូវមុនីរ៉េត ទល់មុខផ្សារដើមគរ ក្នុងសង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង។
- ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** និងនាយក-នាយករង ចូលរួមកិច្ចប្រជុំស្តីពី «ការជំរុញការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ» តាមរយៈការបញ្ជូនរូបភាព និងសម្លេង(Video Zoom Meeting) ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។**
- ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានដឹកនាំក្រុមការងារ ចុះពិនិត្យការបើកដំណើរការ សាលាថ្នាក់មត្តេយ្យ ថ្នាក់បឋមសិក្សា ទាំងសាលារដ្ឋ និងសាលាឯកជនក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។
- រសៀលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមកិច្ចប្រជុំស្តីពី «ការការពារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ក្នុងមូលដ្ឋានខណ្ឌដូនពេញ ៧មករា ទួលគោក បឹងកេងកង និងចំការមន» ក្រោមអធិបតីភាព **ឯកឧត្តម មាន ចាន់យ៉ាដា អភិបាលរងរាជធានីភ្នំពេញ** ។
- ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់បានចុះត្រួតពិនិត្យបច្ចុប្បន្នភាពការដ្ឋាន ចំនួន០២ទីតាំង នៅក្នុងសង្កាត់បឹងកេងកងទី១៖ ការដ្ឋាន «អាគារស្នាក់នៅរួម(Apex) ស្ថិតលើដីឡូត៍លេខ៦១ ភូមិ៩ ផ្លូវលេខ៣៩៨ ការដ្ឋានមានលិខិតអនុញ្ញាតពី សាលារាជធានីភ្នំពេញ (ពុំមានតំកល់ប្លង់សាងសង់នៅការដ្ឋាន) បុគ្គលិកកម្មករមានពាក់មាស់ បាញ់អាកុល និងបានចាក់វ៉ាក់សាំងគ្រប់គ្នា និងអាគារស្នាក់នៅរួម(J-Tower II) ស្ថិតលើដីឡូត៍លេខ១៩៧ ភូមិ៩ ផ្លូវលេខ៣៩៨ ការដ្ឋានមានលិខិតអនុញ្ញាតពីក្រសួងដែនដីនគរូបនីយកម្ម ការដ្ឋានមានលំអៀងគម្លាតលក្ខណៈនគរូបនីយបញ្ញត្តិ របស់ប្លង់អនុញ្ញាត ការដ្ឋានមានកម្មករសរុប ២៨៩នាក់ បានចាក់វ៉ាក់សាំងដូសទី៣ ចំនួន១៤០នាក់ បុគ្គលិកកម្មករ មានពាក់មាស់ និងបាញ់អាកុល» ។
- រសៀលថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌ** បានចូលរួមកិច្ចប្រជុំស្តីពី «អនុគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់រាជធានីភ្នំពេញ ស្តីពីការមិនអនុញ្ញាតឱ្យទទួលយក ការឧបត្ថម្ភជាផលិតផលថ្នាំជក់ ឬជាសម្ភារដែលបង្ហាញឈ្មោះផលិតផលថ្នាំជក់» ក្រោមអធិបតីភាព **លោកជំទាវ កែវ សុខពិសី អភិបាលរងរាជធានីភ្នំពេញ** ។
- ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្តីពី "ការបញ្ចេញកាកសំណល់(សម្រាម)ឱ្យទាន់ពេលកំណត់ និងតែម្តងគត់ក្នុងមួយថ្ងៃ ចាប់ពីម៉ោង១៨:០០នាទី ដល់ ២១:០០នាទីយប់ តាមគេហដ្ឋាន និងភោជនីយដ្ឋានរៀងៗខ្លួន" ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការចូលរួមពី អភិបាលរងខណ្ឌ លោកនាយករងរដ្ឋបាលខណ្ឌ លោក លោកស្រី ប្រធាន-អនុប្រធានការិយាល័យ លោក-លោកស្រីចៅសង្កាត់ តំណាងក្រុមហ៊ុនស៊ិនទ្រី និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានបើកកិច្ចប្រជុំពង្រឹងការងាររដ្ឋបាល និងជួបសំណេះសំណាល សួរសុខទុក្ខ និងបានឧបត្ថម្ភនូវថវិកាមួយចំនួនដល់មន្ត្រីក្រោមឱវាទ ដោយមានការចូលរួមពី អភិបាលរងខណ្ឌ នាយក-នាយករង លោក លោកស្រី ប្រធាន-អនុប្រធានការិយាល័យ និងមន្ត្រីក្រោមឱវាទ។
- ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រោមការចង្អុលបង្ហាញរបស់លោកអភិបាលខណ្ឌ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំកម្លាំងមន្ត្រី សហការជាមួយក្រុមការងាររដ្ឋបាលសង្កាត់ទាំង៧ ធ្វើការចុះផ្សព្វផ្សាយបញ្ហាបញ្ចេញសម្រាមឱ្យទាន់ពេលកំណត់ ជូនដល់បងប្អូនប្រជាពលរដ្ឋទាំង៧សង្កាត់ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។
- ព្រឹកថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី «សារៈសំខាន់នៃការប្រើប្រាស់ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិ

ដែក និងពង្រឹងការអនុវត្តខ្លឹមសារប្រកាសអន្តរក្រសួងលេខ៖០៤៨កជអជ ស្តីពីការផលិត ការប្រើប្រាស់ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក» ក្រោមអធិបតីភាព **ឯកឧត្តម ថេង បញ្ញាធន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ និង **លោកជំទាវ កែវ សុខពិសី អភិបាលរងរាជធានីភ្នំពេញ**។

- ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១ **លោកស្រី ស៊ុយ សែនសករាជ** ប្រធានអនុសាខាសមាគមន៍នារីខណ្ឌបឹងកេងកង **លោកស្រី ស៊ិន រតនា អភិបាលរង** តំណាងលោកអភិបាលខណ្ឌ និង **លោកស្រី ម៉ែន សុភាវី ប្រធាន គ.ក.ស.ក ខណ្ឌ** បានដឹកនាំក្រុមការងារ គ.ក.ស.ក ខណ្ឌ អញ្ជើញចុះសួរសុខទុក្ខ លោកជំទាវ ឃួន គឹមនី សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ និងជាប្រធាន គ.ក.ស.ក រាជធានី ដែលកំពុងសម្រាកព្យាបាលជម្ងឺនៅគេហដ្ឋាន និងបានចូលរួមឧបត្ថម្ភថវិកាសរុបចំនួន ១,០០០,០០០រៀល។
- ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានបន្តចុះចែកអំណោយជូន ដល់បងប្អូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន ៣០គ្រួសារ ក្នុងភូមិ១ សង្កាត់បឹងកេងកងទី៣ និង៣៦គ្រួសារ ក្នុងភូមិ២ សង្កាត់បឹងកេងកងទី២។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២០គីឡូ, មី ១០កញ្ចប់, ទឹកស៊ីអ៊ីវ ទឹកត្រី ០៤ដប, ម៉ាស ០១កញ្ចប់, ត្រីខ ចំនួន០២កំប៉ុង, ថ្នាំ ០១កញ្ចប់, ក្រូចថ្លុង ០១ផ្លែ។
- ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញជួប និងទទួលអំណោយពី ក្រុមការងារតំណាង ឯកឧត្តមបណ្ឌិត ឡី សុភាព ប្រធានសមាគមសហព័ន្ធវិនិយោគកម្ពុជា និងជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ដែលបានឧបត្ថម្ភនូវជែលចំនួន ១០០០ដប ផ្តល់ជូនរដ្ឋបាលខណ្ឌបឹងកេងកង ដើម្បីចូលរួមចំណែកក្នុងសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ការការឆ្លងរីករាលនៃជំងឺកូវីដ-១៩ នៅមូលដ្ឋានខណ្ឌ។
- ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ចុះត្រួតពិនិត្យការដ្ឋាន «អគារស្នាក់នៅរួម(Apex) ស្ថិតនៅលើដីឡូតិ៍លេខ៦១ ផ្លូវលេខ៣៩៨ សង្កាត់បឹងកេងកងទី១ មានធ្លាក់ជុំដែកផ្នែករន្ទាមកលើដំបូលផ្ទះអ្នកជិតខាង»។ (ក្រុមការងារសម្រេច ផ្អាកការសាងសង់ជាបណ្តោះអាសន្នរង់ចាំម្ចាស់ការដ្ឋានដោះស្រាយជាមួយអ្នកជិតខាង ត្រូវរៀបចំនាំងសុវត្ថិភាពអាគារជិតខាង និងចូលខ្លួនដោះស្រាយរាយការណ៍ជាថ្មីជាមួយអាជ្ញាធរដែនដី)។
- ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ **លោកជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានអញ្ជើញចូលរួមពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា នៅវិមានឯករាជ្យ ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា **ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**។
- ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្របសម្រួលវិវាទស្តីពី «បញ្ហាបាតុភាពកម្មករតវ៉ាប្រាក់ខែ នៅការដ្ឋានសំណង់ស្កាយអេនជែល (Sky Angel Condo) ផ្លូវលេខ៩៥ សង្កាត់បឹងកេងកងទី៣» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់បឹងកេងកងទី៣ និងភាគីដែលពាក់ព័ន្ធ។ (លទ្ធផលទទួលបានគឺ ភាគីទាំងពីរឯកភាពគ្នាដោយសន្តិវិធី)។
- ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រុមការងារអនុសាខាកាកបាទខណ្ឌបឹងកេងកង ដែលមាន **លោក គឹម ឈុនអ៊ី** ជាប្រធានកិត្តិយស **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** និងជាអនុប្រធានគណៈកម្មាធិការ ព្រមទាំងមន្ត្រីយុវជនស្ម័គ្រចិត្ត បាននាំយកអំណោយដ៏ថ្លៃថ្លារបស់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅចែកជូនប្រជាពលរដ្ឋខ្វះខាតនៅភូមិ៥ សង្កាត់បឹងកេងកងទី២ ចំនួន៣៥គ្រួសារ។ អំណោយក្នុង១គ្រួសារទទួលបាន៖ អង្ករ ១០គីឡូ, មី ១០កញ្ចប់, ត្រីខ ២កំប៉ុង, ទឹកត្រី-ទឹកស៊ីអ៊ីវ ៤ដប, ម៉ាស ១កញ្ចប់,ឱសថព្យាបាល ១កញ្ចប់។
- ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្តីពី «ក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរកាលថ្នាក់ខណ្ឌ» ក្រោមអធិបតីភាព **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ ដែលមានការអញ្ជើញចូលរួមពីតំណាងមន្ទីរបរិស្ថានរាជធានីភ្នំពេញ លោកនាយករដ្ឋបាលខណ្ឌ ប្រធានការិយាល័យ ចៅសង្កាត់ទាំង៧ នាយប៉ុស្តិ៍ទាំង៧ និងមន្ត្រីដែលពាក់ព័ន្ធ។

- ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌ** និង **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** រួមទាំងក្រុមការងារខណ្ឌ បាននាំយកបច្ច័យកឋិណទានចំនួន ៥,០០០,០០០រៀល ទៅប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សានៅវត្តមហាមន្ត្រី។
- ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ចុះពិនិត្យណែនាំការដ្ឋានសំណង់ ចំនួន០២ទីតាំង នៅក្នុងសង្កាត់បឹងកេងកងទី១៖ ការដ្ឋានអាគារឌឹផ្លរ៉ា(The Flora) ផ្លូវលេខ៧១ ដែលបានដាក់សម្ភារៈសំណង់នៅលើផ្លូវសាធារណៈ និងទីតាំងការដ្ឋាន ផ្លូវលេខ៣០៦ កែងផ្លូវលេខ៥១ បានហ៊ុមព័ទ្ធរបងធ្វើឱ្យខូចបាក់បង្គោលស្លាកសញ្ញា ចំនួន០២ដើម។ (ម្ចាស់ទីតាំងទាំងពីរបានឯកភាពកែសម្រួលតាមការណែនាំរបស់ក្រុមការងារ)។
- ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ចុះត្រួតពិនិត្យបច្ចុប្បន្នភាពការដ្ឋាន ចំនួន០២ទីតាំង នៅក្នុងសង្កាត់បឹងកេងកងទី១៖ ការដ្ឋានផ្លូវលេខ៦៣ កែងផ្លូវលេខ៣០២ ដែលបានហ៊ុមព័ទ្ធរបងលើចិញ្ចើមផ្លូវសាធារណៈ និងការដ្ឋានអាគារសាលាអេស៊ីអ៊ី (ACE) ផ្លូវលេខ៣៣៤ ជិតផ្លូវព្រះមុនីវង្ស ការដ្ឋានមានលិខិតអនុញ្ញាតចេញពីសាលារាជធានីភ្នំពេញ (មិនមានលិខិតបើកការដ្ឋាន) មានកម្មករសរុប៣០នាក់ មានពាក់ម៉ាសបាញ់អាកុលបានត្រឹមត្រូវ (ក្រុមការងារសម្រេចណែនាំម្ចាស់ការដ្ឋានទាំងពីរទីតាំង និងហាមដាច់ខាតមិនឱ្យមានកម្មករស្នាក់នៅក្នុងការដ្ឋាន ពេលចប់ម៉ោងការងារ ត្រូវរៀបចំលិខិតបើកការដ្ឋានឱ្យបានត្រឹមត្រូវ មិនត្រូវទុកសម្ភារៈសំណង់លើចិញ្ចើមផ្លូវសាធារណៈ និងត្រូវពិនិត្យមើលជាប្រចាំលើវិធានការសុខាភិបាល)។
- រសៀលថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមានការចង្អុលបង្ហាញពីលោកអភិបាលខណ្ឌ **លោក កឹមណៃ វីរៈខេមរា** និង**លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** រួមជាមួយលោកប្រធានការិយាល័យអប់រំ និងក្រុមការងារទទួលបន្ទុកការងារអប់រំ យុវជន និងកីឡា បានបន្តចុះពិនិត្យការផ្អាកដំណើរការសាលាមត្តេយ្យក្នុងភូមិសាស្ត្រខណ្ឌបឹងកេងកងជាបណ្ដោះអាសន្ន។
- ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ៨:៣០ នាទីព្រឹក **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានស្ថាបនាផ្លូវលេខ១០៨០ ចាប់ពីមហាវិថីឈ្នះឈ្នះ ដល់ផ្លូវលេខ៤២ ក្នុងភូមិសាស្ត្រខណ្ឌពោធិ៍សែនជ័យ ខណ្ឌកំបូល និងខណ្ឌព្រែកព្នៅ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**។
- ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំអភិបាលរងខណ្ឌ អធិការនគរបាលខណ្ឌ មេបញ្ជាការកងរាជអាវុធខណ្ឌ នាយក-នាយករង ប្រធានការិយាល័យទាំង១១ ចៅសង្កាត់ទាំង៧ និងមន្ត្រីពាក់ព័ន្ធ ចូលរួមកិច្ចប្រជុំ «គណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** តាមរយៈការបញ្ជូនរូបភាព និងសម្លេង (Video Zoom Meeting)។
- ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** និងជាប្រធានកិត្តិយសអនុសាខាកាកបាទក្រហមខណ្ឌបឹងកេងកង **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** និងជាអនុប្រធានអនុសាខាកាកបាទក្រហមខណ្ឌបឹងកេងកង តំណាងលោកអភិបាលខណ្ឌ បានអញ្ជើញចុះចែកអំណោយជូនប្រជាពលរដ្ឋចាស់ជរា ចំនួនពីរគ្រួសារ ផ្លូវលេខ២៨៨ សង្កាត់បឹងកេងកងទី១។ អំណោយក្នុងមួយគ្រួសារទទួលបាន ថវិកា ២០,០០០រៀល, អង្ករ ២៥គីឡូ, មី ១កេស,ទឹកស៊ីវអ៊ីវ ១យួរ, ត្រីខ ១យួរ, ស្ករ ១គីឡូ, តែ ១កញ្ចប់, ទឹកដោះគោខាប់ ២កំប៉ុង,ទឹកសុទ្ធ ១យួរ, ម៉ាស់ ១ប្រអប់, ជែលលាងដៃ ២ដប។
- ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំ «ពិធីដេញថ្លៃ គម្រោងមូលនិធិអភិវឌ្ឍន៍សង្កាត់ទាំង៧ ឆ្នាំ២០២១ ក្នុងខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **ឯកឧត្តម ស៊ុយ សេរិទ្ធ អភិបាលរងរាជធានីភ្នំពេញ** តំណាងឯកឧត្តមអភិបាលរាជធានី ដោយមានការអញ្ជើញចូលរួមពី **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** និង **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ព្រមទាំងលោក-លោកស្រីអភិបាលរង នាយក-នាយករង តំណាងអធិការនគរបាលខណ្ឌ តំណាងមេបញ្ជាការកងរាជអាវុធ

ហត្ថខណ្ឌ ប្រធានការិយាល័យទាំង១១ ចៅសង្កាត់ទាំង៧ គណៈកម្មាធិការលទ្ធកម្មសង្កាត់ទាំង៧ ស្មៀន និងមន្ត្រីដែលពាក់ព័ន្ធ។

- ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំស្ដីពី «ការពង្រឹងការងាររដ្ឋបាលសណ្ដាប់ធ្នាប់ និងវេនយាមប្រចាំការក្នុងឱកាសបុណ្យអុំទូក អកអំបុក និងសំពះព្រះខែខាងមុខនេះ» ក្រោមអធិបតីភាព **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី គណៈអភិបាល លោកនាយករដ្ឋបាល និងលោក-លោកស្រីប្រធាន និងអនុប្រធានការិយាល័យ។
- ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ មានករណីភ្លៀងធ្លាក់លាយឡំនឹងខ្យល់បក់ខ្លាំង ធ្វើឱ្យដើមឈើមួយដើមធំដួលរលំកាត់ទទឹងផ្លូវម៉ៅសេទុង កែងនឹងផ្លូវលេខ១៩៩ ស្ថិតនៅក្នុងសង្កាត់ទួលស្វាយព្រៃទី១។ **លោក ធឹម សំអាន អភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ និងកម្លាំងសណ្ដាប់ធ្នាប់ខណ្ឌ ចុះអន្តរាគមន៍ភ្លាមៗ និងរៀបចំឱ្យមានសណ្ដាប់ធ្នាប់ឡើងវិញ ដើម្បីជៀសវាងការកកស្ទះចរាចរណ៍។
- ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្ដីពី "ការអនុវត្តវិធានការសុវត្ថិភាព និងនិតិវិធីស្តង់ដាអប្បបរមា (SOP)តាមគន្លងប្រក្រតីភាពថ្មី សម្រាប់អាជីវកម្ម សេវាកម្ម មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ(ខារ៉ាអូខេ បៀរហ្គាឌិន រង្គសាល ឌីស្កូតែក) នៅរាជធានីភ្នំពេញ" តាមរយៈប្រព័ន្ធ ZOOM Meeting ក្រោមអធិបតីភាព**ឯកឧត្តម ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ចុះពិនិត្យទីតាំងសំណង់ចំនួន ០២កន្លែងគឺ៖ «ទីតាំងភូមិគ្រឹះកំពុងសាងសង់ និងកំពុងជួសជុលកែលំអពុំមានលិខិតអនុញ្ញាត ស្ថិតនៅលើផ្លូវលេខ៣៦០ ភូមិ១ សង្កាត់បឹងកេងកងទី១ និងមានខ្សាច់គ្រួសលើចិញ្ចើមផ្លូវសាធារណៈបណ្ដាលឱ្យហូរចូលលូ ស្ទះលូហៀរពេញផ្លូវ» និង «ទីតាំងទំនាស់រវាងម្ចាស់ការដ្ឋានសំណង់ និងផ្ទះអ្នកជិតខាង ស្ថិតលើផ្លូវលេខ១៥៣ សង្កាត់អូឡាំពិក ដោយពិនិត្យឃើញថាផ្ទះដែលរងប៉ះពាល់គឺជាសំណង់ចាស់សសរមានច្រេះស៊ីដែក ចំណែកភាគីម្ចាស់ការដ្ឋានបានឯកភាពធ្វើការជួសជុលតាមបច្ចេកទេសដើម្បីការពារសុវត្ថិភាពទាំងអស់គ្នា តែភាគីម្ចាស់ផ្ទះមិនឯកភាពឱ្យជាងចូលជួលជុល» ។ (ក្រុមការងារសម្រេចផ្អាកការជួសជុលរបស់ម្ចាស់ភូមិគ្រឹះជាបណ្ដោះអាសន្ន ត្រូវរៀបចំលិខិតអនុញ្ញាតឱ្យបានត្រឹមត្រូវ និងត្រូវស្តារលូឡើងវិញ ហាមដាច់ខាតមិនឱ្យដាក់សម្ភារៈសំណង់លើផ្លូវសាធារណៈ)។ (ភាគីទំនាស់ទាំងពីរ ក្នុងករណីនេះភាគីម្ចាស់ផ្ទះត្រូវទទួលខុសត្រូវដោយខ្លួនឯង ប្រសិនបើមានហានិភ័យណាមួយ កើតឡើងភាគីទាំងពីរត្រូវបន្តនីតិវិធីតាមផ្លូវច្បាប់) ។
- ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធាន អនុសាខាកាកបាទក្រហមខណ្ឌបឹងកេងកង **លោក ស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** និងជាអនុប្រធាន អនុសាខាកាកបាទក្រហមខណ្ឌបឹងកេងកង ក្រុមការងារកាកបាទខណ្ឌ-សង្កាត់ បានអញ្ជើញចុះចែកអំណោយជូនប្រជាពលរដ្ឋចាស់ជរា ចំនួន ៤គ្រួសារ ក្នុងសង្កាត់បឹងកេងកងទី២ និងសង្កាត់បឹងកេងកងទី៣។ ក្នុងមួយគ្រួសារទទួលបាន៖ ថវិកា ១៤០,០០០រៀល, អង្ករ ២៥គីឡូ, មី ១កេស, ទឹកស៊ីអ៊ីវ ១យួរ, ត្រីខ ១យួរ, ស្ករ ១គីឡូ, តែ ១កញ្ចប់ ទឹកដោះគោខាប់ ២កំប៉ុង, ទឹកសុទ្ធ ១កេស, ម៉ាស់ ១ប្រអប់ , ជែលលាងដៃ ២ដប។
- ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានដឹកនាំមន្ត្រីក្រោមឱវាទ ចុះសួរសុខទុក្ខ និងនាំអំណោយដ៏ថ្លៃថ្លារបស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និង **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង **ឯកឧត្តម ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ជូនលោកស្រី ហួរ ថាវី សមាជិកាក្រុមប្រឹក្សាសង្កាត់បឹងកេងកងទី១ ដែលទើបតែជាពីជំងឺកូវីដ-១៩ និងលោកស្រី សក់ ជួរ សមាជិកភូមិ៤ ដែលមានគ្រោះថ្នាក់ចរាចរណ៍ដើរមិនរួច (ហើមជើង) ហើយមានជីវភាពខ្វះខាត។ អំណោយរួមមាន អង្ករ ២០ គីឡូក្រាម ,មី ០១កេស,ត្រីខកំប៉ុង ០១យួរ,ថវិកា ២០០,០០០ រៀល។

- ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ក៏មណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់បណ្តាញសង្គមប្រកបដោយប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយ និងទទួលព័ត៌មាន ក្រោមអធិបតីភាព **ឯកឧត្តម កើត ឆែ អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានអនុសាខាកាកបាទក្រហមខណ្ឌបឹងកេងកង **លោក ស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** និងជាអនុប្រធាន អនុសាខាកាកបាទក្រហមខណ្ឌបឹងកេងកង ក្រុមការងារកាកបាទខណ្ឌ សង្កាត់ បាននាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ផ្តល់ជូនតាមរយៈ **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** បន្តចុះចែកអំណោយជូនប្រជាពលរដ្ឋចាស់ជរា ចំនួន ៤គ្រួសារ ស្ថិតនៅសង្កាត់ទួលស្វាយព្រៃទី១ ចំនួន ០២គ្រួសារ និង សង្កាត់អូឡាំពិក ចំនួន ០២គ្រួសារ។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២៥គីឡូក្រាម, មី ០១កេស, ម៉ាស់ ០២ប្រអប់, ត្រីខ ០១យួរ, ទឹកស៊ីអ៊ីវ ០១យួរ, ស្ករស ០១គីឡូក្រាម, ទឹកដោះគោខាប់ ០២កំប៉ុង, តែ ០១កញ្ចប់, ដែល ០២ដបថវិកា ៤០,០០០រៀល។
- ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង លោក-លោកស្រីអភិបាលរង ក្រុមការងារកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង និងសង្កាត់ទួលស្វាយព្រៃទី១ បានបន្តអញ្ជើញចុះសួរសុខទុក្ខ និងចែកអំណោយជូនដល់បងប្អូនប្រជាពលរដ្ឋ និងចាស់ជរា ចំនួន ១១១គ្រួសារ ស្ថិតនៅភូមិ៦ សង្កាត់ទួលស្វាយព្រៃទី១។ ក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ១០ គីឡូក្រាម, មី ១០កញ្ចប់, ម៉ាស់ ០១កញ្ចប់, ត្រីខ ០២កំប៉ុង, ទឹកស៊ីអ៊ីវ ០៤ដប, ឃីត ០១កញ្ចប់ ។
- យប់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និង**លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ** បានដឹកនាំគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង ដាក់កម្លាំងចុះត្រួតពិនិត្យឆែកអាវុធជាតិផ្ទុះនៅផ្លូវម៉ៅសេទុង ទល់មុខវិទ្យាស្ថានវ៉ាន់ដា ក្នុងសង្កាត់ទួលស្វាយព្រៃទី១ ដោយមានការចូលរួមពីអធិការនគរបាលខណ្ឌ កងរាជអាវុធហត្ថខណ្ឌ កម្លាំងសណ្តាប់ធ្នាប់ខណ្ឌ។
- ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ និងជាប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង បានចុះសួរសុខទុក្ខ និងបាននាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ចែកជូនប្រជាពលរដ្ឋក្រីក្រ និងចាស់ជរា ចំនួន ៤គ្រួសារ ស្ថិតនៅក្នុងសង្កាត់ទំនប់ទឹក ចំនួន ០២គ្រួសារ និងសង្កាត់ទួលស្វាយព្រៃទី២ ចំនួន ០២គ្រួសារ។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២៥គីឡូក្រាម, មី ០១កេស, ម៉ាស់ ០២ប្រអប់, ត្រីខ ០១យួរ, ទឹកស៊ីអ៊ីវ ១យួរ, ស្ករស ០១គីឡូក្រាម, ទឹកដោះគោខាប់ ០២កំប៉ុង, តែ ០១កញ្ចប់ ដែល ០២ដប, ទឹកសុទ្ធ ០២យួរ, ថវិកា ៤០,០០០រៀល។
- ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង លោក-លោកស្រីអភិបាលរងខណ្ឌ ក្រុមការងារកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង បានអញ្ជើញចុះចែកអំណោយជូនប្រជាពលរដ្ឋខ្វះខាត ចំនួន ៥០គ្រួសារ ស្ថិតក្នុងភូមិ៤ ផ្លូវលេខ២០៧ សង្កាត់ទំនប់ទឹក។ ក្នុងមួយគ្រួសារទទួលបាន ៖អង្ករ ១០គីឡូ, មី ១កេស និង១០កញ្ចប់,ម៉ាស់ ១០ ត្រីខ ២កំប៉ុង, ទឹកស៊ីអ៊ីវ ៤ដប, ថ្នាំ ១កញ្ចប់។
- ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំដកស្រង់បទពិសោធន៍លើកទី៣ ផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម សំណង់រឹង នៅរាជធានីភ្នំពេញ របស់ប្រតិបត្តិករទាំង៣ តាមរយៈប្រព័ន្ធ ZOOM Meeting ក្រោមអធិបតីភាព **ឯកឧត្តម កើត ឆែ** និង **ឯកឧត្តម ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ**។

- ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការដោះស្រាយបញ្ហាចរាចរណ៍តាមដងផ្លូវក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ តាមរយៈប្រព័ន្ធ ZOOM Meeting ក្រោមអធិបតីភាព **ឯកឧត្តម មាន ចាន់យ៉ាដា អភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំសិក្ខាសាលាស្តីពី «សមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ របស់សង្កាត់ខណ្ឌ» ក្រោមអធិបតីភាព **លោកជំទាវ កែវ សុខពិសី អភិបាលរងរាជធានីភ្នំពេញ** តំណាងឯកឧត្តមអភិបាលរាជធានីភ្នំពេញ **លោក គឹម ច័ន្ទឌីណា** ប្រធានមន្ទីរផែនការរាជធានីភ្នំពេញ **លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង និង លោក ធឹម សំអាន អភិបាលខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី លោក-លោកស្រី សមាជិកក្រុមប្រឹក្សាខណ្ឌបឹងកេងកង លោក-លោកស្រីអភិបាលរងខណ្ឌ មន្ទីរ អង្គភាព ជំនាញ អង្គការសប្បុរសជន ការិយាល័យចំណុះ-ជំនាញជុំវិញរដ្ឋបាលខណ្ឌនិង សង្កាត់ទាំង៧។
- ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងការចុះពិនិត្យសំណើរការអនុញ្ញាតខួងផ្លូវលេខ ២៧៤ ១៦៣ ១៤៣ ១២៥ ១១៣ ១០៥ ២៧៨ ២៨៨ ៣១០ ៣៦០ ២៤៥ ៤៥៦ ៩៣ ២៧១ និងជីកចិញ្ចើមផ្លូវលេខ២៧៤ និងផ្លូវលេខ៩៣ ដើម្បីដាក់ខ្សែកាបអគ្គិសនីកប់ដីថ្មីចេញពីពហុកីឡាដ្ឋានជាតិអូឡាំពិកហូតដល់អនុស្ថានីយអគ្គិសនីទី២ ក្រោមអធិបតីភាព **ឯកឧត្តម ស៊ុយ សេរិទ្ធ អភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ ស្តីពីគោលនយោបាយគាំទ្រការស្តារឡើងវិញដំណើរការផលិតកម្ម ប្រកបដោយនិរន្តភាព សម្រាប់រោងចក្រកាត់ដេរធុនតូច និងមធ្យម ក្នុងរាជធានីភ្នំពេញ តាមរយៈប្រព័ន្ធ ZOOM Meeting ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមជាកិត្តិយស ក្នុងពិធីបិទការប្រកួតពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន លើកទី១៥ ឆ្នាំ២០២១ ថ្នាក់ជាតិ នៅកីឡាដ្ឋាន ស្មាត អ អេស អិន របស់ក្លឹបបាល់ទាត់ភ្នំពេញក្រោន ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។
- ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង បានបន្តនាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ចែកជូនប្រជាពលរដ្ឋក្រីក្រ និងជនចាស់ជរា ចំនួន៧១គ្រួសារ មកពីសង្កាត់ទាំង៧ ខណ្ឌបឹងកេងកង។ ក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២៥គីឡូ, មី ០១កេស, ម៉ាស់ ១០, ត្រីខ ០៤កំប៉ុង, ទឹកស៊ីអ៊ីវ ០៤ដប, ស្ករស កន្លះគីឡូ, ជែល ០១ដប, ថ្នាំ ០១កញ្ចប់។
- ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំក្រុមការងារជំនាញ និងមន្ត្រីសង្កាត់ដោយមានការចូលរួមពីលោកអធិការរងខណ្ឌ និងលោកមេប៉ុស្តិ៍បានចុះអនុវត្តន៍ «បើកទ្វារច្រកផ្លូវសេវភាពជាបណ្តោះអាសន្ន នៅផ្លូវព្រះមុនីវង្ស សង្កាត់បឹងកេងកងទី២» ។ (ក្រុមការងារសម្រេច៖ កាត់សោរដើម្បីបើកច្រកទ្វារផ្លូវសេវភាពជាបណ្តោះអាសន្នរយៈពេល៣ខែ និងបានណែនាំភាគីទាំងសងខាងត្រូវអនុវត្តតាមខ្លឹមសារ លិខិតលេខ: ១២៨/២១ សជណ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១)។
- ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានចូលរួមសហការជាមួយក្រុមហ៊ុនស៊ីនទ្រី ដើម្បីរៀបចំសិក្ខាសាលាស្តីពី «ការលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ **លោក កែវ ចាន់ណារិទ្ធ អភិបាលរងរដ្ឋាករស្វយ័តរាជធានីភ្នំពេញ** និង **លោក ខៀវ វុទ្ធី** អនុប្រធានការិយាល័យប្រតិបត្តិ នៃក្រុមហ៊ុនស៊ីនទ្រី ដោយមានការអញ្ជើញចូលរួមពី លោកនាយករដ្ឋបាល សង្កាត់ទាំង៧ បុគ្គលិកក្រុមហ៊ុនស៊ីនទ្រី ម្ចាស់អាជីវកម្ម ហាង ក្រុមហ៊ុនផ្សេងៗ ទាំងខ្នាតតូច និងធំទាំងអស់។

- ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំស្តីពី "ការត្រៀមលក្ខណៈទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយ ឯកឧត្តមបណ្ឌិត ផនខាំ វីផាវ៉ាន់ នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ អញ្ជើញមកបំពេញទស្សនៈកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី២៩-៣០ វិច្ឆិកា ឆ្នាំ២០២១" តាមរយៈប្រព័ន្ធZOOM Meeting ក្រោមអធិបតីភាព **ឯកឧត្តម មាន ចាន់ យ៉ាដា** និង**ឯកឧត្តម នួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ខណ្ឌបឹងកេងកង បានរៀបចំកិច្ចប្រជុំសាមញ្ញលើកទី២៧ ប្រចាំខែតុលា ឆ្នាំ២០២១ ក្រោមអធិបតីភាព **លោកស្រី ម៉ែន សុភារី ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង** និង **លោកស្រី ប៉ា សុខា អនុប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** ដែលមានការចូលរួមពី ប្រធាន-អនុប្រធានការិយាល័យ និងសមាជិក-សមាជិកា គ.ក.ស.កខណ្ឌ និង អ.ក.ន.ក សង្កាត់។
- ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំរវាងក្រុមការងារលេខាធិការដ្ឋាន របស់គណៈកម្មការទទួលបន្ទុកអនុវត្តការពិន័យអន្តរកាលរាជធានីភ្នំពេញ របស់រដ្ឋបាលខណ្ឌទាំង១៤ តាមរយៈប្រព័ន្ធ ZOOM ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ**។
- ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្របសម្រួលវិវាទស្តីពី «បញ្ហារវាងការដ្ឋានអាគារវឌ្ឍន និងអាគារសាលារៀនAii ស្ថិតលើផ្លូវម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល ចៅសង្កាត់ទួលស្វាយព្រៃទី១ និងភាគីដែលពាក់ព័ន្ធ។ (លទ្ធផលទទួលបានគឺ៖ ភាគីទាំងពីរសុំលើកពេលដើម្បីពិចារណា និងបន្តនីតិវិធីនៅពេលក្រោយ) ។
- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកកិច្ចប្រជុំសាមញ្ញលើកទី៣០ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ួ ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង** ដោយមានការអញ្ជើញចូលរួមពី សមាជិកសមាជិកាក្រុមប្រឹក្សាខណ្ឌ អភិបាលរងខណ្ឌ លោក-លោកស្រីអភិបាលរងខណ្ឌ នាយក-នាយរងរដ្ឋបាលខណ្ឌ ការិយាល័យចំណុះ~ជំនាញជុំវិញខណ្ឌ ចៅសង្កាត់ទាំង៧ និងមន្ត្រីពាក់ព័ន្ធ។
- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក គឹម ឈុនអ៊ួ ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង និង លោក ធឹម សំអាន ប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង** លោក-លោកស្រីអភិបាលរងខណ្ឌ **លោកស្រី ម៉ែន សុភារី ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង** ក្រុមការងារកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង និងសមាជិក-សមាជិកា គ.ក.ស.កខណ្ឌ បានអញ្ជើញចុះចែកអំណោយជូនប្រជាពលរដ្ឋខ្វះខាតចំនួន ៦៧គ្រួសារ ស្ថិតនៅទីតាំងផ្ទះបាយកុមារ ផ្លូវលេខ១១៣ សង្កាត់បឹងកេងកងទី៣។ ក្នុងមួយគ្រួសារទទួលបាន៖ អង្ករចំនួន ១០គីឡូ, មី ១០ កញ្ចប់, ម៉ាស់ ១០, ត្រីខ ៤កំប៉ុង,ទឹកស៊ីអ៊ីវ ២ដប, ថ្នាំ ១កញ្ចប់, តែ ១កញ្ចប់ ទឹកដោះគោខាប់ ១កំប៉ុង។
- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមជាកិត្តិយសក្នុងពិធីបើកឱ្យដំណើរការមន្ទីរសំរាកព្យាបាល អូរ៉េន ឃែនស័រ ដែលស្ថិតនៅផ្លូវជាតិលេខ៦A សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** និង **លោកជំទាវ** ។
- ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង លោកស្រីអភិបាលរងខណ្ឌ ក្រុមការងារកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង លោកស្រី ម៉ែន សុភារី អនុប្រធានអចិន្ត្រៃយ៍ អនុសាខាសមាគមនារីខណ្ឌបឹងកេងកង បានអញ្ជើញចុះចែកអំណោយជូនប្រជាពលរដ្ឋខ្វះខាតចំនួន ៣០គ្រួសារ ស្ថិតផ្លូវលេខ២៧៨ សង្កាត់អូឡាំពិក។ អំណោយក្នុង

មួយគ្រួសារទទួលបាន៖ អង្ករចំនួន ២៥គីឡូ, មី ៥កញ្ចប់, ម៉ាស់ចំនួន ២០, ត្រីខ ៤កំប៉ុង, ថ្នាំ ១កញ្ចប់, តែ ២កញ្ចប់, ស្ករស ១គីឡូ, ទឹកដោះគោខាប់ ២កំប៉ុង, ភួយ ១។

- ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានីភ្នំពេញ (គ.រ.ប.ជ) តាមរយៈប្រព័ន្ធ ZOOM ក្រោមអធិបតីភាព **លោកជំទាវ កែវ សុខពីសី អភិបាលរងរាជធានីភ្នំពេញ។**
- ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** និងជាប្រធានអនុសាខាកាកបាទក្រហមខណ្ឌ បានអញ្ជើញជួបសំណេះសំណាលជាមួយសមាគមមនុស្សចាស់នៅក្នុងខណ្ឌបឹងកេងកេង និងបន្តចែកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចែកជូនសមាជិក សមាជិកាសមាគមមនុស្សចាស់ដែលមានជីវភាពក្រីក្រ ចំនួន ៧០នាក់ មកពីសង្កាត់ទាំង៧ ក្នុងខណ្ឌបឹងកេងកង។ អំណោយក្នុងមួយនាក់ទទួលបាន៖ ភួយ ០១, អាវរងា ០១, ក្រម៉ា ០១, ថវិកា៥០០០០រៀល។
- ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមជាកិត្តិយសក្នុងពិធីក្រុងពាលី និងបញ្ចុះបឋមសិលាការដ្ឋានសាងសង់មន្ទីរពេទ្យពហុជំនាញភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាលអភិបាលរាជធានីភ្នំពេញ** និង*លោកជំទាវ* ស្ថិតក្នុងសង្កាត់វាលវង់ ខណ្ឌ៧មករា។
- ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាការងាររៀបចំបុណ្យព្រះសព សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។
- ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ **លោកធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** លោក-លោកស្រីអភិបាលរង នាយក-នាយករងរដ្ឋបាលខណ្ឌ បានចូលរួមកិច្ចប្រជុំស្តីពី «ការសម្ពោធដាក់ប្រើប្រាស់ជាផ្លូវការវិមានកីឡដ្ឋាន នៃពហុកីឡដ្ឋានជាតិមរតកតេជោ» តាមរយៈការបញ្ជូនរូបភាព និងសំឡេង (Video Zoom Meeting) ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។**
- ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ បានអញ្ជើញជាអធិបតីភាព ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីកិច្ចការរដ្ឋបាលដែលរៀបចំឡើងដោយរដ្ឋបាលរាជធានីភ្នំពេញ។
- ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ **លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានចូលរួមជាអធិបតីក្នុងការចរចារថ្លៃការងារអ៊ុតបេទីម ផ្លូវលេខ៣៣៤ ចាប់ពីផ្លូវលេខ៦៣ ដល់ផ្លូវលេខ៥១ កម្រាស់ ៥សង់ទីម៉ែត្រ បណ្តោយ២៤០ម៉ែត្រ ទទឹង ៦ម៉ែត្រ សុរបផ្ទៃក្រឡា១,៤៤០ម៉ែត្រ ក្នុងសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង ឆ្នាំ២០២១ នៅសាលប្រជុំជាន់ទី២។
- ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ **លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌបឹងកេងកង** បានដឹកនាំអង្គប្រជុំសម្របសម្រួលស្តីពី «ការសុំអន្តរាគមន៍កាត់សោបន្ទប់ជួល អាសយដ្ឋានជាន់ទី១ អាគារលេខ៥ ស្ថិតនៅផ្លូវលេខ២៨៤ សង្កាត់អូឡាំពិក» ដោយមានការចូលរួមពីប្រធានការិយាល័យនីតិកម្ម ប្រធានការិយាល័យភូមិបាល មេប៉ុស្តិ៍នគរបាល ចៅសង្កាត់អូឡាំពិក និងភាគីដែលពាក់ព័ន្ធ។ (លទ្ធផលទទួលបានគឺ៖ សាម៉ីខ្លួនស្នើសុំដាក់ពាក្យទៅស្ថាប័នតុលាការ)។
- ព្រឹកថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ **លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមជាអធិបតីក្នុងការប្រគល់ប្រាក់ចំនួន ៤,000,000៛ របស់ សមាគមអតីតយុទ្ធជនកម្ពុជា ផ្តល់ជូនគ្រួសារសព លោក ប៉ែន ទូច ដែលបានទទួលមរណៈភាព កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១។
- ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីការប្រមូលទិន្នន័យភូមិ-សង្កាត់-ខណ្ឌ ឆ្នាំ២០២១ ក្រោមអធិបតីភាព **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹង**

**កេងកង** តំណាងលោកអភិបាលខណ្ឌ និងលោក សាន់ សូផាត ប្រធានការិយាល័យផែនការស្ថិតិ តំណាងលោក គឹម ច័ន្ទឌីណា ប្រធានមន្ទីរផែនការរាជធានីភ្នំពេញ។

- ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការត្រួតពិនិត្យ និងពង្រឹងការអនុវត្តការងាររបស់ក្រុមប្រឹក្សាពត៌មាន និងប្រតិកម្មរហ័សរាជធានីភ្នំពេញ តាមរយៈប្រព័ន្ធ ZOOM ក្រោមអធិបតីភាព **ឯកឧត្តម កើត ឆែ អភិបាលរងរាជធានីភ្នំពេញ** និងជាប្រធានក្រុមការងារពត៌មាន និងប្រតិកម្មរហ័សរាជធានីភ្នំពេញ។
- ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ **លោក ធីម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង** បានបន្តនាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ផ្តល់ជូនប្រជាពលរដ្ឋខ្វះខាតចំនួន ៦៨គ្រួសារ ក្នុងសង្កាត់បឹងកេងកងទី៣ ដោយមានការអញ្ជើញចូលរួមពីលោក-លោកស្រីអភិបាលរងខណ្ឌ នាយករង សមាជិកក្រុមប្រឹក្សាខណ្ឌ ក្រុមការងារកាកបាទក្រហមកម្ពុជាខណ្ឌបឹងកេងកង។ អំណោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ២៥គីឡូ, មី ១០កញ្ចប់, ម៉ាស់ ១០, ត្រីខ ២កំប៉ុង, តែ ០១កញ្ចប់, ទឹកដោះគោខាប់ ០១កំប៉ុង, ស្ករស កន្លះគីឡូ, អំបិល ១គីឡូកន្លះ។
- ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ **លោក ធីម សំអាន អភិបាលនៃគណៈអភិបាលខណ្ឌបឹងកេងកង** បានបើកកិច្ចប្រជុំស្តីពី «ការត្រៀមចូលរួមកម្មវិធីសម្ពោធពហុកីឡដ្ឋានជាតិមរតកតេជោ» ដោយមានការអញ្ជើញចូលរួមពីគណៈអភិបាល នាយក-នាយករង ប្រធានការិយាល័យ និងចៅសង្កាត់ទាំង៧។
- ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់កម្មវិធីពត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក ខណ្ឌ ក្រោមអធិបតីភាព **លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង** តំណាងលោកអភិបាលខណ្ឌ ដោយមានការអញ្ជើញចូលរួមពីលោក-លោកស្រីប្រធានការិយាល័យ អនុប្រធាន និងមន្ត្រីពាក់ព័ន្ធ។
- ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ **លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង** បានចូលរួមកិច្ចប្រជុំស្តីពីការបង្ការ និងពន្លត់អគ្គីភ័យក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ តាមរយៈប្រព័ន្ធ ZOOM ក្រោមអធិបតីភាព **ឯកឧត្តម មាន ចាន់យ៉ាដា អភិបាលរងរាជធានីភ្នំពេញ**។

**តារាងទី៥៖ កិច្ចប្រជុំគណៈអភិបាល**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ១៦ | ០២ | ១៨ |
| ២ | កិច្ចប្រជុំប្រចាំខែ (អឌ្ឍមាសទី២) របស់គណៈអភិបាល | ០៨ | ០១ | ០៩ |

**១.១.៦. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

**តារាងទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ០៩ | ០១ | ១០ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ០០ | ០០ | ០០ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០០ | ០០ | ០០ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ០០ | ០០ | ០០ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ០៩ | ០១ | ១០ |

តារាងទី៧៖ ការរៀបចំវេទិកា

| ល.រ | ឈ្មោះវេទិកា | អ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | បានរៀបចំវេទិកាសាធារណៈអនុវត្តគោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព | ២៥០នាក់ | ១៦៣នាក់ |
| ២ | បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង អាណត្តិទី៣ | | |
| ៣ | បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ | | |

**១.២. ការងារផែនការ និងការគាំទ្រសង្កាត់**

**១.២.១. ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខណ្ឌ**

- ចំពោះគម្រោងជាអាទិភាពសម្រាប់ឆ្នាំ២០២១-២០២៣ របស់រដ្ឋបាលខណ្ឌបឹងកេងកងមាន៖
- ផ្នែកសេដ្ឋកិច្ច៖ មានចំនួន ០៨គម្រោង ក្នុងតម្លៃប៉ាន់ស្មាន ៦៦៨,៥៧០,០០០រៀល។
- ផ្នែកសង្គមកិច្ច៖ មាន១៦គម្រោង ក្នុងតម្លៃប៉ាន់ស្មាន ៣៣៨,៦០០,០០០រៀល។
- ផ្នែកធនធានធម្មជាតិ បរិស្ថាន ការបន្សាំ និងការប្រែប្រួលអាកាសធាតុ៖ មាន០៧គម្រោង ក្នុងតម្លៃប៉ាន់ស្មាន ១៩៤,៦០០,០០០រៀល។
- ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ៖ មាន២៣គម្រោង ក្នុងតម្លៃប៉ាន់ស្មាន ៧០,០០០,០០០រៀល។

**១.២.២. ការអនុវត្តគម្រោងអភិវឌ្ឍន៍ខណ្ឌ ឆ្នាំ២០២១៖** អនុវត្តបាន ១០០%។

**១.២.៣. លទ្ធផលដែលអនុវត្តបាន៖** អនុវត្តបាន ១០០%។

**១.២.៤. ការងារចូលរួមផ្សេងៗ៖** គ្មាន

តារាងទី៨៖ គម្រោងវិនិយោគបីឆ្នាំរំកិលខណ្ឌ

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង(រៀល) |
|---|---|---|---|
| ១ | សេដ្ឋកិច្ច | ០៨ | ៦៦៨,៥៧០,០០០ |
| ២ | សង្គមកិច្ច | ១៦ | ៣៣៨,៦០០,០០០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០៧ | ១៩៤,៦០០,០០០ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ២៣ | ៧០,០០០,០០០ |
| សរុប | | ៥៤ | ១,២៧១,៧៧០,០០០ |

**១.២.៥. ការអនុវត្តគម្រោងវិនិយោគខណ្ឌ**

តារាងទី៩៖ ការអនុវត្តគម្រោងវិនិយោគខណ្ឌ

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ០៨ | ០០ | ០០ | ០៨ |
| ២ | សង្គមកិច្ច | ១៦ | ០០ | ០០ | ១៦ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០៧ | ០០ | ០០ | ០៧ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ២៣ | ០០ | ០០ | ២៣ |
| **សរុប** | | ៥៤ | ០៩ | ០០ | ៥៤ |

### ១.២.៦. ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣

មកដល់ពេលនេះ រដ្ឋបាលខណ្ឌបឹងកេងកង ពុំទាន់ទទួលបានការណែនាំ សម្រាប់អនុវត្តទាំងផែនការសកម្មភាព និងទាំងការបែងចែកថវិកានៅឡើយ។

**តារាងទី១០ ៖ ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣**

| លេខកូដ | ឈ្មោះសកម្មភាព | ស្ថានភាព | %សម្រេច | %ចំណាយ |
|---|---|---|---|---|
| ១ | គ្មាន | គ្មាន | គ្មាន | គ្មាន |

### ១.២.៧. ការគាំទ្រសង្កាត់

- ប្រមូលទិន្នន័យគម្រោងអភិវឌ្ឍន៍មូលនិធិសង្កាត់ទាំង៧ សម្រាប់ឆ្នាំ២០២០-២០២៤។
- ធ្វើសំណើរៀបចំបច្ចុប្បន្នភាព គណៈកម្មការ និងជនបង្គោលនានារបស់សង្កាត់ទាំង៧សម្រាប់ឆ្នាំ២០២១។
- រៀបចំតារាងស្ថិតិប្រជាពលរដ្ឋក្នុងសង្កាត់ទាំង៧ប្រចាំឆ្នាំ២០២១។

## ១.៣. ការគ្រប់គ្រងធនធានមនុស្ស

### ១.៣.១. ការគ្រប់គ្រងបុគ្គលិក

របនាសម្ព័ន្ធខណ្ឌរួមមាន ៖

- សមាជិកក្រុមប្រឹក្សាខណ្ឌ ចំនួន ១៧នាក់ ស្រី ០២នាក់
- ប្រធានក្រុមប្រឹក្សាខណ្ឌ ០១នាក់ ប្រុស
- សមាជិកក្រុមប្រឹក្សាខណ្ឌដែលបានផ្លាស់ប្តូរ គ្មាន
- គណៈអភិបាលខណ្ឌមាន ០៥នាក់
- អភិបាល នៃគណៈអភិបាលខណ្ឌ ០១នាក់
- អភិបាលរងខណ្ឌ ០៤នាក់ ស្រី០១នាក់
- នាយក នាយករងរដ្ឋបាល ០៣នាក់
- ប្រធានការិយាល័យ និងអង្គភាព ០៩នាក់ ស្រី ០១នាក់
- អនុប្រធានការិយាល័យ និងអង្គភាព ១៤នាក់ ស្រី ០៣នាក់
- ស្មៀនសង្កាត់ចំនួន ០៧នាក់
- មន្ត្រីកម្មសិក្សា ១៩នាក់ ស្រី១៤នាក់
- បុគ្គលិកជាប់កិច្ចសន្យា ២០៨នាក់ ស្រី៥៣នាក់

**តារាងទី១១៖ ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា | ១៧ | ០២ |
| ២ | ប្រធានក្រុមប្រឹក្សា | ០១ | ០០ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ០០ | ០០ |
| ៤ | អភិបាល | ០១ | ០០ |
| ៥ | អភិបាលរង | ០៤ | ០១ |
| ៦ | នាយករដ្ឋបាល | ០១ | ០០ |
| ៧ | នាយករងរដ្ឋបាល | ០២ | ០០ |
| ៨ | ប្រធានការិយាល័យ និងអង្គភាព | ០៩ | ០១ |
| ៩ | អនុប្រធានការិយាល័យ និងអង្គភាព | ១៤ | ០៣ |

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១០ | ស្មៀនសង្កាត់ | ០៧ | ០១ |
| ១១ | មន្ត្រីកម្មសិក្សា | ១៩ | ១៤ |
| ១២ | បុគ្គលិកកិច្ចសន្យា | ២០៨ | ៥៣ |

**១.៣.២. ការកសាងសមត្ថភាព**

**តារាងទី១២៖ ការកសាងសមត្ថភាព**

| ល.រ | ឈ្មោះវគ្គសិក្សា | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| | គ្មាន | | | | |

## ១.៤. ការងារអន្តរវិស័យ

**១.៤.១. ការសម្របសម្រួលតាមវិស័យ**

**១.៤.២. ការអនុវត្តមុខងារផ្សេងៗ** (មុខងារដែលបានប្រតិភូកម្ម)

- សាលារាជធានីភ្នំពេញបានធ្វើប្រតិភូកម្មមុខងារក្នុងវិស័យនានា មកឱ្យរដ្ឋបាលខណ្ឌបឹងកេងកង ដែលមានដូចខាងក្រោម៖
  - o វិស័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល
  - o វិស័យអភិវឌ្ឍន៍ជនបទ
  - o វិស័យធនធានទឹក
  - o វិស័យបរិស្ថាន និងធនធានធម្មជាតិ
  - o វិស័យរ៉ែ និងថាមពល
  - o វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - o វិស័យសាធារណការ និងដឹកជញ្ជូន
  - o វិស័យឧស្សាហកម្ម និងសិប្បកម្ម
  - o វិស័យពាណិជ្ជកម្ម
  - o វិស័យទេសចរណ៍
  - o វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  - o វិស័យកិច្ចការនារី
  - o វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  - o វិស័យធម្មការ និងសាសនា
  - o វិស័យវប្បធម៌ និងវិចិត្រសិល្បៈ
  - o វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍
  - o វិស័យសុខាភិបាល
  - o ការងារនីត្យានុកូលកម្ម រដ្ឋបាល និងអត្រានុកូលដ្ឋាន
  - o វិស័យអប់រំ
  - o មុខងារគ្រប់គ្រងសេវាទីប្រជុំជន

**១.៤.៣. ការងារច្រកចេញចូលតែមួយ**

**ចាប់ពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១** រហូតដល់ **ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១** ការិយាល័យច្រកចេញចូលតែមួយបានផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋបានចំនួន **៣៧,៩៥២ នាក់** ស្រីចំនួន **១៥,២០២**នាក់ ក្នុងនោះ ៖

- វិស័យនីត្យានុកូលកម្ម ចំនួន ៣០១២៥នាក់ ស្រីចំនួន ១២១៣១នាក់
- វិស័យវប្បធម៌ និងវិចិត្រសិល្បៈ ចំនួន ១១នាក់ ស្រីចំនួន ០៥នាក់
- វិស័យអប់រំ យុវជន និងកីឡា ចំនួន ០៣នាក់
- វិស័យទេសចរណ៍ ចំនួន ៤៦នាក់ ស្រីចំនួន ០៨នាក់
- វិស័យអត្រានុកូលដ្ឋាន ចំនួន ៦៤៦៣នាក់ ស្រីចំនួន ២៥៧៧នាក់
- វិស័យសុរិយោដី ចំនួន ៩៥នាក់ ស្រីចំនួន ១០នាក់
- វិស័យសំណង់ ចំនួន ៦២នាក់ ស្រីចំនួន ០៣នាក់
- វិស័យឧស្សាហកម្ម ចំនួន ០នាក់
- វិស័យរ៉ែ និងថាមពល ចំនួន ០នាក់
- វិស័យពាណិជ្ជកម្ម ចំនួន ៦៥៣នាក់ ស្រីចំនួន ៣៦៣នាក់
- វិស័យសុខាភិបាល ចំនួន ២៨នាក់ ស្រីចំនួន ០៤នាក់
- វិស័យសាធារណការ ចំនួន ៤៦៦នាក់ ស្រីចំនួន ១០១នាក់
- វិស័យកសិកម្ម ចំនួន ០០នាក់

**តារាងទី១៣ ៖ កិច្ចការច្រកចេញចូលតែមួយ**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | សេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់ | ៣៣១០៥ | ៤៨៤៧ | ៣៧៩៥២ |
| ២ | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | ៣៣១០៥ | ៤៨៤៧ | ៣៧៩៥២ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | ១៣១២៦ | ២០៨៦ | ១៥,២០២ |
| ៤ | ចំណូលដែលទទួលបានពីការផ្តល់សេវា(៛) | ១៥៥,២១២,៧២០ | ១៩,៩១៦,៦១០ | ១៧៥,១២៩,៣៣០ |
| ៥ | ករណីបណ្តឹងដែលទទួលបានសរុប | ០០ | ០០ | ០០ |
| ៦ | ករណីបណ្តឹងដែលបានដោះស្រាយរួចជាស្ថាពរ | ០០ | ០០ | ០០ |

### ១.៤.៤. កិច្ចការសេវាសង្គម និងការបង្កើនសិទ្ធិអំណាចស្ត្រី និងកុមារ

**តារាងទី១៤៖ ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក**

| ល.រ | សូចនាករ | ផែនការប្រចាំឆ្នាំ | លទ្ធផលសម្រេច | |
|---|---|---|---|---|
| | | | ជាក់ស្តែង | % |
| ១ | ចំនួនកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ខណ្ឌ | ១២ | ០៩ | ៧៥ |
| ២ | ចំនួនថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើផ្នែកសេវាសង្គម(រៀល) | ៥,៦១៦,០០០ | ១,២២០,០០០ | ២៣ |
| ៣ | ខណ្ឌបានចងក្រងទិន្នន័យអត្រានុកូលដ្ឋាន ដែលទទួលបានពីសង្កាត់ | ០០ | ០០ | ០០ |
| ៤ | ចំនួនបេសកកម្មដែល គ.ក.ស.ក ខណ្ឌបានចុះគាំទ្រ និងផ្តល់សេវាសង្គម ទាំង៧សង្កាត់ | ៩៤ | ០៧ | ៧.៥ |
| ៥ | ចំនួនសង្កាត់ដែល គ.ក.ស.ក ខណ្ឌ បានចុះគាំទ្រ ទាំង៧សង្កាត់ | ០៧ | ០៧ | ១០០ |
| ៦ | ចំនួនវគ្គបណ្តុះបណ្តាលដែល គ.ក.ស.ក ខណ្ឌបានទទួល | ០០ | ០០ | ០០ |

## ១.៥. ការងារហិរញ្ញវត្ថុ

### ១.៥.១. ការអនុវត្តចំណូល និងចំណាយ

យោងអនុក្រឹត្យលេខ០៣អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតខណ្ឌបឹងកេងកង៖

- សរុបចំណូល៖ ៤,៤៥៤,៥៨០,០០០៛
- សរុបចំណាយ៖ ៤,៤៥៤,៥៨០,០០០៛

**តារាងទី១៥៖ ការអនុវត្តចំណូល និងចំណាយ**

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ផ្នែកចំណូល | | | | |
| ៧០ | ចំណូលសារពើពន្ធ | | | |
| ៧២ | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | | | |
| ៧៣ | ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិ និងសេវា | ៣៧០,០០០,០០០៛ | ២៥១,៤០២,៤០០៛ | ៦៨% |
| ៧៤ | ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម | | | |
| ៧៥ | ការឧបត្ថម្ភកធន | ៤,០៨៤,៥៨០,០០០៛ | ៣,៣១០,៥០០,០០០៛ | ៨១% |
| ៧៦ | ផលហិរញ្ញវត្ថុ | | - | |
| ៧៧ | ផលផ្សេងៗ និងផលពិសេស | | | |
| ៧៨ | ការងារនៃរដ្ឋទេយ្យ | | | |
| ០៨ | ចំណូលមូលនិធិបម្រុង | | | |
| ១៣ | ឧបត្ថម្ភកធន-វិនិយោគ | | | |
| សរុបចំណូល | | ៤,៤៥៤,៥៨០,០០០៛ | ៣,៥៦១,៩០២,៤០០៛ | ៨០% |
| ផ្នែកចំណាយ | | | | |
| ៦០ | ការទិញ | ៤២៤,១៣០,០០០៛ | ១៣១,១៧៥,៦៧០៛ | ៣១% |
| ៦១ | សេវាខាងក្រៅ | ២៦១,០៣០,០០០៛ | ៥៥,២១៦,០០០៛ | ២១% |
| ៦២ | សេវាខាងក្រៅផ្សេងៗ | ២០២,០៨០,០០០៛ | ២០១,៣៤៥,០០០៛ | ៩៩.៦% |
| ៦៣ | ពន្ធ និងអាករ | ០០ | ០០ | ០០ |
| ៦៤ | បន្ទុកបុគ្គលិក | ៣,៣៦៧,៣៤០,០០០៛ | ៣,៣៥៥,៨៧០,៧២០៛ | ៩៩.៦% |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | | | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | | | |
| ៦៧ | បន្ទុកពិសេស | | | |
| ៦៨ | ទាយជ្ជទានឱ្យដល់រម្លស់អចលកម្មរូបី | | | |
| ៦៩ | ចំណាយមិនបានគ្រោងទុក | ២០០,០០០,០០០៛ | ២០០,០០០,០០០៛ | ១០០% |
| ២០ | អចលកម្មអរូបី | | | |
| ២១ | អចលកម្មរូបី | | | |
| | សរុបចំណាយ | ៤,៤៥៤,៥៨០,០០០៛ | ៣,៩៤៣,៦០៧,៣៩០៛ | ៨៩% |

### ១.៥.២.ការគ្រប់គ្រងទ្រព្យសម្បត្តិ

**តារាងទី១៦៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ទ្រព្យសម្បត្តិ ដែលបានទិញ ឬទទួល (ថ្មី) | ០០ | ០០ | ០០ |
| ២ | ទ្រព្យសម្បត្តិ ដែលបានកាត់ចេញ | ០០ | ០០ | ០០ |

### ១.៦. **ការងារលទ្ធកម្ម៖**

- ការងារជួសជុលផ្លូវ ដោយចាក់អ៊ុតកៅស៊ូបេទីមណឺ ផ្លូវលេខ៣៣៤ ចាប់ពីផ្លូវលេខ៦៣ ដល់ផ្លូវលេខ៥១ កម្រាស់ ៥សង់ទីម៉ែត្រ បណ្ដោយ២៤០ម៉ែត្រ ទទឹង៦ម៉ែត្រ សរុបផ្ទៃក្រឡា ១,៤៤០ម៉ែត្រការ៉េ ក្នុងសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង ជូនរដ្ឋបាលខណ្ឌបឹងកេងកង ឆ្នាំ២០២១ អនុវត្តបាន១០០%។
- ការងារផ្គត់ផ្គង់ស្បៀង, សម្ភារសម្អាត និងអនាម័យ, សម្ភារការិយាល័យ, សង្ហារឹម, និង សម្ភារ បរិក្ខាបច្ចេកទេសព័ត៌មានវិទ្យា អនុវត្តបានរួចរាល់។
- ការងារផ្គត់ផ្គង់សម្ភារ និង គេសជ្ជៈសម្រាប់ទទួលភ្ញៀវជាតិ, ប្រជុំ សិក្ខា សាលា និង សម្ភាររៀបចំពិធីបុណ្យ, សម្ភារ និង គេសជ្ជៈ សម្រាប់ឧបត្ថម្ភសហគមន៍កីឡា និង វប្បធម៌, សម្ភារ និងគ្រឿងឧបភោគបរិភោគសម្រាប់ជំនួយកាកបាទក្រហម និង គណៈបញ្ជាការឯកភាពខណ្ឌ អនុវត្តបានរួចរាល់។
- ការងារផ្គត់ផ្គង់ប្រេងឥន្ធនៈ ជូនរដ្ឋបាលខណ្ឌបឹងកេងកងឆ្នាំ២០២១ អនុវត្តបានរួចរាល់។

## ផ្នែកទី២
## ការងាររដ្ឋបាលសង្កាត់

### ២.១. **ការងាររដ្ឋបាលសង្កាត់**
### ២.១.១.**ស្ថិតិក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិក**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាសង្កាត់ | ៦៣ | ២៣ |
| ២ | សមាជិកក្រុមប្រឹក្សាសង្កាត់ដែលបានផ្លាស់ប្ដូរ | ០០ | ០០ |
| ៣ | ចៅសង្កាត់ | ០៧ | ០១ |
| ៤ | ចៅសង្កាត់រងទី១ | ០៧ | ០២ |
| ៥ | ចៅសង្កាត់រងទី២ | ០៦ | ០២ |
| ៦ | ស្មៀនសង្កាត់ | ០៧ | ០១ |
| ៧ | បុគ្គលិកកិច្ចសន្យា | ១៦ | ០៤ |
| ៨ | មេភូមិ | ៥៤ | ១៣ |
| ៩ | អនុប្រធានភូមិ | ៥៤ | ១៧ |
| ១០ | សមាជិកភូមិ | ៥៤ | ២៩ |
| ១១ | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលមិនមែនជាសមាជិកក្រុមប្រឹក្សាសង្កាត់ | ០០ | ០០ |
| ១២ | ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃសង្កាត់ | ២០ | ០៦ |
| សរុប | | ២៨៨ | ៩៨ |

## ២.១.២.ដីកា សេចក្តីសម្រេច និងលិខិត

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ដីកាដែលបានដាក់ចេញ | ០២ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ៥៥ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ៤៦៨៨ |
| ៤ | លិខិតដែលបានទទួល | ២០០០ |

## ២.១.៣.កិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ និង គ.ក.ន.ក

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំសាមញ្ញារបស់ក្រុមប្រឹក្សា | ៨០ |
| ២ | កិច្ចប្រជុំវិសាមញ្ញារបស់ក្រុមប្រឹក្សា | ០៧ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០០ |
| ៤ | កិច្ចប្រជុំគ.ក.ន.ក | ៧៨ |

## ២.១.៤.គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាសង្កាត់(រៀល)

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង(៛) |
|---|---|---|---|
| ១ | សេដ្ឋកិច្ច | ០៩ | ៨៣៩,៩១៩,០៥៣ |
| ២ | សង្គមកិច្ច | ០០ | ០០ |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | ០១ | ៤០,០០០,០០០ |
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | ០០ | ០០ |
| ៥ | យេនឌ័រ | ០១ | ៩,៣០០,០០០ |
| សរុប | | ១៨ | ៨៨៩,២១៩,០៥៣ |

## ២.១.៥.ការអនុវត្តគម្រោងសង្កាត់

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ០៩ | ០៤ | ០១ | ០៤ |
| ២ | សង្គមកិច្ច | ១០៥ | ១៩ | ០ | ៨៦ |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | ២២ | ០៦ | ០០ | ១៦ |
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | ១១២ | ០០ | ០០ | ១១២ |
| ៥ | យេនឌ័រ | ០៤ | ០០ | ០០ | ០៤ |
| សរុប | | ២៥២ | ២៩ | ០១ | ២២២ |

## ២.១.៦.ការអនុវត្តថវិកាសង្កាត់(រៀល)

| ល.រ | ការបរិយាយ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ១ | ចំណូលសរុប | ២,៤២៤,១៩៤,៤៤៨ | ១,៦២៥,១១២,៩៥៣ | ៦៧% |
| ២ | ចំណាយសរុប | ២,៣៣១,១០៤,៤៥៣ | ១,៥១៤,៨៧៨,៩៨៩ | ៦៥% |

### ២.១.៧.ការគ្រប់គ្រងទ្រព្យសម្បត្តិសង្កាត់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិសង្កាត់ដែលបានទិញ ឬទទួល(ថ្មី) | ០១ |
| ២ | ទ្រព្យសម្បត្តិសង្កាត់ដែលបានកាត់ចេញ | ០០ |
| ៣ | ទ្រព្យសម្បត្តិសង្កាត់សរុប | ៤៣ |

### ២.១.៨.ការអភិវឌ្ឍន៍សមត្ថភាព

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ២២ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៧២ |
| ៣ | សិក្ខាកាមជាស្ត្រីដែលចូលរួមវគ្គសិក្សា | ៣៧ |

### ២.១.៩.សកម្មភាពសេវាសង្គម

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីសង្កាត់ | ០០ |
| ២ | គ្រួសារងាយរងគ្រោះគាំទ្រពីសង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃ និងសាប៊ូ) | ០០ |
| ៣ | គ្រួសារងាយរងគ្រោះគាំទ្រពីសង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | ០០ |
| ៤ | គ្រួសារងាយរងគ្រោះគាំទ្រពីសង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | ០០ |
| ៥ | គ្រួសារងាយរងគ្រោះដែលសង្កាត់ចុះកំណត់អត្តសញ្ញាណ | ៨៣ |
| ៦ | ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីសង្កាត់ | ០០ |

### ២.១.១០.ការសម្រុះសម្រួលទំនាស់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយសង្កាត់ | ៦៥ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ០២ |

### ២.១.១១.ការងារអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សំបុត្រកំណើត | ៦៩៦ |
| ២ | សំបុត្របញ្ជាក់កំណើត | ៤០១ |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | ១៩៨៤ |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១១៣១ |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ៣១៩ |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៨៩៣ |
| ៧ | សំបុត្រមរណភាព | ៣២៣ |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | ៩៥៤ |

### ២.១.១២.ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០២១

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | ១៩២០ |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | ១៥៧៨ |
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) | ៤៣២១៥ |

### ២.២.បញ្ហាប្រឈមដែលរដ្ឋបាលសង្កាត់បានជួបប្រទះ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១ | -ជម្ងឺកូវីដ១៩ បានធ្វើឱ្យប៉ះពាល់ដល់បញ្ហាជីវភាព និងសុខភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ | -បានចុះផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ ឱ្យយកចិត្តទុកដាក់អំពីបញ្ហាសុខភាព ដោយណែនាំឱ្យគាត់ពាក់ម៉ាស និងលាងសម្អាតដៃដោយសាប៊ូ ឬដែលឱ្យបានញឹកញាប់ និងពាំនាំអំណោយទៅចែកជូន ដល់គ្រួសារជួបការលំបាក ក្នុងកំឡុងពេលជម្ងឺកូវីដ១៩។ |
| ២ | -បញ្ហាកកស្ទះចរាចរណ៍នៅចំណុចផ្លូវលេខ១៩៩ កែងផ្លូវលេខ៤៣០ និងនៅចំណុចផ្លូវលេខ២៧១ កែងផ្លូវលេខ១៩៩។ | -ស្នើសុំសាលារាជធានីភ្នំពេញ តម្លើងភ្លើងស្តុប នៅចំណុចផ្លូវទាំង២ ដើម្បីសម្រួលការកកស្ទះចរាចរណ៍។ |

## ផ្នែកទី៣
## ការងាររបស់ការិយាល័យ អង្គភាពជំនាញ

### ២.១. សេដ្ឋកិច្ច

### ២.១.១. ការងារផែនការ ស្ថិតិ

- ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ រដ្ឋបាលបាលខណ្ឌបឹងកេងកង បានចុះអនុវត្តការដាក់លូ ០២ ក្នុងសង្កាត់ទំនប់ទឹក និងសង្កាត់បឹងកេងកងទី២ ក្រោមអធិបតីភាព លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ ដោយមានការចូលរួមពីប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ ប្រធានការិយាល័យលទ្ធកម្ម ប្រធានការិយាល័យសាធារណៈការ និងដឹកជញ្ជូនខណ្ឌបឹងកេងកង ចៅសង្កាត់ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៧ របស់ គ.ក.ស.ក ខណ្ឌបឹងកេងកង ក្រោមអធិបតីភាពលោកស្រី ម៉ែន សុភារី ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង និងលោកស្រី ប៉ា សុខា សមាជិកក្រុមប្រឹក្សាខណ្ឌ និងជាអនុប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង។
- ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី២០ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព លោក គឹម ឈុនអ៊ូ ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង ។
- ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ការិយាល័យផែនការ និងហិរញ្ញវត្ថុខណ្ឌ បានបើកកិច្ចប្រជុំ «ណែនាំពីការប្រមូលតម្រូវការអាទិភាព» ក្រោមអធិបតីភាព លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ តំណាងលោកអភិបាលខណ្ឌ។
- ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៨ របស់ គ.ក.ស.ក ខណ្ឌបឹងកេងកង ក្រោមអធិបតីភាពលោកស្រី ម៉ែន សុភារី ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង និងលោកស្រី ប៉ា សុខា សមាជិកក្រុមប្រឹក្សាខណ្ឌ និងជាអនុប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង។
- ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ បានចូលរួមរៀនវគ្គបណ្តុះបណ្តាលស្តីពី "ការប្រើប្រាស់ប្រព័ន្ធទប់ស្កាត់កូវីដ-១៩ (STOP COVID-19)" ជាមួយនឹងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដោយមានការចូលរួមពីលោកប្រធាន

ការិយាល័យផែនការ និងហិរញ្ញវត្ថុ ប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ និងមន្ត្រីដែលពាក់ព័ន្ធ រួមទាំងអាជីវករ ដែលជាម្ចាស់ហាង និងភោជនីយដ្ឋាននានា ស្ថិតក្នុងសង្កាត់ទាំង០៧ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។

- ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី២១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព លោក គឹម ឈុនអ៊ូ ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង។
- ថ្ងៃទី១៣-១៥ ខែឧសភា ឆ្នាំ២០២១ ការិយាល័យផែនការ និងហិរញ្ញវត្ថុខណ្ឌ បានចូលរួមវគ្គបណ្តុះបណ្តាតាម ZOOM ស្តីពី «ការកំណត់អត្តសញ្ញាណគ្រួសារក្រុមគោលដៅក្នុងតំបន់បិទខ្ទប់» ក្រោមអធិបតីភាព ឯកឧត្តម កែវ អ៊ូលី ទីប្រឹក្សាប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ។
- ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ បានចូលរួមវគ្គបណ្តុះបណ្តាលសង្កាត់ទាំង៧តាម ZOOM ស្តីពី «ការកំណត់អត្តសញ្ញាណគ្រួសារក្រុមគោលដៅក្នុងតំបន់បិទខ្ទប់» ក្រោមអធិបតីភាព លោក សាន សុផាត ប្រធានការិយាល័យផែនការ នៃមន្ទីរផែនការរាជធានី។
- ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ បានចុះត្រួតពិនិត្យផ្លូវ ០១ខ្សែ ផ្លូវលេខ៣៣៤(៦៣-៥១) ស្ថិតក្នុងភូមិ៨ សង្កាត់បឹងកេងកងទី១ ក្រោមការដឹកនាំរបស់ លោក សែន វ៉ាន់ណាក់ នាយករងរដ្ឋបាលខណ្ឌ ដែលមានការចូលរួមពីក្រុមហ៊ុន SIX STAR និងមន្ត្រីដែលពាក់ពន្ធ័។
- បានចូលរួមវគ្គបំប៉នលើកទី១ និង លើកទី២ នៅទីស្តីការក្រសួងសង្គមកិច្ចស្តីពី «និតិវិធី និងយន្តការ នៃការបើកផ្តល់សម្រាប់កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ក្រោយពេលបិទខ្ទប់សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានលំបាកផ្នែកជីវភាព ប្រជាពលរដ្ឋ និងគ្រួសារដែលមានអ្នកឆ្លងជម្ងឺកូវីដ-១៩ និងគ្រួសារដែកមានអ្នកស្លាប់ដោយសារជម្ងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍២០ កុម្ភៈ ឆ្នាំ២០២១» ក្រោមអធិបតីភាព ឯកឧត្តម កែវ អ៊ូលី ទីប្រឹក្សាប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ។
- ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកវគ្គបំប៉នស្តីពី «និតិវិធី និងយន្តការ នៃការបើកផ្តល់សម្រាប់កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ក្រោយពេលបិទខ្ទប់សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានលំបាកផ្នែកជីវភាព ប្រជាពលរដ្ឋ និងគ្រួសារដែលមានអ្នកឆ្លងជម្ងឺកូវីដ-១៩ និងគ្រួសារដែកមានអ្នកស្លាប់ដោយសារជម្ងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍២០ កុម្ភៈ ឆ្នាំ២០២១» ក្រោមអធិបតីភាពលោក សាន សុផាត ប្រធានការិយាល័យផែនការ នៃមន្ទីរផែនការរាជធានី។
- ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ រដ្ឋបាលខណ្ឌបឹងកេងកង បានបើកសិក្ខាសាលាស្តីពី «ពន្ធលើចំនេញមូលធន» តាមរយៈប្រព័ន្ធ ZOOM ក្រោមអធិបតីភាព លោក គឹម ឈុនអ៊ូ ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង ដែលមានការអញ្ជើញចូលរួមពី មន្ត្រីការិយាល័យផែនការ និងហរិញ្ញវត្ថុ លោក-លោកស្រីចៅសង្កាត់ទាំង៧ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយការឆ្លើយតបគម្រោងស្តីពី «ការឆ្លើយតបចម្រុះលើការបង្ការ និងការគាំពារចំពោះ កូវីដ១៩ សម្រាប់សហគមន៍ងាយរងគ្រោះក្នុងរាជធានីភ្នំពេញ» ក្រោមអធិបតីភាព លើកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង ដែលមានការអញ្ជើញចូលរួមពីអង្គការ People in need ប្រធានការិយាល័យសង្គមកិច្ច និងលោក-លោកស្រី ចៅសង្កាត់ទាំង៧ របស់ខណ្ឌបឹងកេងកង។
- ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ បានចូលរួមវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយបន្ត ស្តីពី « កម្មវិធីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ» តាមរយៈប្រព័ន្ធ ZOOM ក្រោមអធិបតីភាព ឯកឧត្តម នួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ ។
- ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ បានរៀបចំកិច្ចប្រជុំស្តីពី «វគ្គបណ្តុះបណ្តាលបន្តស្តីពីកម្មវិធីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ» ក្រោមអធិបតីភាព លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌ។

- ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំស្តីពី «ពិធីដេញថ្លៃការផ្គត់ផ្គង់សម្ភារៈសម្អាត និងអនាម័យ សម្ភារៈការិយាល័យ ស្បៀង គ្រឿងសង្ហារឹម និងសម្ភារៈបច្ចេកទេសពត៌មានវិទ្យាជូនរដ្ឋបាលខណ្ឌបឹងកេងកង» ក្រោមអធិបតីភាពលោកស្រី ស៊ិន រតនា អភិបាលរង តំណាងលោកអភិបាលខណ្ឌ។
- ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ បានចូលរួមវគ្គបណ្តុះបណ្តាល «សេចក្តីណែនាំពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងអនុម័តថវិការបស់រដ្ឋបាល ឃុំ សង្កាត់» តាមរយៈប្រព័ន្ធ ZOOM ក្រោមអធិបតីភាព ឯកឧត្តម នួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ ដោយមានការចូលរួមពី លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ លោក សែន វ៉ាន់ណាក់ នាយករងរដ្ឋបាលខណ្ឌ លោក លោកស្រីចៅសង្កាត់ទាំង៧ និងមន្ត្រីដែលពាក់ព័ន្ធ។
- ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំសាមញ្ញ លើកទី២៨ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ក្រោមអធិបតីភាព លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌបឹងកេងកង។
- បានចូលរួមកម្មវិធីកាកបាទក្រហម ក្រោមអធិបតីភាព លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង ។
- ថ្ងៃទី១៣-១៤ ខែតុលា ឆ្នាំ២០២១ បានចូលរួមវគ្គបណ្តុះបណ្តាលបន្តស្តីពី «ការអនុវត្តការងារសេវាសង្គម រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់» តាមរយៈប្រព័ន្ធ ZOOM ក្រោមអធិបតីភាព ឯកឧត្តម នួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ។
- ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ បានរៀបចំកិច្ចប្រជុំ «ពិធីដេញថ្លៃ គម្រោងមូលនិធិអភិវឌ្ឍន៍សង្កាត់ទាំង៧ ឆ្នាំ២០២១ ក្នុងខណ្ឌបឹងកេងកង» ក្រោមអធិបតីភាព ឯកឧត្តម ស៊ុយ សេរិទ្ធ អភិបាលរងរាជធានីភ្នំពេញ។
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី «សមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ របស់សង្កាត់ខណ្ឌ» ក្រោមអធិបតីភាព លោកជំទាវ កែវ សុខពិសី អភិបាលរងរាជធានីភ្នំពេញ។
- ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ បានចូលរួមវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីកិច្ចការរដ្ឋបាលដែលរៀបចំឡើងដោយរដ្ឋបាលរាជធានីភ្នំពេញ។
- ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំ ការចរចារថ្លៃការងារអ៊ុតបេទីម ផ្លូវលេខ៣៣៤ ចាប់ពីផ្លូវលេខ៦៣ ដល់ផ្លូវលេខ៥១ កម្រាស់ ៥សង់ទីម៉ែត្រ បណ្តោយ ២៤០ម៉ែត្រ ទទឹង៦ម៉ែត្រ សរុបផ្ទៃក្រឡា ១,៤៤០ម៉ែត្រការ៉េ ក្នុងសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង ឆ្នាំ២០២១ ក្រោមអធិបតីភាព លោក លន់ សោ អនុប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានីភ្នំពេញ និងលោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង។
- ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ បានចូលរួម វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីការប្រមូលទិន្នន័យភូមិ-សង្កាត់-ខណ្ឌ ឆ្នាំ២០២១ ក្រោមអធិបតីភាពលោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង។
- ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ មន្ត្រីការិយាល័យផែនការ និងហិរញ្ញវត្ថុខណ្ឌ បានចូលរួមកិច្ចប្រជុំស្តីពី«ការពង្រឹងការងាររដ្ឋបាលខណ្ឌ និងជួបសំណេះ សំណាលជាមួយមន្ត្រីកម្មសិក្សា» ក្រោមអធិបតីភាពលោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។

### ២.១.២ <u>ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍</u>

- នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ បានចុះណែនាំ និងជម្រុញឱ្យម្ចាស់អាជីវកម្មហាងគុយទាវ រីករាយ ដែលស្ថិតនៅផ្ទះលេខ A-៩៣ ផ្លូវ២៧១ សង្កាត់ទំនប់ទឹក ឱ្យម្ចាស់មកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម នៅការិយាល័យប្រកចេញចូលតែមួយ ខណ្ឌបឹងកេងកង។
- នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ បានចុះណែនាំ និងពិនិត្យទីតាំងអាជីវកម្មផ្សារ ឡេង ណាវ៉ាត្រា ដែលស្ថិតនៅផ្ទះលេខ១៩២E0E1.១៩០E0E1 ផ្លូវម៉ៅសេទុង សង្កាត់ទំនប់ទឹកពីព្រោះការសុំបើកផ្សាររបស់ម្ចាស់អាជីវកម្មមានអាសយដ្ឋានខុសពីកិច្ចសន្យាជួល។

- បានចូលរួមចុះធ្វើរដ្ឋបាលតាមផ្ទះសំណាក់ ជាមួយកម្លាំងចម្រុះរបស់រដ្ឋបាលខណ្ឌបឹងកេងកង ដឹកនាំដោយលោក គឹម ណែរីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង។
- នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ បានសហការណ៍ជាមួយមន្ត្រីសង្កាត់បានចុះណែនាំ និងជម្រុញឱ្យមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្មនៅការិយាល័យ ច្រកចេញចូលតែមួយ នៃរដ្ឋបាលខណ្ឌបឹងកេងកង ជាលទ្ធផលបានចំនួន១៧ទីតាំងក្នុងសង្កាត់បឹងកេងកងទី៣។
- នៅយប់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ បានចុះត្រួតពិនិត្យវិធានសុវត្ថិភាពទេសចរណ៍ក្នុងខណ្ឌបឹងកេងកង ក្រុមការងារចម្រុះមានក្រសួង មន្ទីរ ខណ្ឌ សង្កាត់ និងប៉ូលីសប៉ុស្តិ៍ដឹកនាំដោយ ឯកឧត្តម ម៉ម វាសនា ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ នាយកដ្ឋានបណ្តុះបណ្តាលទេសចរណ៍ ជាលទ្ធផលបានចំនួន ១៤ ទីតាំង ក្នុងសង្កាត់ទាំង៧។
- នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ បានចូលរួមសិក្ខាសាលាជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីបើកវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធQR Code("STOP COVID") ដល់ម្ចាស់ភោជនីដ្ឋាន និងអាហារដ្ឋានក្នុងមូលដ្ឋានខណ្ឌដើម្បីចូលរួមការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ក្នុងរាជធានីភ្នំពេញ។
- នៅល្ងាចថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១ បានចូលរួមជាមួយគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង បានចុះផ្អាកទីតាំងអាជីវកម្មម៉ាស្សា ដឹកនាំដោយ លោកស្រី ស៊ិន រតនា អភិបាលរង នៃគណៈអភិបាលខណ្ឌបឹងកេងកង ជាលទ្ធផលបានចំនួន ០២ទីតាំង ក្នុងសង្កាត់បឹងកេងកងទី១។
- កំពុងរៀបចំធ្វើសេចក្តីសម្រេចដើម្បីបង្កើតក្រុមការងារជម្រុញ និងតាមដានការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ" សម្រាប់ឆ្នាំ (២០២១-២០២៤)
- បានរៀបចំសំណើសុំបញ្ជូនឈ្មោះតំណាងបេក្ខភាពខណ្ឌបឹងកេងកង ដើម្បីបង្កើតគណនីប្រើប្រាស់ (User Account) សម្រាប់ដាក់ពាក្យស្នើសុំចូលរួមប្រឡងប្រណាំងតាមប្រព័ន្ធអនឡាញ ក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត លើកទី៣។
- ក្នុងព្រឹត្តិការណ៍២០កុម្ភៈ ការិយាល័យ សេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ បានចុះណែនាំ ផ្សព្វផ្សាយដល់បងប្អូនដែលជាម្ចាស់អាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ភោជនីយដ្ឋាន អាហារដ្ឋាន ខ្លឹបកម្សាន្ត ម៉ាស្សាស្ប៉ា ខារ៉ាអូខេ បៀរហ្គាឌេន ដើម្បីឱ្យគាត់ចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងផ្អាកអាជីវកម្មជាបណ្តោះអាសន្នតាមការណែនាំរបស់ក្រសួងសុខាភិបាល ។
- បានចូលរួមជាមួយ គណៈបញ្ជាការឯកភាពខណ្ឌ និងក្រុមគ្រូពេទ្យ ដើម្បីយកសំណាកក្នុងតំបន់វិជ្ជមាននៃមូលដ្ឋានខណ្ឌបឹងកេងកងគ្រប់ទីតាំង និងចុះត្រួតពិនិត្យទីតាំងវិជ្ជមាន ក្រុមការងារបានរៀបចំចងខ្សែនិងណែនាំពួកគាត់មិនឱ្យចេញពីបរិវេណដែលបានហ៊ុមព័ន្ធជៀសវាងការចម្លងជំងឺទៅអ្នកដ៏ទៃគ្រប់ទីតាំង ។
- ចូលរួមជាមួយគណៈបញ្ជាការឯកភាពខណ្ឌ ដើម្បីចុះអនុវត្ត បម្រាមគោចរ ក្នុងសង្កាត់ទាំង០៧ នៃមូលដ្ឋានខណ្ឌបឹងកេកងជាប្រចាំ ។
- បានចូលរួមចែកអំណោយស្បៀងអាហារជូនដល់ប្រជាពលរដ្ឋក្នុងអំឡុងពេលបិទខ្ទប់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលពុំអាចចេញក្រៅបាន ។
- បានចុះជួយសម្របសម្រួលជូនប្រជាពលរដ្ឋ ដែលអញ្ជើញមកទទួលការចាក់វ៉ាក់សាំងប្រឆាំងនិងជំងឺកូវីដ-១៩ ជាប្រចាំ។

- នៅរសៀលថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំ ស្តីពីសំណើរបស់ផ្សារបឹងកេងកង និងផ្សារអូឡាំពិកសុំបើកដំណើរការលក់ដូរឡើងវិញ នូវមុខទំនិញចាំបាច់មួយចំនួន ជាបណ្តោះអាសន្នមករដ្ឋបាលខណ្ឌ ដែលដឹកនាំដោយ លោក គឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេង។
- នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ បានសហការណ៍ជាមួយរដ្ឋបាលសង្កាត់បឹងកេងកងទី១ និងប៉ូលីសប៉ុស្តិ៍ ដែលដឹកនាំដោយ លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង បានចុះផ្អាកជាបណ្តោះអាសន្ន KAI FUN ដែលមានបុគ្គលិកហាង ១នាក់ មានវិជ្ជមានកូវីដ-១៩ មានអាសយដ្ឋានផ្ទះលេខ២៥ ផ្លូវលេខ ៣៣៤ ភូមិ ៨ សង្កាត់បឹងកេងកងទី១។
- នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ បានសហការណ៍ជាមួយមន្ទីរពាណិជ្ជកម្មរាជធានី គណៈកម្មការផ្សារបឹងកេងកង និងផ្សារអូឡាំពិក បានចុះណែនាំនិងផ្សព្វផ្សាយស្តីពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដល់អាជីវករក្នុងផ្សារឱ្យក្បោគម្លាត ពាក់ម៉ាស់ បាញ់ថ្នាំសម្លាប់មេរោគ និងគោរពតាមគោលការណែនាំរបស់ក្រសួងសុខាភិបាលជាប្រចាំ។
- នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ បានចុះណែនាំ និងពិនិត្យទីតាំងអាជីវកម្ម លក់ម៉ូតូគ្រប់ប្រភេទ ដែលស្ថិតនៅតាមបណ្តោយផ្លូវ នរោត្តម ក្នុងសង្កាត់អូឡាំពិក និងសង្កាត់បឹងកេងកងទី២ ឱ្យមានសណ្តាប់ធ្នាប់ និងសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម បានចំនួន៦៥ទីតាំង ។
- នៅថ្ងៃទី០៧ ខែកក្កដា ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ បានចុះជម្រុញ និងណែនាំអាជីវកម្ម សេវាកម្ម ដែលស្ថិតនៅតាមបណ្តោយផ្លូវ ១៦៣ ក្នុងសង្កាត់អូឡាំពិក សង្កាត់បឹងកេងកងទី៣ និងសង្កាត់ទួលស្វាយព្រៃទី១ ឱ្យម្ចាស់អាជីវកម្មមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម នៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលខណ្ឌបឹងកេងកង បានចំនួន២៦៨ទីតាំង។
- នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ បានចូលរួមជាមួយគណៈបញ្ជាការឯកភាពខណ្ឌបានចុះផ្អាកអាជីវកម្មម៉ាស្សា(វេហា) មួយកន្លែងជាបណ្តោះអាសន្នដែលមានអាសយដ្ឋានផ្ទះលេខ៧៨ ផ្លូវ៣៦០ សង្កាត់ទួលស្វាយព្រៃទី១។
- ចាប់ថ្ងៃទី២៩ ខែកក្កដា ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ បានចូលរួមធ្វើបំរាមគោចរជាប្រចាំ ជាមួយគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង ដើម្បីប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជម្ងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ "សហគមន៍ ២០ កុម្ភៈ"ជាប្រចាំ។
- នៅថ្ងៃទី០១ ខែសីហា ដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ បានចុះជម្រុញ និងណែនាំអាជីវកម្ម សេវាកម្ម ដែលស្ថិតនៅក្នុងសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង ឱ្យម្ចាស់អាជីវកម្មមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម នៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលខណ្ឌបឹងកេងកង បានចំនួន៨៧ទីតាំង។
- នៅថ្ងៃទី១៨ រហូតដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ បានចូលរួមជាមួយក្រុមគ្រូពេទ្យនៅមណ្ឌលសុខភាពទួលស្វាយព្រៃ ដើម្បីសម្របសម្រួលជូនមន្ត្រីជួរមុខដែលបានអញ្ជើញមកទទួលការចាក់វ៉ាក់សាំង ប្រឆាំងជំងឺកូវីដ-១៩ ដូសទី៣ ដែលជាដូសជម្រុញ នៅមណ្ឌលសុខភាព ទួលស្វាយព្រៃជាប្រចាំ។
- នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ បានសហការណ៍ជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដើម្បីចុះត្រួតពិនិត្យទីតាំងលក់សំលៀកបំពាក់បុរស ដែលមានអាសយដ្ឋានផ្ទះលេខ ៦២A,B ផ្លូវលេខ ៣៨៦ សង្កាត់បឹងកេងកងទី៣។

- នៅព្រឹកថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ យោងតាមលិខិតលេខ៣២ ស.ប.ក របស់មន្ទីរទេសចរណ៍ រាជធានីភ្នំពេញ បានសហការណ៍ជាមួយ មន្ទីរទេសចរណ៍ រាជធានីភ្នំពេញ និងសង្កាត់បឹងកេងកងទី១ បានចុះណែនាំ និងផ្សព្វផ្សាយដើម្បីជំរុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងវិធាននានានៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ក្នុងដំណាក់កាលកូវីដ-១៩ បានចំនួន ០៤ទីតាំង។
- នៅថ្ងៃទី០៦ ដល់ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ បានចូលរួមដើម្បីសម្របសម្រួលជូនដល់លោកគ្រូ អ្នកគ្រូ ដែលអញ្ជើញមកទទួលការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ ដូសទី៣ ដែលជាដូសជំរុញ នៅមណ្ឌលសុខភាពទួលស្វាយព្រៃជាប្រចាំ ។
- នៅថ្ងៃទី០៩ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ បានសហការណ៍ជាមួយរដ្ឋបាលសង្កាត់ ដើម្បីសម្របសម្រួលជូនដល់មនុស្សចាស់ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង ដែលអញ្ជើញមកទទួលការចាក់វ៉ាក់សាំង (AstraZeneca) ប្រឆាំងជំងឺកូវីដ-១៩ ដូសទី៣ ដែលជាដូសជំរុញនៅមណ្ឌលសុខភាពទួលស្វាយព្រៃជាប្រចាំ ។
- នៅថ្ងៃទី២៨-២៩ ខែកញ្ញា ឆ្នាំ២០២១ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ បែបបទ និងនិតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ( តាម ZOOM) ក្រោមអធិបតីភាពលោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង។
- នៅព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ បានសហការណ៍ជាមួយ មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ ដើម្បីចុះអប់រំ និងណែនាំស្តីពីការត្រួតពិនិត្យកាតចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ នៅតាមផ្សារទំនើប នៅក្នុងសង្កាត់បឹងកេងកងទី១ បានចំនួន ០៥ទីតាំង។
- នៅរសៀលថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ បានសហការណ៍ជាមួយ មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ សង្កាត់ និងប៉ុស្តិ៍នគបាលដើម្បីណែនាំ និងផ្សព្វផ្សាជំរុញពីការអនុវត្តច្បាប់ទេសចរណ៍ វិធានសុវត្ថិភាពទេសចរណ៍ និងការប្រើប្រាស់កាត់ចាក់វ៉ាក់សាំង ស្ថិតនៅក្នុងសង្កាត់បឹងកេងកងទី១ បានចំនួន ០៤ទីតាំង។
- យប់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ បានសហការណ៍ជាមួយកងរាជអាវុធហត្ថ អធិការនគរបាល ចុះពិនិត្យអាវុធជាតិផ្ទុះម៉ោសេទុងទល់មុខវិទ្យាស្ថានវ៉ាន់ដា។
- នៅរសៀលថ្ងៃទី២៧-២៨ ខែតុលា ឆ្នាំ២០២១ បានសហការណ៍ជាមួយរដ្ឋបាលសង្កាត់បឹងកេងកងទី៣ ចុះជំរុញ និងណែនាំឱ្យបុគ្គលិកតាមភោជនីដ្ឋាន អាហារដ្ឋាន ម៉ាស្សា ខារ៉ាអូខេ ផ្សារទំនើបឱ្យមកចាក់វ៉ាក់សាំងដូសទី៣ ជាដូសជំរុញឱ្យបានគ្រប់គ្នា ជាលទ្ធផលបានចំនួន ០៩ទីតាំង។
- នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ បានសហការណ៍ជាមួយមន្ទីរទេសចរណ៍រាជធានីភ្នំពេញ ដែលដឹកនាំដោយឯកឧត្តម ម៉ម វាសនា បានចុះត្រួតពិនិត្យភោជនីដ្ឋាន ដាយមិនវីជៀន ដែលមានអាសយដ្ឋានផ្លូវព្រះនរោត្តមសង្កាត់បឹងកេងកងទី២ ក្រុមការងារបានណែនាំឱ្យម្ចាស់អាជីវកម្មគោរពតាមវិធានការសុខាភិបាលក្នុងការបើកដំណើការអាជីវកម្មរបស់ខ្លួនឡើងវិញ។
- នៅរសៀលថ្ងៃទី០៣-០៥ ខែវិច្ឆិកា ឆ្នាំ២០២១ បានសហការណ៍ជាមួយរដ្ឋបាលសង្កាត់ទំនប់ទឹក និងសង្កាត់ទួលស្វាយព្រៃទី១ បានចុះជំរុញ និងណែនាំមូលដ្ឋានអាជីវកម្មទេសចរណ៍អត់ច្បាប់ឱ្យមកធ្វើច្បាប់ បានចំនួន ១១ទីតាំង។
- នៅល្ងាចថ្ងៃទី០៣ ខែវិច្ឆកា ឆ្នាំ២០២១ បានចូលរួមជាមួយគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង ដឹកនាំដោយ លោកស្រី ស៊ិន រតនា អភិបាលរង បានចុះណែនាំឱ្យតំណាងភោជនីយដ្ឋាន សាគូរ៉ា ដែលស្ថិតនៅផ្លូវ

លេខ៩៣ សង្កាត់បឹងកេងកងទី៣ ក្រុមការងារបានឱ្យផ្អាកខារ៉ាអូខេ ជាបណ្ដោះអាសន្នចំពោះភោជនីយដ្ឋានឱ្យបើកជាធម្មតា និងណែនាំឱ្យគាត់គោរពគោលការតាមក្រសួងសុខាភិបាលដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩។

- នៅល្ងាចថ្ងៃទី០៣ ខែវិច្ឆកា ឆ្នាំ២០២១ បានចូលរួមប្រជុំ ដឹកនាំដោយ លោកស្រី ស៊ិន រតនា អភិបាលរង តាម (ZOOM) ជាមួយក្រសួងមហាផ្ទៃ ស្ដីពីនិតិវិធីនៃការផ្ដល់សេវាកម្មលើវិស័យរ៉ែនិងថាមពលជូនដល់អាជីវករ។
- នៅព្រឹកថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ បានសហការណ៍ជាមួយរដ្ឋបាលសង្កាត់បឹងកេងកងទី៣ ចុះចែកសេចក្ដីជូនដំណឹងស្ដីពីការញែកសំរាមវេចខ្ចប់ទុកដាក់សំរាម និងបញ្ចេញសំរាមតាមពេលម៉ោងបានកំណត់ ជាលទ្ធផលបានចំនួន០៩ភូមិ។
- នៅយប់ថ្ងៃទី០៩ ខែវិច្ឆកា ឆ្នាំ២០២១ បានចូលរួមជាមួយរដ្ឋបាលខណ្ឌបឹងកេងកង អញ្ជើញម្ចាស់អាជីវកម្មមកធ្វើកំណត់ហេតុស្ដីពីការផ្អាកការចាក់ភ្លេង ភោជនីដ្ឋានកាត់ចិត្ត ដឹកនាំដោយលោកស្រី ស៊ិន រតនា អភិបាលរង ម្ចាស់អាជីវកម្មបានយល់ព្រមផ្អាកការចាក់ភ្លេងលឺៗ និងគោរពតាមគោលការរបស់ក្រសួងសុខាភិបាលដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩។
- នៅព្រឹកថ្ងៃទី០៩ -១១ ខែវិច្ឆិកា ឆ្នាំ២០២១ បានចូលរួមអបអរសាទរខួបលើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ នៅវិមានឯករាជ្យ។
- នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ បានចូលរួមកម្មពិធីដេញថ្លៃគម្រោងមូលនិធិអភិវឌ្ឍន៍សង្កាត់ ខណ្ឌ ក្នុងឆ្នាំ ២០២១ ក្រោមអធិបតីភាព ឯកឧត្តម ស៊ុយ សេរិទ្ធ អភិបាលរងរាជធានីភ្នំពេញ។
- នៅព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ បានចូលរួមសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២៤)របស់សង្កាត់ ខណ្ឌ ក្រោមអធិបតីភាព លោកជំទាវ កែវ សុខពិសី អភិបាលរងអភិបាលរាជធានីភ្នំពេញ។
- នៅព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ បានចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីការប្រើប្រាស់បណ្ដាញសង្គមប្រកបដោយប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយ និងទទួលព័ត៌មាននៅសាលាក្រុងភ្នំពេញ។
- បានចូលរួមគ្រប់កិច្ចប្រជុំជាមួយគណៈអភិបាលជាប្រចាំ។
- បានចូលរួមចែកអំណោយស្បៀងអាហារជូនដល់ប្រជាពលរដ្ឋ ដែលមានការខ្វះខាតក្នុងសង្កាត់ទាំង៧។

➢ **<u>ការងារពាណិជ្ជកម្ម</u>**

- បានចុះជំរុញ និងណែនាំដល់ម្ចាស់អាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ឱ្យមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម របស់ខ្លួននៅការិយាល័យច្រកចេញចូលតែមួយ ខណ្ឌបឹងកេងកង ក្នុងនោះមាន៖
    - ចុះជម្រុញ និងណែនាំក្នុងសង្កាត់បឹងកេងកងទី១ បានចំនួន ១៥៧ ទីតាំង
    - ចុះជម្រុញ និងណែនាំក្នុងសង្កាត់បឹងកេងកងទី២ បានចំនួន ១១៩ ទីតាំង
    - ចុះជម្រុញ និងណែនាំក្នុងសង្កាត់បឹងកេងកងទី៣ បានចំនួន ១៤៤ ទីតាំង
    - ចុះជម្រុញ និងណែនាំក្នុងសង្កាត់ទួលស្វាយព្រៃទី១ បានចំនួន ១៣១ ទីតាំង
    - ចុះជម្រុញ និងណែនាំក្នុងសង្កាត់ទួលស្វាយព្រៃទី២ បានចំនួន ១៤២ ទីតាំង
    - ចុះជម្រុញ និងណែនាំក្នុងសង្កាត់អូឡាំពិក បានចំនួន ២៣២ ទីតាំង
    - ចុះជម្រុញ និងណែនាំក្នុងសង្កាត់ទំនប់ទឹក បានចំនួន ៩២ ទីតាំង
    - សរុប បានចំនួន ១០១៧ទីតាំង
    - ជាលទ្ធផលម្ចាស់អាជីវកម្មបានមកធ្វើលិខិតអនុញ្ញាតប្រកបអាជីវកម្មបាន ៦៥៣ទីតាំង ស្រី ៣៦៣នាក់

- **ការងារទេសចរណ៍**

– ចុះចែកលិខិតរបស់ក្រសួងទេសចរណ៍ រដ្ឋបាលរាជធានីភ្នំពេញ និងមន្ទីរទេសចរណ៍រាជធានីភ្នំពេញនៅក្នុងខណ្ឌ។

– ចូលរួមសហការជាមួយរដ្ឋបាលរាជធានីភ្នំពេញ និងមន្ទីរទេសចរណ៍រាជធានីភ្នំពេញ ចុះអប់រំផ្សព្វផ្សាយ ស្តីការទប់ស្កាត់ការ ការពារ ជំងឺកូវីដ១៩ ។

– ចុះជម្រុញ និងស្រង់ស្ថិតិមូលដ្ឋានអាជីវកម្មទេសចរណ៍ជាប្រចាំ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង ។

– បានចេញច្បាប់អនុញ្ញាតប្រកបអាជីវកម្មទេសចរណ៍បានចំនួន៖

  - សង្កាត់បឹងកេងកងទី១ បានចំនួន ថ្មី: ២៤ទីតាំង បន្ត: ១៥ទីតាំង
  - សង្កាត់បឹងកេងកងទី២ បានចំនួន ថ្មី: ០៥ទីតាំង បន្ត: ០៣ទីតាំង
  - សង្កាត់បឹងកេងកងទី៣ បានចំនួន ថ្មី: ០៧ទីតាំង បន្ត: ០៤ទីតាំង
  - សង្កាត់អូឡាំពិក បានចំនួន ថ្មី: ០១ទីតាំង បន្ត: ០០ទីតាំង
  - សង្កាត់ទួលស្វាយព្រៃទី១ បានចំនួន ថ្មី: ០៤ទីតាំង បន្ត: ០២ទីតាំង
  - សង្កាត់ទួលស្វាយព្រៃទី២ បានចំនួន ថ្មី: ០១ទីតាំង បន្ត: ០១ទីតាំង
  - សង្កាត់ទំនប់ទឹក បានចំនួន ថ្មី: ០៣ទីតាំង បន្ត: ០០ទីតាំង
  - សរុបការចេញអាជ្ញាបណ្ណក្នុងឆ្នាំ២០២១ បាន ៧០ទីតាំងក្នុងនោះ ថ្មី ៤៥ទីតាំង និងបន្ត ២៥ទីតាំង។

### ២.១.៣. ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ

- **ការងារសាធារណការ និងដឹកជញ្ជូន**

– ចុះពិនិត្យការជីកកប់បណ្តាញអគ្គិសនីនៅផ្លូវលេខ៣០២ ក្នុងសង្កាត់បឹងកេងកងទី១។

– ចុះពិនិត្យការកាត់ខ្សែភ្លើង និងខ្សែកាបនៅផ្លូវលេខ២៩៤ ក្នុងសង្កាត់បឹងកេងកងទី១ ជាមួយលោកស្រីចៅសង្កាត់។

– ចុះដោះស្រាយទំនាស់របស់ប្រជាជននៅជិតខាងគ្នា ទាក់ទងនឹងផ្លូវចេញចូលនៅ ផ្លូវមហាវិថីព្រះមុនីវង្សក្នុងសង្កាត់បឹងកេងកងទី២ ជាមួយក្រុមការងារដែលមានលោក ហេង ពិសិដ្ឋ ជាអ្នកដឹកនាំ។

– ចុះពិនិត្យការស្ទះអណ្តូងលូនៅផ្លូវលេខ៣៥៨ ជាមួយលោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌ។

– ចុះពិនិត្យការដ្ឋានសំណង់ដាក់ខ្សាច់ និងឥដ្ឋ លយចូលមកលើផ្លូវលេខ៣៦៨ ក្នុងសង្កាត់ទួលស្វាយព្រៃទី១។

– ចុះពិនិត្យការរំកិលប្តូរទីតាំងដើមឈើរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ នៅមហាវិថីម៉ៅសេទុងសង្កាត់ទំនប់ទឹក។

– ចុះត្រួតពិនិត្យការជីកចិញ្ចើមផ្លូវលេខ៤០២ របស់មន្ទីរសាធារណការក្នុងសង្កាត់ទំនប់ទឹក។

– ចុះពិនិត្យការជីកកប់ខ្សែបណ្តាញអគ្គិសនីនៅផ្លូវលេខ១៩៩ សង្កាត់ទួលស្វាយព្រៃទី២។

– ចុះពិនិត្យការជីកលូនៅផ្លូវលេខ៣៣៨ កែងផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២។

– ចូលរួមជួសជុលកំណាត់ផ្លូវលេខ១៩៩ កែងផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក។

– ចុះពិនិត្យការជីកកប់ខ្សែបណ្តាញអគ្គិសនីរបស់EDC ផ្លូវលេខ១៨៣ សង្កាត់ទំនប់ទឹក។

– ចូលរួមជួសជុលកំណាត់ផ្លូវលេខ៣៦៤ សង្កាត់ទួលស្វាយព្រៃទី២។

– ចុះពិនិត្យស្លាកសញ្ញាចរាចរណ៍ នៅផ្លូវលេខ៣១០ សង្កាត់បឹងកេងកងទី១។

– ចុះពិនិត្យការស្តារលូនៅផ្លូវលេខ៣៦០ កែងផ្លូវលេខ៧១ សង្កាត់បឹងកេងកងទី១។

– ចុះពិនិត្យការជីកដាក់លូថ្មីផ្លូវលេខ២៨២ សង្កាត់បឹងកេងកងទី១។

– ចូលរួមរៀបចំសណ្តាប់ធ្នាប់ និងធ្វើអនាម័យលាងសំអាតកំណាត់ផ្លូវលេខ៣៦៤ សង្កាត់ទួលស្វាយព្រៃទី២។

– ចូលរួមបើកការដ្ឋានដាក់លូទឹកមូលនៅផ្លូវលេខ៣១០ ក្នុងសង្កាត់បឹងកេងកងទី២ និងផ្លូវលេខ១៨៣ កែងផ្លូវលេខ៤៣០ ក្នុងសង្កាត់ទំនប់ទឹក ក្រោមអធិបតីភាព លោកស្រី អភិបាលរង ស៊ិន រតនា។

– ចូលរួមជួសជុល ដាក់បណ្តាញលូថ្មីនៅផ្លូវលេខ២៨២ សង្កាត់បឹងកេងកងទី១។

- ចុះពិនិត្យគម្របលូបាក់ស្រុត នៅផ្លូវលេខ៣៧០ កែងផ្លូវលេខ៥៧ សង្កាត់បឹងកេងកងទី១។
- ត្រួតពិនិត្យគម្របលូបែក និងបាក់ស្រុតនៅផ្លូវលេខ១៦៣ កែង៣៨០ ក្នុងសង្កាត់បឹងកេងកងទី៣ មានគម្របលូបែក និងលូស្រុតខូងក្រោម នៅផ្លូវលេខ១៦៣ សង្កាត់បឹងកេងកងទី៣ ។
- ត្រួតពិនិត្យស្លាកសញ្ញាចរាចរណ៍មានសភាពទ្រេតចំនួន ១ដើម ផ្លូវលេខ១៦៣ សង្កាត់បឹងកេងកងទី៣។
- ចុះពិនិត្យលូកកស្ទះនៅមហាវិថីព្រះសីហនុ សង្កាត់អូឡាំពិក។
- ចុះពិនិត្យការបើការដ្ឋានចាក់កៅស៊ូអាស់ស្វាល់ផ្លូវលេខ ៣២៨ ក្នុងសង្កាត់ទួលស្វាយព្រៃទី១។
- ចុះពិនិត្យការបើកការដ្ឋានចាក់កៅស៊ូអាស់ស្វាល់នៅផ្លូវលេខ៤០៤ ក្នុងសង្កាត់ទំនប់ទឹក។
- ចុះពិនិត្យការបើកការដ្ឋានចាក់កៅស៊ូអាល់ស្វាល់នៅផ្លូវបើកថ្មីក្នុងសង្កាត់ទំនប់ទឹក។
- ចុះពិនិត្យការជីកដាក់លូនៅផ្លូវលេខ១៨៣ សង្កាត់ទំនប់ទឹក។
- ចុះពិនិត្យការជីកដីដាក់បណ្តាញលូទំហំ០,៦០ម៉ែត្រ នៅលើផ្លូវលេខ៣១០ ចាប់ពីកែងផ្លូវលេខ១៤៣ ដល់កែងផ្លូវលេខ១០៥ សង្កាត់បឹងកេងកងទី២។
- ចុះពិនិត្យការជីកដីដាក់បណ្តាញលូទំហំ០,៦០ម៉ែត្រ នៅលើផ្លូវលេខ១៨៣ ចាប់ពីកំណាត់ផ្លូវលេខ៤៣០ ដល់ផ្លូវលេខ៤០២។
- ចុះហាមឃាត់សំណង់សាងសង់ខុសប្លង់ នៅផ្លូវលេខ៤០២ សង្កាត់ទំនប់ទឹក។
- ចុះកាប់ដើមឈើនៅកំណាត់វិថីម៉ៅសេទុងដែលបានដួលរលំក្រោយពេលភ្លៀងរួច។
- ចុះណែនាំប្រជាពលរដ្ឋឱ្យចូលរួមការក្នុងការស្តារប្រឡាយទួលសែន ស្ថិតនៅផ្លូវលេខ៣៩៦ ដល់ផ្លូវលេខ១០៥ សង្កាត់បឹងកេងកងទី៣។
- ចុះពិនិត្យការជីកសាច់ផ្លូវលំ និងចិញ្ចើមផ្លូវលេខ៣២០ ក្នុងសង្កាត់បឹងកេងកងទី៣។
- ចុះពិនិត្យការជីកខួងផ្លូវលេខ៥៨ និងចិញ្ចើមផ្លូវលេខ៣១០ ក្នុងសង្កាត់បឹងកេងកងទី១។
- ចុះណែនាំហាងលក់ធុរ៉េនយីហោស្រីមុំ ឱ្យអនុវត្តតាមសេចក្តីជូនដំណឹងលេខ០៦១ របស់រដ្ឋបាលខណ្ឌបឹងកេងកងឱ្យរុះរើសំយ៉ាប និងជញ្ជាំងដែលលយចូលមកលើចិញ្ចើមផ្លូវសាធារណៈ។
- ចុះរៀបចំសណ្តាប់ធ្នាប់ និងកាប់ដើមឈើដែលបានដួលរលំដោយសារខ្យល់កន្ត្រាក់ នៅផ្លូវលេខ២៨៤ សង្កាត់អូឡាំពិក។
- សហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ចុះកាប់ដើមឈើងាប់ ១ដើម នៅចន្លោះផ្ទះលេខ១២៨ និងផ្លូវលេខ១៣១ ស្ថិតនៅចិញ្ចើមផ្លូវម៉ៅសេទុង សង្កាត់បឹងកេងកងទី៣។
- សហការជាមួយមន្ទីរសាធារណការ កាប់ដើមឈើដែលងាប់នៅចន្លោះផ្លូវលេខ៥១ និងផ្លូវលេខ៥៧ ស្ថិតក្នុងសង្កាត់បឹងកេងកងទី១។
- កាប់ដើមឈើដែលរលើងគល់ទ្រេត នៅផ្លូវលេខ៣១០ សង្កាត់បឹងកេងកងទី១។
- ចុះណែនាំដល់ក្រុមហ៊ុនដឹកជញ្ជូន នៅតាមបណ្តោយផ្លូវលេខ២១៧ ឱ្យចតយានយន្តអោយមានសណ្តាប់ធ្នាប់ចៀសវាងការរាំងស្ទះដល់ការធ្វើដំណើររបស់អ្នកដទៃ។
- ចុះត្រួតពិនិត្យក្នុងមូលដ្ឋានខណ្ឌបឹងកេងកងជាប្រចាំ។
- ចុះត្រួតពិនិត្យដើមឈើ មែកឈើតាមដងផ្លូវក្នុងមូលដ្ឋាន។
- ចុះពិនិត្យផ្លូវគ្រលុកសំបុកមាន់តាមបណ្តាផ្លូវដែលនៅក្នុងមូលដ្ឋាន។
- ចុះពិនិត្យលូបាក់បែកនៅផ្លូវព្រះសីហនុ កែងផ្លូវលេខ១៧៣ សង្កាត់អូឡាំពិក។
- ចុះពិនិត្យលូស្រុតនៅផ្លូវលេខ៣១០ កែងផ្លូវលេខ១៩៩ សង្កាត់ទួលស្វាយព្រៃទី១។
- ចុះសិក្សាគម្រោងអភិវឌ្ឍន៍ភូមិសង្កាត់ទាំង៧។
- ចុះវាស់ផ្លូវក្នុងគម្រោងអភិវឌ្ឍន៍សង្កាត់ទាំង៧។
- ចុះត្រួតពិនិត្យដើមឈើមែកឈើតាមដងផ្លូវក្នុងមូលដ្ឋាន។
- ចុះកាប់ដើមឈើដែលបានដួលរលំដោយសាឡានកុងតឺន័របុក នៅផ្លូវលេខ២០៥ សង្កាត់ទំនប់ទឹក។

- ចុះពិនិត្យស្លាកសញ្ញាចរាចរណ៍។
- ចុះពិនិត្យខ្សែបណ្ដាញអគ្គីសនី ខ្សែកាបអុបទិកក្នុងមូលដ្ឋាន។
- ចុះពិនិត្យដើមឈើបាក់រលំក្រោយពេលភ្លៀងនៅតាមបណ្ដោយផ្លូវ ២០៥ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង កម្លាំងសន្តិសុខខណ្ឌបានចុះកាប់ភ្លាមៗដើម្បីបញ្ចៀសការកកស្ទះ។
- សហការជាមួយសង្កាត់បឹងកេងកងទី១ ចុះកាត់ខ្សែកាបដែលពុំប្រើប្រាស់ នៅផ្លូវ២៩៤ កែងផ្លូវ៥៧ និងផ្លូវ៦៣ កែង២៧៨។
- ចុះពិនិត្យគម្របលូដែក ដែលនៅសល់តាមបណ្ដោយផ្លូវម៉ៅសេទុង។
- ចុះពិនិត្យការកាប់ដើមឈើរបស់អង្គភាពថែទាំសួនច្បារ និងដើមឈើសាធារណៈនៅផ្លូវលេខ១៩៩ កែង២៧១ សង្កាត់ទំនប់ទឹក។
- ចុះពិនិត្យផ្លូវគ្រលុកនៃកំណាត់ផ្លូវលេខ១៩៩ ស្ថិតក្នុងសង្កាត់ទំនប់ទឹក។

➢ **ការងារអនាម័យ និងបរិស្ថាន**

- បានចុះត្រួតពិនិត្យនិងតាមដានការប្រមូលសំរាមរបស់ក្រុមហ៊ុនស៊ីនទ្រីជាប្រចាំ នៅផ្លូវលេខ១៨៧ ខាងកើតមន្ទីរពេទ្យរុស្សី ក្នុងសង្កាត់ទំនប់ទឹក ផ្លូវលេខ២៧៨ ខាងត្បូងវិទ្យាល័យព្រះយុគន្ធរ ក្នុងសង្កាត់បឹងកេងកងទី២ និងផ្លូវព្រះមុន្នីវ៉ែត សង្កាត់ទួលស្វាយព្រៃទី២។
- សហកាជាមួយភ្នាក់ងារអនាម័យសង្កាត់ ចុះតាមដានការទុកដាក់សំរាមរបស់ប្រជាពលរដ្ឋ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកងជាប្រចាំ។
- ចុះធ្វើអនាម័យបរិស្ថាននៅបណ្ដោយផ្លូវលេខ១៦៣ ពីកំណាត់ផ្លូវម៉ៅសេទុង ដល់ផ្លូវព្រះសីហនុ ផ្លូវលេខ១៤៣ ពីកំណាត់ផ្លូវម៉ៅសេទុងដល់ផ្លូវព្រះសីហនុ ស្ថិតក្នុងសង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ និងសង្កាត់អូឡាំពិក ក្រោមអធិបតីភាព លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។
- ចុះពិនិត្យសម្អាតទីតាំងឃ្លាំងស្តុកទំនិញ ដែលមានអគ្គីភ័យឆាបឆេះនៅផ្លូវលេខ៣៤៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង។
- ចូលរួមកាប់ដើមឈើនៅផ្លូវលេខ៤០២ សង្កាត់ទំនប់ទឹក។
- ចុះពិនិត្យការកាប់ និងដាំដើមឈើនៅផ្លូវព្រះសីហនុ សង្កាត់អូឡាំពិក។
- សហការជាមួយអាជ្ញាធរសង្កាត់ទួលស្វាយព្រៃទី១ ចុះពិនិត្យទីតាំងឃ្លាំងស្តុកទំនិញ ដែលត្រូវបានអគ្គីភ័យឆាបឆេះនៅផ្លូវលេខ៣៤៨ ដោយអោយម្ចាស់ទីតាំងធ្វើរបងបិទបាំងជាបណ្ដោះអាសន្ន ដើម្បីកុំអោយមានការបោះចោលសំរាមអាណាធិបតេយ្យមកក្នុងទីតាំងនេះ។
- សហការជាមួយក្រុមការងារមន្ទីរបរិស្ថានរាជធានីភ្នំពេញ ចុះសម្រង់ទិន្នន័យទីតាំងទិញលក់អេតចាយ និងសំណល់រឹងដែលអាចកែច្នៃបាននៅក្នុង សង្កាត់បឹងកេងកងទី២ សង្កាត់ទួលស្វាយព្រៃទី២ សរុប ៣ទីតាំង។
- ចុះធ្វើអនាម័យកាប់ដើមឈើតាមប្រឡាយលូផ្លូវ១០៥ ចាប់ពីមហាវិថីម៉ៅសេទុង ដល់ផ្លូវលេខ៣១០ ស្ថិតក្នុងសង្កាត់បឹងកេងកងទី៣។
- សហការជាមួយមន្ទីរបរិស្ថានរាជធានីភ្នំពេញ និងអាជ្ញាធរសង្កាត់អូឡាំពិក ចុះដោះស្រាយផលប៉ះពាល់បរិស្ថាន (បំពុលដោយក្លិន)នៅមូលដ្ឋានសិប្បកម្មធ្វើស្លាកយីហោ ចន្ទ រង្សី ស្ថិតនៅផ្ទះលេខ៨០Eo ផ្លូវលេខ២៧៦ សង្កាត់អូឡាំពិក។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន ភ្នាក់ងារអនាម័យសង្កាត់ ចុះធ្វើអនាម័យសំអាត ប្រមូលសំរាមនិងកាប់ដើមឈើដុះតាមប្រឡាយលូផ្លូវ១០៥ ចាប់ពីផ្លូវលេខ៣១០ ដល់មហាវិថីម៉ៅសេទុង និងជំរះស្មៅនៅស្តុបផ្លូវលេខ៣១០ និងផ្លូវលេខ៣៦ កែងមហាវិថីព្រះមុនីវង្ស ស្ថិតក្នុងសង្កាត់បឹងកេងកងទី៣។
- ចុះអប់រំណែនាំដល់ឃ្លាំងស្តុកបន្លែនៅផ្លូវលេខ៣៣៨ សង្កាត់ទួលស្វាយព្រៃទី២ ឱ្យវេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។

- សហការជាមួយភ្នាក់ងារ ស.ស.យ.ក សង្កាត់ទំនប់ទឹក ចុះធ្វើអនាម័យនៅជុំវិញ និងក្នុងសាលាបឋមសិក្សាភូមិ៧។
- ចុះធ្វើអនាម័យបរិស្ថាន នៅវិទ្យាល័យជាស៊ីមបឹងកេងកង វិទ្យាល័យព្រះយុគន្ធរ និងវិទ្យាល័យទួលស្វាយព្រៃ ក្រោមការដឹកនាំរបស់លោកអភិបាលខណ្ឌ។
- ចុះត្រួតពិនិត្យបញ្ហារំខានដោយសំឡេងនៅទីតាំងឃ្លាំងស្តុកបន្លែលេខ១៨ ផ្លូវលេខ៤០២ សង្កាត់ទំនប់ទឹក ក្រោមការដឹកនាំរបស់ លោក ហេង ពិសិដ្ឋ អភិបាលរងខណ្ឌ។
- ចុះត្រួតពិនិត្យបញ្ហាអនាម័យ បរិស្ថាននៅបណ្តោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក និងផ្លូវលេខ២១៧ ស្ថិតក្នុងសង្កាត់ទួលស្វាយព្រៃទី២។
- ចុះធ្វើអនាម័យប្រមូលសម្អាតមែកឈើ ស្លឹកឈើនិងកំទេចឈើនៅផ្លូវលេខ២០៥ ស្ថិតក្នុងសង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង។
- ចុះពិនិត្យបញ្ហាអនាម័យ បរិស្ថាននៅផ្សារក្រមួនស្ថិតនៅផ្លូវលេខ១១៣ សង្កាត់បឹងកេងកងទី២។
- ចុះអប់រំនិងផ្សព្វផ្សាយសេចក្តីណែនាំលេខ០២៥ របស់រដ្ឋបាលរាជធានីភ្នំពេញ ដល់ប្រជាពលរដ្ឋស្តីពីការវេចខ្ចប់ ញែកសំរាម និងបញ្ចេញសំរាមអោយត្រូវតាមពេលវេលាកំណត់ នៅសង្កាត់ទំនប់ទឹក និងសង្កាត់ទួលស្វាយព្រៃទី២។
- ចុះពិនិត្យគំនរសំរាមពេលយប់នៅផ្លូវលេខ២៨៦ កែងផ្លូវលេខ១៩៣ សង្កាត់អូឡាំពិក។
- ចូលរួមសិក្ខាសាលាស្តីពីការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិចនៅមន្ទីរ បរិស្ថានរាជធានីភ្នំពេញ។
- ចូលរួមសិក្ខាសាលាស្តីពីការផាកពិន័យអន្តរការណ៍ ចំពោះអំពើល្មើសនៃអនុក្រឹតលេខ១១៣ ស្តីពីការគ្រប់គ្រង សំណល់រឹងទីប្រជុំជន ជាមួយក្រុមហ៊ុន ស៊ីន ទ្រី នៅរដ្ឋបាលខណ្ឌបឹងកេងកង។
- ចុះពិនិត្យសំរាមបញ្ចេញខុសពេលវេលាកំណត់ នៅតាមបណ្តោយផ្លូវលេខ១០៥ សង្កាត់បឹងកេងកងទី២ និង សង្កាត់បឹងកេងកងទី៣។

➢ **ការងារសណ្តាប់ធ្នាប់សាធារណៈ និងការងារផ្សេងៗ**

- ចូលរួមចុះរៀបចំសណ្តាប់ធ្នាប់នៅតាមបណ្តាផ្លូវផ្សេងៗ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។
- ចុះរៀបចំសណ្តាប់ធ្នាប់លើបណ្តោយផ្លូវ២៧១ មុខមន្ទីពេទ្យមិត្តភាពខ្មែរសូវៀត និងដាក់កម្លាំងប្រចាំការរៀបចំ អ្នកលក់ដូតាមរទេះដែលដាក់លក់មុខមន្ទីពេទ្យ។
- ដាក់កម្លាំងប្រចាំការតាមមណ្ឌលចាក់វ៉ាក់សាំងជាប្រចាំទាំង ៨មណ្ឌល។
- ចុះល្បាតក្នុងភូមិសាស្ត្រសង្កាត់ទាំង៧ ដើម្បីទប់ស្កាត់ការជួបជុំ ចាក់ភ្លេង និងបញ្ហាផ្សេងៗ។
- ចុះរៀបចំសណ្តាប់ធ្នាប់លើផ្លូវមុនីរ៉េត និងដាក់កម្លាំងប្រចាំការដើម្បីទប់ស្កាត់បងប្អូនអាជីវករ មិនអោយដាក់បន្លែ លក់បន្តទៀតទេ។
- ចូលរួមពិធីទទួលអំណោយជាអង្ករ ១០តោន ពីកាកបាទក្រហមរាជធានីភ្នំពេញ។
- ចុះធ្វើរដ្ឋបាលនៅក្នុងសង្កាត់បឹងកេងកងទី១ និងសង្កាត់បឹងកេងកងទី២ ក្រោមអធិបតីភាព លោក ម៉ៅ កុលម៉ារឌី អភិបាលរងខណ្ឌបឹងកេងកង។
- ចូលរួមចែកអំណោយកាកបាទក្រហម ដល់គ្រួសារសពជនរងគ្រោះដែលទទួលរងអគ្គីភ័យឆាបឆេះនៅបរិវេណ វត្តស្ទឹងមានជ័យ ក្រោមអធិបតីភាព លោកស្រី ស៊ិន រតនា អភិបាលរងខណ្ឌបឹងកេងកង។
- បានចូលរួមសំណេះសំណាល សួរសុខទុក្ខដល់ប្រជាពលរដ្ឋរងគ្រោះដោយអគ្គីភ័យចំនួន ១០គ្រួសារ នៅផ្លូវលេខ ៣៤៨ សង្កាត់ទួលស្វាយព្រៃទី១ ក្រោមអធិបតីភាព លោកជឹម សំអាន អភិបាលខណ្ឌបឹងកេង។
- ចុះអប់រំផ្សព្វផ្សាយទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ១៩ ក្នុងព្រឹត្តិការណ៍ ថ្ងៃ២០ ខែកុម្ភៈ ឆ្នាំ២០២១ដល់ប្រជា ពលរដ្ឋក្នុងមូលដ្ឋានខណ្ឌបឹងកេងកងជាប្រចាំ។
- ចុះពិនិត្យតាមគោលដៅចត្តាឡីស័កក្នុងមូលដ្ឋានខណ្ឌបឹងកេងកងជាប្រចាំ ។
- ចូលរួមវេនយាមប្រចាំការ២៤លើ២៤ម៉ោង ។
- ចុះសម្របសម្រួលដំណើរការចាក់វ៉ាក់សាំងការពារវីរុសកូវីដ១៩។

- បានចូលរួមក្នុងយុទ្ធនាការបំរាមគោចរ ពីម៉ោង២០ ដល់ម៉ោង៣ភ្លឺ ក្រោមអធិបតី លោក ហេង ពិសិដ្ឋ និង លោក កឹមណៃ វីរៈខេមរា អភិបាលរងខណ្ឌបឹងកេងកង។
- ចុះផ្អាកជាបណ្តោះអាសន្ន ផ្សារដែលមិនរៀបរយ នៅលើផ្លូវលេខ៣១០ និងផ្លូវលេខ១៩៣ សង្កាត់អូឡាំពិក ផ្លូវលេខ ១១៣ ផ្សារលើលូ ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលជម្ងឺកូវីដ១៩។
- ចុះសម្របសម្រួលដល់ការយកសំណាករបស់ប្រជាពលរដ្ឋអាជីវករផ្សារបឹងកេងកង និងអ្នកពាក់ព័ន្ធនៅវិទ្យាល័យជាស៊ីមបឹងកេងកង អាជីវករផ្សារអូឡាំពិក និងអ្នកពាក់ព័ន្ធនៅវិទ្យាល័យទួលស្វាយព្រៃ។
- ចុះស្ទាបស្ទង់មតិប្រជាពលរដ្ឋដែលកំពង់ធ្វើចត្តាឡីស័ក និងពិនិត្យសំណាកថ្ងៃចុងក្រោយនៅវិទ្យាល័យជាស៊ីមបឹងកេងកង ក្រោមអធិបតីភាពលោក ធឹម សំអាន អភិបាលខណ្ឌ ។
- ចូលរួមសម្របសម្រួលក្នុងការចាក់វ៉ាក់សាំងការពារជម្ងឺកូវីដ១៩ នៅមណ្ឌលសុខភាពទួលស្វាយព្រៃ។
- ចូលរួមសហការចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ ជាមួយកម្លាំងសមត្ថកិច្ចប៉ូលីស និងកងរាជអាវុធហត្ថខណ្ឌបឹងកេងកង។

### ២.១.៤. <u>ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន</u>

- សំណុំរឿងរបស់ការិយាល័យ នីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន ក្នុងឆ្នាំ២០២១ រួមមាន៖

  <u>សំណុំឯកសារចូល</u>

  - សំណុំរឿងសះជា ១៤
  - សំណុំរឿងមិនសះជា ១៤
  - សំណុំរឿងបន្តតាមប្រព័ន្ធតុលាការ ១៨
  - ណែនាំសាម៉ីខ្លួនឱ្យដឹងពីប្រព័ន្ធច្បាប់ ១០
  - សុំដកពាក្យបណ្តឹង ០៧
  - អនុវត្តដីកាតុលាការ ០៤ (មិនចូលរួមសហការ ០២)
  - ដីកាអម ០៨
  - សំណុំរឿងកំពុងដោះស្រាយ ១៣
  - សរុប ៨៨

### ២.២. <u>សង្គមកិច្ច</u>

### ២.២.១. <u>ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម</u>

➢ **<u>ការងារសង្គមកិច្ច</u>**

- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌបឹងកេងកង ចំនួន០៧លើក។
- បានចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង ចំនួន១២លើក។
- បានចូលរួមកិច្ចប្រជុំ គ.ក.ស.ក. បានចំនួន០៩លើក។
- បានចុះបើកប្រាក់មរណសង្គ្រោះរបស់សមាគមអតីតយុទ្ធជន បានចំនួន០៧គ្រួសារ។
- បានទទួលប័ណ្ណ បសស ចំនួន១០៨៥ប័ណ្ណ ពីការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមខណ្ឌចំការមន។
- បានសហការជាមួយ ក្រសួង សអយ ក្នុងការចុះអង្កេតគ្រួសារសុំកូនចិញ្ចឹមពីអង្គការហូល បាន២គ្រួសារ។
- បានសហការជាមួយនឹងសង្កាត់ទាំង៧ ចែកប័ណ្ណ បសស បានចំនួន១៤១ប័ណ្ណ នៅសល់៩៤៤ប័ណ្ណ។
- បានចូលរួមចុះរដ្ឋបាលតាមសង្កាត់ក្នុងភូមិសាស្ត្រខណ្ឌបឹងកេងកង។
- បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីពង្រឹងការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំអឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ ក្រោមអធិបតីភាព ឯកឧត្តម នួន ផារ័ត្ន អភិបាលរងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ បានចំនួន០១លើក។
- បានចុះអង្កេតរហ័សជនអនាថានៅតាមសង្កាត់ទាំង៧ បានចំនួន២លើក។

- បានសហការជាមួយអធិការ អធិការរងខណ្ឌបឹងកេងកង មេប៉ុស្តិ៍ ចៅសង្កាត់ទាំង៧ នាំគ្រួសារអតីតយុទ្ធជន ទៅចាក់វ៉ាក់សាំងកូវីដ១៩ នៅមន្ទីរពេទ្យកេតុមាលា បានចំនួន៣លើក។
- បានចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាលផ្សេងៗតាមប្រព័ន្ធZOOM និងផ្ទាល់ បានចំនួន១២លើក ។
- បានសហការជាមួយរដ្ឋបាលខណ្ឌពោធិសែនជ័យ អង្គការដំណឹងល្អ ចៅសង្កាត់ចោមចៅទី៣ និងចៅសង្កាត់បឹងកេងកងទី៣ ចុះប៉ាន់ប្រមាណគ្រួសារកុមារ និងសមាហរណកម្មកុមារ ឈ្មោះ ហេង រតនៈ ទៅនៅជាមួយគ្រួសារ ឈ្មោះ កើត ធីតា និង ថត សេងឈៀង ក្នុងសហគមន៍គ្រួសារវិញ បានចំនួន០១គ្រួសារ។
- បានសហការជាមួយមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះចំនួន៦៨៨នាក់ ពីមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ លើកទី៤ ឲ្យទៅរស់នៅតាមគ្រួសារតាមបណ្តា ភូមិ ស្រុក ខេត្ត ក្រុងវិញបានចំនួន២លើក។
- បានចូលរួមកម្មវិធីចែកអំណោយជូនជនចាស់ជរាចំនួន ៩២គ្រួសារ ០២លើក ក្រោមអធិបតីភាព លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង នៅសាលាខណ្ឌបឹងកេងកង។
- បានសហការជាមួយក្រសួង ស.អ.យ មន្ទីរ ស.អ.យ និងសង្កាត់ទួលស្វាយព្រៃទី១ ក្នុងការចុះពិនិត្យអង្គការកុមារអាស៊ី ដើម្បីផ្តល់ការគាំទ្របន្តMOU បានចំនួន០៤លើក។
- បានចូលរួមជាមួយរដ្ឋបាលខណ្ឌចុះផ្សព្វផ្សាយ និងសំអាតបរិស្ថាននៅតាមបណ្តាសង្កាត់ទាំង៧ ក្នុងមូលដ្ឋានខណ្ឌបឹងកេងកង បានចំនួន០១លើក។
- បានសហការជាមួយនឹងសង្កាត់ទាំង៧ ចុះអនុវត្តសម្ភាសន៍ជនមានពិការភាពបានលទ្ធផល ជារបាយការណ៍បឋម បឹងកេងកងទី១ បាន០២នាក់ បឹងកេងកងទី២ បាន៤១នាក់ បឹងកេងកងទី៣ បាន៥០នាក់ ទួលស្វាយព្រៃទី១ បាន៣នាក់ ទួលស្វាយព្រៃទី២ បាន៧នាក់ អូឡាំពិក បាន១៧នាក់ ទំនប់ទឹកបាន៩៦នាក់ ចំនួនសរុប២១៦នាក់ បានចំនួន០១លើក។
- បានសហការជាមួយក្រសួង ស.អ.យ មន្ទីរ ស.អ.យ និងអធិការដ្ឋាននគរបាលខណ្ឌបឹងកេងកង ធ្វើបច្ចុប្បន្នភាពសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា តាមបណ្តាសង្កាត់ទាំង៧ មានចំនួន៣៧៨នាក់ បានចំនួន០១លើក។
- បានចូលរួមប្រចាំការនៅតាមមណ្ឌលចាក់វ៉ាក់សាំង ជូនកុមារមានអាយុ៥ឆ្នាំ។
- ចូលរួមប្រចាំការវេនយាម២៤ម៉/២៤ម៉ នៅតាមគោលដៅ តាមការដឹកនាំរបស់លោកអភិបាលខណ្ឌ។
- បានចូលរួមកិច្ចប្រជុំស្តីពី វគ្គបណ្តុះបណ្តាលយុទ្ធសាស្ត្រទាំងប្រាំពីរ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងការការពារកុមារ ព្រមទាំងការថែទាំជំនួស បានចំនួន០២លើក។
- បានសហការជាមួយសង្កាត់ទាំង៧ ធ្វើការទំនាក់ទំនងជាមួយគ្រួសារសព(តំណាងគ្រួសារសព) ដើម្បីបើកប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា។
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់បណ្តាញសង្គមប្រកបដោយប្រសិទ្ធភាព ក្នុងការផ្សព្វផ្សាយ និងទទួលព័ត៌មាន នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម កើត ឆែ អភិបាលរងរាជធានីភ្នំពេញ បានចំនួន០១លើក។
- បានចូលរួមបើកប្រាក់ធានារ៉ាប់រង១២ខែ ជូនគ្រួសារសពចំនួន០៦គ្រួសារ នៅមន្ទីរ ស.អ.យ រាជធានីភ្នំពេញ ក្រោមអធិបតីភាព លោកស្រី មុំ ចាន់ដានី ប្រធានមន្ទីរ ស.អ.យ រាជធានីភ្នំពេញ។
- បានចូលរួមកិច្ចប្រជុំស្តីពី កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ក្រោយពេលបិទខ្ទប់ ដើម្បីបើកប្រាក់ឧបត្ថម្ភជូនគ្រួសារសព ដែលស្លាប់ដោយសារជំងឺកូវីដ១៩ នៅក្នុងតំបន់រាជធានីភ្នំពេញ ក្រោមអធិបតីភាព លោកស្រី មុំ ចាន់ដានី ប្រធានមន្ទីរ ស.អ.យ ចំនួន០១លើក។
- បានចូលរួមជាមួយ អ.ក.ន.ក សង្កាត់បឹងកេងកងទី៣ ឧបត្ថម្ភគ្រួសារសព ចំនួន២លើក។
- បានចូលរួមជាមួយ អ.ក.ន.ក.សង្កាត់បឹងកេងកងទី៣ ចុះសួរសុខទុក្ខសមាជិក សមាគមមនុស្សចាស់ និងឧបត្ថម្ភគ្រួសារសព ចំនួន០១លើក។
- បានចូលរួមឧបត្ថម្ភសាច់ប្រាក់ ជូនកុមារក្រោមអាយុ០២ឆ្នាំ បានចំនួន០៣លើក។

- បានចូលរួមក្នុងកិច្ចប្រជុំក្រុមការងារដឹកនាំ ពង្រឹង និងការគ្រប់គ្រងសមាគមមនុស្សចាស់ រាជធានីភ្នំពេញ ក្រោមអធិបតីភាព លោកជំទាវ កែវ សុខពិសី អភិបាលរងរាជធានីភ្នំពេញ តាមប្រព័ន្ធZOOM ចំនួន០១លើក។

➢ **ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ**

- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌបឹងកេងកង ចំនួន០៧លើក។
- បានចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង ចំនួន១២លើក។
- បានចូលរួមកិច្ចប្រជុំ គ.ក.ស.ក. បានចំនួន០៩លើក។
- បានចូលរួមកិច្ចប្រជុំ សំណេះសំណាលជាមួយមន្ត្រីរាជការ ដែលកំពុងបម្រើការងារ នៅក្នុងរដ្ឋបាលខណ្ឌបឹងកេងកង បានចំនួន ០១លើក ក្រោមអធិបតីភាព លោក ជឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។
- បានចូលរួមប្រចាំការនៅតាមមណ្ឌលចាក់វ៉ាក់សាំង គ្រប់ការចាត់តាំងរបស់រដ្ឋបាលខណ្ឌ។
- ចូលរួមវេនយាមប្រចាំការ ក្នុងសាលាខណ្ឌបឹងកេងកង រាល់វេនយាម។
- បានចូលរួមពិធីចែកអំណោយរបស់កាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាព លោកអភិបាលខណ្ឌបឹងកេងកង។
- បានចូលរួមសហការអនុវត្តអនាម័យនៅតាមសាលារៀន នៅក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។

➢ **ការងារវប្បធម៌**

- បានចុះពិនិត្យ និងជំរុញទីតាំងសាឡន ហាងកាត់សក់ ធ្វើក្រចក ឲ្យមកដាក់ស្នើសុំពាក្យនៅការិយាល័យច្រកចេញចូលតែមួយ បានចំនួន១៥ទីតាំង មានច្បាប់ចំនួន ២ទីតាំង។
- បានចុះពិនិត្យ និងជំរុញទីតាំងអាជីវកម្ម ដែលលើកស្លាកយីហោ ផ្ទាំងផ្សព្វផ្សាយ បានសរុបចំនួន១០ទីតាំង មានច្បាប់ចំនួន ០២ទីតាំង។
- បានចុះពិនិត្យ និងជំរុញទីតាំងអាជីវកម្ម ដែលលើកស្លាកយីហោ ព្រីនរូបភាព ជាងគំនូរ សរុបចំនួន ០៦ទីតាំង មានច្បាប់ចំនួន ០០ទីតាំង។
- បានចូលរួមប្រជុំផ្សព្វផ្សាយអំពីការរៀបចំដាក់បញ្ចូលទីតាំងប្រវត្តិសាស្ត្រ ម១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងប្រល័យពូជសាសន៍ជើងឯក ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាព លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ។

➢ **ការងារសុខាភិបាល**

- ការពិនិត្យផ្ទៃពោះសរុប ៣៨២នាក់
- ការសម្រាលកូនសរុប ០នាក់
- ការផ្តល់ជាតិដែក ៩០គ្រាប់មុនសម្រាល ៣៨២នាក់
- ចំនួនកុមារចាក់ថ្នាំបង្ការគ្រប់មុខ ២៦៩នាក់
- ស្ត្រីមានផ្ទៃពោះចាក់ថ្នាំបង្ការតេតាណុសលើសពី ២ដង ៥៣១នាក់
- តាមដានជាប្រចាំករណីមាតាស្លាប់ និងទារកស្លាប់ក្រោម ២៨ថ្ងៃ ០លើក
- តាមដានជាប្រចាំករណីជម្ងឺផ្សេងៗ ០លើក
- ប្រជុំពង្រឹងការងារគាំពារមាតា និងទារក កុមារ ០១ដង
- ផ្តល់ថ្នាំមេបង់ជាហ្សុលដល់សិស្សានុសិស្ស ០លើក

➢ **ការងារធម្មការ និងសាសនា**

- បានចូលរួមសិក្ខាសាលាស្តីពី «បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព» និង «កម្រងឯកសារបណ្តុះបណ្តាលអំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល» នៅសណ្ឋាគារ សាន់វ៉េ ក្រោមអធិបតីភាព ឯកឧត្តម សំហេង បុរស រដ្ឋលេខាធិការ ក្រសួង ស.អ.យ។
- បានចុះពិនិត្យការរៃអង្គាសនៅតាមសង្កាត់ទាំង៧ បានចំនួន០៧លើក។

- បានចុះប្រមូលសេវាសង្គម នៅតាមសង្កាត់ទាំង០៧ បានចំនួន០៧លើក ក្រោមអធិបតីភាព លោកស្រី ម៉ែន សុភារី សមាជិកាក្រុមប្រឹក្សាខណ្ឌ និងជាប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង។
- បានចូលរួមសម្របសម្រួលការងារចាក់វ៉ាក់សាំងកូវីដ១៩ ជូនប្រជាពលរដ្ឋក្នុងខណ្ឌបឹងកេងកង។
- បានចូលរួមប្រចាំការនៅតាមទីតាំងបម្រាមគោចរ តាមការកំណត់របស់ថ្នាក់ដឹកនាំខណ្ឌ។
- បានសហការជាមួយរដ្ឋបាលខណ្ឌពោធិសែនជ័យ អង្គការដំណឹងល្អ ចៅសង្កាត់ចោមចៅទី៣ និងចៅសង្កាត់បឹងកេងកងទី៣ ចុះប៉ាន់ប៉ាន់ប្រមាណគ្រួសារកុមារ និងសមាហរណកម្មកុមារ ឈ្មោះ ហេង រតនៈ ទៅនៅជាមួយគ្រួសារ ឈ្មោះ កើត ធីតា និង ថត សេងឈៀង ក្នុងសហគមន៍គ្រួសារវិញ។
- បានចុះពិនិត្យទីតាំងសុំចុះបញ្ជីពាហិរសាសនា ឈ្មោះវិទ្យស្ថានបេសកកម្មគ្រិះបរិសស័ទចិន ដែលមានអាសយដ្ឋានផ្ទះលេខ៩៩ ផ្លូវលេខ២៩៤ សង្កាត់បឹងកេងកងទី១។
- បានជួយបំពេញពាក្យសុំបំបួសកុលបុត្រ ០១រូប។
- បានចូលរួមជាមួយរដ្ឋបាលខណ្ឌបឹងកេងកង នាំយកបច្ច័យកឋិណទានទៅវត្តលង្កាព្រះកុសុមារាម។
- បានចូលរួមកិច្ចប្រជុំសំណេះសំណាលជាមួយមន្ត្រីរាជការ ដែលកំពុងបម្រើការងារ នៅក្នុងរដ្ឋបាលខណ្ឌបឹងកេងកង ក្រោមអធិបតីភាព លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។
- បានចូលរួមពិធីសម្ពោធ ជាផ្លូវការវិមានពហុកីឡាដ្ឋានជាតិមរតកតេជោ ចំនួន០១លើក។

➢ **<u>ការងារកិច្ចការនារី</u>**

- បានចូលរួមវេទិកាផ្សព្វផ្សាយស្តីពី "ទំនាមទម្លាប់ប្រពៃណី សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ" ក្រោមអធិបតីភាព ឯកឧត្តម ផន ដារី សមាជិកក្រុមប្រឹក្សារាជធានី លោកស្រី កាន់ រតនឧប្បល ប្រធានមន្ទីរកិច្ចការនារី រាជធានីភ្នំពេញ ចំនួន០១លើក មានសមាជិកចូលរួមសរុប១២០នាក់ ស្រី៨០នាក់។
- បានចូលរួមផ្សព្វផ្សាយណែនាំ រាល់វិធានការរបស់ក្រសួងសុខាភិបាលស្តីពី ការការពារជំងឺកូវីដ១៩ នៅតាមសង្កាត់ទាំង៧ ជាប្រចាំ។
- បានចូលរួមផ្សព្វផ្សាយដល់ស្ត្រីទើបសម្រាលកូន ទៅចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងរយៈពេល៣០ថ្ងៃ ក្រោយកំណើត ចំនួន០៧លើក នៅក្នុងសង្កាត់ទាំង០៧។
- បានចូលរួមកិច្ចប្រជុំ គ.ក.ន.ក នៅសង្កាត់បឹងកេងកងទី១ ទី២ ទី៣។
- បានចូលរួមផ្សព្វផ្សាយដល់ក្រុមប្រឹក្សាសង្កាត់ និងសមាជិកភូមិ អំពីការរៀនជំនាញធុងកាហ្វេ អ៊ុតសក់ និងជួសជុល ឡាន ម៉ូតូ ចំនួន០១លើក។
- បានបំពេញបែបបទ ជូនគ្រួសារក្រីក្រដើម្បីរៀនជំនាញធុងកាហ្វេ អ៊ុតសក់ និងជួសជុល ឡាន ម៉ូតូ ចំនួន០៩នាក់ ស្រី០១នាក់។
- បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ ឆ្លុះបញ្ចាំងលទ្ធផលអនុវត្តការងារឆ្នាំ២០២០ និងទិសដៅឆ្នាំ២០២១ របស់ គ.ក.ស.ក រាជធានីភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម ប៉ា សុជាតិវង្ស ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ ចំនួន០១លើក នៅសាលារាជធានីភ្នំពេញ។
- បានចូលរួមចែកអំណោយរបស់ ឯកឧត្តម ហ៊ុន ម៉ាណែត និងលោកជំទាវ ពេជ្រ ចន្ទមុន្នី ជូនដល់ប្រជាពលរដ្ឋដែលកំពុងធ្វើចត្តាឡីស័ក សរុបចំនួន១០៩គ្រួសារ អំណោយរួមមាន អង្ករ២៥គីឡូក្រាម ទឹកស៊ីអ៊ីវ០១យួរ ម៉ាស១០ ទឹកសុទ្ធ ០១កេស ស្ករស ០១គីឡូក្រាម និងថ្នាំពេទ្យ ០១កញ្ចប់។
- បានសហការជាមួយអ្នកទទួលបន្ទុកកិច្ចការនារីសង្កាត់ទាំង០៧ ដើម្បីស្រង់ស្ថិតិកុមារ អាយុក្រោម១៨ឆ្នាំ ដែលឆ្លង ជំងឺកូវីដ១៩ មានចំនួនសរុប៤៨នាក់។
- បានសហការជាមួយ អ.ក.ន.ក សង្កាត់អូឡាំពិក ចូលរួមកម្មវិធីផ្តល់អាហារូបករណ៍សិស្សថ្នាក់បឋមសិក្សាវត្តមហាមន្ត្រី ចំនួន២២នាក់ ក្នុងមួយនាក់ទទួលបានថវិកាចំនួន១៦០០០០រៀល ក្រោមការឧបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា និងសមាគមអឺរ៉ុប។

- បានសហការជាមួយនឹង អ.ក.ន.ក សង្កាត់៧ ចុះសួរសុខទុក្ខគ្រួសារ ធ្វើចត្តាឡីស័កចំនួន ០៤គ្រួសារ និងឧបត្ថម្ភ ១គ្រួសារអង្ករ ២០គីឡូក្រាម មី១កេស ទឹកត្រី ២យួរ។
- បានសហការជាមួយ អ.ក.ន.ក សង្កាត់៧ ចុះផ្សព្វផ្សាយអំពីសុខភាពស្ត្រី និងកុមារ បានចំនួនសរុប៣៣៥នាក់។
- បានសហការជាមួយនឹងសង្កាត់៧ ចែក បន្លែ សាច់ជ្រូក អង្ករ ពងមាន់ និងគ្រឿងបរិភោគ ឧបភោគ មួយចំនួន ដែលជាអំណោយរបស់ លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង ជូនប្រជាពលរដ្ឋ ក្នុងកំឡុងពេលបិទខ្ទប់ បានចំនួន១២១៩គ្រួសារ។
- បានសហការជាមួយ អ.ក.ន.ក សង្កាត់បឹងកេងកងទី៣ ចូលរួមចលនាប្រជាពលរដ្ឋ រៀបចំស្តារលូ នៅផ្លូវ៣៣០ កែងផ្លូវ៩៥ ភូមិ៧ ប្រវែងសរុប៤៥ម៉ែត្រ ចំណាយថវិកាសរុបចំនួន៥៥០,០០០រៀល។
- បានសហការជាមួយ អ.ក.ន.ក.សង្កាត់៧ ចូលរួមសម្របសម្រួលរៀបចំឯកសារ បំពេញបែបបទជូនគ្រួសារ ដែលមានជីវភាពខ្វះខាត ក្នុងកំឡុងពេលបិទខ្ទប់ ដើម្បីបើកថវិការបស់រាជរដ្ឋាភិបាលកម្ពុជា បានចំនួន៥លើក។
- បានចូលរួមកិច្ចប្រជុំ និងរៀបចំឯកសារអំពីការវាយតម្លៃពានរង្វាន់សេវាសង្គម ក្រោមអធិបតីភាព លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។
- លោកស្រី ម៉ែន សុភាវី ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង បានដឹកនាំសមាជិក-សាមាជិកា គ.ក.ស.ក ខណ្ឌ និង គ.ក.ន.ក សង្កាត់ទាំង៧ ទៅសួរសុខទុក្ខ លោកជំទាវ ឃួន គឹមនី សមាជិកាក្រុមប្រឹក្សារាជធានីភ្នំពេញ ដែលកំពុងសម្រាក ព្យាបាលនៅគេហដ្ឋាន និងឧបត្ថម្ភថវិកាចំនួន ១,០០០,០០០រៀល។
- លោកស្រី ម៉ែន សុភាវី ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង បានដឹកនាំសមាជិក-សាមាជិកា ចូលរួមប្រជុំស្តីពីសេវាសង្គម តាមរយៈZOOM ដែលរៀបចំដោយក្រសួងមហាផ្ទៃ ចំនួន១លើក។
- លោកស្រី ម៉ែន សុភាវី ប្រធាន គ.ក.ស.ក ខណ្ឌបឹងកេងកង បានចូលរួមចែកអំណោយ ដល់សមាជិកសមាគមមនុស្សចាស់សង្កាត់ទាំង៧ ចំនួន៩១នាក់ ចំនួន២លើក ក្រោមអធិបតីភាព លោក គឹម ឈុនអ៊ី ប្រធានក្រុមប្រឹក្សាខណ្ឌ និង លោក ធឹម សំអាន អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។
- បានចូលរួមចុះសួរសុខទុក្ខ និងចូលរួមបុណ្យគ្រួសារសព ចំនួន០៩គ្រួសារ និងឧបត្ថម្ភ ថវិកាសរុបចំនួន ២,៦៤០,០០០រៀល អង្ករ ២៥០គីឡូក្រាម មី ០៩កេស និង ឃីត០៩កញ្ចប់។
- បានសហការជាមួយនឹងសង្កាត់ទាំង៧ ចុះសួរសុខទុក្ខស្ត្រីក្រីក្រ អ្នកគ្មានទីពឹង និងចាស់ជរា សរុប៥១នាក់ ឧបត្ថម្ភថវិកាសរុប ១,៤៥០,០០០រៀល អង្ករ ១០០០គីឡូក្រាម និងឃីត ៥១កញ្ចប់។
- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ ក្រោមអធិបតីភាព លោកជំទាវ កែវ សុខពិសី អភិបាលរងរាជធានីភ្នំពេញ តាមប្រព័ន្ធZOOM ចំនួន ០១លើក។

## ២.២.២. **<u>ការិយាល័យអប់រំ យុវជន និងកីឡា</u>**

- ចូលរួមពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី២០២០-២០២១ នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ។
- រៀបចំការប្រឡងឡើងថ្នាក់(ដើមឆ្នាំ)សិស្សធ្លាក់មធ្យមភាគគ្រប់កម្រិតថ្នាក់ ។
- ណែនាំគណៈនាយកគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ក្នុងការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) និងវិធានការសុខាភិបាល ។
- ណែនាំ និងពង្រឹងការសិក្សាពីចម្ងាយ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច និងការដាក់កែកិច្ចការសិស្ស
- គ្រប់គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន ត្រូវរៀបចំបង្កើតបន្ទប់ថតវីដេអូបង្រៀនពីចម្ងាយដល់សិស្សតាមប្រព័ន្ធទូរស័ព្ទឆ្លាតវៃ ឱ្យសិស្សរៀនតាមទូរទស្សន៍នៅតាមផ្ទះ ។ល។
- ប្រមូលបញ្ជីសិស្សក្រីក្រដែលទទួលបានអាហារូបករណ៍ជាផ្លូវការ ចុះពិនិត្យបែងចែកថវិកាអាហារូបករណ៍សិស្សក្រីក្រ ជាពិសេសកូនយុទ្ធជន និងតាមដានការសិក្សាសិស្សមានអាហារូបករណ៍ ។
- បំផុសចលនាប្រឡងប្រណាំងនាយកសាលាល្អ គ្រូបង្រៀនល្អ សាលារៀនកុមារមេត្រី បរិស្ថានស្អាត ។

- ទទួលពិនិត្យផែនការប្រតិបត្តិប្រចាំឆ្នាំ ប្រតិទិនការងារប្រចាំឆ្នាំ ផែនការអភិវឌ្ឍន៍សាលារៀន ផែនការសកម្មភាពសាលារៀន។ល។
- បូកសរុបរបាយការណ៍លើការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិច និងបំប៉នពីចម្ងាយគ្រប់កម្រិតថ្នាក់បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា ក្នុង១សប្តាហ៍១ម្តង។
- ការចុះពិនិត្យតាមដានវាយតម្លៃកាបង្រៀន រៀននៅក្នុងសាលា ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ដល់សិស្ស តាមសាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាសាធារណៈ និង ឯកជន រួចបញ្ជូនរបាយការណ៍ផ្ញើមករដ្ឋបាលខណ្ឌបឹងកេងកង និងមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញរៀងរាល់ថ្ងៃ។
- តាមដានបុគ្គលិកអប់រំសិស្សឆ្លងជំងឺកូវីដ១៩ តាមសាលាសាធារណៈ និងឯកជនសរុបរាយការណ៍ប្រចាំថ្ងៃផ្ញើជូនមករដ្ឋបាលខណ្ឌបឹងកេងកង និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ។
- ចាត់តាំងគណៈកម្មការចុះពិនិត្យការប្រឡងឆមាសលើកទី២ ថ្នាក់ទី៦ នាសម័យប្រឡង៣០.១១.២១ រយៈពេល ១ព្រឹក លើមុខវិជ្ជាគោល២ គឺភាសាខ្មែរ (វិញ្ញាសា សរសេរតាមអាន) និងគណិតវិទ្យា ។
- ប្រមូលមធ្យមភាគប្រចាំឆមាសលើកទី២ មធ្យមភាគប្រចាំឆ្នាំ គ្រប់កម្រិតថ្នាក់ ពីសាលាធារណៈ និងឯកជន ចុះហត្ថលេខា បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ។
- ទទួលបញ្ជីសិស្សថ្នាក់ទី៦គ្រប់សាលាបឋមសិក្សារដ្ឋ និងឯកជន ដែលត្រូវទៅរៀនថ្នាក់ទី៧ នៅមធ្យមសិក្សា (ឆ្លងភូមិសិក្សា) រួចបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ។
- ការចូលរួមការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ២៧ ធ្នូ ២០២១។

## ២.៣. ការគ្រប់គ្រងដីធ្លីធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

### ១. ការងារសុរិយោដី និងភូមិបាល

**អំណោយផ្តាច់**

- ប័ណ្ណកម្មសិទ្ធផ្ទះសរុបចំនួន ០១ប័ណ្ណ
- ប័ណ្ណដីសរុបចំនួន ០៧ប័ណ្ណ
- ប័ណ្ណសហកម្មសិទ្ធិ ០០ប័ណ្ណ

**លក់ផ្តាច់**

- កម្មសិទ្ធផ្ទះសរុបចំនួន ០០ប័ណ្ណ
- ប័ណ្ណដីសរុបចំនួន ១៩ប័ណ្ណ
- សហកម្មសិទ្ធិ ០៥ប័ណ្ណ

**ចេញប័ណ្ណ**

- កម្មសិទ្ធផ្ទះសរុបចំនួន ០៣ប័ណ្ណ
- ប័ណ្ណដីសរុបចំនួន ០៩ប័ណ្ណ
- សហកម្មសិទ្ធិសរុបចំនួន ០០ប័ណ្ណ
- បង្រួមក្បាលដីសរុបចំនួន ០៣ប័ណ្ណ

### ២. ការងារសំណង់

**ច្រកសាលាខណ្ឌ**

| | | | |
|---|---|---|---|
| - សំណង់ថ្មីមានច្បាប់បានចំនួន | ០៣ | -សំណង់ជួសជុលមានច្បាប់បានចំនួន | ០៥ |
| - សំណង់ថ្មីគ្មានច្បាប់បានចំនួន | ០០ | -សំណង់ជួសជុលគ្មានច្បាប់បានចំនួន | ០០ |
| - សំណង់ថ្មីខុសប្លង់បានចំនួន | ០០ | -សំណង់ជួសជុលខុសប្លង់ចំនួន | ០០ |

ប្រកសាលាក្រុង

- សំណង់ថ្មីមានច្បាប់បានចំនួន ០០ -សំណង់ជួសជុលមានច្បាប់បានចំនួន ០០
- សំណង់ថ្មីគ្មានច្បាប់បានចំនួន ០០ -សំណង់ជួសជុលគ្មានច្បាប់បានចំនួន ០០
- សំណង់ថ្មីខុសប្លង់បានចំនួន ០០ -សំណង់ជួសជុលខុសប្លង់ចំនួន ០០

ប្រកក្រសួង

- សំណង់ថ្មីមានច្បាប់បានចំនួន ០០ -សំណង់ជួសជុលមានច្បាប់បានចំនួន ០០
- សំណង់ថ្មីគ្មានច្បាប់បានចំនួន ០០ -សំណង់ជួសជុលគ្មានច្បាប់បានចំនួន ០០
- សំណង់ថ្មីខុសប្លង់បានចំនួន ០០ -សំណង់ជួសជុលខុសប្លង់ចំនួន ០០
- ស្នើសុំជួសជុលនៅមន្ទីរបានចំនួន ០០

## ២.៤. រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

## ២.៤.១.ការខាអនុវត្តគោលនយោបាយ "ភូមិ-សង្កាត់ មានសុវត្ថិភាព"

### ១. សភាពការណ៍សន្តិសុខ

ក.សភាពការណ៍សន្តិសុខនយោបាយ៖ គ្មាន

ខ.សភាពការណ៍សន្តិសុខសង្គម៖

- ក្រសួងសុខាភិបាលបានបញ្ជូនជនបរទេសចម្រុះជាតិសាសន៍ ដែលទើបមកពីប្រទេសនានា ចំនួន ២១៨លើក សរុប ៨,៩៧១នាក់ ស្រីចំនួន ២,៣៦៧នាក់ ឱ្យមកស្នាក់នៅដើម្បីធ្វើចត្តាឡីស័កនៅសណ្ឋាគារ ៧ទីតាំង ក្នុងនោះមានអ្នកតេស្តវិជ្ជមានមេរោគកូវីដ-១៩ ចំនួន ១៥នាក់ ស្រីចំនួន ០៩នាក់។
- ក្រសួងសុខាភិបាល បានរៀបចំធ្វើការយកសំណាកអ្នកសង្ស័យជាប់ពាក់ព័ន្ធ និងអ្នកវិជ្ជមានជម្ងឺកូវីដ១៩ ទីតាំងក្នុងខណ្ឌបឹងកេងកង ក្នុងព្រឹត្តិការណ៍ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ សរុបចំនួន ៣១២ទីតាំង៖
  - ជាលទ្ធផលបានយកសំណាក សរុបចំនួន ១៤,៤៤១នាក់ ស្រីចំនួន ៣,០១៦នាក់។
  - បានរកឃើញអ្នកមានវិជ្ជមានចំនួន ១,៧៦៥នាក់ ស្រី៧៤៥នាក់ (ជនជាតិខ្មែរ ១,៧១៣នាក់ ស្រី៧២៥នាក់) (ជនបរទេស ៥៤នាក់ ស្រី ១៧នាក់)។

• អង្គការសង្គមស៊ីវិល៖ ៧៣លើក

- អង្គការសង្គមស៊ីវិលបានប្រជុំចំនួន ៧៣លើក (មាន ២៣អង្គការ) មានមនុស្សចូលរួមសរុបចំនួន ១,៧៧៦នាក់ សង្កាត់បឹងកេងកងទី៣ ចំនួន ៦៦លើក , សង្កាត់អូឡាំពិក ចំនួន ០៧លើក។

• សភាពការណ៍ប្រជាពលរដ្ឋ និងសាសនា៖ ០៤លើក

- ក្នុងសង្កាត់បឹងកេងកងទី១ ប្រជាពលរដ្ឋមានការជួបជុំ និងប្រមូលផ្តុំធ្វើកូដកម្មទាមទារមានចំនួន ០៤លើក។
- ចាប់ពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រជាពលរដ្ឋដែលបានមកចុះឈ្មោះបោះឆ្នោតក្នុងមូលដ្ឋានខណ្ឌបឹងកេងកង មានសរុបចំនួន ៨១៩នាក់ (ស្រី៤៤៧នាក់)។

• សភាពការណ៍ការងាររោងចក្រសហគ្រាសក្រុមហ៊ុន៖ ០៥លើក

- មានការប្រមូលផ្តុំធ្វើកូដកម្មទាមទារផ្នែកកម្មករ បុគ្គលិកក្រុមហ៊ុន មានចំនួន ០៥លើក។ សង្កាត់បឹងកេងកងទី០១ ចំនួន ០១លើក សង្កាត់ទួលស្វាយព្រៃទី០១ ចំនួន ០១លើក សង្កាត់ទួលស្វាយព្រៃទី០២ ចំនួន ០១លើក សង្កាត់បឹងកេងកងទី០៣ ចំនួន ០២លើក ។

• សភាពការណ៍សន្តិសុខ៖ គ្មាន

### ២. សភាពការណ៍បទល្មើសព្រហ្មទណ្ឌ៖

- ការងារបង្រ្កាបបទល្មើសព្រហ្មទណ្ឌ៖ សរុប ៤១លើក ឃាត់ខ្លួនជនសង្ស័យ ៦០នាក់ប្រុស,ស្រី ០៣នាក់

### ក. បទល្មើសឧក្រិដ្ឋ ៖

- ៥លើក ឃាត់ខ្លួនសរុប ០៨នាក់។

**ខ.<u>បទល្មើសមជ្ឈឹម</u>៖**

- ៣៦លើក ឃាត់ខ្លួនសរុប ៥២នាក់ ស្រី០៣នាក់។

**៣ .<u>ការងារបង្រ្កាបគ្រឿងញៀន</u>៖** ០២លើក

- សរុប ១០លើក ឃាត់ខ្លួនសរុប ១៧នាក់ ស្រី០១នាក់។

**៤.<u>ការងារបង្រ្កាបបទល្មើសជួញដូរមនុស្ស ផ្លូវភេទ អនាចារនិងអំពើហិង្សាក្នុងគ្រួសារ</u>៖**

- គ្មាន

**៥.<u>ការងារបង្រ្កាបក្មេងទំនើង</u>៖**

- ១៧លើក ឃាត់ខ្លួន ៣១នាក់ ស្រី០២នាក់។

**៦.<u>ការងារបង្រ្កាបការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់និងបទល្មើសគ្រប់ប្រភេទ</u>៖**

- ០១លើក ក្នុងសង្កាត់បឹងកេងកងទី២។

**៧.<u>សភាពការណ៍គ្រោះថ្នាក់សង្គម និងវិធានការដោះស្រាយ</u> ៖**

- <u>គ្រោះថ្នាក់ចរាចរណ៍</u>៖ ៨៣លើក របួសស្រាល ៣១នាក់ របួសធ្ងន់ ៧១នាក់ ស្លាប់ ០២នាក់។
- <u>គ្រោះថ្នាក់សង្គម</u>៖ ០១លើក បាក់ស្រុតផ្ទះបណ្ដាលមកពីការដ្ឋានបុកគ្រឹះ ក្នុងសង្កាត់បឹងកេងកងទី១។
- <u>គ្រោះថ្នាក់ឧប្បទ្ទវហេតុផ្សេងៗ</u>៖ ៥០លើក។

**៨.<u>លទ្ធផលកិច្ចប្រតិបត្តិការ</u>៖**

<u>**ការងារការពារ**</u>៖ ១៩៨លើក

- កម្លាំងចុះការពារក្បួន **ព្រះករុណា** ចំនួន ០២លើក លើផ្លូវព្រះនរោត្តម, ផ្លូវមុនីវង្ស, ផ្លូវម៉ៅសេទុង។
- កម្លាំងចុះការពារក្បួន **សម្ដេចនាយករដ្ឋមន្ត្រី** ចំនួន ៥៣លើក លើផ្លូវព្រះនរោត្តម, ផ្លូវព្រះមុនីវង្ស, ផ្លូវម៉ៅសេទុង។
- កម្លាំងចុះការពារក្បួន **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី** ចំនួន ៤១លើក ផ្លូវព្រះសីហនុ។
- កម្លាំងចុះការពារក្បួន **សម្ដេច ហេង សំរិន** ចំនួន ២២លើក ផ្លូវព្រះនរោត្តម, ផ្លូវលេខ ២៧១។
- កម្លាំងចុះការពារក្បួន **សម្ដេច ស ខេង** ចំនួន ៨២លើក ផ្លូវព្រះនរោត្តម។
- កម្លាំងការពារគណៈប្រតិភូអន្តរជាតិ គោលដៅយូនីស្កូ (ជាប្រចាំ)។

<u>**ការងារចុះត្រួតពិនិត្យ និងរឹតបន្តឹងច្បាប់ចរាចរណ៍ផ្លូវគោក(ពេលថ្ងៃ)**</u>៖ បានចំនួន ៤៩៥លើក ៧គោលដៅ

- ឃាត់យានយន្តល្មើសច្បាប់ចរាចរណ៍សរុប ៥,៦៤៨គ្រឿង៖
- ឃាត់រថយន្ត ១,៣៧២គ្រឿង៖
  - មិនពាក់ខ្សែក្រវ៉ាត់ ៨៥១នាក់
  - ប្រើប្រាស់ទូរសព្ទ ៥១៩នាក់
  - បើកបរហួសល្បឿន ០នាក់
  - មិនគោរពផ្លាកសញ្ញា ០២គ្រឿង
- ឃាត់ម៉ូតូសរុបចំនួន ៤,២៧៦គ្រឿង៖
  - បើកបរមិនពាក់មួកសុវត្ថិភាព ៣,៩៧០នាក់
  - ប្រើប្រាស់ទូរសព្ទ ៣០០នាក់
  - ម៉ូតូគ្មានស្លាកលេខ ០៥គ្រឿង
  - មិនគោរពផ្លាកសញ្ញា ០១គ្រឿង
- លទ្ធផលធ្វើការផាកពិន័យនៅអធិការដ្ឋានខណ្ឌសរុបអ្នកបើកបរ ៥,៦៤៨នាក់។

**ការងាររឹតបណ្តឹងច្បាប់ចរាចរណ៍ផ្លូវគោក ត្រួតពិនិត្យជាតិអាល់កុល និងអាវុធជាតិផ្ទុះ(ពេលយប់)៖ ១៨៨លើក**

- ឃាត់យានយន្តឆ្លងកាត់គោលដៅត្រួតពិនិត្យសរុបចំនួន ៩,០៩៤គ្រឿង៖
- ឃាត់រថយន្តចំនួន ៤៥៨ គ្រឿង ៖
  - មិនពាក់ខ្សែក្រវ៉ាត់ ៣៤៧ នាក់
  - ប្រើប្រាស់ទូរសព្ទ ៩៤នាក់
  - គ្មានប័ណ្ណបើកបរចំនួន ០១នាក់
  - មិនគោរពស្លាកសញ្ញា ០១គ្រឿង
  - រថយន្តគ្មានស្លាកលេខ ០២គ្រឿង
  - អ្នកបើកបរមានជាតិស្រវឹង ០៨នាក់ បញ្ជូនទៅចរាចរណ៍ក្រុង ០៥នាក់។
- ឃាត់ម៉ូតូសរុបចំនួន ៨,៦៣៦គ្រឿង៖
  - បើកបរមិនពាក់មួកសុវត្ថិភាព ៨,៤៥៨នាក់
  - បើកម៉ូតូប្រើប្រាសទូរសព្ទ ៦៧នាក់
  - គ្មានស្លាកលេខ ១៤គ្រឿង
  - មិនគោរពស្លាកសញ្ញាចរាចរណ៍ ៣៥នាក់
  - ឃាត់អ្នកប្រើប្រាស់ទូរស័ព្ទ ៦៧នាក់
  - គ្មានស្លាកលេខ១៤គ្រឿង មិនគោរពសញ្ញា ៣៥គ្រឿង។
  - ឃាត់អ្នកបើកបរមានជាតិស្រវឹងចំនួន ៣៥នាក់
  - បញ្ជូនទៅចរាចរណ៍ក្រុង ២៧នាក់។
- ធ្វើការផាកពិន័យនៅអធិការដ្ឋានខណ្ឌសរុបអ្នកបើកបរ ៩,០៩៤នាក់។
- សហការត្រួតពិនិត្យអាវុធជាតិផ្ទុះ ជាមួយគណៈបញ្ជាការឯកភាពខណ្ឌបឹងកេងកង ចំនួន ៣៣លើក ០៣គោលដៅ
- យានយន្តឆ្លងកាត់ ៣,៤៩៣គ្រឿង រថយន្តចំនួន ១,៥៤៧គ្រឿង បានរកឃើញអាវុធឆ្លងកាត់ចំនួន ០ដើម។

**ការគ្រប់គ្រងជនបរទេស៖**

- ការស្នាក់នៅរបស់ជនបរទេសរយៈពេលវែងសរុប ១,៤៥៨ នាក់ ស្រី ៤៩៩នាក់ មាន ៣០ សញ្ជាតិ។
- ការស្នាកនៅរបស់ជនបរទេសរយៈពេលខ្លី សរុប ១,៧៦២ នាក់ស្រី ៥១៩ មាន២៧ សញ្ជាតិ។

**ការងារវេទិកាសាធារណៈ**៖ ១០លើក លើ៧ សង្កាត់ មានប្រជាពលរដ្ឋចូលរួម ២៥០ នាក់ស្រី១៦៣។

**ការងារគ្រប់គ្រងស្ថិតិប្រជាជន៖**

- កម្លាំងផ្នែកស្ថិតិសហការជាមួយប៉ុស្តិ៍សង្កាត់ទាំង៧ ដឹកនាំដោយលោកអធិការ បានចុះផ្តល់សៀវភៅស្នាក់នៅ (ក២) និងសៀវភៅគ្រួសារ (ក៤) ពីខណ្ឌចំការមន មកខណ្ឌបឹងកេងកង បានចំនួន (ក២) ២៤០គ្រួសារ និង (ក៤) ៣៤២គ្រួសារ។

**ការងារបំពេញបែបបទថតធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាជន៖**

- អធិការនគរបាលខណ្ឌបឹងកេងកង ក្នុងខែនេះបានបំពេញបែបបទថតធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ បានចំនួន ៤០៩នាក់ ប្រុស ២២២នាក់។

**៩. សភាពការណ៍គ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងវិធានការដោះស្រាយ៖**

- ខណ្ឌបឹងកេងកងមិនទាន់រកឃើញមានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅឡើយទេ។

**១០.សភាពការណ៍ទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព៖**

- គ្មាន

**១១.សភាពការណ៍ទប់ស្កាត់ ការត្រួតពិនិត្យខុសច្បាប់៖**

- ក្នុងភូមិសាស្ត្រខណ្ឌបឹងកេងកង ពុំមានការដាក់ប៉ុស្តិ៍ត្រួតពិនិត្យខុសច្បាប់ទេ។

## ផ្នែកទី៤
## បញ្ហាប្រឈម និងដំណោះស្រាយ

### ៣.១.រដ្ឋបាលខណ្ឌ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១).**ការងាររដ្ឋបាល និងបុគ្គលិក**(គ្មាន) | | |
| ២).**ការងារអន្តរវិស័យ** (គ្មាន) | | |
| ៣).**ការងារផែនការស្ថិតិ** (គ្មាន) | | |
| ៤).**ការងារច្រកចេញចូលតែមួយ** (គ្មាន) | | |
| ៥).**ការងារលទ្ធកម្ម** (គ្មាន) | | |

### ៣.២.ការិយាល័យ អង្គភាពជំនាញៈ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១).**ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍**(គ្មាន) | | |
| ២). **ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ** | | |
| ១ | នៅមិនទាន់មានការចូលរួមពីប្រជាពលរដ្ឋ បានល្អប្រសើរនៅឡើយ លើបញ្ហាញែក ទុកដាក់ និងវេចខ្ចប់សំរាម។ | ចុះអប់រំណែនាំ ដល់ប្រជាពលរដ្ឋតាមខ្នងផ្ទះ សាលារៀនសហគមន៍ ឱ្យចេះញែកនិងវេចខ្ចប់សំរាមឱ្យបានត្រឹមត្រូវតាមពេលវេលាកំណត់។ |
| ២ | នៅមានការបញ្ចេញសំរាមខុសពេលវេលា និងការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់ដោយអ្នកលក់ដូរចល័តតាមរទេះ និងបញ្ហាអេតចាយហែកចង់សំរាមបណ្តាលឱ្យមានសំរាមរាយប៉ាយ។ | សហកាជាមួយភ្នាក់ងារអនាម័យបរិស្ថានសង្កាត់ត្រួតពិនិត្យមើលតាមដេប៉ូសំរាមក្នុងសង្កាត់រៀងៗខ្លួន។ |
| ៣ | នៅមានបញ្ហាសំរាមតាមច្រកផ្លូវវៀងហែម និងផ្ទះជាន់លើ។ | សហការជាមួយ ប្រធានសំអាតប្រចាំខណ្ឌជួយជម្រុញបន្ថែម ដល់ការប្រមូលសំរាមរបស់ក្រុមហ៊ុន។ |
| ៣). **ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន** (គ្មាន) | | |
| ៤). **ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម** | | |
| | ❖ ការងារសុខាភិបាល | |
| ១ | -ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត។ | -សូមមូលដ្ឋានជួយចូលរួមអប់រំ ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋមកទទួលសេវារដ្ឋ ដែលមានតម្លៃថោក ដើម្បីជួយកាត់បន្ថយភាពក្រីក្រ។ |
| ២ | -ការទំនាក់ទំនងនៅកន្លែងខ្លះមានកម្រិត។ | -អប់រំផ្សព្វផ្សាយដល់ សិស្សានុសិស្សស្តីពីអនាម័យស្អាតបី អនាម័យលំនៅដ្ឋាន។ |
| ៣ | -ពុំមានដៃគូជួយគាំទ្រ។ | -ដើម្បីលើស្ទួយសុខភាពស្ត្រី និងកុមារតម្រូវឱ្យមានការចូលរួមគ្រប់ផ្នែកយ៉ាងសកម្ម។ |
| ៥). **ការិយាល័យអប់រំ យុវជន និងកីឡា**(គ្មាន) | | |
| ៦).**ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល** (គ្មាន) | | |

# ផ្នែកទី៥
## ទិសដៅការងារខែបន្ទាប់

| ល.រ | សកម្មភាពអាទិភាព | សប្តាហ៍ | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| **៤.១. ការងារក្រុមប្រឹក្សាខណ្ឌ និងគណៈកម្មាធិការនានា** | | | | | |
| ៤.១.១ | រៀបចំកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង អាណត្តិទី៣ | | | | X |
| ៤.១.២ | រៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង អាណត្តិទី៣ ក្នុងករណីមានការងារចាំបាច់បន្ទាន់ | X | X | X | X |
| ៤.១.៣ | រៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការនានា | X | X | X | X |
| ៤.១.៤ | រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង | | | | |
| **៤.២. ការងារគណៈអភិបាលខណ្ឌ** | | | | | |
| ៤.២.១ | ប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | | X | | |
| ៤.២.២ | ប្រជុំប្រចាំខែរបស់គណៈអភិបាល | | | | X |
| ៤.២.៣ | រៀបចំវេទិកាសាធារណៈអនុវត្តគោលនយោបាយ ភូមិ-សង្កាត់ មានសុវត្ថិភាព | X | | | |
| ៤.២.៤ | បន្តរៀបចំសណ្តាប់ធ្នាប់តាមទីសាធារណៈ និងផ្លូវសំខាន់ៗឱ្យបានល្អ | X | X | X | X |
| ៤.២.៥ | អនុវត្តការងារការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ | X | X | X | X |
| ៤.២.៦ | បន្តតាមដានព្រឹត្តិការណ៍សំខាន់ៗ និងធ្វើរបាយការណ៍ជូនសាលារាជធានីភ្នំពេញ | X | X | X | X |
| ៤.២.៧ | ចុះពិនិត្យការដ្ឋានសំណង់ ទប់ស្កាត់សំណង់គ្មានច្បាប់អនុញ្ញាត និងសំណង់ខុសប្លង់ | X | X | X | X |
| ៤.២.៨ | ចុះជម្រុញមូលដ្ឋានសិប្បកម្មផលិតស្បៀងអាហារ ភេសជ្ជៈ អំពីគុណភាពផលិតផល | X | X | X | X |
| ៤.២.៩ | បន្តចុះត្រួតពិនិត្យអាជីវកម្មហ្គាស អុកស៊ីហ្សែន ដោយជម្រុញឱ្យសុំច្បាប់អនុញ្ញាត និងណែនាំឱ្យ រៀបចំទុកដាក់ប្រកបដោយសុវត្ថិភាពត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស | X | X | X | X |
| ៤.២.១០ | សហការជាមួយមន្ទីរទេសចរណ៍រាជធានីភ្នំពេញ បើកវគ្គអប់រំផ្សព្វផ្សាយច្បាប់ ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ដើម្បីជម្រុញការអនុវត្តច្បាប់ ស្តីពីទេសចរណ៍ក្នុងការពង្រឹងគ្រប់គ្រងមូលដ្ឋានអាជីវកម្មទេសចរណ៍ | X | X | X | X |
| ៤.២.១១ | បន្តចុះពិនិត្យ និងជម្រុញម្ចាស់អាជីវកម្មដ្ឋានទេសចរណ៍ដែលអស់សុពលភាព និងកើតថ្មីឱ្យចូល មកបំពេញបែបបទ ដើម្បីសុំអាជ្ញាប័ណ្ណទេសចរណ៍ប្រកបអាជីវកម្មឱ្យបានត្រឹមត្រូវ | X | X | X | X |
| ៤.២.១២ | បន្តជម្រុញនិងណែនាំម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ឱ្យកត់ត្រាអត្តសញ្ញាណភ្ញៀវស្នាក់នៅប្រចាំថ្ងៃសំដៅ ពង្រឹងការគ្រប់គ្រងស្ថិតិភ្ញៀវឱ្យបានច្បាស់លាស់ និងការពារសន្តិសុខ សុវត្ថិភាពភ្ញៀវទេចរណ៍ជាតិ-អន្តរជាតិ | X | X | X | X |
| ៤.២.១៣ | សហការជាមួយមន្ទីរសុខាភិបាលចុះពិនិត្យឱសថស្ថាន ឱសថស្ថានរង ដើម្បីកែលម្អចំណុចខុសឆ្គង លុបបំបាត់ ឱសថខុសច្បាប់ដែលដាក់លក់ | X | X | X | X |
| ៤.២.១៤ | បន្តជម្រុញអ្នកបើកសេវាសុខាភិបាលឯកជនថ្មី ឱ្យមកសុំច្បាប់អនុញ្ញាត | X | X | X | X |
| ៤.២.១៥ | សហការជាមួយមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ចុះអប់រំអំពីជម្ងឺអេដស៍ដល់ស្ត្រីបម្រើការងារក្នុងសេវាកំសាន្តនានា | X | X | X | X |
| ៤.២.១៦ | បន្តកាត់បន្ថយជនអនាថាតាមចិញ្ចើមផ្លូវ និងទីសាធារណៈ | X | X | X | X |
| ៤.២.១៧ | បន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ | X | X | X | X |

| | | | | | |
|---|---|---|---|---|---|
| ៤.២.១៨ | យកចិត្តទុកដាក់គ្រប់គ្រងតាមវត្តអារាម និងត្រួតពិនិត្យសកម្មភាពពាហិរសាសនា | X | X | X | X |
| ៤.២.១៩ | បន្តការងារអប់រំ និងផាកពិន័យអ្នកបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់ | X | X | X | X |
| ៤.២.២០ | ជម្រុញការងារសហការជាមួយក្រុមហ៊ុនប្រមូលសំរាម ក្នុងការប្រមូលសំរាម | X | X | X | X |
| ៤.២.២១ | ពង្រឹងការគ្រប់គ្រងអាជីវកម្មមណ្ឌលកម្សាន្តមនុស្សពេញវ័យ | X | X | X | X |
| ៤.២.២២ | សហការជាមួយមន្ទីរការងារ ជម្រុញដល់សហគ្រាសធុនតូច និងមធ្យម ឱ្យលើកកម្ពស់លក្ខខ័ណ្ឌ ការងារនិងសន្តិសុខ សុវត្ថិភាពការងាររបស់កម្មករនិយោជិតតាមសហគ្រាស គ្រឹះស្ថាន | X | X | X | X |
| ៤.២.២៣ | សហការជាមួយមន្ទីរការងារ ពង្រឹងការគ្រប់គ្រង ស្ថិតិសាលាបណ្តុះបណ្តាលវិជ្ជាជីវៈឯកជន ដែលមានកម្មវិធីបណ្តុះបណ្តាល ៣ខែ ចុះឱ្យបានច្បាស់ | X | X | X | X |
| ៤.២.២៤ | សហកាជាមួយមន្ទីរការងារ ជម្រុញម្ចាស់សហគ្រាស ដែលមានកម្មករនិយោជិតចាប់ពី ៦០ ដល់១០០នាក់ ត្រូវបំពេញកាតព្វកិច្ច ហ្វឹកហ្វឺនកូនជាងតាមការកំណត់របស់ច្បាប់ ស្តីពីការងារ | X | X | X | X |
| ៤.២.២៥ | សហការជាមួយមន្ទីរបរិស្ថានរាជធានីភ្នំពេញ ត្រួតពិនិត្យការបំពុលបរិស្ថាន | X | X | X | X |
| ៤.២.២៦ | តាមដានការអនុវត្តគម្រោងមូលនិធិសង្កាត់ | X | X | X | X |
| ៤.២.២៧ | បន្តចុះផ្សព្វផ្សាយវិធានការការពារជម្ងឺកូវីដ១៩ និងចែកជូនសម្ភារៈការពារជម្ងឺកូវីដ ១៩ ព្រមទាំងគ្រឿងឧបភោគបរិភោគ ជូនដល់ប្រជាពលរដ្ឋក្រីក្រក្នុងមូលដ្ឋានខណ្ឌ | X | X | X | X |
| ៤.២.២៨ | អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីនិតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ កំឡុងពេលកូវីដ១៩ | X | X | X | X |
| ៤.២.២៩ | បន្តតាមដានកម្មវិធីឧបត្ថម្ភបន្ថែមពីរាជរដ្ឋាភិបាលចំពោះស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ (ប.ស.ស) | X | X | X | X |
| ៤.២.៣០ | បន្តដោះស្រាយបញ្ហាអគ្រានុកូលដ្ឋាន (ការកោសលុប) | X | X | X | X |
| ៤.២.៣១ | តាមដានការអនុវត្តការងាររបស់សង្កាត់ដែលចុះធ្វើអនាម័យរៀងរាល់សប្តាហ៍ | X | X | X | X |
| ៤.២.៣២ | រៀបចំយុទ្ធនាការចាក់វ៉ាក់សាំងដូសទី៣ ដល់កុមារអាយុ១២ឆ្នាំ ដល់១៨ឆ្នាំ | X | | | |

# ផ្នែកទី៦
# សេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ ២០២១ កន្លងមកនេះ ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានីភ្នំពេញ ខណ្ឌបឹងកេងកង បានបន្តខិតខំជំនះ ពុះពាររាល់ការលំបាកស្មុគស្មាញ និងអនុវត្តគ្រប់វិធានការ ពិសេសការងារចាត់តាំងគោលនយោបាយភូមិ-សង្កាត់មានសុវត្ថិភាពបានកាន់តែល្អ ទ្រោលបានសភាពការណ៍ សន្តិសុខនៅក្នុងខណ្ឌ ក្នុងនោះគួរឱ្យកត់សំគាល់សកម្មភាពបង្កចលាចលនយោបាយ និងអំពើភេរវកម្ម ត្រូវបានទប់ស្កាត់មិនឱ្យកើតមានអំពើប្លន់ប្រដាប់អាវុធ អំពើអានាចារ្យ អំពើអបាយមុខបង្កដោយក្រុមក្មេងទំនើង ល្បែងស៊ីសង និងគ្រឿងញៀន ត្រូវបានកាត់បន្ថយ ផ្តល់នូវភាពកក់ក្តៅដល់ប្រជាពលរដ្ឋវិនិយោគិន និងភ្ញៀវបរទេស ម៉្យាងទៀតបានបន្តខិតខំផ្សព្វផ្សាយអប់រំ និងរឹតបណ្តឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកដើម្បីឱ្យអ្នកបើកបរយានយន្តគ្រប់ប្រភេទ គោរព និងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានត្រឹមត្រូវ ព្រមទាំងខិតខំកសាងនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅតាមតំបន់ដែលមាន និងរួមចំណែកធ្វើឱ្យករណីគ្រោះថ្នាក់ និងករណីកកស្ទះចរាចរណ៍ត្រូវបានកាត់បន្ថយ។ បានខិតខំរៀបចំផែនការសកម្មភាពលម្អិត សន្ទស្សន៍ និងប្រតិទិនការងារតាមសង្កាត់នីមួយៗ ដើម្បីជម្រុញការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិ ខ្មែរជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ទន្ទឹមនឹងលទ្ធផល ដែលសម្រេចបានជាវិជ្ជមានខាងលើ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវប្រមូលផ្តុំដោះស្រាយឱ្យបានល្អនាពេលខាងមុខជាអាទិ៍៖

១.បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ក្មេងទំនើង និងគ្រឿងញៀននៅតែជាចំណុចក្តៅរបស់ខណ្ឌបឹងកេងកង។

២.បញ្ហាចរាចរណ៍ និងសណ្តាប់ធ្នាប់តាមដងផ្លូវនៅតែចោទជាបញ្ហាអាស្រ័យ ដោយកំណើនយ៉ាងឆាប់រហ័សនៃមធ្យោបាយយានយន្ត និងប្រជាពលរដ្ឋ។

៣.បញ្ហាគ្រោះអគ្គីភ័យនៅតែជាកង្វល់ដ៏ធំរបស់អាជ្ញាធរខណ្ឌ និងប្រជាពលរដ្ឋ។

៤.បញ្ហាសំរាមក៏នៅតែជាបញ្ហាចោទ ធ្វើឱ្យប្រជាពលរដ្ឋថ្នាំងថ្នាក់ចំពោះក្រុមហ៊ុនស៊ិនទ្រី។

៥.បញ្ហាការរីករាលដាល នៃជម្ងឺកូវីដ១៩ ជាបញ្ហាដែលរដ្ឋបាលខណ្ឌបឹងកេងកងនៅតែបន្តយកចិត្តទុកដាក់ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងពីវិធានការបង្ការ និងការពាររហូតជម្ងឺនេះរលាយសាបសូន្យវិញ។

របាយការណ៍ប្រចាំឆ្នាំ២០២១ និងទិសដៅការងារខែមករា ឆ្នាំ២០២២ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌបឹងកេងកង ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី៣១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង នាថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

បឹងកេងកង, ថ្ងៃទី ខែ ឆ្នាំ២០២១

**អភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង**

ចម្លងជូន៖

-សាលារាជធានីភ្នំពេញ

-ក្រុមប្រឹក្សារាជធានីភ្នំពេញ

-ក្រុមប្រឹក្សាខណ្ឌបឹងកេងកង

*"ដើម្បីជូនជ្រាប"*

-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៣.
# អនុក្រឹត្យស្តីពីការបង្កើតខណ្ឌបឹងកេងកង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន០៧ ពីខណ្ឌចំការមន នៃរាជធានីភ្នំពេញគឺ សង្កាត់បឹងកេងកងទី១ សង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់អូឡាំពិច សង្កាត់ទំនប់ទឹក សង្កាត់ទួលស្វាយព្រៃទី១ និងសង្កាត់ទួលស្វាយព្រៃទី២។

ព្រំប្រទល់រដ្ឋបាលខណ្ឌបឹងកេងកង ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានផ្ទេរទីតាំងសាលាខណ្ឌចំការមនដែលស្ថិតក្នុងសង្កាត់បឹងកេងកងទី៣ ទៅឲ្យសាលាខណ្ឌបឹងកេងកង។

ទីតាំងសាលាខណ្ឌចំការមន ត្រូវស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខណ្ឌបឹងកេងកង ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌចំការមន ក្រុមប្រឹក្សាខណ្ឌបឹងកេងកង គណៈអភិបាលខណ្ឌបឹងកេងកង និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែមករា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៤.
# រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌបឹងកេងកង

# រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌបឹងកេងកង



# ឧបសម្ព័ន្ធ ៥.
# អនុក្រឹត្យលេខ ៦៧៧ អនក្រ.តត ស្តីពីការ ទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខណ្ឌបឹងកេងកង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ជរដ្ឋាភិបាលកម្ពុជា

ខ:...៦៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៧៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការកំណត់ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣

- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៣៧៧ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

ប្រការ ១.-

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ ក្នុងអាណត្តិទី៣ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | លោក គឹម ឈុនអ៊ី | ១១/០២/១៩៥៤ | ជាប្រធានក្រុមប្រឹក្សាខណ្ឌ |
| ២- | លោក នៅ ភារុន | ១០/០៩/១៩៥១ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៣- | លោក ទិន សុខសន្តិរ័ត្ន | ០១/០៤/១៩៦៩ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៤- | លោក ស៊ុន ផាត | ១៤/០១/១៩៤៦ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៥- | លោកស្រី ម៉ែន សុភាទី | ១១/០៩/១៩៥៨ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៦- | លោក ប៉ាង សេង | ០១/០៨/១៩៥២ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៧- | លោក ហ៊ីន សារឿន | ០៧/០៤/១៩៥២ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៨- | លោកស្រី ប៉ា សុខា | ០៩/០៤/១៩៥១ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៩- | លោក ឧស់ សំអាន | ០៤/១០/១៩៨៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១០- | លោក រស់ សុផារិទ្ធិ | ០៥/០៨/១៩៧៣ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១១- | លោក ចិន ទិបុល | ០២/០៦/១៩៩០ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១២- | លោក ចាន់ ផល | ០៩/០២/១៩៦១ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៣- | លោក ស៊ឹម ច័ន្ទដារ៉ា | ១៧/០៧/១៩៨៩ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៤- | លោក ឌី ចន្ទូ | ០២/០២/១៩៨៥ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៥- | លោក ខៀវ សុផាន់ណា | ០៥/០៣/១៩៦៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៦- | លោក ណុប ម៉ុនហ៊ី | ០១/១២/១៩៦៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៧- | លោក ហែម រតនា | ១៣/០២/១៩៩១ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |

ប្រការ ២.-

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ ត្រូវអនុវត្តតាមវិជ្ជាជីវៈ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៨កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៦.
# សម្ភាសជាមួយប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កម្រងសំនួរ

នាងខ្ញុំជានិស្សិតឆ្នាំទី៤ ឆមាសទី២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញរដ្ឋបាលសាធារណៈ។ នាងខ្ញុំកំពុងសិក្សាស្រាវជ្រាវទាក់ទងនិងការគ្រប់គ្រងរដ្ឋបាលនៅក្នុងវិស័យសាធារណៈលើប្រធានបទ «**ការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកង ក្នុងឆ្នាំ២០២១**» ក្នុងគោលបំណង ដើម្បីពង្រីកនូវចំណេះដឹងលើការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសគឺរដ្ឋបាលថ្នាក់ខណ្ឌនេះតែម្តង។

នាងខ្ញុំសង្ឃឹមថា លោកប្រធានក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ ប្រធានការិយាល័យ និងអង្គភាពចំណុះ រួមទាំងមន្ត្រី មន្ត្រីជាប់កិច្ចសន្យា ដែលបំពេញការងារនៅក្នុងខណ្ឌបឹងកេងកងដោយបានអញ្ជើញចូលរួមឆ្លើយសំនួរជាមួយនាងខ្ញុំដោយក្តីអនុគ្រោះ។

នាងខ្ញុំ សូមថ្លែងអំណរគុណ ចំពោះការចូលរួមផ្តល់នូវចម្លើយ ដ៏មានសារៈសំខាន់អំពីសំណាក់លោកប្រធានក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ ប្រធានការិយាល័យ អង្គភាពរួមទាំងមន្ត្រី ដែលបំពេញការងារនៅក្នុងសាលាខណ្ឌបឹងកេងកង តាមរយៈការឆ្លើយសំនួរដូចខាងក្រោមនេះ៖

សម្ភាសជាមួយ **ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក។**

១. តើស្ថានភាពភូមិសាស្ត្រ និងស្ថានភាពប្រជាសាស្ត្រ ដែលស្ថិតនៅក្នុងខណ្ឌបឹងកេងកងមានលក្ខណៈដូចម្តេច?

(ផ្ទៃដី សង្កាត់ចំណុះ ព្រំប្រទល់ ស្ថានភាពសេដ្ឋកិច្ច)

.....ស្ថានភាពភូមិសាស្ត្រ.....និងស្ថានភាពប្រជាសាស្ត្រដែលស្ថិតនៅក្នុងខណ្ឌ.....
បឹងកេងកង.....................................................................................

.....ខណ្ឌបឹងកេងកង...គឺជាខណ្ឌមួយស្ថិតនៅក្នុងចំណោមខណ្ឌទាំង..១៤......
នៃរាជធានីភ្នំពេញ.......[illegible]......
[illegible]......ខណ្ឌ..៧..សង្កាត់........

ខាងកើតជាប់សង្កាត់ ខណ្ឌចំការមន ខាងត្បូងជាប់សង្កាត់ ខណ្ឌមានជ័យ និងមួយផ្នែកខាងជើងជាប់សង្កាត់ខណ្ឌចំការមន ខាងលិចជាប់សង្កាត់ ខណ្ឌទួលគោក និងមានប្រវែងបណ្តោយប្រមាណ ៥៤,០៥៨ ម៉ែត្រ ទទឹងប្រមាណ ២៣,៥២៨ ម៉ែត្រ ។

២. តើសមាសភាពរបស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកងមានសមាជិកប៉ុន្មានរូប? មានឈ្មោះអ្វីខ្លះ?

សមាសភាពរបស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកងមាន ១៧ រូប ដូចជា៖

១. លោក តឹម ឈុនផល

២. លោក ឆៅ ភារិន

៣. លោក ឃិន សុខសិរីវ៉ុន

៤. លោក ស៊ុន ភ័ត្ត

៥. លោកស្រី ម៉ីន សុភាវី

៦. លោក ហ៊ាង ចេង

៧. លោក ហ៊ិន សារឿន

៨. លោកស្រី ញ៉ី សុខា

៩. លោក ម៉ន សំណាង

១០. លោក រស់ សុភារិទ្ធ

១១. លោក ង៉ែន វិបុល

១២. លោក ចន់ ម៉ាល

១៣. លោក ស៊ឹម ច័ន្ទសោភា

១៤. លោក ទ្រី ចន្ធូ

១៥. លោក ឈៀង សុភ័ន្តតា

១៦. លោក សាយ ប៊ុនហ៊ី

១.៧ ...ទេសោក ...ស៊ីម ...ចេះ

៣. ក្នុងសាលាបាលខណ្ឌបឹងកេងកងមានគណៈកម្មាធិការ និងគណៈកម្មការចំនួនប៉ុន្មាន? អ្វីខ្លះ? ប៉ុន្មានរូប?

ក្នុងសាលាខណ្ឌបឹងកេងកង មានគណៈកម្មាធិការ និងគណៈកម្មការចំនួន ៤ គឺ ៖

– គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានសមាសភាពចំនួន ៥ រូប ដឹកនាំដោយប្រធាន ១ រូប និងអនុប្រធាន ១ រូប ព្រមទាំងសមាជិកចំនួន ៣ រូប

– គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ សមាសភាពចំនួន ៥ រូប ដឹកនាំដោយប្រធាន ១ រូប និងអនុប្រធាន ១ រូប ព្រមទាំងសមាជិកចំនួន ៣ រូប

– គណៈកម្មការលទ្ធកម្ម មានសមាសភាពចំនួន ៥ រូប ដឹកនាំដោយប្រធាន ១ រូប អនុប្រធាន ១ រូប និងសមាជិកចំនួន ៣ រូប

– គណៈបញ្ជាការឯកភាព ដើម្បីរដ្ឋបាលស្រុក ក្រុង ខណ្ឌ សមាសភាពតាមគោលការណ៍ និងរង្វង់ ១៥ មានសមាសភាពចំនួន ៥ រូប ដឹកនាំដោយប្រធាន ១ រូប អនុប្រធាន ១ រូប និងសមាជិកចំនួន ៣ រូប ។

៤. តើកិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកងមានដំណើរការយ៉ាងដូចម្ដេច? ប្រជុំមួយខែប៉ុន្មានដង?

ការប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ធ្វើការប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ (ទៀងទាត់រាល់ខែ) ក្នុងករណីមានការចាំបាច់ ក្រុមប្រឹក្សាអាចធ្វើការប្រជុំវិសាមញ្ញបាន តាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សា ឬតាមការស្នើសុំរបស់សមាជិកក្រុមប្រឹក្សា ហើយការប្រជុំត្រូវមានកំណត់ហេតុ ក្រុមប្រឹក្សាត្រូវបន្ទាន់ការណ៍ជូនមួយ ។

៥. តើការរៀបចំ និងការអនុម័តថវិកាមានលក្ខណៈយ៉ាងដូចម្តេច?

ការរៀបចំ និងការអនុម័តថវិកា ត្រូវរៀបចំឡើងតាមការណែនាំរបស់ ក្រសួង [illegible] និងដោយមានជំនួយបច្ចេកទេស [illegible] ផែនការ និងហិរញ្ញវត្ថុ [illegible] ក្រុមប្រឹក្សាខណ្ឌ [illegible] និងអនុម័ត។ [illegible] ត្រូវរៀបចំ និងអនុម័តដោយ [illegible]។

៦. តើប្រភពចំណូលរបស់សាលាខណ្ឌបឹងកេងកងមានប្រភពមកពីណាខ្លះ?

ប្រភពចំណូលរបស់សាលាខណ្ឌបឹងកេងកងមានប្រភពមកពី៖
– [illegible] និងផ្សេងៗ
២៥១,៤០២,៤០០ រៀល
– [illegible] ៣,៣២០,៥០០,០០០ រៀល

៧. តើការចំណាយរបស់រដ្ឋបាលខណ្ឌបឹងកេងកងទៅលើអ្វីខ្លះ?

ការចំណាយរបស់រដ្ឋបាលខណ្ឌបឹងកេងកង ក្នុងឆ្នាំ ២០២១ មានដូចខាងក្រោម ចំណាយលើផ្លូវ ការសាងសង់ផ្លូវបេតុងនៅក្នុងខណ្ឌបឹងកេងកង ការជួសជុល ការប្រឡាយបង្ហូរទឹក ចំណាយលើប្រព័ន្ធលូ ការរៀបចំសោភ័ណភាពទីក្រុង និងការថែទាំសួនច្បារ ចំណាយសរុបមានចំនួន ៣,៥២៣,៤០៣,៣៥០ រៀល ដែលជាការចំណាយក្នុងឆ្នាំ ២០២១ ទាំងនេះដើម្បីអភិវឌ្ឍន៍ ១៨ ដើម្បីអោយមានការរីកចម្រើននៅក្នុងមូលដ្ឋានខណ្ឌបឹងកេងកង។

៨. តើសាលាខណ្ឌបឹងកេងកងមានគោលនយោបាយអ្វីខ្លះ ដើម្បីអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានខណ្ឌ?

សាលាខណ្ឌបឹងកេងកងមានគោលនយោបាយ ដើម្បីអភិវឌ្ឍន៍នៅមូលដ្ឋានខណ្ឌ ដើម្បីការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ក្នុងការកែលម្អទីសាធារណៈ សួនច្បារ និងបរិស្ថាន ការផ្តល់សេវាសាធារណៈនៅខណ្ឌបឹងកេងកង ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ ដល់ប្រជាពលរដ្ឋ និងលើកកម្ពស់ការចូលរួម ពីប្រជាពលរដ្ឋ ដើម្បីធ្វើឲ្យមានការរីកចម្រើន និងប្រកបដោយសុខដុមរមនា។

៩. ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាមានការកំណត់ដែលឬទេ?

ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីជាប់កិច្ចសន្យាមានការកំណត់ដូចខាងក្រោម ៖

ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែរបស់ប្រធានក្រុមប្រឹក្សា ទទួលបាន ១,១១៥,០០០ រៀល

ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សា ទទួលបាន ៩៧០,០០០ រៀល

ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីជាប់កិច្ចសន្យា ទទួលបាន ៤៧០,០០០ រៀល

១០. តើកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់សាលាខណ្ឌបឹងកេងកងមានការរៀបចំ និងប្រព្រឹត្តទៅយ៉ាងដូចម្តេច?

ចំពោះក្របខណ្ឌវិនិយោគ ដែលជាផ្នែកមួយនៃសំខាន់របស់កម្មវិធីវិនិយោគរបស់ខណ្ឌបឹងកេងកង ។ ក្រុមប្រឹក្សាខណ្ឌបឹងកេងកង ចំណាយមានគណៈកម្មការ លប្រមូលផ្ដុំបញ្ហាចេញជាជំនួយការ ធានាការចូលរួមពីគ្រប់ភាគី និងធានាឲ្យបានគោលការណ៍សំខាន់ៗ ដើម្បីធ្វើការវិភាគស្ថានភាពខណ្ឌតាមរយៈផែនការ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ជាមួយគោលដៅ និងជាក្រោយៗ សម្រាប់ក្រុមប្រឹក្សាខណ្ឌបឹងកេងកង នឹងសម្រេចតាមរយៈតាមការរៀបចំ និងការវិនិយោគប្រចាំឆ្នាំ ដើម្បីរៀបៗ របស់ខណ្ឌបឹងកេងកង ។ ពិនិត្យឡើងវិញបញ្ចប់ និងតម្រូវការរបស់ប្រជាពលរដ្ឋឡើងវិញ

ការសម្របសម្រួលជាមួយដៃគូផ្សេងៗ ក្នុងការគាំទ្រ ស្ត្រី និងកុមារ
ក្រុមប្រឹក្សា និងមិត្តភក្តិ ក្នុងការជួយប្រជាពលរដ្ឋ
អនុវត្តន៍ ក្នុងការដោះស្រាយបញ្ហា ការអភិវឌ្ឍន៍ ក្នុងសង្គម
ដំណោះស្រាយ និងការងារ សាលាខណ្ឌបឹងកេងកង ៖
ការចុះជួបពិភាក្សាជាមួយពលរដ្ឋ និងផ្សព្វផ្សាយអំពីការអនុវត្តន៍ និងការ
ការកសាងសមត្ថភាពដល់បុគ្គលិក សម្រាប់ការងារ និងការផ្សព្វផ្សាយអំពីការ
ផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ និងការផ្សព្វផ្សាយ ការអនុវត្តន៍
ផ្តល់ជូនការ និងការអនុវត្ត និងការ
ដល់ប្រជាជន និងអនុវត្តន៍ ក្នុងការអនុវត្តន៍ និងការ

១១. តើសាលាខណ្ឌបឹងកេងកងមានគម្រោងអភិវឌ្ឍន៍អ្វីខ្លះសម្រាប់នាពេលបច្ចុប្បន្ន និងអនាគត?

សាលាខណ្ឌបឹងកេងកងមានគម្រោងអភិវឌ្ឍន៍ទាំងផ្នែក សម្រាប់ពេល
បច្ចុប្បន្ន និង ពេលអនាគត ៖
អភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ប្រឡាយ ដូចជា
ការក្រាលកៅស៊ូ ផ្លូវបេតុង ការដាក់លូ និងលើកកម្ពស់ផ្លូវ
បរិស្ថាន ការសម្អាត ដើម្បីភាពស្អាត និងរបៀបរៀបរយ
និងសណ្តាប់ធ្នាប់
ផ្នែកសង្គមកិច្ច

១២. ចំពោះការទូទាត់ថវិកា និងគណនេយ្យភាពរបស់សាលាខណ្ឌបឹងកេងកងមានលក្ខណៈដូចម្តេច?

ចំពោះការទូទាត់ថវិកា និងគណនេយ្យភាពរបស់សាលាខណ្ឌ
បឹងកេងកង គឺការទូទាត់តាមនីតិវិធី ឆាប់រហ័សទាន់ពេលវេលា
ទៅតាមទូទាត់តាមនីតិវិធី ទាន់ពេល ។ ចំណែកឯប្រព័ន្ធគណនេយ្យ
ភាពវិញ មានពីរគឺ គណនេយ្យហិរញ្ញវត្ថុ និងគណនេយ្យ
ថវិកា ។

១៣. តើសមិទ្ធផលសម្រេចដែលសម្រេចបានរបស់ខណ្ឌបឹងកេងកងមានអ្វីខ្លះ?

សមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកង សម្រេចបាន
មានដូចជា ទៅក្នុងផ្នែកការបញ្ចប់ឯកសារ មានការងាររដ្ឋបាលទូទៅ
សេវាផ្សេងៗ [illegible] ការងារផែនការ [illegible] សន្តិសុខ
សណ្តាប់ធ្នាប់ គ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ការងារអភិវឌ្ឍ
ហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងសណ្តាប់ធ្នាប់ ការបញ្ជ្រាបយេនឌ័រ
សាធារណៈ [illegible] និងការងារក្រុមប្រឹក្សាខណ្ឌ
បឹងកេងកង ដែលកិច្ចការទាំងនេះ [illegible]
[illegible] និងនីតិវិធី [illegible]
[illegible] សាធារណៈ [illegible]
[illegible]

ប្រកបដោយ...តម្លាភាព...ពេលវេលា...គណនេយ្យភាព...និងអភិបាលកិច្ចល្អ...
ភាពឆ្លើយតបដល់ប្រជាពលរដ្ឋ ។

១៨. នៅក្នុងការគ្រប់គ្រងរដ្ឋបាលខណ្ឌបឹងកេងកងបានជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ? ក្នុងវិស័យអ្វីខ្លះ?

សេវាកម្មក្នុងការគ្រប់គ្រងទីក្រុងនៃខណ្ឌបឹងកេងកង [illegible]
ប្រកបដោយជំនាញ

- ផ្នែកសន្តិសុខ ...និងសណ្តាប់ធ្នាប់សាធារណៈ ...ដូចជា គឺមាន
ក្រុមចោរ [illegible] ...ប្រជាពលរដ្ឋ [illegible]
[illegible]
[illegible]

- ផ្នែកបរិស្ថាន ...ជាក់ស្តែង [illegible]
[illegible] និងការ [illegible] ប្រជាពលរដ្ឋ ។

- ផ្នែកចរាចរណ៍ ...ការកកស្ទះ [illegible]
និងការ [illegible]
[illegible]

- ផ្នែកសាធារណការ ...មិនបានទូលំទូលាយ ...ផ្តល់ប្រជាពលរដ្ឋ
[illegible]
[illegible] (ផ្លូវ ។

- ផ្នែកវប្បធម៌ និងសីលធម៌ ...មានបញ្ហា [illegible] ...[illegible] (CD)
វីស៊ីឌី (VCD) ឌីវីឌី (DVD) ...[illegible]
[illegible] ...និងច្បាប់ [illegible]

- ផ្នែក [illegible] ...និង [illegible]
[illegible] ខណ្ឌបឹងកេងកង [illegible]
[illegible] ។

១៥. នៅក្នុងការបំពេញការងាររបស់ខណ្ឌបឹងកេងកងមានបញ្ហាកង្វះខាតដែរឬទេ?

នៅក្នុងការបំពេញការងាររបស់ខណ្ឌបឹងកេងកងមានបញ្ហាកង្វះ
ខាតដោយសារតែ ខ្វះធនធានមនុស្ស ... ក្រុមប្រឹក្សាខណ្ឌ
បំពេញការងាររបស់ខណ្ឌបឹងកេងកងនៅមានការខ្វះខាតក្នុងការងារតាម
ការរំពឹងទុក ហើយនៅមានការប្រើប្រាស់ថវិកា ... ។

១៦. តើនៅពេលអនាគត រដ្ឋបាលខណ្ឌបឹងកេងកងមានទិសដៅ ឬគម្រោងអ្វីខ្លះ?

នៅពេលអនាគត រដ្ឋបាលខណ្ឌបឹងកេងកងមានទិសដៅ ដូចជា៖
ការរៀបចំផែនការអភិវឌ្ឍន៍ និងវិនិយោគ
ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ជូន ប្រជាពលរដ្ឋ
ប្រកបដោយតម្លាភាព គណនេយ្យភាព និងទទួលខុសត្រូវ ឆ្លើយតប
ទៅនឹងតម្រូវការ។
បន្តពង្រឹងការគ្រប់គ្រងរដ្ឋបាល...

- [illegible] និង [illegible]
- [illegible]
- [illegible]
- [illegible] ភូមិ [illegible]
[illegible]
- [illegible]
[illegible]
[illegible]

ថ្ងៃសុក្រ..១៤កើត.....ខែភទ្របទ.ឆ្នាំ.ខាល.ចត្វាស័ក ព.ស២៥៦៦

សាលាខណ្ឌបឹងកេងកង ថ្ងៃទី.០៩..ខែ.កញ្ញា..ឆ្នាំ២០២២

**ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក**

**ហត្ថលេខា**

**សាត ឆវិន**

[illegible] ប្រធានការិយាល័យ

17 959 623

# ឧបសម្ព័ន្ធ ៧.
# សម្ភាសជាមួយប្រជាពលរដ្ឋ

## កម្រងសំនួរស្ទង់មតិជាមួយប្រជាពលរដ្ឋ

## ស្តីអំពី

## ការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកង

នាងខ្ញុំជានិស្សិតឆ្នាំទី៤ ឆមាសទី២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញ រដ្ឋបាលសាធារណៈ។ នាងខ្ញុំកំពុងធ្វើការសិក្សាស្រាវជ្រាវនៅក្នុងវិស័យសាធារណៈ លើប្រធានបទ «ការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលសម្រេចបានរបស់ខណ្ឌបឹងកេងកងក្នុងឆ្នាំ២០២១» ក្នុងគោលបំណងដើម្បី ពង្រឹង និងពង្រីក ចំណេះដឹងលើការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ការបម្រើសេវាសាធារណៈ និងការដោះស្រាយបញ្ហាជូនដល់ប្រជាពលរដ្ឋ ជាពិសេសចំពោះថ្នាក់ខណ្ឌ ដែលស្ថិតនៅជិតប្រជាពលរដ្ឋ។ នាងខ្ញុំសង្ឃឹមជឿជាក់ថា ប្រជាពលរដ្ឋដែលរស់នៅក្នុងខណ្ឌបឹងកេងកងបានចូលរួមឆ្លើយនូវសំនួរខាងក្រោមនេះ។

នាងខ្ញុំ សូមថ្លែងអំណរគុណ ចំពោះការចូលរួមផ្តល់នូវចម្លើយដ៏មានសារៈសំខាន់អំពីសំណាក់ប្រជាពលរដ្ឋទាំងអស់គ្នាហើយនាងខ្ញុំសូមធានាខុសត្រូវទាំងស្រុងរាល់ចម្លើយទាំងអស់ដោយរក្សាទុកជាសម្ងាត់។

១. ភេទ ☑ ប្រុស ☐ ស្រី

២. អាយុ....64..ឆ្នាំ..

៣.កម្រិតវប្បធម៌សិក្សា ☐ បឋម ☑ អនុវិទ្យាល័យ ☐ វិទ្យាល័យ

☐ បរិញ្ញាបត្រ ☐ អនុបណ្ឌិត ☐ បណ្ឌិត

៤. ស្ថានភាពគ្រួសារ ☐ នៅលីវ ☑ មានគ្រួសារ

☐ ពោះម៉ាយ ☐ លែងលះគ្នា

៥. មុខរបរបច្ចុប្បន្ន............លក់ដូរ............................................។

៦. ជីវភាពគ្រួសារ ☐ ក្រីក្រ ☑ មធ្យម ☐ ធូរធារ

៧. រស់នៅក្នុងសង្កាត់បឹងកេងកងទី៣ អស់រយៈពេល......64...ឆ្នាំ....................................។

៨. តើតាមអ្វីដែលលោកអ្នក មើលឃើញសព្វថ្ងៃនេះ នៅក្នុងខណ្ឌបឹងកេងកងមានការអភិវឌ្ឍអ្វីខ្លះ?

.........ខ្ញុំបានមើលឃើញ...នៅក្នុងខណ្ឌបឹងកេងកងមានការអភិវឌ្ឍ ច្រើន.........ផ្លូវថ្នល់........សាលារៀន..................មន្ទីរពេទ្យ.......ផ្សារទំនើប ...សំណង់អគារខ្ពស់ៗ.........និងមានការធានាលើ......ប្រព័ន្ធទឹកភ្លើង ...ដល់ប្រជាពលរដ្ឋមានភាពងាយស្រួលជាងមុន ។..........................

..........................................................................................

៩. តើរដ្ឋបាលនៅក្នុងខណ្ឌបឹងកេងកង ពួកគាត់យកចិត្តទុកដាក់ចំពោះសុខទុក្ខប្រជាពលរដ្ឋ ក៏ដូចជាបញ្ហារបស់ប្រជាពលរដ្ឋដែរឬទេ?

រដ្ឋបាលខណ្ឌនៅក្នុងខណ្ឌបឹងកេងកង ពួកគាត់បានយកចិត្តទុកដាក់ចំពោះសុខទុក្ខ ប្រជាពលរដ្ឋ ហើយពេលមានគ្រោះការណ៍អ្វីមួយ ពួកគាត់តែងតែជួយដោះស្រាយ [illegible] ប្រជាពលរដ្ឋគ្រប់ [illegible] ធ្វើការ [illegible] និងប្រាកដ [illegible] ជួយរក្សាសន្តិសុខខណ្ឌបឹងកេងកងតែងតែ [illegible] ប្រជាពលរដ្ឋដែលបានរង [illegible] គាត់បានយកចិត្តទុកដាក់ [illegible] ប្រជាពលរដ្ឋ [illegible] ហើយជាពិសេសនៅក្នុងឆ្នាំ ២០២១ [illegible] កូវីដ ១៩ [illegible] ដែលប្រជាពលរដ្ឋគ្រប់គ្រួសារនៅក្នុងខណ្ឌ [illegible] រដ្ឋបាលខណ្ឌបានយកចិត្តទុកដាក់ជួយប្រជាពលរដ្ឋ [illegible] ខណ្ឌបឹងកេងកង [illegible] ប្រជាពលរដ្ឋ [illegible] ។

១០. ចំពោះការផ្សព្វផ្សាយ ឬបិទផ្សាយព័ត៌មានផ្សេងៗ តើសាលាខណ្ឌបឹងកេងកងបានធ្វើលក្ខណៈទូលំទូលាយដែរឬទេ?

ចំពោះការផ្សព្វផ្សាយ ឬបិទផ្សាយព័ត៌មានផ្សេងៗ សាលាខណ្ឌបឹងកេងកងបានធ្វើឡើង [illegible] ដែលមានបិទផ្សាយតាមការ [illegible] ព័ត៌មាន [illegible] ផ្សព្វផ្សាយតាមបណ្តាញសង្គម [illegible] សាលាខណ្ឌបឹងកេងកង និងទៅតាមភូមិ

ដូចនេះ សិទ្ធិប្រជាពលរដ្ឋបានល្អគ្រប់ៗគ្នា គ្មានការរើសមុខនោះទេ។

១១. នៅក្នុងការបំពេញការងារជូនប្រជាពលរដ្ឋ តើសាលាខណ្ឌបឹងកេងកងមានការប្រកាន់បក្សពួកដែរឬទេ?

នៅក្នុងការបំពេញការងារជូនប្រជាពលរដ្ឋ សាលាខណ្ឌបឹងកេងកង គឺមិនមានការប្រកាន់បក្សពួកនោះទេ ព្រោះគណបក្សនយោបាយណាមួយក៏ដោយ គឺបំពេញជូនប្រជាពលរដ្ឋដោយស្មើភាព និងគ្រប់ៗគ្នា។

១២.តើមានបញ្ហាអំពើពុករលួយកើតមានឡើងនៅក្នុងខណ្ឌបឹងកេងកងដែរឬទេ?

បញ្ហាអំពើពុករលួយនៅក្នុងខណ្ឌបឹងកេងកង គឺឃើញថាមិនមានអំពើពុករលួយនៅក្នុងខណ្ឌនោះទេ។

១៣. តើលោកអ៊ុំ \ពូ\ មីង\ លោកយាយ\ លោកតា ពេញចិត្តចំពោះការដឹកនាំរបស់អភិបាលខណ្ឌ ក្រុមប្រឹក្សាខណ្ឌបឹងកេងកងដែរឬទេ?

ចំពោះការដឹកនាំរបស់លោកអភិបាលខណ្ឌបឹងកេងកង គឺមានការពេញចិត្ត ដោយសារគាត់ខិតខំយកចិត្តទុកដាក់ និងសួរសុខទុក្ខរបស់ប្រជាពលរដ្ឋ ដល់ខ្នងផ្ទះ សួរនាំសុខទុក្ខ ជូនប្រជាពលរដ្ឋបានយ៉ាងល្អ រហូតមក រួមទាំងមិនមានការ

ប្រាក់បន្ទប់ថ្លៃពេក បុរាណទើបសម្រេចប្រជាពលរដ្ឋលោកមកស្នាក់នៅ
ដោយមានបញ្ហានឹងកត្តាគ្រប់ផ្នែក ជីវភាពមិនធូរធារ ថ្ងៃនេះ ក្រោយ
ជូនសមត្ថប្រជាពលរដ្ឋ បានភ្ញាក់ ចេះចិត្ត ។

១៨. តើលោកអ៊ំ ព្រូមីង លោកយាយ លោកតា មានជាមតិយោបល់និងការស្នើសុំអ្វីខ្លះទៅកាន់រដ្ឋបាលបឹងកេងកង និងសង្កាត់នៅក្នុងខណ្ឌ?

សូមស្នើសុំទៅកាន់រដ្ឋបាលខណ្ឌបឹងកេងកង ក៏ដូចជាមានការ
សាងការសម្អាតប្រឡាយ ទឹក ស្អុយ គេ ចាក់ចោល
សំរាមនៅតាមផ្លូវ រួមទាំងវិធានការ សំរាមផលិតពីផ្ទះ
ទ្រើបទ្រើស ដោយបន្តអភិវឌ្ឍន៍ ដើម្បីភាពស្អាតនៅ
ដើម្បីផ្ដល់ភាពស្អាតនេះ ។ សូមអោយរដ្ឋបាលខណ្ឌ
ជួយការពារផ្លូវទឹក ដើម្បីលើកកម្ពស់ជីវភាព
សូមសម្អាតបញ្ហាប្រឡាយ ដែលតាមផ្លូវ សាធារណៈ
ដើម្បីជៀសវាង ជំងឺ ដង្កូវ ត្រូវបានសុខភាព សន្តិសុខ សណ្តាប់
ធ្នាប់ សាធារណៈ ។

ថ្ងៃ.សុក្រ.៨..កើត...ខែ.ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
សាលាខណ្ឌបឹងកេងកង ថ្ងៃទី០៥..ខែ.សីហា.ឆ្នាំ២០២២

# ឧបសម្ព័ន្ធ ៨.
# ផែនទីខណ្ឌបឹងកេងកង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីរដ្ឋបាល ខណ្ឌបឹងកេងកង




| ពត៌មានខណ្ឌបឹងកេងកង | |
|---|---|
| ផ្ទៃដី (គ.ម²) | ៣,៤៧៦ គ.ម² |
| សង្កាត់ | ០៧ |
| ភូមិ | ៥៤ |
| ប្រជាជន (នាក់) | ៨៣,០៤៣ |
| គ្រួសារ (គ្រួសារ) | ៩,៨៧៦ |
| ដង់ស៊ីតេ/គ.ម² | ១៣៥៥០ |

**កំណត់សំគាល់**

- សង្កាត់បឹងកេងកងទី១
- សង្កាត់បឹងកេងកងទី២
- សង្កាត់បឹងកេងកងទី៣
- សង្កាត់អូឡាំពិក
- សង្កាត់ទួលស្វាយព្រៃទី១
- សង្កាត់ទួលស្វាយព្រៃទី២
- សង្កាត់ទំនប់ទឹក
- ព្រំប្រទល់ខណ្ឌ
- ព្រំប្រទល់សង្កាត់

# ឧបសម្ព័ន្ធ ៩.

# អនុក្រឹត្យស្តីពីតែងតាំងអភិបាល
# ខណ្ឌបឹងកេងកង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៨/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាល នៃគណៈអភិបាលខណ្ឌ ក្នុងរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១-លោក **ធឹម សំអាន** | ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៤ ជាអភិបាល នៃគណៈអភិបាលខណ្ឌបឹងកេងកង។ |
| ២-លោក **ឃឹម ស៊ុនសូដា** | ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ ជាអភិបាល នៃគណៈអភិបាលខណ្ឌកំបូល។ |

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣ កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

10116.

លេខ:....................អ.ច្រ

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃទី 28 MAY 2020

គណៈអភិបាលរាជធានីភ្នំពេញ

នាយករងរដ្ឋបាល

វេជ្ជបណ្ឌិត ជូ យ៉េងចាន់